សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មករា ឆ្នាំ 2014

# លីអាហូណា



## យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ៖ អ្នកការពារសេចក្ដីជំនឿ ទំព័រ 32

សាសនាចក្រនៅក្នុងប្រទេសមិកស៊ីកូ — ប្រវត្តិសាស្ត្រដ៏បរិបូរ អនាគតដ៏ស្រស់ស្អាតមួយ ទំព័រ 24

បាវចនាម៉្យូឆល ឆ្នាំ 2014 ទំព័រ 50, 52, 53

សកម្មភាពផាត់ពណ៌ និងតារាងការអានព្រះគម្ពីរសញ្ញាចាស់ ទំព័រ 74, 76



*« អ្នករាល់គ្នាមួយចំនួន អាចមានអារម្មណ៍ថា អ្នកពុំអាចងើបចេញពីបឹងភក់ខ្វក់បានទេ ថាស្ថានភាពរបស់អ្នក គឺពិបាកខ្លាំងណាស់ ការសាកល្បងរបស់អ្នកគឺធ្ងន់ធ្ងរណាស់ ការល្បួងរបស់អ្នកគឺមហិមាណាស់ ។ . . . ចូរចាំថា ដើមព្រលឹតដុះចេញមកនៅក្នុងភាពមិនអនុគ្រោះ ហើយដូចជាដើមព្រលឹតទ្រផ្កាព្រលឹងតយ៉ាងណា នោះសេចក្ដីជំនឿនឹងគាំទ្រ ហើយលើកអ្នកឡើងយ៉ាងនោះដែរ » ។*

ម៉ារី អិន. ឃុក អតីតទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានយុវនារីទូទៅ « យុត្ថានៃទីបន្ទាល់ » *Liahona*, ខែឧសភា ឆ្នាំ ២០០៨, ១២២ ។

# លីអាហូណា ខែ មករា ឆ្នាំ 2014


18

## សារលិខិត


4 **សារលិខិតគណៈប្រធានទីមួយ ៖ គ្រាដ៏ល្អបំផុតដើម្បីដាំដើមឈើ**
ដោយ ប្រធាន ឌៀថើរ អែហ្វ អុជដូហ្វ

7 **សារលិខិតសួរសុខទុក្ខ ៖ បេសកកម្មដ៏ទេវភាពនៃព្រះយេស៊ូវគ្រីស្ទ ៖ អង្គដ៏ជាគំរូ**


## អត្ថបទពិសេស។


18 **ប្រឈមមុខនឹងអនាគតដោយសេចក្ដីជំនឿ និង សេចក្ដីសង្ឃឹម**
ដោយ អែលឌើរ អិម រ័សុល បាឡឺដ
*យើងត្រូវតែប្ដេជ្ញា ហើយលះបង់ជីវិតរបស់យើងចំពោះបុព្វហេតុរបស់ព្រះអង្គសង្គ្រោះ ដោយដើរក្នុងសេចក្ដីជំនឿ និងដោយធ្វើការជាមួយនឹងភាពជឿជាក់ ។*

24 **ពួកអ្នកត្រួសត្រាយផ្លូវនៅគ្រប់ដែនដី: ប្រទេស ម៉ិចស៊ិក បានអភិវឌ្ឍ—ពីបញ្ហាទៅកាន់ភាពរឹងមាំ**
ដោយ សាលី ចនសុន អូឌេឃឹក
*ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅប្រទេស ម៉ិចស៊ិក បានលះបង់យ៉ាងអស្ចារ្យដើម្បីស្ថាបនាសាសនាចក្រនៅក្នុងប្រទេសរបស់ខ្លួន ។*

32 **ភក្ដីភាព និង ភាពស្មោះត្រង់ ៖ ការបំផុសគំនិតដកស្រង់ចេញពីខ្សែជីវិត និង ការបង្រៀនរបស់ យ៉ូសែប ហ្វីលឌីង ស្ម៊ីធ**
ដោយ ហាត់ ដបុលយូ ប្រ៊ូស្ទី ជុញ្ញ័រ
*សូមជួបនឹងព្យាការីសម័យទំនើបមួយរូប ដែលពូកែក្នុងការវាយកូនបាល់ ហើយមានចិត្តទន់ភ្លន់ ហើយដែលបានបម្រើព្រះអម្ចាស់ដោយស្មោះត្រង់ ។*


## ផ្នែកទាំងឡាយ


8 **សៀវភៅកំណត់ចំណាំសន្និសីទខែ តុលា ឆ្នាំ 2013**

10 **យើងនិយាយអំពីព្រះគ្រីស្ទ: ចេញពីភាពងងឹតចូលទៅក្នុងពន្លឺ**
ឈ្មោះត្រូវបានដកចេញ

12 **ពួកព្យាការីព្រះគម្ពីរសញ្ញាចាស់: អ័ដាម**

14 **ដំណឹងល្អពីបុរាណ: ក្រុមព្រះដ៏ទេវភាព**
ដោយ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី

17 **ការបង្រៀន*ដើម្បីកម្លាំងនៃយុវជន:* ការរក្សាថ្ងៃបរិសុទ្ធ**

38 **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

80 **លុះត្រាជួបទៀត: តើទ្រង់អាចឃើញខ្ញុំឬទេ ?**
ដោយ ធេរេសា ស្តារ


**នៅលើគម្រប**
ខាងមុខ ៖ រូបថតរបស់យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានថតនៅថ្ងៃទី 26 ខែ មេសា ឆ្នាំ 1910 មិនយូរប៉ុន្មានបន្ទាប់ពីការតែងតាំងរបស់លោកជាសាវកនៅវ័យ 33 ឆ្នាំ ។នៅលើគម្របខាងមុខ ៖ ថតរូបដោយ ឡារេណេ ភ័តធើរ ហ្គាន់ ។

**មជ្ឈិមវ័យវ័យក្មេង**


42


**42 ការស៊ូទ្រាំបានល្អ**
ដោយ អែលឌើរ ដេ ត្រីស្តូហ្វើរ ឡេនសឹង
*តើអ្វីខ្លះទៅដែលព្រះអម្ចាស់រំពឹងទុកឲ្យយើងធ្វើនៅពេលសេចក្តីសង្ឃឹម និងក្តីសុបិនរបស់យើងត្រូវបានបំផ្លាញខ្ទេចខ្ទាំអស់នោះ ?*




*ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។តម្រុយ ៖ សូមមើលព្រះគម្ពីរ !*


46

**យុវវ័យ**


**46 ការរៀបចំអំណោយសម្រាប់គ្រួសារនាពេលអនាគតរបស់អ្នក**
ដោយ ប្រធាន ហិនរី ប៊ី អាវរិង
*តើអំណោយអ្វីទៅដែលអ្នកអាចរៀបចំនៅពេលឥឡូវនេះ ដើម្បីប្រទានពរដល់គ្រួសារនាពេលអនាគតរបស់អ្នក ?*

**50 បាវចនាម៉្ងូឆលឆ្នាំ 2014**
ដោយ គណៈប្រធានយុវជន និង យុវនារីទូទៅ
*« ចូរមករកព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ ហើយចូរលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធចុះ »។*

**52 មួយបន្ទាត់ម្តងៗ: មរ៉ូណៃ 10:32**
*បាវចនាម៉្ងូឆលនៅឆ្នាំនេះបង្រៀនអ្នកពីផ្លូវទៅកាន់ភាពល្អឥតខ្ចោះ ។*

**53 ប័ណ្ណប្រកាស: មករកព្រះគ្រីស្ទ**

**54 តើការស្គាល់ពីក្រុមព្រះផ្លាស់ប្តូរខ្ញុំតាមរបៀបណា ?**
ដោយ ឡូរី ហ្វូល្លី
*គោលការណ៍ទាំងប្រាំនេះស្តីពីក្រុមព្រះអាចផ្លាស់ប្តូរនូវរបៀបដែលអ្នករស់នៅ—ទាំងតាមរបៀបតូច និងធំ ។*

**56 ដើម្បីកម្លាំងនៃយុវជន: ខ្ញុំតែងតែចងចាំទ្រង់ជានិច្ច**
ដោយ ល៉ៃរី អិម ហ៊ីបសុន
*ការរក្សាថ្ងៃបរិសុទ្ធឲ្យបរិសុទ្ធវាបង្ហាញពីការតាំងចិត្តរបស់អ្នកចំពោះសេចក្តីសញ្ញាទាំងឡាយរបស់អ្នក ។*

**58 បន្ថែមពីលើភាពជោគជ័យ**
ដោយ ដានីយ៉ែល កាវ៉ែ
*ជើងឯកអូឡាំពិកផ្នែកគណិតវិទ្យាម្នាក់ត្រូវជ្រើសរើសរវាងការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ និង ការបាត់បង់ឱកាសចូលប្រកួត ។*

**59 ទៅកាន់គោលដៅ**

**60 ពរជ័យទាំងសងខាង**
ដោយ ប្រ៊ីតានី បឺធី
*យើងអាចទទួលពរជ័យបន្ថែម នៅពេលយើងស្រាវជ្រាវឈ្មោះក្រុមគ្រួសាររបស់យើងផ្ទាល់ ហើយ យកឈ្មោះទាំងនោះទៅព្រះវិហារបរិសុទ្ធ ។*

**64 ទីកន្លែងរបស់យើង**


**កុមារ**


72


**66 មិត្តនៅជុំវិញពិភពលោក: ម៉ាហូនរី និង ហេលេមិន មកពីប្រទេស ម៉ិចស៊ិក**

**68 សាក្សីពិសេស: តើដើម្បីធ្វើជាពួកគ្រីស្ទានមានន័យដូចម្តេច ?**
ដោយ អែលឌើរ រ៉ូប៊ើត ឌី ហែល

**69 មិត្តនៅជុំវិញពិភពលោក: លិខិតឆ្លងដែន**

**71 ទំព័ររបស់យើង**

**72 ដូចជាព្រះគម្ពីរ !**
ដោយ រ៉េណេ វ៉េត ម៉ាគ្គី
*ព្រះគម្ពីរពិតជាប្រៀបបាននឹងជីវិតរបស់ខ្ញុំមែន !*

**74 ការសាកល្បងព្រះគម្ពីរសញ្ញាចាស់**

**77 ផ្លូវនៃជ័យជំនះ**
ដោយ រ៉ូសម៉ារី អិម វិកស្សុម
*តើនរណាអាចបង្ហាញផ្លូវអ្នកឲ្យត្រលប់ទៅព្រះវរបិតាសួគ៌វិញ ?*

**78 ការនាំថ្នាក់កុមារមកក្នុងលំនៅដ្ឋាន: ព្រះវរបិតាសួគ៌បានរៀបចំផ្លូវមួយសម្រាប់ខ្ញុំឲ្យត្រលប់ទៅរកទ្រង់វិញ**

**81 រូបគំនូរព្យាការី: ហារ៉ូល ប៊ីលី**

**វ៉ុល ខែ មករា ឆ្នាំ 2014 ច្បាប់ 14 លេខ. 1**
**លីអាហូណា 10981 258**
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** ប៊យដ៍ ខេ. ផាកកឺ, អិល. ថម ភែរី, រ័សុល អិម. ណិលសុន, ដាល្លិន អេក. អូក, អិម. រ័សុល បាឡឺដ, រីឆាដ ជី. ស្កត, រ៉ូបឺត ឌី. ហែល, ជែហ្វ្រី អ័រ. ហូឡិន, ដេវីឌ អេ. បែដណា, ឃ្វីនថិន អិល. ឃុក, ឌី ថត. គ្រីស្តូហ្វឺសិន, នែល អិល. អាន់ឌើរសិន

**អ្នកកែសម្រួល ៖** គ្រេក អេ. ខារដុន
**អ្នកប្រឹក្សា ៖** សមើរវីន ប៊ី អាណុល, រូនេ អិម. បូវិន, ប្រ៊ែដលី ឌី. ហ្វូស្ទើរ, ចស អិល អាឡុនសូ, គ្រីស្តូហ្វែល ហ្គូលឌិន ជុញ្ញ័រ

**នាយកគ្រប់គ្រង ៖** ដេវីឌ ធី. វ៉នើរ
**នាយកគាំទ្រគ្រួសារ និង សមាជិក ៖** វីនសេនត៍ អេ. វ៉ញ
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ. ឡយបិច
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន

**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ. វ៉ាល ចនសុន
**ជំនួយការអ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** ប៉អិន ខារ
**និពន្ធ និងកែសម្រួល ៖** ស៊ូសាន បាប៉េត, ប្រ៊ីតថានី ប៊ីតធី, ដេវីដ ឌិកសុន, ដេវីដ អេ. អែដវ៉ីដ, ម៉ាថាយ ឌី. ហ្វលិតតុន, មិនឌី រ៉េ ហ្រ្វីដមែន, ហ្គែរី អេច. ហ្គាហ្វ, ឡារិននេ ផតធើរ ហ្គុន, ជេនីហ្វើរ គ្រេហ្គស ជូនស៍, ម៉ៃឃើល អ័រ. ម៉ូរីស, សាលី ចនសុន អូឌេឃឹក, យ៉ូស្វេ ជេ ភឺគី, ជេន ភីនប៊ូហ៉ាហ្វ, រីឆាដ អិម. រ៉មនី, ប៉ុល វ៉ែនដិនប៊ើជ, ម៉ារីស្សា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ. ស្កត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ថាត អ័រ. ភីធើរសុន
**រចនាម៉ូត ៖** ជេនែត អែនឌ្រូ, ហ្វៃ ភី អែនឌ្រើស, ស៊ី. ឃិមបល ប៊ុត, ថូម៉ាស ឆាលដ៍, ខូលីន ហ៊ីងគ្លី, អ៊ីរីក ភី. ចនសិន, ស៊ូហ្សិន ឡហ្វ៍ហ្គ្រេន, ស្កត អិម. មូយ, ម៉ាក ជបុលយូ រូប៊ីសុន, ប្រេដ ធាប៉

**អ្នកសម្របសម្រួលកម្មសិទ្ធបញ្ញា ៖** ខូលែត នែបេឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ខេវិន ស៊ី បេិងស៍, ខននី ប៊ូស្រូប ប្រ៊ីដ, ជូលី បើដែត, ប្រាយអែន ដបុលយូ. ជីគី, ដេនីស គើប៉េ, ហ្គីននី ជេ. នីលសុន, ហ្គេលី ថេត វ៉ាហ្វើធី, ឃេ នីកូល វ៉ែកខេនហោស្ដ
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល. ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** គ្រេហ្គ ខេ. សែតវីត
**នាយកផ្នែកចែកចាយ ៖** ស្ដេហ្វិន អ័រ គ្រីស្ទិនសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬ សាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអ៊ិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងហ្គារី, អាយឡែនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។

© 2014 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
January 2014 Vol. 14 No. 1. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 707.4.12.5). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# គំនិតទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។នៅខាងក្រោមនេះជាគំនិតចំនួនពីរ ។*



« **ការរៀបចំអំណោយសម្រាប់គ្រួសារនាពេលអនាគតរបស់អ្នក** » ទំព័រ 46 ៖ បន្ទាប់ពីអានអត្ថបទរបស់ប្រធាន អាវរិង មក សូមពិចារណាបង្កើតកម្មវិធីបង្ហាញទេពកោសល្យជាគ្រួសារមួយដែលឪពុកម្ដាយ និង កូនៗអាចចែកចាយទេពកោសល្យ ។ បន្ទាប់ពីមនុស្សគ្រប់គ្នាមានឱកាសចែកចាយហើយ នោះឪពុកម្ដាយអាចពិពណ៌នាពីវិធីដែលទេពកោសល្យរបស់ពួកគេប្រទានពរដល់គ្រួសារ ។ បន្ទាប់មក ពួកគេអាចអញ្ជើញកូនៗ ចែកចាយពីរបៀបដែលទេពកោសល្យរបស់ពួកគេប្រទានពរដល់គ្រួសារ និង របៀបដែលពួកគេនឹងប្រទានពរដល់ក្រុមគ្រួសារនាពេលអនាគតរបស់ពួកគេនៅថ្ងៃណាមួយ ។ ឪពុកម្ដាយអាចលើកទឹកចិត្តកូនៗឲ្យដាក់គោលដៅដើម្បីបន្តអភិវឌ្ឍទេពកោសល្យរបស់ពួកគេ ។

« **ការសាកល្បងព្រះគម្ពីរសញ្ញាចាស់** » ទំព័រ 74 ៖ សូមពិចារណាចាប់ផ្ដើមសាកល្បងការអានព្រះគម្ពីរសញ្ញាចាស់ជាគ្រួសារ ។ អ្នកអាចដកយកតារាងពណ៌ពីទស្សនាវដ្ដីនេះ ឬ បោះពុម្ពវាចេញពី liahona.lds.org ដើម្បីកត់ចំណាំពីការរីកចម្រើនរបស់អ្នក ។ សូមអាន ហើយ ពិភាក្សាពីបទគម្ពីរដែលបានណែនាំជាគ្រួសារ ព្រមទាំងពិចារណាធ្វើផែនការមួយដើម្បីបញ្ចប់ការសាកល្បងអានប្រចាំសប្ដាហ៍នេះក្នុងឆ្នាំនេះ ។

## ជាភាសារបស់អ្នក

***លីអាហូណា*** និង ឯកសារផ្សេងទៀតរបស់សាសនាចក្រមានជាច្រើនភាសា សូមចូលទៅកាន់ **languages.lds.org ។**

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយគឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*

***ការធ្លាក់របស់អ័ដាម,*** *12*
***ការបម្រើ,*** *40*
***ការប្រែចិត្ត,*** *4, 10, 46*
***ការយាងមកជាលើកទីពីរ,*** *18*
***ការសាកល្បង,*** *42*
***ការស៊ូទ្រាំ,*** *42, 72*
***ការអធិស្ឋាន,*** *64*
***កិច្ចការផ្សព្វផ្សាយសាសនា,*** *38, 59*
***កុមារ,*** *41*
***កេរតំណែល,*** *24, 32*
***ក្រុមគ្រួសារ,*** *46, 60, 64*
***ក្រុមព្រះ,*** *14, 54*
***គោលដៅ,*** *4, 18, 46*
***គំរូ,*** *7*
***គ្រីស្ទាន,*** *40, 68*
***ដង្វាយធួន,*** *4, 10, 14, 54*
***ថ្ងៃបរិសុទ្ធ,*** *17, 56, 58*
***ទីបន្ទាល់,*** *64*
***បាវចនាម៉ូតឆល,*** *50, 52, 53*
***ប្រទេស ម៉ិចស៊ិក,*** *24, 39, 66*
***ផែនការនៃសេចក្ដីសង្គ្រោះ,*** *78*
***ពង្សប្រវត្តិ,*** *60, 64*
***ព្រះគម្ពីរមរមន,*** *38*
***ព្រះគម្ពីរសញ្ញាចាស់,*** *12, 74*
***ព្រះយេស៊ូវគ្រីស្ទ,*** *7, 14, 50, 52, 54, 56, 68*
***ព្រះវរបិតាសួគ៌,*** *14, 54, 77, 78, 80*
***ព្រះវិញ្ញាណបរិសុទ្ធ,*** *14, 40, 54, 64, 81*
***ព្រះវិហារបរិសុទ្ធ,*** *24, 39, 60*
***ភាពចម្រុងចម្រើន,*** *18*
***ភាពរឹងមាំ,*** *12, 42, 78*
***ភាពរាបសា,*** *10*
***ភាពល្អឥតខ្ចោះ,*** *50, 52*
***ភាពសុខសាន្ត,*** *41*
***លី, ហារ៉ូល ប៊ី,*** *81*
***សេចក្ដីជំនឿ,*** *18*
***សេចក្ដីសង្ឃឹម,*** *18*
***សេចក្ដីសញ្ញាទាំងឡាយ,*** *56, 58*
***ស្មីធ យ៉ូសែប ហ្វិលឌីង,*** *32*
***អំនួត,*** *10*
***អ្នកត្រួសត្រាយ,*** *24*



ដោយ ប្រធាន
ឌៀថើរ អែហ្វ អុជដូហ្វ
ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ

## គ្រាដ៏ល្អបំផុតដើម្បី

# ដាំដើមឈើ

នៅក្នុងសាសនារ៉ូមកាលពីបុរាណ ជេនណុស គឺជាព្រះនៃការចាប់ផ្ដើម ។ ជារឿយៗទ្រង់ត្រូវបានបរិយាយថាមានព្រះភ័ក្រពីរ—ព្រះភ័ក្រមួយមើលទៅអតីតកាល ព្រះភ័ក្រមួយទៀតមើលឆ្ពោះទៅរកអនាគត ។ មានភាសាខ្លះបានដាក់ឈ្មោះខែមករាតាមឈ្មោះរបស់ទ្រង់ ដោយសារដើមឆ្នាំគឺជាគ្រាមួយសម្រាប់ការគិតក៏ដូចជាការរៀបចំផែនការផងដែរ ។

រាប់ពាន់ឆ្នាំក្រោយមក មានវប្បធម៌ជាច្រើននៅជុំវិញពិភពលោកបានអនុវត្តនូវប្រពៃណីមួយនៃការធ្វើការតាំងចិត្តនានាសម្រាប់ឆ្នាំថ្មី ។ ពិតណាស់ ការធ្វើការតាំងចិត្តជារឿងងាយស្រួលទេ—ប៉ុន្តែរក្សាការតាំងចិត្តនោះគឺជារឿងមួយដែលផ្ទុយស្រឡះ ។

បុរសម្នាក់ដែលបានសរសេរបញ្ជីមួយយ៉ាងវែងស្ដីពីការតាំងចិត្តសម្រាប់ឆ្នាំថ្មីមានអារម្មណ៍ល្អពីការរីកចម្រើនរបស់ខ្លួន ។ គាត់បានគិតក្នុងចិត្តថា « មកដល់ពេលនេះ ខ្ញុំបានប្រកាន់ខ្ជាប់នឹង របបអាហាររបស់ខ្ញុំ ខ្ញុំពុំឆាប់ខឹង ខ្ញុំបានធ្វើតាមគម្រោងថវិការបស់ខ្ញុំ ហើយខ្ញុំពុំបានត្អូញត្អែរម្ដងណាឡើយពីឆ្កែរបស់អ្នកជិតខាងខ្ញុំ ។ ប៉ុន្តែថ្ងៃនេះជាថ្ងៃទី 2 ខែ មករា ហើយនាឡិកាបានរោទិ៍ឡើង ជាពេលដែលខ្ញុំត្រូវក្រោកពីដេក ។ វាត្រូវការអព្ភូតហេតុមួយដើម្បីខ្ញុំបន្តធ្វើតាមការតាំងចិត្តរបស់ខ្ញុំ » ។

### ការចាប់ផ្ដើមម្ដងទៀត

មានអ្វីមួយដែលពោរពេញដោយសេចក្ដីសង្ឃឹមយ៉ាងអស្ចារ្យចំពោះការចាប់ផ្ដើមថ្មីមួយនោះ ។ ខ្ញុំសូមសន្មតថា នៅពេលខ្លះយើងទាំងអស់គ្នាចង់ចាប់ផ្ដើមម្ដងទៀតដោយគ្មានកំហុស ។

ខ្ញុំចូលចិត្តមានកុំព្យូទ័រថ្មីមួយដែលមានថាសរឹងគឺទទេរស្អាត ។ មានគ្រាមួយវាដំណើរការយ៉ាងល្អឥតខ្ចោះ ។ ប៉ុន្តែពេលវេលាចេះតែកន្លងផុតទៅ ហើយនៅពេលមានកម្មវិធីកាន់តែច្រើនត្រូវបានដាក់ដំឡើង ( ដោយចេតនាខ្លះអចេតនាខ្លះ ) នោះនៅទីបំផុតកុំព្យូទ័រនោះបានចាប់ផ្ដើមគាំង ហើយកិច្ចការទាំងឡាយដែលធ្លាប់តែធ្វើយ៉ាងលឿន ហើយល្អ បានក្លាយទៅជាយឺត ។ ពេលខ្លះ វាអត់ដំណើរការទាល់តែសោះ ។ សូម្បីតែធ្វើឲ្យដំណើរការក៏ពិបាកដោយសារថាសរឹងនោះបានពង្រាយដោយភាពច្របូលច្របល់ផ្សេងៗ និងកំទេចអេឡិចត្រូនិក ។ មានពេលខ្លះវិធីតែមួយគត់គឺត្រូវ លុបថាសរឹងនោះចេញហើយចាប់ផ្ដើមសារជាថ្មី ។

ដូចគ្នានេះដែរ មនុស្សអាចត្រូវបានពោរពេញដោយភាពភ័យខ្លាច ភាពសង្ស័យ និងកំហុសដ៏ធំ ។ កំហុសទាំងឡាយដែលយើងធ្វើ ( ទាំងចេតនា និងអចេតនា ) អាចដាក់បន្ទុកលើយើងរហូតដល់វាធ្វើឲ្យយើងមានការលំបាកធ្វើចំពោះអ្វីដែលយើងគួរធ្វើ ។

នៅក្នុងករណីនៃអំពើបាប មានដំណើរការលុបបំបាត់មួយដ៏អស្ចារ្យហៅថាការប្រែចិត្តដែលអនុញ្ញាតឲ្យយើងសម្អាតបន្ទុកនៅក្នុងខ្លួនរបស់ខ្លួនដែលធ្វើឲ្យដួងចិត្តរបស់យើងមានទុក្ខព្រួយ ។ តាមរយៈដង្វាយធួនដ៏អស្ចារ្យ ហើយពេញដោយសេចក្ដីមេត្តាករុណានៃព្រះយេស៊ូវគ្រីស្ទ ដំណឹងល្អបង្ហាញផ្លូវយើងឲ្យសម្អាតស្នាមប្រឡាក់នៃអំពើបាបចេញពីព្រលឹងរបស់យើង ហើយប្រែក្លាយជាមនុស្សថ្មី បរិសុទ្ធ ហើយគ្មានកំហុសដូចជាកូនក្មេងម្នាក់ ។

ប៉ុន្តែពេលខ្លះ មានរឿងផ្សេងទៀតបានរារាំង ហើយបង្អាក់យើង ដោយធ្វើឲ្យកើតឡើងនូវគំនិត និងទង្វើឥតប្រយោជន៍ដែលធ្វើឲ្យយើងមានការលំបាកដើម្បីចាប់ផ្ដើម ។

### ការធ្វើឲ្យអស់ពីសមត្ថភាពរបស់យើង

ការដាក់គោលដៅគឺជាកិច្ចការមួយដ៏មានតម្លៃ ។ យើងដឹងថា ព្រះវរបិតាសួគ៌យើងមានគោលដៅច្រើន ដោយសារទ្រង់បានប្រាប់យើងថា កិច្ចការ និងសិរីល្អ



រូបថតពី iStockphoto/Thinkstock

**ការបង្រៀនចេញពីសារលិខិតនេះ**

ប្រធាន អុជដូហ្វ បានពន្យល់ថា នៅពេលយើងបរាជ័យនៅក្នុងការសម្រេចគោលដៅរបស់យើង « យើងអាចត្រូវបានប្រទានអំណាចឲ្យ ។. . . ទោះជាយើងអាចបរាជ័យនៅចុងបញ្ចប់ក្តី ការបន្តធ្វើដំណើរនឹងធ្វើឲ្យយើងបានប្រសើរឡើងជាងពីមុន » ។សុំឲ្យសមាជិកគ្រួសារចែកចាយបទពិសោធន៍ដែលពួកគេបានរៀនពីដំណើរការនេះច្រើនជាងអ្វីដែលពួកគេរៀនពីលទ្ធផល ដូចជាការបញ្ចប់ការសិក្សា ឬការទទួលរង្វាន់មួយ ។

របស់ទ្រង់គឺ « ដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ( ម៉ូសេ 1:39 ) ។

គោលដៅផ្ទាល់ខ្លួនរបស់យើងអាចឲ្យយើងធ្វើបានល្អបំផុត ។ ប៉ុន្តែ រឿងមួយដែលបំផ្លាញការខិតខំរបស់យើងនៅក្នុងការធ្វើ និងការរក្សាការតាំងចិត្តគឺការពន្យាពេល ។ ពេលខ្លះ យើងពន្យាពេលការចាប់ផ្តើម ដោយរង់ចាំពេលត្រឹមត្រូវដើម្បីចាប់ផ្តើម—ជាថ្ងៃដំបូងនៃឆ្នាំថ្មី នៅដើមរដូវក្តៅ ពេលដែលយើងត្រូវបានហៅជាប៊ីស្សព ឬប្រធានសមាគមសង្គ្រោះ បន្ទាប់ពីកូនៗចូលសាលារៀន បន្ទាប់ពីយើងចូលនិវត្តន៍ ។

អ្នកពុំចាំបាច់ឲ្យមានការអញ្ជើញមួយពីមុនអ្នកចាប់ផ្តើមងាកចូលទៅក្នុងទិសដៅនៃគោលដៅដ៏សុចរិតរបស់អ្នកឡើយ ។ អ្នកពុំចាំបាច់រង់ចាំការអនុញ្ញាតដើម្បីក្លាយជាមនុស្សដែលអ្នកត្រូវបានរៀបចំឲ្យប្រែក្លាយនោះទេ ។ អ្នកពុំចាំបាច់រង់ចាំឲ្យគេអញ្ជើញដើម្បីបម្រើនៅក្នុងសាសនាចក្រនោះទេ ។

ពេលខ្លះ យើងអាចខ្ជះខ្ជាយពេលវេលាពេញមួយជីវិតរបស់យើងដើម្បីរង់ចាំឲ្យគេជ្រើសរើស ( សូមមើល គ. និង ស. 121:34–36 ) ។ ប៉ុន្តែនោះជាគំនិតមួយដែលមិនពិត ។ អ្នកត្រូវបានជ្រើសរើសរួចហើយ !

ពេលខ្លះ នៅក្នុងជីវិតរបស់ខ្ញុំ ខ្ញុំដេកមិនលក់ដោយគិតពីបញ្ហា ការព្រួយបារម្ភ ឬភាពសោកសៅផ្ទាល់ខ្លួន ។ ប៉ុន្តែមិនថាយប់នោះមានភាពងងឹតដល់កម្រិតនោះទេ ខ្ញុំតែងតែលើកទឹកចិត្តខ្លួនឯងនូវគំនិតនេះថា ៖ នៅពេលព្រឹកព្រះអាទិត្យនឹងរះឡើង ។

ជាមួយនឹងថ្ងៃថ្មី នោះពន្លឺនៃព្រឹកព្រលឹមថ្មីមួយបានមកដល់—ពុំមែនតែចំពោះផែនដីប៉ុណ្ណោះទេ ប៉ុន្តែចំពោះយើងផងដែរ ។ ហើយជាមួយនឹងថ្ងៃថ្មីនោះការចាប់ផ្តើមថ្មីមួយបានមកដល់—ជាឱកាសដើម្បីចាប់ផ្តើមម្តងទៀត ។

## ចុះបើយើងបរាជ័យវិញ ?

ពេលខ្លះ រឿងដែលធ្វើឲ្យយើងរារែកគឺការភ័យខ្លាច ។ យើងប្រហែលជាភ័យខ្លាចថា យើងនឹងពុំទទួលបានជោគជ័យ ថាយើងនឹងទទួលបាន

ជោគជ័យ ថាយើងអាចនឹងត្រូវធ្វើឲ្យអាម៉ាស់មុខ ថាជោគជ័យនឹងផ្លាស់ប្ដូរយើង ឬថាវាអាចផ្លាស់ប្ដូរមនុស្សដែលយើងស្រឡាញ់ ។

ដូច្នេះហើយយើងក៏រង់ចាំ ។ ឬបោះបង់ ។

រឿងមួយទៀតដែលយើងត្រូវចងចាំនៅពេលដាក់គោលដៅនោះគឺថា ៖ យើងអាចនឹងបរាជ័យយ៉ាងប្រាកដ—យ៉ាងហោចណាស់នៅពេលដ៏ខ្លីខាងមុខ ។ ប៉ុន្តែជាជាងបាក់ទឹកចិត្ត យើងអាចត្រូវបានផ្ដល់អំណាចឲ្យដោយសារការយល់ដឹងនេះបានដកយកសម្ពាធនៃការមានភាពល្អឥតខ្ចោះនៅពេលនេះ ។ វាទទួលស្គាល់តាំងពីដើមដំបូងមកថា នៅពេលណាមួយ យើងអាចធ្វើខុស ។ ការដឹងពីបញ្ហានេះទុកជាមុនអាចដកយកការភ្ញាក់ផ្អើល និងការបាក់ទឹកចិត្តនៃការបរាជ័យជាច្រើន ។

នៅពេលយើងចាប់ផ្ដើមគោលដៅរបស់យើងតាមរបៀបនេះ ការបរាជ័យមិនអាចកំណត់យើងបានឡើយ ។ សូមចងចាំថា ទោះជាយើងបរាជ័យនៅក្នុងការសម្រេចគោលដៅដែលប៉ងប្រាថ្នាភ្លាមៗក្ដី ក៏យើងនឹងបានធ្វើនូវការរីកចម្រើនដែលនឹងដឹកនាំទៅរកវាផងដែរ ។

ហើយនោះជាបញ្ហាសំខាន់—វាមានន័យធំធេងណាស់ ។

ទោះជាយើងអាចបរាជ័យនៅចុងបញ្ចប់ក្ដី ការបន្តធ្វើដំណើរនឹងធ្វើឲ្យយើងបានប្រសើរឡើងជាងពីមុន ។

**គ្រាចាប់ផ្ដើមដ៏ល្អបំផុតគឺនៅពេលនេះ**

មានសុភាសិតបុរាណមួយពោលថា « គ្រាដ៏ល្អបំផុតដើម្បីដាំដើមឈើមួយគឺនៅ 20 ឆ្នាំមុន ។ គ្រាដ៏ល្អបំផុតទីពីរគឺនៅពេលនេះ » ។

មានអ្វីមួយដែលអស្ចារ្យ និងពោរពេញដោយសេចក្ដីសង្ឃឹមចំពោះពាក្យថា*នៅពេលនេះ* ។ មានអ្វីមួយដែលមានអំណាចចំពោះការពិតថាប្រសិនបើយើងជ្រើសរើសសម្រេចចិត្តនៅពេលនេះ នោះយើងអាចដើរឆ្ពោះទៅមុខឥឡូវនេះភ្លាម ។

*នៅពេលនេះ* គឺជាគ្រាដ៏ល្អបំផុតដើម្បីចាប់ផ្ដើមក្លាយជាមនុស្សដែលយើងចង់ប្រែក្លាយ—ពុំមែនត្រឹម 20 ឆ្នាំរាប់ពីពេលនេះទៅនោះទេ ប៉ុន្តែដ៏នៅអស់កល្បជានិច្ចផងដែរ ។ ■

## យុវវ័យ




### សូមធ្វើឲ្យខ្លួនអ្នកបានល្អបំផុត—ដោយចាប់ផ្ដើមនៅពេលនេះ

ប្រធាន អុជដូហ្វ បង្រៀនថា « គោលដៅផ្ទាល់ខ្លួនអាចឲ្យយើងធ្វើបានល្អបំផុត » ។ សូមពិចារណាដាក់គោលដៅមួយចំនួននៅក្នុងផ្នែកពីរ ឬបីនៃជីវិតរបស់អ្នក ឧទាហរណ៍ដូចជា សុខភាពរាងកាយ សុខភាពខាងវិញ្ញាណ និងមិត្តភាព ។ តើជោគជ័យអ្វីខ្លះដែលអ្នកចង់បានក្នុងផ្នែកទាំងនេះនៅឆ្នាំនេះ ? នៅពេលអ្នកគិតពីគោលដៅមួយចំនួនប្រកបដោយការអធិស្ឋាន សូមធ្វើឲ្យប្រាកដថា វាអាចធ្វើទៅបាន ប៉ុន្តែនឹងធ្វើឲ្យអ្នករីកចម្រើន ។ នៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក សូមរៀបរាប់លម្អិតពីគោលដៅរបស់អ្នក ដើម្បីអ្នកអាចមើលឃើញពីការរីកចម្រើនរបស់អ្នកនៅពេលមួយឆ្នាំបានកន្លងផុតទៅ ។





រូបថតដោយ គ្រីស្ទីណា ស្មីត និង ឡូរី ម៉ែល

*សូមសិក្សាឯកសារនេះ ហើយស្វែងរកដើម្បីបានដឹងនូវអ្វីដែលត្រូវចែកចាយប្រកបដោយការអធិស្ឋាន ។ តើការយល់ដឹងពីឆាកជីវិត និង បេសកកម្មរបស់ព្រះអង្គសង្គ្រោះ នឹងពង្រីកសេចក្ដីជំនឿរបស់អ្នកលើទ្រង់ ហើយប្រទានពរដល់ជន ដែលមើលថែតាមរយៈការបង្រៀនសួរសុខទុក្ខតាមផ្ទះដោយរបៀបណា ? សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ* reliefsociety.lds.org ។

# បេសកកម្មដ៏ទេវភាពនៃព្រះយេស៊ូវគ្រីស្ទ ៖ អង្គដ៏ជាគំរូ

*នេះជាផ្នែកនៃគំរូមួយអំពីសារលិខិតបង្រៀនសួរសុខទុក្ខតាមផ្ទះ ឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃបេសកកម្មរបស់ព្រះអង្គសង្គ្រោះ ។*



នៅពេលយើងយល់ថា ព្រះយេស៊ូវគ្រីស្ទគឺជាគំរូរបស់យើងនៅគ្រប់កិច្ចការទាំងអស់ នោះយើងអាចបង្កើនបំណងប្រាថ្នារបស់យើងដើម្បីធ្វើតាមទ្រង់ ។ ព្រះគម្ពីរគឺពោរពេញដោយការលើកទឹកចិត្តសម្រាប់យើងដើម្បីដើរតាមស្នាមព្រះបាតរបស់ព្រះគ្រីស្ទ ។ ព្រះគ្រីស្ទបានមានបន្ទូលទៅសាសន៍នីហ្វៃថា « ត្បិតអ្វីៗដែលអ្នករាល់គ្នាបានឃើញយើងធ្វើយ៉ាងណា នោះអ្នកត្រូវធ្វើតាមយ៉ាងនោះដែរ » ( នីហ្វៃទី 3 27:21 ) ។ ព្រះយេស៊ូវបានមានបន្ទូលទៅថូម៉ាសថា « ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ » ( យ៉ូហាន 14:6 ) ។

សព្វថ្ងៃនេះ ពួកអ្នកដឹកនាំរបស់យើងរំឭកយើងឲ្យយកព្រះអង្គសង្គ្រោះធ្វើជាគំរូរបស់យើង ។ លីនដា ខេ ប៊ើតុន ជាប្រធានសមាគមសង្គ្រោះទូទៅបានមានប្រសាសន៍ថា « នៅពេលយើងម្នាក់ៗមានគោលលទ្ធិនៃដង្វាយធួនឆ្លាក់ជាប់យ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់យើង នោះយើងនឹងចាប់ផ្ដើមក្លាយជាមនុស្សដែលព្រះអម្ចាស់ចង់ឲ្យយើងប្រែក្លាយ » ។[1]

ប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា « ព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ គឺជាអង្គដ៏គំរូរបស់យើង និងជាកម្លាំងរបស់យើង » ។[2]

ចូរយើងខិតខំចូលទៅជិតព្រះយេស៊ូវគ្រីស្ទ គោរពព្រះបញ្ញត្តិរបស់ទ្រង់ ហើយព្យាយាមត្រលប់ទៅរកព្រះវរបិតាសួគ៌របស់យើងវិញ ។

### *ចេញពីព្រះគម្ពីរ*

នីហ្វៃទី 2 នីហ្វៃទី 31:16, អាលម៉ា 17:11, នីហ្វៃទី 3 27:27, មរ៉ូណៃ 7:48

**កំណត់ចំណាំ**
1. លីនដា ខេ ប៊ើតុន « Is Faith in the Atonement of Jesus Christ Written in Our Hearts? » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 114 ។
2. ថូម៉ាស អេស ម៉នសុន « Meeting Life's Challenges » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1993 ទំព័រ 71 ។
3. « ឱប្រាជ្ញា និងក្ដីស្រឡាញ់ដ៏ធំអស្ចារ្យ » *ទំនុកតម្កើង និង ចម្រៀងកុមារាកុមារី* ទំព័រ 19 ។
4. ឌៀថើរ អេស្វ អុជដូហ្វ « Happiness, Your Heritage » ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ 2008 ទំព័រ 120 ។

## តើខ្ញុំអាចធ្វើអ្វីបាន ?

1. ហេតុអ្វីព្រះយេស៊ូវគ្រីស្ទគឺជាអង្គដ៏គំរូរបស់ខ្ញុំ ? ដោយរបៀបណា ?
2. តើការបម្រើដល់បងប្អូនស្រីដែលខ្ញុំបានទៅសួរសុខទុក្ខ អាចជួយខ្ញុំឲ្យដើរតាមព្រះអង្គសង្គ្រោះបានដោយរបៀបណា ?

## សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ

### *ចេញពីប្រវត្តិសាស្ត្ររបស់យើង*

អ៊ីឡៃហ្សា អរ ស្នូ ជាប្រធានសមាគមសង្គ្រោះទូទៅទីពីរ បានសរសេរពីការបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះយេស៊ូវគ្រីស្ទថា « ទ្រង់បានគូសដាន ហើយដឹកនាំផ្លូវ » ។[3] ទ្រង់បានបម្រើមនុស្សទូទៅ—ម្នាក់ម្ដងៗ ។ ទ្រង់បានបង្រៀនថា យើងគួរទុកសត្វចៀមកៅសិបប្រាំបួន ហើយទៅសង្គ្រោះសត្វចៀមមួយដែលវង្វេងផ្លូវ ( សូមមើល លូកា 15:3–7 ) ។ ទ្រង់បានព្យាបាល ហើយបានបង្រៀនមនុស្សទូទៅថែមទាំងចំណាយពេលសម្រាប់មនុស្សម្នាក់ៗក្នុងក្រុមមនុស្ស 2,500 នាក់ ( សូមមើល នីហ្វៃទី 3 11:13–15, 17:25 ) ។

ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ជាទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ បានមានប្រសាសន៍ពីស្ត្រីនៃពួកបរិសុទ្ធថ្ងៃចុងក្រោយថា ៖ « អ្នកដែលជាបងប្អូនស្រីដ៏អស្ចារ្យបានផ្ដល់ការបម្រើដ៏សប្បុរសដល់មនុស្សដទៃសម្រាប់ហេតុផលដែលធំធេងជាងបំណងប្រាថ្នាចង់បានផលប្រយោជន៍ផ្ទាល់ខ្លួន ។ ក្នុងកិច្ចការនេះ អ្នកបានដើរតាមព្រះអង្គសង្គ្រោះ ។. . . គំនិតរបស់ទ្រង់តែងតែចង់ជួយដល់មនុស្សដទៃជានិច្ច » ។[4]

ការលេចឡើងវិញ ដោយ ហារី អាន់ឌើរសិន

# សៀវភៅកំណត់ចំណាំសន្និសីទខែ តុលា ឆ្នាំ ២០១៣

*« អ្វីដែលយើងជាព្រះអម្ចាស់បានមានបន្ទូល នោះយើងបានមានបន្ទូលហើយ . . . ទោះជាដោយ សំឡេងរបស់យើងផ្ទាល់ ឬ ក៏ដោយសំឡេងនៃពួកអ្នកបម្រើរបស់យើងក្តី គឺដូចតែគ្នា » ( គ. និង ស.១:៣៨ ) ។*

*នៅពេលអ្នកមើលសន្និសីទទូទៅខែ តុលា ឆ្នាំ ២០១៣ ឡើងវិញ នោះអ្នកអាចប្រើប្រាស់ទំព័រទាំងនេះ ( និង សៀវភៅកំណត់ចំណាំសន្និសីទសម្រាប់ច្បាប់ចេញផ្សាយនាពេលខាងមុខទៀត ) ដើម្បីជួយអ្នកសិក្សា និង អនុវត្ត ការបង្រៀនថ្មីៗរបស់ពួកព្យាការី និង សាវក ដែលកំពុងរស់នៅ និង ពួកអ្នកដឹកនាំដទៃៗទៀតនៃសាសនាចក្រ ។*



## ការសន្យាពីព្យាការី ៖ ការប្រឈមមុខនឹងការសាកល្បងនានា

« **ព្រះ**បិតាសួគ៌យើង ដែលប្រទានពរជ័យច្រើនដល់យើងឲ្យរីករាយ ក៏ជ្រាបដែរថា យើងរៀន និងរីកចម្រើន ហើយកាន់តែរឹងមាំពេលយើងប្រឈមហើយរស់ក្នុងការសាកល្បងដែលយើងត្រូវឆ្លងកាត់ ។ យើងដឹងថា ពេលខ្លះ យើងនឹងជួបទុក្ខព្រួយដ៏ខ្លាំង ជាពេលយើងសោកសៅ ជាពេលយើងនឹងសាកល្បងនឹងភាពអំណត់យើង ។ តែការលំបាកបែបនោះអនុញ្ញាតឲ្យយើងផ្លាស់ប្តូរ ឬ កសាងជីវិតថ្មីតាមរបៀបដែលព្រះវរបិតាសួគ៌បង្រៀន ហើយប្រែក្លាយជាអ្វីមួយខុសពីមុន គឺធ្វើឲ្យកាន់តែ—ប្រសើរ យល់កាន់តែច្បាស់ យល់ចិត្តកាន់តែខ្លាំង និង ទីបន្ទាល់កាន់តែរឹងមាំជាងកាលពីមុន ។

« ការណ៍នេះគប្បីជាគោលបំណងយើង—ដើម្បីរក្សា និងកាន់ខ្ជាប់ មែនហើយ ប្រែជាបរិសុទ្ធខាងវិញ្ញាណលើសពីមុន ពេលធ្វើដំណើរកាត់ពន្លឺ និងទីងងឹត ។ បើគ្មានឧបសគ្គ ដើម្បីយកឈ្នះ និងបញ្ហា ដើម្បីដោះស្រាយទេ នោះ យើងច្បាស់ជានៅដដែល ដោយគ្មាន ឬមានការរីកចម្រើនតែបន្តិចប៉ុណ្ណោះឆ្ពោះទៅជីវិតអស់កល្ប » ។

**ប្រធាន ថូម៉ាស អេស ម៉នសុន « យើងមិនដែលខាននឹងប្រោសឯង ក៏មិនដែលបោះបង់ចោលឯងឡើយ »** ***Liahona*** **ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៨៧ ។**

## ចម្លើយសម្រាប់អ្នក

សន្និសីទនិមួយៗ ពួកព្យាការី និងសាវក ផ្តល់ចម្លើយដ៏បំផុសគំនិតចំពោះសំណួរ ដែលសមាជិកសាសនាចក្រអាចមាន ។ សូមប្រើប្រាស់ច្បាប់ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឬ ចូលទៅកាន់គេហទំព័រ conference.lds.org ដើម្បីស្វែងរកចម្លើយចំពោះសំណួរទាំងនេះ ៖

- តើយើងរៀនពីគោលលទ្ធិអ្វីខ្លះនៅក្នុងមាត្រានៃសេចក្តីជំនឿ ? សូមមើល អិល ថម ភែរី « គោលលទ្ធិ និង គោលការណ៍ដែលមាននៅក្នុងមាត្រានៃសេចក្តីជំនឿ » ។
- តើយើងអាចរួមចំណែកនៅក្នុងកិច្ចការផ្សព្វផ្សាយសាសនាបានយ៉ាងដូចម្តេច បើយើងមានអារម្មណ៍ភ័យខ្លាចនោះ ? សូមមើល អិម រ័សុល បាឡឺដ « ចូរទុកចិត្តដល់ព្រះយេហូវ៉ាចុះ » ។
- តើដង្វាយមួយភាគក្នុងដប់ត្រូវបានប្រើប្រាស់សម្រាប់អ្វី ? សូមមើល ដេវីឌ អេ បែដណា « បង្អួចនៃស្ថានសួគ៌ » ។
- តើអំពើបាប និងការបះបោរ អាចជះឥទ្ធិពលដល់សិទ្ធិជ្រើសរើសរបស់យើង ហើយដឹកនាំយើងទៅកាន់សេវកភាពយ៉ាងដូចម្តេច ? សូមមើល ឃ្វីនថិន អិល ឃុក « ការទួញសោកយេរេមា ៖ ចូរចៀសវាងពីការជាប់ឃុំឃាំង » ។

ដើម្បីអាន ទស្សនា ឬ ស្តាប់សុន្ទរកថាសន្និសីទទូទៅ សូមចូលទៅកាន់គេហទំព័រ conference.lds.org ។
តើក្រុមគ្រួសាររបស់អ្នក កំពុងតែអនុវត្តអ្វីដែលអ្នករៀនពីសន្និសីទទូទៅយ៉ាងដូចម្តេច ? សូមផ្ញើសារអេឡិចត្រូនិកទៅកាន់ liahona@ldschurch.org ។



## ទៅ ហើយ ធ្វើ

អែលឌើរ រ៉ូប៊ឺត ឌី ហែល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា ពរជ័យមហិមានៃសន្និសីទកើតមាននៅពេលយើង ៖



1. « ប្រមូលគ្នាស្ដាប់បន្ទូលព្រះអម្ចាស់ » ។



2. « ត្រឡប់ទៅផ្ទះវិញរស់នៅតាមអ្វីដែលស្ដាប់ឮ » ។

**ចេញពី « សន្និសីទទូទៅ ៖ ការពង្រឹងសេចក្ដីជំនឿ និងទីបន្ទាល់ » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៧ ) ។**

## ប្រសាសន៍ព្យាការីស្ដីពីស្ត្រី និងបព្វជិតភាព

អែលឌើរ នែល អិល អាន់ឌើរសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍សួរថា ៖ « ចុះហេតុអ្វីពិធីបរិសុទ្ធបព្វជិតភាពត្រូវធ្វើឡើងដោយបុរស ? . . .

« ទោះជាយើងដឹងថា ក្ដីស្រឡាញ់ព្រះ ‹ គឺដូចគ្នា › សម្រាប់បុត្រា និងបុត្រីទ្រង់ យើងក៏ដឹងថា ទ្រង់ពុំបង្កើតបុរស និងស្ត្រីឲ្យដូចគ្នានោះទេ ។ យើងដឹងថា ភេទជាលក្ខណៈសម្បត្តិសំខាន់ទាំងអត្តសញ្ញាណ និងគោលបំណងលើផែនដី និងអស់កល្ប ។ ទំនួលខុសត្រូវពិសិដ្ឋត្រូវបានផ្ដល់ចំពោះភេទនីមួយៗ ។

« យើងដឹងថា តាំងពីដំបូងឡើយ ព្រះបង្កើតរបៀប ដែលបព្វជិតភាពទ្រង់ត្រូវបានប្រើ » ។

នៅក្នុងការកត់ចំណាំចុងក្រោយទី ១២ នៃសុន្ទរកថានេះ អែលឌើរ អាន់ឌើរសិន បានលើកឡើងចំពោះពួកព្យាការីផ្សេងទៀត ដែលឆ្លើយតបនឹងសំណួរនេះ ។ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ ១៩១០–២០០៨ ) បានមានប្រសាសន៍ថា « គឺជាព្រះអម្ចាស់ ដែលចាត់តាំងឲ្យបុរសនៅក្នុងសាសនាចក្ររបស់ទ្រង់កាន់បព្វជិតភាព » ។ អែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា « ព្រះអម្ចាស់ពុំបើកសម្ដែងពីមូលហេតុ ដែលទ្រង់បានបង្កើតសាសនាចក្រនេះឡើងដូចដែលទ្រង់បានមាននោះឡើយ » ។

**ចេញពី « អំណាចដែលមានក្នុងបព្វជិតភាព » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៩២ ។**



### សូមបំពេញក្នុងចន្លោះ

1. « ជនរក្សាសេចក្ដីសញ្ញាគឺជា ជនរក្សា________________ » ! ( លីនដា ខេ ប៊ើតុន « អំណាច ក្ដីអំណរ និងក្ដីស្រឡាញ់ក្នុងការរក្សាសេចក្ដីសញ្ញា » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ១១៣ ) ។
2. « មនុស្សជាច្រើនត្រូវបានដឹកនាំដោយព្រះដោយមិនដឹងខ្លួន ទៅតំបន់ដែលគេអាចឮ______________ហើយចូលមកក្នុង______________ទ្រង់ ( ហ្គេរ៉ាល កូសសេ « អ្នករាល់គ្នាមិនមែនជាអ្នកដទៃទៀតទេ » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៥០ ) ។
3. « សេចក្ដីសុចរិត មានអំណាចជាង______________ » ( ប៊ិយជ័ យេ ជាកកឺ « កូនសោទៅកាន់ការការពារខាងវិញ្ញាណ » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ២៧ ) ។
4. « ពេលភាពទីទៃរវាងស្ត្រី និងបុរសកាន់តែច្របូកច្របល់ នោះយើងបាត់បង់ភាពច្បាស់លាស់ ថ្លឹងថ្លែងអំណោយទានរវាង______________ និង ______________ ដែលគេទាំងពីររូបអាចបង្កើតជាផ្លែផ្កាធំសម្បើម » ( ឌី ថត គ្រីស្តូហ្វឺសិន « កម្លាំងសីលធម៌របស់ស្ត្រី » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៣១ ) ។

ចម្លើយ ៖ 1. បទបញ្ញត្តិ 2. ដំណឹងល្អ, ក្រោល 3. សេចក្ដីទុច្ចរិត 4. ស្ត្រី, បុរស ។

ខាងឆ្វេង ៖ រូបថតដោយ អាស្ទុគុន ជី ស្មឹធ; ខាងស្ដាំ មើលពីលើ ពីឆ្វេងទៅស្ដាំ ៖ រូបថតដោយ អរហ្គើស មីលើរ; ការបង្ហាញរូបថតដោយ ខាឡូស អ៊ីស្រាអែល ហ្គូទៀរេស រូបល; រូបថតដោយ អែមិលី លែសមែន ប៊ីស

# ចេញពីភាពងងឹតចូលទៅក្នុងពន្លឺ

*យើងអាចដឹងដោយភាពពិតប្រាកដមួយ នៅពេលជីវិតរបស់យើងស្ថិតនៅក្នុងភាពខ្មៅងងឹតរហូតដល់ព្រះយេស៊ូវគ្រីស្ទអាចផ្លាស់ប្តូរភាពខ្មៅងងឹតនោះទៅជាពន្លឺ នៅពេលយើងប្រែចិត្តដោយស្មោះត្រង់ ។*

**ឈ្មោះត្រូវបានដកចេញ**

នៅក្នុងជីវិតរបស់ខ្ញុំ ពេលខ្លះខ្ញុំមានអារម្មណ៍ថា វាគ្មានសង្ឃឹមសម្រាប់ខ្ញុំដើម្បីមានភាពរីករាយ ឬ ត្រលប់ទៅរកព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌វិញឡើយ ។ ប៉ុន្មានឆ្នាំមុន ខ្ញុំត្រូវបានបញ្ឈប់ការរាប់អានពីសាសនាចក្រ ។ ខ្ញុំបានរស់នៅក្នុងជីវិតមួយនៃអំនួត និងអំពើបាប ហើយបានរងទុក្ខយ៉ាងធំធេង ដោយសារតែទង្វើររបស់ខ្ញុំ ។ ការភ្ជាប់ពាក្យជាមួយនឹងមនុស្សស្រីដែលខ្ញុំស្រឡាញ់បានប្រេះឆា ទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងមនុស្សដទៃជារឿងសោសៅ ហើយខ្ញុំគ្មានភាពរីករាយ ។

ទោះបីជាខ្ញុំមានបំណងប្រាថ្នាថាខ្ញុំបានជ្រើសយកមានចិត្តរាបសាពីមុននោះក្តី ក៏ខ្ញុំត្រូវបានបង្ខំចិត្តឲ្យមានចិត្តរាបសា ហើយព្យាយាមធ្វើតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ដែរ ។ ខ្ញុំបានចាប់ផ្តើមអានព្រះគម្ពីរជាញឹកញាប់ អធិស្ឋានជានិច្ច ហើយស្វែងរកការបម្រើដល់មនុស្សដទៃទៀត ។ ខ្ញុំបានព្យាយាមព្យាបាលទំនាក់ទំនងដែលខ្ញុំបានបដិសេធជាយូរមកហើយ រួមទាំង ទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងព្រះវរបិតាសួគ៌របស់ខ្ញុំផងដែរ ។ ខ្ញុំពិតជាមានបំណងធ្វើការផ្លាស់ប្តូរដួងចិត្តមែន ។

នៅព្រឹកព្រលឹមនាថ្ងៃមួយ ពេលខ្ញុំបើកឡានទៅសាលា ហើយព្រះអាទិត្យនៅមិនទាន់រះនៅឡើយ ។ ផ្ទៃមេឃនៅភាគខាងកើតបានភ្លឺ ហើយផ្ទៃមេឃនៅភាគខាងលិចមានភាពងងឹត ដោយមានព្រះច័ន្ទពេញវង់ដែលលិចសន្សឹមៗនៅពីក្រោយវា ។ ខ្ញុំបានអភិវឌ្ឍនូវទម្លាប់សន្ទនាជាមួយនឹងព្រះវរបិតាសួគ៌របស់យើងខណៈដែលកំពុងបើកបរឡាន ។ នៅពេលខ្ញុំបានអធិស្ឋានអំឡុងពេលបើកឡាន គំនិតរបស់ខ្ញុំត្រូវបានបំភ្លឺ ហើយសេចក្តីសង្ឃឹមថ្មីមួយបានកើតមាននៅក្នុងដួងចិត្តរបស់ខ្ញុំ ។

ខ្ញុំបានដឹងថា ជីវិតរបស់ខ្ញុំកំពុងមានពន្លឺ ហើយភ្លឺជាងមុន ដូចជាផ្ទៃមេឃនៅទិសខាងកើតដែរ ។ ភាពងងឹតបានរសាយបាត់ ហើយអំពើបាបរបស់ខ្ញុំដែលធំដូចជាព្រះច័ន្ទពេញវង់នោះដែរ ត្រូវបានកំពុងលាងជម្រះ ។ វាពុំទាន់ស្អាតអស់នៅឡើយទេ ប៉ុន្តែខ្ញុំបានដឹងថាមិនយូរប៉ុន្មានវានឹងរលុបបាត់ប្រសិនបើខ្ញុំបន្តការប្រែចិត្តដ៏ស្មោះត្រង់របស់ខ្ញុំ ។



**សុភមង្គលតាមរយៈការប្រែចិត្ត**

« តើយើងយល់ពី [ ការយកព្រះទ័យទុកដាក់ ] របស់ព្រះវរបិតាសួគ៌នៃយើង នៅរាល់កិច្ចខិតខំប្រឹងប្រែងរបស់យើងដើម្បីត្រលប់ទៅរកទ្រង់ដែរឬទេ ? ទោះជាពេលនៅលើផ្លូវដ៏សែនឆ្ងាយក្តី ក៏ទ្រង់ស្វាគមន៍ការត្រលប់មកវិញរបស់យើងដែរ ។ យើងជួបសេចក្តីអំណរ នៅពេលសេចក្តីស្រឡាញ់នៃព្រះអង្គសង្គ្រោះរបស់យើងអះអាងចំពោះយើងថា យើងនឹងអាចត្រូវបានលាងសម្អាតឲ្យស្អាត ថានៅថ្ងៃណាមួយយើងនឹងទៅដល់ផ្ទះម្តងទៀត ។ សុភមង្គលនេះកើតមានតែតាមរយៈការប្រែចិត្តប៉ុណ្ណោះ ។

« នៅពេលយើងលះបង់នូវការធ្វើខុស ហើយអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ នោះយើងទទួលបានការលោះលាងមួយចេញពីអំពើបាបរបស់យើង ។ យើងមានអារម្មណ៍ថា ព្រះអង្គសង្គ្រោះកំពុងធ្វើការសម្រាប់យើងនូវអ្វីដែលយើងមិនអាចធ្វើដោយខ្លួនឯងបាន » ។

**អែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « The Joy of Becoming Clean » *Ensign* ខែ មេសា ឆ្នាំ 1995 ទំព័រ 51 ។**



ខ្ញុំមានសេចក្តីសង្ឃឹមថា នៅថ្ងៃមួយជីវិតរបស់ខ្ញុំនឹងភ្លឺដូចជាពេលថ្ងៃដូច្នោះដែរ ។

ជាមួយនឹងពេលវេលា និងនៅពេលខ្ញុំអធិស្ឋានសុំសេចក្តីស្រឡាញ់ចំពោះព្រះវរបិតាសួគ៌របស់ខ្ញុំ និងមនុស្សដទៃទៀត នោះខ្ញុំកាន់តែមានចិត្តរាបសា ។ ការកើនឡើងនូវចិត្តរាបសាបានដឹកនាំខ្ញុំឲ្យបម្រើព្រះ និងមនុស្សដទៃទៀតដោយគ្មានភាពអាត្មានិយម ហើយសេចក្តីសង្ឃឹមរបស់ខ្ញុំសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច និងអនាគតដ៏ប្រសើរត្រូវបានចាប់ផ្តើមជាថ្មី ហើយរីកចម្រើន ។ នៅពេលសេចក្តីសង្ឃឹមបានចម្រើនឡើង នោះសេចក្តីជំនឿរបស់ខ្ញុំថា ព្រះអង្គសង្គ្រោះរបស់ខ្ញុំគឺព្រះយេស៊ូវគ្រីស្ទ មានមហិទ្ធិឫទ្ធិដើម្បីសង្គ្រោះ និងដើម្បីលាងសម្អាតខ្ញុំពីរាល់សេចក្តីទុច្ចរិតកើនឡើងផងដែរ ។ ខ្ញុំដឹងថា សម្តីរបស់មរមនគឺជាការពិត ៖ « អ្នករាល់គ្នានឹងមានសេចក្តីសង្ឃឹម ដោយតាមរយៈដង្វាយធួននៃព្រះគ្រីស្ទ និងអំណាចនៃដំណើររស់ឡើងវិញរបស់ទ្រង់ ដើម្បីឲ្យបានប្រោសឲ្យមានជីវិតដ៏នៅអស់កល្បជានិច្ច » ( មរ៉ូណៃ 7:41 ) ។ ■

**តើលក្ខខណ្ឌនៃការប្រែចិត្តមានអ្វីខ្លះ ?**

ព្យាការីហេលេមិនបានបង្រៀនថា ការប្រែចិត្តមានលក្ខខណ្ឌដូចជា ៖

« ព្រះអម្ចាស់ទ្រង់ប្រាកដជានឹងយាងមកប្រោសលោះរាស្ត្រទ្រង់ ប៉ុន្តែ. . .ទ្រង់នឹងមិនយាងមកប្រោសលោះពួកគេក្នុងអំពើបាបទាំងឡាយរបស់ពួកគេទេ ប៉ុន្តែមកប្រោសលោះពួកគេពីអំពើបាបរបស់គេវិញ ។

« ហើយទ្រង់មានព្រះចេស្តាដែលព្រះវរបិតាបានប្រទានដល់ទ្រង់ ដើម្បីប្រោសលោះពួកគេពីអំពើបាបរបស់គេដោយមកពីការប្រែចិត្ត ហេតុដូច្នេះហើយ ទ្រង់បានចាត់ឲ្យពួកទេវតារបស់ទ្រង់មកប្រកាសដំណឹងល្អអំពី*លក្ខខណ្ឌទាំងឡាយនៃការប្រែចិត្ត* ដែលនាំទៅកាន់ព្រះចេស្តានៃព្រះដ៏ប្រោសលោះឲ្យបានដល់សេចក្តីសង្គ្រោះព្រលឹងរបស់គេ » ( ហេលេមិន 5:10–11;, ជាការគូសបញ្ជាក់បន្ថែម ) ។

សូមពិចារណាសិក្សានូវបទគម្ពីរដូចតទៅនេះ ដើម្បីយល់ដឹងឲ្យបានច្បាស់ពីលក្ខខណ្ឌមួយចំនួននោះ ៖ រ៉ូម 3:23, នីហ្វៃទី 1 នីហ្វៃទី 10:21, នីហ្វៃទី 2 2:8, ម៉ូសាយ 4:9–10, គោលលទ្ធិ និង សេចក្តីសញ្ញា 58:42–43 ។

---

***យើងស្វាគមន៍ដំណើររឿងនៃបទពិសោធន៍របស់អ្នកក្នុងដំណឹងល្អដែលទាក់ទងនឹងការបម្រើ និងបេសកកម្មរបស់ព្រះអង្គសង្គ្រោះ ។ អត្ថបទដែលអាចបញ្ចូលរួមមានដង្វាយធួន ព្រះគុណ ការព្យាបាល សេចក្តីសង្ឃឹម ឬការកែប្រែចិត្ត ។ សូមកំណត់អត្ថបទរបស់អ្នកត្រឹម 600 ពាក្យ សូមបិទស្លាកឈ្មោះវាថា « យើងនិយាយអំពីព្រះគ្រីស្ទ » ហើយផ្ញើមក liahona.lds.org ឬអ៊ីម៉ែលវាទៅកាន់ liahona@ldschurch.org ។***

រូបថត © Shutterstock.com/Krivosheev Vitaly

# អ័ដាម

*« មានមនុស្សពីរបីនាក់បានចូលរួមដោយផ្ទាល់នៅក្នុងភាពអស់កល្បជានិច្ចក្នុងផែនការនៃសេចក្ដីសង្គ្រោះលើសពី. . .បុរសឈ្មោះអ័ដាម » ។*[1]

មនុស្សភាគច្រើនស្គាល់ខ្ញុំថាជាបុរសទីមួយដែលរស់នៅលើផែនដី ប៉ុន្តែពុំដឹងថាខ្ញុំមានទំនួលខុសត្រូវពិសេសមួយពីមុនខ្ញុំមកកាន់ផែនដីនេះឡើយ ។ នៅជីវិតមុនផែនដី ខ្ញុំបានដឹកនាំទ័ពរបស់ព្រះច្បាំងនឹងទ័ពរបស់សាតាំងក្នុងសង្គ្រាមលើស្ថានសួគ៌[2] ហើយខ្ញុំបានជួយព្រះយេស៊ូវគ្រីស្ទបង្កើតផែនដីនេះ ។[3] ខ្ញុំត្រូវបានគេស្គាល់ថាជាមីកែល នៅពេលនោះ ដែលមានន័យថា ជាបុរសម្នាក់ « ដែលប្រៀបបាននឹងព្រះ » ។[4]

ព្រះបានជ្រើសខ្ញុំឲ្យធ្វើបុរសទីមួយនៅលើផែនដី ហើយបានដាក់ខ្ញុំនៅក្នុងសួនច្បារអេដែន ជាស្ថានសួគ៌លោកិយមួយដែលមានរុក្ខជាតិ និងសត្វគ្រប់ប្រភេទ ។ ទ្រង់បានផ្លុំ « ខ្យល់ដង្ហើមនៃជីវិត »[5] ចូលទៅក្នុងខ្លួនខ្ញុំ ហើយបានប្រទានឈ្មោះថ្មីមួយឲ្យខ្ញុំថា ៖ អ័ដាម ។[6]

ព្រះទ្រង់បានប្រាប់ភរិយារបស់ខ្ញុំ អេវ៉ា និងខ្ញុំកុំឲ្យបរិភោគផ្លែឈើដឹងខុសត្រូវ ។[7] ប្រសិនបើយើងមិនបរិភោគផ្លែឈើនោះ យើងអាចនៅក្នុងសួនច្បារនោះ ហើយរស់នៅជារៀងរហូត ប៉ុន្តែយើងនឹងមិនអាច « រីកចម្រើនដោយការដកពិសោធន៍នូវភាពផ្ទុយនៅក្នុងជីវិតរមែងស្លាប់ »[8] ឬមានកូនចៅឡើយ ។[9] ការជ្រើសរើសនោះគឺជាសិទ្ធិរបស់យើង ។

ដោយសារបានជ្រើសរើសបរិភោគផ្លែឈើនោះ យើងត្រូវបានចាកចេញពីសួនច្បារនោះ និងពីវត្តមានរបស់ព្រះ ។ នេះត្រូវបានស្គាល់ថាជាការធ្លាក់ ។ យើងបានក្លាយជាមនុស្សរមែងស្លាប់ ដកពិសោធន៍ទាំងសេចក្ដីល្អ និងសេចក្ដីអាក្រក់ក្នុងជីវិត ហើយបាននាំយកកូនចៅមកផែនដី ។[10]

ព្រះទ្រង់បានជ្រាបថា ការធ្លាក់នឹងកើតមានឡើង—ទ្រង់បានបញ្ជូនព្រះយេស៊ូវគ្រីស្ទឲ្យធ្វើដង្វាយធួនសម្រាប់អំពើបាបរបស់យើង ហើយយកឈ្នះលើសេចក្ដីស្លាប់ ដើម្បីឲ្យយើង និងកូនចៅរបស់យើងអាចត្រលប់ទៅរកទ្រង់វិញ ។[11]

អេវ៉ា និងខ្ញុំបានរៀនពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ—រួមមានសេចក្ដីជំនឿជឿលើ



ព្រះយេស៊ូវគ្រីស្ទ ការប្រែចិត្ត បុណ្យជ្រមុជទឹក ការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ និងការកាន់ខ្ជាប់ដរាបដល់ចុងបំផុត—ហើយយើងបានបង្រៀនការណ៍នោះដល់កូនចៅរបស់យើង ។[12]

ដោយសារតែបទពិសោធន៍របស់ខ្ញុំ ភ្នែករបស់ខ្ញុំត្រូវបានបើក ហើយខ្ញុំមានសេចក្ដីអំណរនៅក្នុងជីវិតនេះ ។[13] សូមចងចាំថា អ្នកក៏អាចទទួលអារម្មណ៍ពីសេចក្ដីស្រឡាញ់របស់ព្រះ ហើយត្រលប់ទៅរកទ្រង់ផងដែរ ប្រសិនបើអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ[14] ដូចជាខ្ញុំបានរៀនធ្វើវា ។ ■






ពីខាងឆ្វេង ៖ រូបគំនូរដោយ ឌេន បាកស្នើរ, *Adam and Eve in the Garden ( អ័ដាម និង អេវ៉ា ក្នុងសួនច្បារ )* ដោយ ឡូវែល ប្រ៊ូស បើណេត, *Leaving the Garden of Eden ( ការចាកចេញពីសួនច្បារអេដែន )* ដោយ យ៉ូសែប ប្រ៊ីឃី, *In Similitude ( និមិត្តរូប )* ដោយ យ៉ូសែប ប្រ៊ីឃី, *Adam and Eve Teaching Their Children ( អ័ដាម និងអេវ៉ាកំពុងបង្រៀនកូនចៅខ្លួន )* ដែល ឌេល ផាសុន, *Adam Ordaining Seth ( អ័ដាមតែងតាំងសេត )* ដោយ ឌេល ផាសុន, *Adam-ondi-Ahman ( អាដាម-អុនដៃ-អាម៉ាន )* ដោយ ឌេល ផាសុន, *The Archangel Michael Defeating Satan ( មហាទេវតា មីកែល កំពុងតតាំងនឹងសាតាំង )* ដោយ Guido Reni/Bridgeman Art Library/Getty Images, ផ្ទៃខាងក្រោយមកពី iStockphoto/Thinkstock

**ប្រអប់ការពិត ៖ អ័ដាម**

**ឈ្មោះ ៖** អ័ដាម, អ័ដាម ជាឪពុក, អ្នកពីចាស់បុរាណ, មីកែល[15]

**អាយុនៅពេលស្លាប់ ៖** 930[16]

**តួនាទីក្នុងជីវិតមុនផែនដី ៖** ដឹកនាំទ័ពរបស់ព្រះច្បាំងនឹងសាតាំង, បានជួយព្រះយេស៊ូវគ្រីស្ទបង្កើតផែនដី ។

**តួនាទីក្នុងជីវិតរមែងស្លាប់ ៖** អយ្យកោ, ស្វាមី និងឪពុក ។ គាត់បានជួយនាំឲ្យមានការធ្លាក់ ។ គាត់បានរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

**តួនាទីក្រោយជីវិតរមែងស្លាប់ ៖** នឹងមកជួបប្រជាជនរបស់លោកនៅអ័ដាម-អុនដៃ-អាម៉ាន[17] ជួយនៅក្នុងការរស់ឡើងវិញ[18] ដឹកនាំចម្បាំងចុងក្រោយច្បាំងនឹងសាតាំង[19]

**កំណត់ចំណាំ**

1. រ៉ូប៊ឺត អិល មិល្លីត « The Man Adam » *Ensign* ខែ មករា ឆ្នាំ 1994 ទំព័រ 8 ។
2. សូមមើល វិវរណៈ 12:7–8 ។
3. សូមមើល រ៉ូប៊ឺត អិល មិល្លីត « The Man Adam » ទំព័រ 10 ។
4. សេចក្ដីណែនាំដល់បទគម្ពីរ « មីកែល » scriptures.lds.org ។
5. លោកុប្បត្តិ 2:7 ។
6. សូមមើល ម៉ូសេ 1:34 ។
7. សូមមើល លោកុប្បត្តិ 2:16–17, ម៉ូសេ 3:16–17 ។
8. *ប្រកាសដំណឹងល្អរបស់យើង ៖ មគ្គុទេសន៍ចំពោះការបម្រើជាអ្នកផ្សព្វផ្សាយសាសនា* ( ឆ្នាំ 2004 ) ទំព័រ 49 ។
9. សូមមើល នីហ្វៃទី 2 2:22–23 ) ។
10. សូមមើល ម៉ូសេ 4:22–31, 5:10–11, អាលម៉ា 12:21–27 ។
11. សូមមើល យ៉ូហាន 3:16–17, កូរិនថូសទី 1 15:22, នីហ្វៃទី 2 9:21, អាលម៉ា 42:2–15 ។
12. សូមមើល ម៉ូសេ 5:1–12, 58–59, 6:51–67 ។
13. សូមមើល ម៉ូសេ 5:10 ។
14. សូមមើល ម៉ូសាយ 27:25–26 ។
15. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 27:11 ។
16. សូមមើល លោកុប្បត្តិ 5:5 ។
17. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 116:1, ដានីយ៉ែល 7:9–14 ។
18. សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា 29:26 ។
19. សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា 88:114–16 ។



**ដោយ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី**
**( ឆ្នាំ 1910–2008 )**
ប្រធានទីដប់ប្រាំនៃសាសនាចក្រ

# ក្រុមព្រះដ៏ទេវភាព

*ជំនឿរបស់យើងជឿលើព្រះជាព្រះវរបិតាដ៏អស់កល្ប លើព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ និងលើព្រះវិញ្ញាណបរិសុទ្ធគឺជាកត្តាដ៏សំខាន់នៅក្នុងសាសនារបស់យើង ។*

*ហ្គរដុន ប៊ី ហ៊ិងគ្លី ជាប្រធានទី 15 នៃសាសនាចក្រ បានកើតនៅថ្ងៃទី 23 ខែ មិថុនា ឆ្នាំ 1910 ។ លោកត្រូវបានតែងតាំងធ្វើជាសាវកនៅថ្ងៃទី 5 ខែ តុលា ឆ្នាំ 1961 នៅក្នុងវ័យ 51 ឆ្នាំ ហើយនៅថ្ងៃទី 12 ខែ មិនា ឆ្នាំ 1995 លោកត្រូវបានគាំទ្រជាប្រធាននៃសាសនាចក្រ ។*

នៅក្នុងការពន្យល់ពីពីកត្តាចម្បងនៃគោលលទ្ធិរបស់យើង នោះព្យាការីយ៉ូសែប បានដាក់ចំណុចនេះជាចំណុចលេខមួយ ៖

« យើងខ្ញុំជឿដល់ព្រះគឺព្រះវរបិតាដ៏គង់នៅអស់កល្បជានិច្ច និង ដល់ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ហើយដល់ព្រះវិញ្ញាណបរិសុទ្ធ » ( មាត្រានៃសេចក្ដីជំនឿ 1:1 ) ។

[ ព្យាការីក៏បានបង្រៀនផងដែរថា ] ៖ « វាជាគោលការណ៍ទីមួយនៃដំណឹងល្អដើម្បីដឹងពីភាពជាក់លាក់មួយពីបុគ្គលិកលក្ខណៈនៃព្រះ » ( *History of the Church*, 6:305 ) ។

ការប្រកាសដ៏ចម្បង ហើយសំខាន់បំផុតទាំងនេះគឺស្របគ្នានឹងព្រះបន្ទូលនៃព្រះអម្ចាស់ថា ៖. . . ៖ « នេះជាជីវិតដ៏នៅអស់កល្បជានិច្ច គឺឲ្យគេបានស្គាល់ដល់ទ្រង់ដ៏ជាព្រះពិតតែមួយ និងព្រះយេស៊ូវគ្រីស្ទដែលទ្រង់បានចាត់ឲ្យមកផង » ( យ៉ូហាន 17:3 ) ។ . . .

## ព្រះជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ច

ខ្ញុំជឿដោយគ្មានការស្ទាក់ស្ទើរ ឬពោរពេញដោយការតាំងចិត្តលើព្រះ ជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ច ។ ទ្រង់គឺជាព្រះវរបិតារបស់ខ្ញុំ ជាព្រះវរបិតានៃវិញ្ញាណខ្ញុំ និងជាព្រះវរបិតានៃវិញ្ញាណមនុស្សទាំងអស់ ។ ទ្រង់គឺជាព្រះដ៏បង្កបង្កើតដ៏អស្ចារ្យ ជាព្រះគ្រប់គ្រងសកលលោកនេះ ។. . . មនុស្សត្រូវបានបង្កើតឡើងតាមរូបរបស់អង្គទ្រង់ ។ ទ្រង់មានតួអង្គជាក់លាក់ ។ ទ្រង់មានរូបកាយ ។ ទ្រង់មានរូបរាងដូចមនុស្ស ។ ទ្រង់មាន « ព្រះកាយជាសាច់ និងឆ្អឹងដែលជាក់ស្ដែងដូចជារូបកាយមនុស្ស » ( គ. និង ស. 130:22 ) ។

នៅក្នុងដំណើររឿងនៃការបង្កើតផែនដីនេះ « ទ្រង់ក៏មានបន្ទូលថា ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើង ឲ្យមានភាពដូចយើង » ( លោកុប្បត្តិ 1:26 ) ។

តើមានភាសាណាទៀតដែលអាចមានភាពជាក់លាក់ជាងនេះទៀតនោះ ? តើវាធ្វើឲ្យព្រះបាត់បង់នូវតម្លៃមែនទេ ដោយសារតែមនុស្សត្រូវបានបង្កើតតាមរូបភាពជាក់លាក់របស់ទ្រង់នោះ ដូចដែលមនុស្សមួយចំនួនបានធ្វើឲ្យយើងជឿ ? ផ្ទុយទៅវិញ វាគួរតែធ្វើឲ្យដួងចិត្តបុរស និងស្ត្រីគ្រប់រូបមាននូវអំណរគុណដ៏ធំធេងមួយចំពោះខ្លួនឯងក្នុងនាមជាបុត្រា ឬបុត្រីម្នាក់នៃព្រះ ។. . .

. . . ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ ខ្ញុំបាននិយាយ [ នៅទីក្រុង ឡុងដ៏ ប្រទេសអង់គ្លេស នៅពេលអ្នករិះគន់ម្នាក់បានបង្អាក់ដោយសួរថា ] « ហេតុអ្វីបានជាអ្នកមិនតាមគោលលទ្ធិក្នុងព្រះគម្ពីរប៊ីបដែលបានចែងថាក្នុងយ៉ូហាន ( 4:24 ) ថា ‹ ព្រះទ្រង់ជាវិញ្ញាណ › ? »

ខ្ញុំបានបើកព្រះគម្ពីរប៊ីបរបស់ខ្ញុំទៅរកបទគម្ពីរនោះដែលគាត់បានលើកឡើង ហើយបានអានខគម្ពីរនោះទាំងអស់ឲ្យគាត់ស្ដាប់ ៖ « ព្រះទ្រង់ជាវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់ នោះត្រូវតែថ្វាយបង្គំដោយវិញ្ញាណ និងសេចក្ដីពិតដែរ » ។

ខ្ញុំបាននិយាយថា « ពិតណាស់ ព្រះទ្រង់ជាវិញ្ញាណ ហើយអ្នកក៏ដូចគ្នាផងដែរ ដោយការរួមគ្នារវាងវិញ្ញាណ និងរូបកាយទើបធ្វើឲ្យអ្នកក្លាយជាទៅមនុស្សម្នាក់ដែលមានជីវិតរស់ ហើយរួមទាំងខ្ញុំផងដែរ » ។

យើងម្នាក់ៗមានរូបកាយពីរគឺរូបកាយខាងវិញ្ញាណ និងរូបកាយខាងសាច់ឈាម ។ មនុស្សទាំងអស់ស្គាល់ពីជីវិតនៃសេចក្ដីស្លាប់ . . . ហើយយើងម្នាក់ៗក៏ដឹងផងដែរថា វិញ្ញាណរស់នៅជារូបកាយមួយដាច់ដោយឡែក ហើយថានៅពេលខ្លះដោយស្ថិតនៅក្រោមផែនការដ៏ទេវភាពដែលអាចធ្វើទៅបានដោយសារការលះបង់របស់ព្រះរាជបុត្រានៃព្រះ នោះនឹងមានការរួបរួមគ្នាមួយរវាងវិញ្ញាណ និងរូបកាយ ។ ការប្រកាសរបស់ព្រះយេស៊ូវថា ព្រះទ្រង់ជាវិញ្ញាណពុំមែនមានន័យថា ទ្រង់គ្មានរូបកាយនោះទេ ដូចជាការប្រកាសនោះដែរ ខ្ញុំជាវិញ្ញាណពុំមែនមានន័យថា ខ្ញុំគ្មានរូបកាយឡើយ ។

ខ្ញុំពុំបានប្រៀបធៀបរូបកាយរបស់ខ្ញុំនឹងរូបកាយរបស់ទ្រង់នៅក្នុងភាពប្រសើរឡើង សមត្ថភាព ភាពស្រស់ស្អាត និងសិរីល្អឡើយ ។ រូបកាយទ្រង់មានភាពអស់កល្បជានិច្ច ។ រូបកាយខ្ញុំជារូបកាយរមែងស្លាប់ ។ ប៉ុន្តែការណ៍នោះបង្កើតតែការគោរពរបស់ខ្ញុំចំពោះទ្រង់ប៉ុណ្ណោះ ។. . . ខ្ញុំខិតខំស្រឡាញ់ទ្រង់ដោយអស់ពីដួងចិត្ត កម្លាំង គំនិត និងពលំរបស់ខ្ញុំ ។ ព្រះប្រាជ្ញាញាណរបស់ទ្រង់គឺលើសពីប្រាជ្ញារបស់មនុស្សទាំងអស់ ។. . . សេចក្ដីស្រឡាញ់របស់ទ្រង់មានចំពោះកូនចៅរបស់ទ្រង់ទាំងអស់ ហើយវាជាកិច្ចការ និង សិរីល្អរបស់ទ្រង់ដើម្បីនាំឲ្យកើតមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់បុត្រា និងបុត្រីរបស់ទ្រង់ . . . ( សូមមើល ម៉ូសេ 1:39 ) ។ . . .

## ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ

ខ្ញុំជឿលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅអស់កល្បជានិច្ច ។ ខ្ញុំជឿលើទ្រង់ជាបុត្រច្បងនៃព្រះវរបិតា



និងជាបុត្រាបង្កើតតែមួយនៃព្រះវរបិតាក្នុងសាច់ឈាម ។ ខ្ញុំជឿលើទ្រង់ជាព្រះមួយអង្គដែលដាច់ដោយឡែកពីព្រះវរបិតាទ្រង់ ។ . . .

ខ្ញុំជឿថា នៅក្នុងជីវិតរមែងស្លាប់របស់យើង ទ្រង់ជាអង្គល្អឥតខ្ចោះដែលបានរស់នៅលើផែនដីនេះ ។ ខ្ញុំជឿថា ពន្លឺ និងសេចក្ដីពិតដែលនឹងសង្គ្រោះដល់ពិភពលោក ហើយនាំមកនូវភាពតម្កើងឡើងដល់មនុស្សលោកត្រូវបានរកឃើញនៅក្នុងព្រះបន្ទូលរបស់ទ្រង់ ប្រសិនបើបានរកឃើញ ។ ខ្ញុំជឿថា នៅក្នុងបព្វជិតភាពរបស់ទ្រង់មាននូវសិទ្ធិអំណាចដ៏ទេវភាព—ជាអំណាចដើម្បីប្រទានពរ ជាអំណាចដើម្បីព្យាបាល ជាអំណាចដើម្បីគ្រប់គ្រងកិច្ចការរបស់ព្រះលើផែនដី ជាអំណាចដើម្បីចងភ្ជាប់នៅស្ថានសួគ៌នូវអ្វីដែលបានចងភ្ជាប់នៅលើផែនដី ។

ខ្ញុំជឿថា តាមរយៈការលះបង់ដែលធ្វើឲ្យធួនរបស់ទ្រង់ ជាការថ្វាយព្រះជន្មរបស់ទ្រង់នៅលើភ្នំកាល់វ៉ារី នោះទ្រង់បានធួនចំពោះអំពើបាបរបស់មនុស្សលោក ធ្វើឲ្យយើងរួចផុតពីបន្ទុកនៃអំពើបាបប្រសិនបើយើងលះបង់អំពើអាក្រក់ចោល ហើយធ្វើតាមទ្រង់ ។ ខ្ញុំជឿលើភាពជាក់ស្ដែង និងអំណាចនៃការរស់ឡើងវិញរបស់ទ្រង់ ។ . . . ខ្ញុំជឿថា តាមរយៈដង្វាយធួនរបស់ទ្រង់ . . . យើងម្នាក់ៗត្រូវបានផ្ដល់ឲ្យនូវអំណោយនៃការរស់ឡើងវិញពីសេចក្ដីស្លាប់ ។ ខ្ញុំជឿថែមទៀតថា តាមរយៈការលះបង់នោះគឺបង្កើតឱកាសសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច និងភាពតម្កើងឡើងនៅក្នុងនគររបស់ព្រះវរបិតាយើង ដល់បុរសស្ត្រី បុត្រាបុត្រីនៃព្រះគ្រប់រូប នៅពេលយើង . . . គោរពព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

គ្មានមនុស្សដ៏អស្ចារ្យណាម្នាក់ដែលបានរស់នៅលើផែនដីឡើយ ។ គ្មាននរណាផ្សេងទៀតដែលបានធ្វើការលះបង់ ឬផ្ដល់ពរជ័យដូចនេះឡើយ ។ ទ្រង់គឺជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះនៃពិភពលោក ។ ខ្ញុំជឿលើទ្រង់ ។ ខ្ញុំសូមប្រកាសពីទេវភាពរបស់ទ្រង់. . . ។ ខ្ញុំស្រលាញ់ទ្រង់ ។ ខ្ញុំសូមនិយាយពីព្រះនាមទ្រង់ដោយការគោរព និងការសើ្ងចសរសើរ ។ . . .

. . . ព្រះគម្ពីរបានប្រាប់ពីមនុស្សដែលទ្រង់បានបង្ហាញអង្គទ្រង់ ហើយដែលទ្រង់បានមានបន្ទូលជាមួយក្នុងនាមជាបុត្រានៃព្រះដែលបានរស់ឡើងវិញ ហើយមានព្រះជន្មរស់ ។ ដូចគ្នានេះដែរ នៅគ្រាកាន់កាប់ត្រួតត្រានេះទ្រង់បានបង្ហាញអង្គទ្រង់ ហើយមនុស្សដែលបានឃើញទ្រង់បានប្រកាសថា ៖

« ហើយឥឡូវនេះ បន្ទាប់ពីទីបន្ទាល់ជាច្រើនដែលបានថ្លែងអំពីទ្រង់ នេះគឺជាទីបន្ទាល់ចុងក្រោយបង្អស់ ដែលយើងខ្ញុំសូមថ្លែងអំពីទ្រង់ ៖ គឺថាទ្រង់មានព្រះជន្មរស់នៅ !

« ត្បិតយើងខ្ញុំបានឃើញទ្រង់គង់នៅខាងស្ដាំព្រះហស្តនៃព្រះ ហើយយើងខ្ញុំបានឮសម្លេងដែលថ្លែងទីបន្ទាល់ថា ទ្រង់គឺជាបុត្រាបង្កើតតែមួយនៃព្រះវរបិតា—

« ថាដោយសារព្រះអង្គ និងតាមរយៈព្រះអង្គ ហើយពីព្រះអង្គ នោះពិភពលោកទាំងឡាយមានឡើង ហើយបានបង្កើតមក ហើយបណ្ដាជននៅទីនោះ គឺជាបុត្រាបុត្រីបង្កើតចំពោះព្រះ » ( គ. និង ស. 76:22–24 ) ។

នេះគឺជាព្រះគ្រីស្ទ ជាអង្គដែលខ្ញុំជឿ ហើយថ្លែងទីបន្ទាល់ ។

*នីហ្វៃទី 3 11:15 ៖ One by One ( ម្នាក់ម្តងៗ ) ដោយ វ៉លធើរ រ៉ាន ទទួលបានសិទ្ធិអនុញ្ញាតពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ*



**ព្រះវិញ្ញាណបរិសុទ្ធ**

ចំណេះដឹងនោះកើតចេញពីបន្ទូលនៅក្នុងព្រះគម្ពីរ ហើយទីបន្ទាល់នោះកើតចេញតាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។ វាជាអំណោយទានមួយ ពិសិដ្ឋ ហើយអស្ចារ្យ បានថ្លែងតាមរយៈវិវរណៈពីសមាជិកទីបីនៃក្រុមព្រះ ។ ខ្ញុំជឿលើព្រះវិញ្ញាណបរិសុទ្ធជាអង្គនៃវិញ្ញាណដែលគង់នៅជាមួយនឹងព្រះវរបិតា និងព្រះរាជបុត្រា អង្គទាំងបីនេះបានបង្កើតទៅជាក្រុមព្រះដ៏ទេវភាព ។. . .

ថាព្រះវិញ្ញាណបរិសុទ្ធត្រូវបានរៀបចំឡើងកាលពីបុរាណឲ្យធ្វើជាសមាជិកនៃក្រុមព្រះ គឺមានភស្ដុតាងក្នុងការសន្ទនារវាងពេត្រុស និងអាន៉ានាស នៅពេលគេទុកតម្លៃដីមួយចំណែក ដែលបានមកពីការលក់ដីមួយកន្លែង ។

« តែពេត្រុសសួរថា អាន៉ានាសអើយ ហេតុអ្វីបានជាអារក្សសាតាំងមកនៅពេញក្នុងចិត្តអ្នក . . . ?

« . . . អ្នកកាត់ចិត្តធ្វើដូច្នេះ នេះមិនមែនកុហកដល់មនុស្សទេ គឺឈ្មោះថាកុហកដល់ព្រះវិញ » ( កិច្ចការ 5:3–4 ) ។

ព្រះវិញ្ញាណបរិសុទ្ធ [ គឺជា ] អង្គលួងលោមចិត្ត ដែលបានសន្យាដោយព្រះអង្គសង្គ្រោះថា ជាអង្គដែលនឹងបង្រៀនដល់ពួកអ្នកដើរតាមរបស់ទ្រង់នូវរាល់កិច្ចការទាំងអស់ ហើយធ្វើឲ្យពួកគេចងចាំនូវរាល់កិច្ចការទាំងអស់ . . . ( សូមមើល យ៉ូហាន 14:26 ) ។

ព្រះវិញ្ញាណបរិសុទ្ធគឺជាអង្គថ្លែងទីបន្ទាល់ពីសេចក្ដីពិត ជាអង្គដែលអាចបង្រៀនមនុស្សនូវកិច្ចការទាំងឡាយដែលពួកគេមិនអាចបង្រៀនគ្នាទៅវិញទៅមកបាន ។. . . ចំណេះដឹងមួយពីសេចក្ដីពិតស្ដីពីព្រះគម្ពីរមរមនត្រូវបានសន្យា « ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ » ។ បន្ទាប់មក ម៉ូរ៉ូណៃ បានប្រកាសថា « ហើយដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះអ្នករាល់គ្នាអាចស្គាល់សេចក្ដីពិតនៃគ្រប់ការណ៍ទាំងអស់ » ( ម៉ូរ៉ូណៃ 10:4–5 ) ។

ខ្ញុំជឿថា អំណាចនេះ អំណោយទាននេះ គឺមានសម្រាប់ពួកយើងនៅសព្វថ្ងៃនេះ ។

**ពិត ហើយដាច់ដោយឡែក**

. . .យើងខ្ញុំជឿដល់ព្រះគឺព្រះវរបិតាដ៏គង់នៅអស់កល្បជានិច្ច និងដល់ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ហើយដល់ព្រះវិញ្ញាណបរិសុទ្ធ ។

ខ្ញុំបានជ្រមុជទឹកនៅក្នុងព្រះនាមនៃអង្គទាំងបីនេះ ។ ខ្ញុំបានរៀបការនៅក្នុងព្រះនាមនៃអង្គទាំងបីនេះ ។ ខ្ញុំគ្មានការងឿងឆ្ងល់ស្ដីពីភាពពិត និងភាពដាច់ដោយឡែករបស់ទ្រង់ឡើយ ។ ភាពដាច់ដោយឡែកនោះត្រូវបានបង្ហាញនៅពេលព្រះយេស៊ូវ ជ្រមុជដោយយ៉ូហាន នៅទន្លេយ័រដាន់ ។ ព្រះរាជបុត្រានៃព្រះបានឈរនៅក្នុងទឹកទន្លេនោះ ។ ព្រះសូរសៀងរបស់ព្រះវរបិតាទ្រង់បានបន្លឺប្រកាសពីបុត្រាដ៏ទេវភាពនៃទ្រង់ ហើយព្រះវិញ្ញាណបរិសុទ្ធបានបង្ហាញក្នុងរាងជាសត្វព្រាប ( សូមមើល ម៉ាថាយ 3:16–17 ) ។

ខ្ញុំដឹងថា ព្រះយេស៊ូវបានមានបន្ទូលថា ពួកអ្នកដែលធ្លាប់បានឃើញទ្រង់ ហាក់ដូចជាបានឃើញព្រះវរបិតាដូច្នោះដែរ [ សូមមើល យ៉ូហាន 14:9 ] ។ តើការណ៍នេះមិនអាចត្រូវបាននិយាយដូចគ្នាពីសំណាក់កូនដែលមានរូបរាងដូចជាឪពុកម្ដាយខ្លួនទេឬ ?

នៅពេលព្រះយេស៊ូវបានអធិស្ឋានទៅកាន់ព្រះវរបិតា ប្រាកដណាស់គឺទ្រង់ពុំមែនកំពុងអធិស្ឋានទៅអង្គឯងនោះឡើយ !

**ការរួបរួមដ៏ល្អឥតខ្ចោះ**

ពួកទ្រង់ជាអង្គដាច់ដោយឡែកពីគ្នា ប៉ុន្តែពួកទ្រង់មានគោលបំណង និងកិច្ចខិតខំតែមួយ ។ ពួកទ្រង់បានរួបរួមតែមួយនៅក្នុងការនាំឲ្យកើតមាននូវផែនការដ៏ទេវភាពយ៉ាងធំធេងសម្រាប់សេចក្ដីសង្គ្រោះ និងភាពតម្កើងឡើងដល់កូនចៅនៃព្រះ ។

. . . ព្រះគ្រីស្ទបានទូលអង្វរជាមួយព្រះវរបិតាទ្រង់ស្ដីពីពួកសាវក ដែលទ្រង់ស្រឡាញ់ ដោយមានបន្ទូលថា ៖

« ទូលបង្គំមិនអធិស្ឋានឲ្យអ្នកទាំងនេះតែប៉ុណ្ណោះទេ គឺឲ្យដល់ទាំងអ្នកណាដែលនឹងជឿដល់ទូលបង្គំ ដោយសារពាក្យរបស់គេថែមទៀតដែរ

« ដើម្បីឲ្យទាំងអស់បានរួមមកតែមួយ ឱព្រះវរបិតាអើយ ដូចជាទ្រង់គង់ក្នុងទូលបង្គំ ហើយទូលបង្គំនៅក្នុងទ្រង់ដែរ គឺឲ្យអ្នកទាំងនោះបានរួមគ្នាតែមួយនៅក្នុងយើង » ( យ៉ូហាន 17:20–21 ) ។

ដោយសារតែសាមគ្គីភាពដ៏ល្អឥតខ្ចោះនោះហើយគឺរវាងព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ទើបធ្វើឲ្យទ្រង់ទាំងបីអង្គមានព្រះទ័យតែមួយនៅក្នុងក្រុមព្រះដ៏ទេវភាព ។ ■

*ដកស្រង់ចេញពី « The Father, Son, and Holy Ghost »* Ensign *ខែ វិច្ឆិកា ឆ្នាំ 1986 ទំព័រ 49–51; capitalization and punctuation standardized*

*Prayer at Gethsemane ( ការអធិស្ឋាននៅក្នុងសួនគេតសេម៉ានី ) ដោយ ដែល ផាសុន*



# ការរក្សាថ្ងៃបរិសុទ្ធ

ចំពោះមនុស្សជាច្រើន ថ្ងៃអាទិត្យគឺគ្រាន់តែជាថ្ងៃមួយទៀតនៅចុងសប្ដាហ៍សម្រាប់ការសម្រាក និងការកម្សាន្តបន្ថែមទៀត ។ ប៉ុន្តែ វិវរណៈពីបុរាណ និងសម័យទំនើបបានបង្រៀនពីសារៈសំខាន់នៃការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ នៅទំព័រ 56–57 ក្នុងទស្សនាវដ្ដីច្បាប់នេះ លែរី អិម ហ្គិបសុន ជាទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានយុវជនទូទៅ ពិភាក្សាពីតួនាទីដ៏សំខាន់នៃការរក្សាថ្ងៃបរិសុទ្ធ ។ បងប្រុស ហ្គិបសុន បានមានប្រសាសន៍ថា « របៀបដែលយើងរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ គឺជាការបង្ហាញពីខាងក្រៅមួយនូវសេចក្ដីសញ្ញារបស់យើងក្នុងការចងចាំដល់ព្រះយេស៊ូវគ្រីស្ទជានិច្ច » ។

នៅពេលកូនចៅរបស់អ្នករៀនរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ នោះពួកគេនឹងរៀបចំខ្លួនទទួលពរជ័យជាច្រើន ។ ដូចជាបងប្រុសហ្គិបសុនបានមានប្រសាសន៍ថា « ប្រសិនបើយើងធ្វើ ហើយរស់នៅតាមបញ្ញត្តិដ៏ទេវភាពដើម្បីរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ នោះព្រះអម្ចាស់នឹងប្រទានពរយើង ដឹកនាំយើង ហើយបំផុសគំនិតយើងក្នុងការដោះស្រាយបញ្ហាដែលយើងជួបប្រទះ » ។

**យោបល់ទាំងឡាយសម្រាប់បង្រៀនយុវវ័យ**

- សូមអានអត្ថបទរបស់បងប្រុសហ្គិបសុន នៅទំព័រ 56–57 រួមគ្នា ។ បន្ទាប់មកពិភាក្សាពីអ្វីដែលគ្រួសាររបស់អ្នកអាចធ្វើនៅរាល់សប្ដាហ៍ដើម្បីរៀបចំខ្លួនរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ នៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ អ្នកអាចច្រៀង « Gently Raise the Sacred Strain » ( *Hymns* លរ. 146 ) ឬទំនុកតម្កើងព្រះផ្សេងទៀតស្ដីពីថ្ងៃឈប់សម្រាក ហើយពិភាក្សាពីអ្វីដែលគ្រួសាររបស់អ្នកអាចធ្វើដើម្បីរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។
- សូមពិចារណាអានជាមួយកូនជំទង់ៗរបស់អ្នកនូវផ្នែកការរក្សាថ្ងៃបរិសុទ្ធឲ្យបរិសុទ្ធនៅក្នុង *ដើម្បីកម្លាំងនៃយុវជន* រួមទាំងបទគម្ពីរដែលមាននៅចុងបញ្ចប់ផងដែរ ។ អ្នកអាចរកមើលរួមគ្នានូវបទគម្ពីរផ្សេងទៀតស្ដីពីការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ហើយពិភាក្សាពីគោលការណ៍ដែលបង្កប់នៅក្នុងការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។
- អ្នកគួរមើលខ្សែវីដេអូដែលទាក់ទង ហើយអានអត្ថបទនានាជាមួយនឹងកូនជំទង់ៗរបស់អ្នក ។ ចូលទៅ youth.lds.org រួចចុច « For the Strength of Youth » នៅក្នុង menu ។ រួចចុចលើផ្នែក Sabbath day observance ( ការរក្សាថ្ងៃបរិសុទ្ធ ) ហើយអ្នកនឹងរកឃើញខ្សែវីដេអូ និងអត្ថបទដែលទាក់ទងនៅផ្នែកខាងស្ដាំ និងខាងក្រោមនៃទំព័រនោះ ។

**យោបល់ទាំងឡាយដើម្បីបង្រៀនកូនចៅ**

- សូមអាន « ឪកុនថ្មោងថ្មី » នៅក្នុង *លីអាហូណា* ខែ តុលា ឆ្នាំ 2013 ហើយពិភាក្សាពីសារៈសំខាន់នៃសាក្រាម៉ង់ក្នុងការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។
- សូមពិចារណាអាន « A Lesson in Reverence » ក្នុង *Liahona* ខែ មិនា ឆ្នាំ 2010 ។ អ្នកក៏គួរធ្វើសកម្មភាពដែលសមស្របនឹងអត្ថបទនោះផងដែរ ។ សូមពិភាក្សាជាមួយនឹងកូនរបស់អ្នកថាតើការមានគារវភាពនៅព្រះវិហារជួយរក្សាថ្ងៃសម្រាកឲ្យបរិសុទ្ធយ៉ាងដូចម្ដេចដែរ ។
- សូមពិភាក្សាពីអ្វីដែលគ្រួសាររបស់អ្នកអាចធ្វើនៅថ្ងៃអាទិត្យដើម្បីគោរពដល់ព្រះអម្ចាស់ ។ អ្នកក៏គួរអាន « Decide Right Now » នៅក្នុង *Liahona* ខែ មិនា ឆ្នាំ 2012 ពីគំរូរបស់មនុស្សម្នាក់ដែលបានរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធក្នុងកាលៈទេសៈមួយដ៏លំបាក ។
- អ្នកអាចច្រៀងជាមួយនឹងកូនរបស់អ្នកនូវចម្រៀងមួយចំនួនដែលទាក់ទងនឹងថ្ងៃឈប់សម្រាក រួមទាំង « ថ្ងៃសៅរ៍ » ផងដែរ ( *Children's Songbook* 196 ) ។ សូមពិភាក្សាពីរបៀបដែលគ្រួសាររបស់អ្នកអាចប្រើថ្ងៃសៅរ៍ និងថ្ងៃផ្សេងទៀតក្នុងសប្ដាហ៍ដើម្បីរៀបចំខ្លួនសម្រាប់ថ្ងៃអាទិត្យ ។ ■

**បទគម្ពីរស្ដីពីប្រធានបទនេះ**

និក្ខមនំ 20:8–11
អេសាយ 58:13–14
កូរិនថូសទី 1 11:23–26
នីហ្វៃទី 3 18:3–11
ម៉ូរ៉ូណៃ 6:4–6
គោលលទ្ធិ និង សេចក្ដីសញ្ញា 59:9–13

រូបភាពដោយ ប្រែដ ក្លាក

*សូមចងចាំជានិច្ចថា ព្រះយេស៊ូវគ្រីស្ទ—ជាព្រះបង្កបង្កើតនៃសកលលោក ជាវិស្វករនៃសេចក្ដីសង្គ្រោះរបស់យើង និងជាព្រះសិរសានៃសាសនាចក្រនេះ—គឺកំពុងមើលការខុសត្រូវ ។*



ដោយ អែលឌើរ
អិម រ័សុល បាឡឺដ
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់



# ប្រឈមមុខនឹងអនាគតដោយ សេចក្ដីជំនឿ និង សេចក្ដីសង្ឃឹម

ស្ថានភាពនានាក្នុងពិភពលោកនេះគឺគ្មានភាពជាក់លាក់ ហើយគ្រោះថ្នាក់ ហើយសេដ្ឋកិច្ចនៃពិភពលោកគ្មានស្ថេរភាព ហើយមិនអាចទស្សន៍ទាយបាន ។ តម្លៃដែលមិនអាចបំភ្លេចបាននៃជីវិត សេរីភាព និងការស្វែងរកសុភមង្គលគឺស្ថិតនៅក្រោមការវាយប្រហារពីសំណាក់ជនដែលចង់កំណត់នូវសិទ្ធិជ្រើសរើស ហើយធ្វើឲ្យយើងខ្វះនូវភាពឯករាជ្យ ជាជាងលើកទឹកចិត្តយើងឲ្យប្រើនូវជំនាញ និងទេពកោសល្យរបស់យើងដើម្បីបង្កើតនូវរបៀបថ្មីដ៏រំភើបនៅក្នុងការធ្វើកិច្ចការទាំងឡាយ ។

បទដ្ឋានទាំងឡាយនៃសីលធម៌កំពុងធ្លាក់ចុះ ។ គ្រួសារគឺស្ថិតនៅក្រោមការវាយប្រហារ ហើយកំពុងធ្វើឲ្យខ្ទេចខ្ទី ។ សេចក្ដីស្រឡាញ់នៅក្នុងដួងចិត្តរបស់បុរស និងស្ត្រីទាំងឡាយកាន់តែស្អិតរមួតត្រជាក់ ហើយខុសពីធម្មតា ( សូមមើល ម៉ាថាយ 24:12, រ៉ូម 1:31 ) ។ មាននូវការបរាជ័យជាបន្តបន្ទាប់មួយនៅក្នុងភាពសច្ចៈធម៌ ភាពស្មោះត្រង់ និងភាពសុចរិតនៃនយោបាយ ពាណិជ្ជកម្ម និងពួកអ្នកដឹកនាំផ្សេងទៀត ។ សង្គ្រាម និងពាក្យចចាមអារាមនៃសង្គ្រាមក្នុងចំណោមជាតិសាសន៍ និងជំនឿគឺជារឿងទូទៅ ។ ហើយអ្វីដែលបំផ្លិចបំផ្លាញលើសពីវិបត្តិផ្ទែកកងទ័ពណាៗទាំងអស់គឺជាសង្គ្រាមដ៏ក្ដៅគគុករវាងអំពើល្អ និងអំពើអាក្រក់—រវាងព្រះអង្គសង្គ្រោះរួមនឹងពលទ័ពនៃពន្លឺរបស់ទ្រង់ ជាមួយនឹងសាតាំងរួមនឹងពួកបរិវារដ៏អាក្រក់នៃសេចក្ដីងងឹតរបស់វា—សម្រាប់រាល់ព្រលឹងនៃកូនចៅនៃព្រះ ។

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ 1910–2008 ) បានពិពណ៌នាពីពិភពលោកដែលយុវវ័យនៅសព្វថ្ងៃរៀបនឹងចូលទៅ ដោយលោកបានមានប្រសាសន៍ថា ៖ « យើងរស់នៅក្នុងគ្រាមួយដែលមនុស្សកាចសាហាវធ្វើនូវរឿងដ៏អាក្រក់ ហើយគួរឲ្យស្អប់ខ្ពើម ។ យើងរស់នៅក្នុងគ្រាមួយនៃសង្គ្រាម ។ យើងរស់នៅក្នុងគ្រាមួយនៃភាពអំនួត ។ យើងរស់នៅក្នុងគ្រាមួយនៃអំពើទុច្ចរិត រូបអាសគ្រាម ភាពអសីលធម៌ ។ រាល់អំពើបាបនៃក្រុងសូដុំម និងក្រុងកូម៉ូរ៉ាបានធ្វើឲ្យសង្គមរបស់យើងជួបបញ្ហា ។ យុវវ័យរបស់យើងពុំធ្លាប់ជួបការប្រឈមមុខមួយធំដូច្នេះឡើយ ។ យើងពុំធ្លាប់ឃើញយ៉ាងច្បាស់នូវមុខមាត់ដ៏អនាចារនៃអំពើអាក្រក់ជាងនេះនោះទេ » ។[1]



រូបថត ដោយ ក្រេហ្គ ឌីម៉ុង

យើងមិនគួរភ្ញាក់ផ្អើលចំពោះស្ថានភាពទាំងនេះនៅជំនាន់របស់យើងឡើយ ដោយសារព្រះគម្ពីរ និងការព្យាករទាំងឡាយពីជំនាន់របស់យើងបានធ្វើទីបន្ទាល់ពីអ្វីដែលនឹងកើតឡើងនៅក្នុងពិភពលោកនេះ ប្រសិនបើមនុស្សបែរខ្នងរបស់ខ្លួនដាក់ព្រះនោះ ។ យើងនឹងនៅតែជួបនឹងរឿងដែលសោកសៅច្រើនទៀត ពីព្រោះអារក្សបន្តកិច្ចការខិតខំរបស់វាដើម្បីសម្រេចបាននូវគម្រោងដ៏អាក្រក់របស់វា ។ នៅពេលជាមួយគ្នានោះដែរ ពួកព្យាការីពីបុរាណដែលបានឃើញពីជំនាន់របស់យើង ដែលបានឃើញពីជំនាន់វ័យក្មេងនៅសព្វថ្ងៃនេះ បានដឹងថា គ្រានេះនឹងក្លាយទៅជាជំនាន់នៃពន្លឺ និងភាពអស្ចារ្យ ដែលពិភពលោកពុំធ្លាប់ជួបពីមុនមក ។

នៅពេលខ្ញុំរៀបចំសារលិខិតនេះ ខ្ញុំទូលសុំការដឹកនាំដើម្បីបានដឹងថាតើសារលិខិតអ្វីទៅដែលព្រះវរបិតាសួគ៌សព្វព្រះទ័យចង់ឲ្យខ្ញុំចែកចាយ ។ ពាក្យលួងលោមចិត្តដ៏ស្ងប់ស្ងាត់ដែលព្រះអម្ចាស់បានមានបន្ទូលទៅកាន់ព្យាការី យ៉ូសែប ស្ម៊ីធ បានកើតមាននៅក្នុងគំនិតរបស់ខ្ញុំ ៖ « ចូរសង្ឃឹមឡើង ត្បិតយើងនឹងដឹកនាំអ្នករាល់គ្នា ។ នគរជារបស់ផងអ្នករាល់គ្នា . . . ហើយទ្រព្យសម្បត្តិទាំងឡាយខាងភាពអស់កល្បជានិច្ចជារបស់ផងអ្នករាល់គ្នា » ( គ. និង ស. 78:18 ) ។

## ជំនួសសេចក្ដីភ័យខ្លាចដោយសេចក្ដីជំនឿ

អ្វីដែលខ្ញុំជឿថាព្រះអម្ចាស់សព្វព្រះទ័យឲ្យខ្ញុំនិយាយគឺថា យើងគួរជំនួសសេចក្ដីភ័យខ្លាចដោយសេចក្ដីជំនឿ—ជាសេចក្ដីជំនឿជឿលើព្រះ និងអំណាចនៃដង្វាយធួនរបស់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ។

ខ្ញុំអាចនៅចាំបាន ពីការត្រលប់មកផ្ទះវិញពីការប្រជុំបព្វជិតភាពនៅថ្ងៃអាទិត្យ ទី 7 ខែ ធ្នូ 1941 កាលពីនៅជាក្មេងប្រុសម្នាក់អាយុ 13 ឆ្នាំ នោះឪពុកខ្ញុំបានប្រាប់ថាប្រទេសជប៉ុនទើបតែទម្លាក់គ្រាប់បែកនៅភើល ហាប័រ ។ ការណ៍នេះបាននាំឲ្យសហរដ្ឋចូលទៅក្នុងសង្គ្រាមពិភពលោកមួយដែលកំពុងតែកើតមានរួចហើយក្នុងទ្វីបអឺរ៉ុបរយៈពេលពីរឆ្នាំ ។ វាហាក់ដូចជាជីវិតដែលយើងធ្លាប់ស្គាល់នឹងត្រូវបញ្ចប់ ។ មាននូវភាពមិនច្បាស់លាស់ជាច្រើន នៅពេលយុវជនជាច្រើនត្រូវបានបញ្ជូនចូលទៅបម្រើកងទ័ព ។ ដូចជាឥឡូវនេះ ទោះជាស្ថិតក្នុងចំណោមវិបត្តិ ភាពស្មុគស្មាញ និងឥទ្ធិពលអាក្រក់ក្នុងពិភពលោកយ៉ាងណាក្ដី ក៏នៅមានរឿងល្អច្រើនដែរ ។

នៅពេលយើងគិតពីអនាគត យើងគួរតែពោរពេញដោយសេចក្ដីជំនឿ និងសេចក្ដីសង្ឃឹម ។ សូមចងចាំជានិច្ចថា ព្រះយេស៊ូវគ្រីស្ទ—ជាព្រះបង្កបង្កើតនៃសកលលោក ជាវិស្វករនៃសេចក្ដីសង្គ្រោះរបស់យើង និងជាព្រះសិរសានៃសាសនាចក្រនេះ—គឺកំពុងមើលការខុសត្រូវ ។ ទ្រង់នឹងមិនអនុញ្ញាតឲ្យកិច្ចការរបស់ទ្រង់បរាជ័យឡើយ ។ ទ្រង់នឹងទទួលបានជ័យជំនះលើរាល់សេចក្ដីងងឹត និងអំពើទុច្ចរិត ។ ហើយទ្រង់អញ្ជើញយើងទាំងអស់គ្នា ជាសមាជិកនៃសាសនាចក្រទ្រង់ និងមនុស្សដទៃទៀតដែលមានចិត្តស្មោះត្រង់ ឲ្យចូលរួមនៅក្នុងចម្បាំងច្បាំងដើម្បីព្រលឹងនៃកូនចៅរបស់ព្រះ ។ ជាមួយនឹងអ្វីផ្សេងទៀតដែលយើងនឹងធ្វើនៅក្នុងជីវិត យើងក៏ត្រូវឧទ្ទិស ហើយធ្វើឲ្យចិត្ត កម្លាំង គំនិត និងពលំរបស់យើងបានបរិសុទ្ធដើម្បីបុព្វហេតុរបស់ទ្រង់ ដោយដើរនៅក្នុងសេចក្ដីជំនឿ ហើយធ្វើការដោយភាពជឿជាក់ ។

ប្រឈមមុខនឹងអនាគតដោយភាពសុទិដ្ឋិនិយម ។ ខ្ញុំជឿថា យើងកំពុងឈរនៅលើទីចាប់ផ្ដើមនៃយុគសម័យថ្មីមួយនៃភាពរីកចម្រើន ភាពរុងរឿង និងភាពបរិបូណ៌ ។ បើគ្មានគ្រោះមហន្តរាយ ឬវិបត្តិអន្តរជាតិដែលមិនបានរំពឹងមួយ នោះខ្ញុំគិតថា ពីរបីឆ្នាំខាងមុខនឹងនាំមកនូវការស្ដារឡើងវិញមួយនៅក្នុងសេដ្ឋកិច្ចពិភពលោក ដោយសាររបកគំហើញថ្មីៗត្រូវបានធ្វើឡើងនៅក្នុងវិស័យទូរគមនាគមន៍ វេជ្ជសាស្ត្រ ថាមពល ដឹកជញ្ជូន រូបសាស្ត្រ បច្ចេកវិទ្យាកុំព្យូទ័រ និងវិស័យនៃការខិតខំផ្សេងទៀត ។

របកគំហើញជាច្រើនទាំងនេះ ដូចជានៅពីអតីតកាលផងដែរ នឹងក្លាយជាលទ្ធផលនៃព្រះវិញ្ញាណខ្សឹបប្រាប់នូវការយល់ដឹង និងការបំភ្លឺគំនិតនៃបុគ្គលដែលស្វែងរកសេចក្ដីពិត ។ ជាមួយនឹងរបកគំហើញ និងការអភិវឌ្ឍន៍ទាំងនេះនឹងបង្កើតនូវឱកាសការងារ និងភាពរីកចម្រើនថ្មីសម្រាប់អ្នកដែលខិតខំធ្វើការ និងជាពិសេសចំពោះអ្នកដែលខិតខំគោរពតាមព្រះបញ្ញត្តិនៃព្រះ ។ ការណ៍នេះបានក្លាយជាផ្នែកដ៏ចាំបាច់នៅក្នុងគ្រាដ៏សំខាន់ផ្សេងទៀតនៃការរីកចម្រើនផ្នែកសេដ្ឋកិច្ចទាំងក្នុងស្រុក និងអន្តរជាតិ ។

ជាងនេះទៀត របកគំហើញជាច្រើនទាំងនេះនឹងត្រូវបានបង្កើតឡើងដើម្បីជួយនាំឲ្យកើតមាននូវគោលបំណង និងកិច្ចការនៃព្រះ ព្រមទាំងដើម្បីពន្លឿនដល់ការស្ថាបនានគររបស់ទ្រង់លើផែនដីនៅសព្វថ្ងៃនេះ រួមទាំងកិច្ចការផ្សព្វផ្សាយសាសនាផងដែរ ។

## សូមធ្វើនូវផ្នែករបស់អ្នក

ពីមុនការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ— ហើយដោយផ្អែកលើពេលវេលាដ៏ទេវភាពរបស់ទ្រង់—នោះដំណឹងល្អត្រូវនាំទៅគ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន រហូតដល់ពេញទូទាំងផែនដីទាំងមូល ។ នៅពេលព្យាការី យ៉ូសែប បានប្រកាសថា ៖ « គ្មានដៃដែលមិនស្អាតស្អំណាអាចបញ្ឈប់កិច្ចការនេះពីការរីកចម្រើនឡើយ ការធ្វើទុក្ខបុកម្នេញអាចកញ្ជ្រោលឡើង ពួកមនុស្សកាចសាហាវអាចប្រមូលផ្ដុំគ្នា ពួកទាហានអាចប្រជុំគ្នា ពួកអ្នកមួលបង្កាច់អាចបង្ខូចកេរ្ដិ៍ឈ្មោះ តែសេចក្ដីពិតនៃព្រះនឹងឆ្ពោះទៅមុខ ដោយក្លៀវក្លា ថ្លៃថ្នូរ និង ឯករាជ្យរហូតទាល់តែវាបានដល់គ្រប់ទាំងទ្វីប គ្រប់តំបន់ គ្រប់ប្រទេស និងបាន ឮដល់គ្រប់ត្រចៀក រហូតដល់គោលបំណងនៃព្រះនឹងបានសម្រេច ហើយព្រះយេហូវ៉ាដ៏អស្ចារ្យនឹងមាន បន្ទូលថា កិច្ចការបានចប់ហើយ » ។[2]

នៅពេលដំណឹងល្អត្រូវបាននាំទៅកាន់មនុស្សរាប់លាននាក់ដែលមានភាពស្រេកឃ្លានខាងវិញ្ញាណ នោះអព្ភូតហេតុនឹងធ្វើឡើងដោយព្រះហស្តរបស់ព្រះអម្ចាស់ ។ ពួកអ្នកផ្សព្វផ្សាយសាសនានៃជាតិសាសន៍ជាច្រើននឹងបម្រើព្រះអម្ចាស់នៅទូទាំងពិភពលោក ។ រោងថ្វាយបង្គំថ្មី និងព្រះវិហារបរិសុទ្ធជាច្រើន



*របកគំហើញជាច្រើនទាំងនេះ នឹងត្រូវបានបង្កើតឡើងដើម្បីជួយនាំឲ្យកើតមាននូវគោលបំណង និងកិច្ចការនៃព្រះ ព្រមទាំងដើម្បីពន្លឿនដល់ការស្ថាបនានគររបស់ទ្រង់លើផែនដីនៅសព្វថ្ងៃនេះ រួមទាំងកិច្ចការផ្សព្វផ្សាយសាសនាផងដែរ ។*

ទៀតនឹងត្រូវបានសាងសង់ដើម្បីប្រទានពរដល់ពួកបរិសុទ្ធ ដូចដែលបានព្យាករណ៍ស្ដីពីការរីកចម្រើនរបស់សាសនាចក្រពីមុនសហសវត្សរ៍ ។

អ្នកប្រហែលជាសួរថា « តើនឹងបានធនធានហិរញ្ញវត្ថុមកពីណាដើម្បីផ្ដល់មូលនិធិដល់ការរីកចម្រើននេះ ? » ធនធាននោះនឹងបានមកពីសមាជិកស្មោះត្រង់តាមរយៈដង្វាយមួយភាគក្នុងដប់ និងដង្វាយផ្សេងៗរបស់ពួកគេ ។ នៅពេលយើងធ្វើផ្នែករបស់យើង នោះព្រះអម្ចាស់នឹងប្រទានពរយើងជាមួយនឹងភាពចម្រើន និងប្រាជ្ញា ដើម្បីរក្សាគំនិតរបស់យើងផ្ដោតលើអ្វីដែលសំខាន់បំផុតនៅក្នុងជីវិត ៖ « ចូរស្វែងរកនគរ និងសេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះនឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង » ( ម៉ាថាយ 6:33 ) ។

ដូច្នេះដោយសារនោះជាហេតុផលមួយ ប្រហែលជាហេតុផលមួយខ្លី ទោះជាយ៉ាងណាវាហាក់ដូចជាទ្វារស្ថានសួគ៌នឹងបានបើកឡើងយ៉ាងពិតប្រាកដដែលនឹង « គ្មានកន្លែងល្មមទុកបានទេ » ( ម៉ាឡាគី 3:10 ) ។

ខ្ញុំជឿថា ពួកមជ្ឈិមវ័យវ័យក្មេងជាច្រើននៅសព្វថ្ងៃនេះនឹងចូលរួមចំណែកយ៉ាងសកម្មនៅក្នុងពរជ័យខាងសាច់ឈាម ប្រសិនបើពួកគេគោរពព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ។ ជាមួយនឹងភាពចម្រើនឡើង ក៏នឹងកើតមានឧបសគ្គពិសេសមួយ—ជាការសាកល្បងដែលនឹងល្បួងដល់មនុស្សជាច្រើនរហូតដល់ផ្នែកសំខាន់ខាងវិញ្ញាណរបស់ពួកគេ ។ នៅពេលអ្នកឈានជើងចូលក្នុងពិភពថ្មីនៃភាពចម្រើនឡើងនេះ ហើយចូលប្រឡូកក្នុងការបំពេញការអប់រំ និងជំនាញរបស់អ្នកទៅជាជោគជ័យខាងហិរញ្ញវត្ថុ នោះអ្នកនឹងត្រូវសម្រេចចិត្តរវាងការចង់បាន និងសេចក្ដីត្រូវការជានិច្ច ។

## ស្វែងរកនគរនៃព្រះជាមុនសិន

អ្នកនឹងមានជម្រើសពីរ ។ តើកម្លាំងចិត្តរបស់អ្នកដើម្បីស្ថាបនា ហើយទូលសុំពរជ័យរបស់ព្រះអម្ចាស់នឹងសម្រាប់ជាការបំពេញចិត្តផ្ទាល់ខ្លួន សម្រាប់ការទទួលស្គាល់របស់មនុស្ស និងសម្រាប់អំណាច ឥទ្ធិពល និងមហិច្ឆតាផ្ទាល់ខ្លួនមែនទេ ? ឬកម្លាំងចិត្តរបស់អ្នកគឺដើម្បីសរសើរតម្កើងដល់ព្រះ ធ្វើការដើម្បីជួយដឹកនាំនៅក្នុងការរីកចម្រើន និងការកើនឡើងនៃសាសនាចក្ររបស់ទ្រង់ ?

ជនដែលស្វែងរកទ្រព្យសម្បត្តិដើម្បីធ្វើឲ្យខ្លួនឯងបានប្រសើរឡើង នឹងរកឃើញថាទ្រព្យសម្បត្តិរបស់ពួកគេងាយនឹងបាត់បង់ក្នុងផ្លូវដែលមិនឆ្លាតវៃ ( សូមមើល ហេលេមិន 13:31 ) ។ សុខុមាលភាពនៃព្រលឹងរបស់ពួកគេនឹងស្ថិតនៅក្នុងក្ដីមហន្តរាយដ៏ធំ ។ យ៉ាកុប ជាប្អូនប្រុសបន្ទាប់របស់នីហ្វៃដែលជាអ្នកគោរពប្រតិបត្តិមួយរូប បានព្រមានយើងថា ៖

« ហើយបាតដៃនៃទិព្វញ្ញាណបានញញឹមមកលើអ្នករាល់គ្នា ដើម្បីជួយឲ្យអ្នករកបានទ្រព្យជាច្រើន ហើយដោយមកពីពួកអ្នកខ្លះរកបានបរិបូរច្រើនជាងបងប្អូនអ្នក នោះអ្នករាល់គ្នាលើកខ្លួនឡើងក្នុងការឆ្មើងឆ្មៃនៃចិត្តរបស់អ្នក ហើយធ្វើក-រឹង ព្រមទាំងងើយក្បាលដោយព្រោះប្រដាប់ស្លៀកពាក់របស់ខ្លួនមានតម្លៃខ្ពស់ ហើយក៏បៀតបៀនបងប្អូនខ្លួន ព្រោះអ្នកគិតស្មានថា ខ្លួនគ្រាន់បើជាងគេ ។

« . . . តើអ្នកគិតស្មានថា ព្រះទ្រង់ចាត់អំពើរបស់បងប្អូននេះទុកជាសុចរិតឬអី ? មើលចុះ ខ្ញុំប្រាប់អ្នកថា ៖ ទេ ។ ប៉ុន្តែទ្រង់នឹងកាត់ទោសអ្នក ហើយបើសិនជាអ្នករាល់គ្នានៅតែទទូចធ្វើការនេះតទៅទៀត នោះសេចក្ដីជំនុំជំរះរបស់ទ្រង់នឹងត្រូវតែធ្លាក់មកលើអ្នកយ៉ាងឆាប់រហ័ស ។

« . . . សូមកុំឲ្យសេចក្ដីឆ្មើងឆ្មៃនៃចិត្តអ្នកបំផ្លាញព្រលឹងទាំងឡាយរបស់អ្នកឡើយ ! » ( យ៉ាកុប 2:13, 14, 16 ) ។

បន្ទាប់មក យ៉ាកុប បានដាក់កម្លាំងចិត្តរបស់យើងដើម្បីទទួលបានទ្រព្យសម្បត្តិនៅក្នុងទស្សនវិស័យដ៏ត្រឹមត្រូវជាមួយនឹងការសន្យាថា ៖

« ប៉ុន្តែ មុនអ្នករាល់គ្នាស្វែងរកទ្រព្យសម្បត្តិ ចូរអ្នករាល់គ្នាស្វែងរកនគរនៃព្រះសិន ។

« ហើយបន្ទាប់ពីអ្នករាល់គ្នាបានសេចក្ដីសង្ឃឹមនៅក្នុងព្រះគ្រីស្ទ នោះអ្នករាល់គ្នានឹងបានទ្រព្យសម្បត្តិ បើសិនជាអ្នករាល់គ្នាស្វែងរករបស់ទាំងនេះ ហើយអ្នករាល់គ្នានឹងស្វែងរកទ្រព្យសម្បត្តិដោយមានបំណងចង់ធ្វើល្អ—គឺដើម្បីបំពាក់ពួកអ្នកអាក្រាត ហើយចិញ្ចឹមពួកអ្នកដែលអត់ឃ្លាន ហើយរំដោះពួកអ្នកដែលត្រូវជាប់ឃុំឃាំង ហើយជួយសង្គ្រោះដល់ពួកអ្នកឈឺ និងអ្នកកំសត់ទុរគត៌ » ( យ៉ាកុប 2:18–19 ) ។

ព្រះអម្ចាស់ពុំមែនកំពុងមានបន្ទូលប្រាប់យើងថា យើងពុំគួរមានភាពចម្រើនឡើង ឬថាភាពចម្រើនឡើងគឺជាអំពើបាបមួយនោះទេ ។ ផ្ទុយទៅវិញ ទ្រង់បានប្រទានពរដល់កូនចៅរបស់ទ្រង់ដែលគោរពប្រតិបត្តិជានិច្ច ។ ប៉ុន្តែ ទ្រង់កំពុងប្រាប់យើងថា យើងគួរស្វែងរកភាពចម្រើនឡើងបន្ទាប់ពីយើងស្វែងរក រកឃើញ ហើយបម្រើទ្រង់តែប៉ុណ្ណោះ ។ ក្រោយមក ដោយសារដួងចិត្តរបស់យើងត្រឹមត្រូវ ដោយសារយើងស្រឡាញ់ទ្រង់មុនអ្វីៗទាំងអស់ នោះយើងនឹងជ្រើសរើសដាក់ទ្រព្យសម្បត្តិដែលរកបាននៅក្នុងការស្ថាបនានគរព្រះ ។

ប្រសិនបើយើងជ្រើសរើសស្វែងរកទ្រព្យសម្បត្តិដើម្បីមានបាន នោះអ្នកនឹងបរាជ័យយ៉ាងឆាប់រហ័ស ។ អ្នកនឹងមិនស្កប់ស្កល់ ឡើយ ។ អ្នកនឹងមានភាពទទេរស្អាត ពុំដែលស្គាល់សុភមង្គលពិត និងសេចក្ដីអំណរដ៏អស់កល្បឡើយ ។



**ចូរមានចិត្តរីករាយ**

« ទោះជាពពកខ្មៅងងឹតប្រមូលផ្ដុំគ្នា ទោះជាភ្លៀងធ្លាក់មកលើយើង ក៏ចំណេះដឹងរបស់យើងពីដំណឹងល្អ និងសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះវរបិតាសួគ៌របស់យើង និងចំពោះព្រះអង្គសង្គ្រោះរបស់យើងនឹងលួងលោមចិត្ត ហើយគាំទ្រយើង ហើយនាំយកសេចក្ដីអំណរមកដួងចិត្តរបស់យើង នៅពេលយើងដើរដោយសុចរិត ហើយគោរពតាមព្រះបញ្ញត្តិ ។ គ្មានអ្វីនៅក្នុងពិភពលោកនេះអាចរារាំងយើងបានឡើយ ។

« បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំអើយ ចូរកុំភ័យខ្លាចឡើយ ។ ចូរមានចិត្តរីករាយ ។ អនាគតគឺភ្លឺត្រចះត្រចង់ដូចជាសេចក្ដីជំនឿរបស់អ្នកដែរ » ។

**ប្រធាន ថូម៉ាស អេស ម៉នសុន « Be of Good Cheer » *Liahona* ខែ ឧសភា ឆ្នាំ 2009 ទំព័រ 92 ។**

ការសាកល្បងនៃសេចក្ដីជំនឿរបស់អ្នកនៅក្នុងប៉ុន្មានឆ្នាំខាងមុខនឹងប្រហែលជាពុំមែនជាការដែលអ្នកខ្វះនូវសម្ភារនៃលោកិយនេះទេ ។ ផ្ទុយទៅវិញ វានឹងជាការជ្រើសរើសអ្វីដែលត្រូវធ្វើជាមួយនឹងពរជ័យខាងសាច់ឈាមដែលអ្នកបានទទួល ។

ប្រធាន អែសរ៉ា ថាហ្វ បែនសឹន ( ឆ្នាំ 1899–1994 ) បានមានប្រសាសន៍ពីជំនាន់វ័យក្មេងសព្វថ្ងៃនេះថា ៖

« ជិតប្រាំមួយពាន់ឆ្នាំហើយ ព្រះបានរក្សាទុកអ្នកដើម្បីឲ្យអ្នកចេញមកនៅក្នុងថ្ងៃចុងក្រោយនេះពីមុនការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។ . . .

«. . . ព្រះបានរក្សាទុកសម្រាប់ថ្ងៃចុងក្រោយនូវកូនចៅ . . . របស់ទ្រង់មួយចំនួនដែលខ្លាំងបំផុត ជាអ្នកនឹងជួយដឹកនាំនគរនេះដោយជោគជ័យ » ។[3]

ប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា « អ្នកគឺជាកូនចៅមួយចំនួនរបស់ព្រះវរបិតាសួគ៌នៃយើងដែលខ្លាំងក្លាជាងគេបំផុត ហើយទ្រង់បានរក្សាអ្នកទុកដើម្បីមកកាន់ផែនដី ‹ សម្រាប់ពេលនេះឯង › [ នាងអេសធើរ 4:14 ] » ។[4]

ដើម្បីក្លាយជាផ្នែកដ៏សំខាន់មួយនៃ « ការមួយយ៉ាងអស្ចារ្យ ហើយចម្លែក » ( នីហ្វៃទី 2 25:17 ) ក្នុងថ្ងៃចុងក្រោយនេះ អ្នកត្រូវដាក់ឆន្ទៈរបស់អ្នកតាមព្រះ ដោយបណ្ដោយឲ្យវាត្រូវបានលេបដណ្ដប់នៅក្នុងព្រះហឫទ័យរបស់ទ្រង់ ។ នៅពេលអ្នក « ឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទដោយមានការភ្លឺថ្លានៃសេចក្ដីសង្ឃឹមដ៏ឥតខ្ចោះ ហើយដោយមានចិត្តស្រឡាញ់ព្រះ និងមនុស្សគ្រប់រូប . . . ដោយទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ » ( នីហ្វៃទី 2 31:20 ) ដោយការស្រាវជ្រាវដោយឧស្សាហ៍ ការអធិស្ឋានជានិច្ច ហើយជឿ នោះដូចជាព្រះអម្ចាស់បានសន្យា « គ្រប់ការណ៍ទាំងអស់ផ្សំគ្នាសម្រាប់សេចក្ដីល្អដល់អ្នក » ( គ. និង ស. 90:24 ) ។

**ឧទ្ទិស ហើយធ្វើឲ្យបរិសុទ្ធ**

ខ្ញុំលើកទឹកចិត្តអ្នកឲ្យធ្វើការតាំងចិត្តមួយចំពោះខ្លួនឯង និងចំពោះព្រះវរបិតាសួគ៌ ដើម្បីឧទ្ទិសជីវិតរបស់អ្នក និងដើម្បីញែកពេលវេលា និងទេពកោសល្យរបស់អ្នកឲ្យបរិសុទ្ធដើម្បីស្ថាបនាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ដោយទន្ទឹងចាំការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។ ចូរឲ្យគោលបំណងនៃគំនិត និងទង្វើររបស់អ្នក គឺដើម្បីថ្វាយបង្គំព្រះ និងដើម្បីប្រទានពរដល់បងប្អូនរបស់អ្នក ។ ចូរឲ្យបំណងប្រាថ្នានេះបំផុសគំនិតអ្នកឲ្យស្វាគមន៍ព្រឹកថ្មីជារៀងរាល់ថ្ងៃជាមួយនឹងភាពរីករាយ ហើយចូរឲ្យវាបំពេញគំនិត និងទង្វើររបស់អ្នកជារៀងរាល់ថ្ងៃ ។

ប្រសិនបើអ្នកធ្វើដូច្នេះ អ្នកនឹងត្រូវបានប្រទានពរឲ្យនៅក្នុងពិភពលោកមួយដែលកំពុងបាត់បង់បទដ្ឋានរបស់ខ្លួនយ៉ាងខ្លាំង ហើយអ្នក និងមនុស្សជាទីស្រឡាញ់របស់អ្នកនឹងមានសុវត្ថិភាព ហើយរីករាយ ។ នេះពុំមែនមានន័យថា អ្នកនឹងមិនប្រឈមមុខនឹងឧបសគ្គ និងការសាកល្បងនោះទេ ប៉ុន្តែវាមានន័យថា អ្នកនឹងមានអំណាចខាងវិញ្ញាណ



**ចំណុចគោលលទ្ធិ**

យើងអាចបន្តមានភាពសុទិដ្ឋិនិយមពីអនាគតនោះ ប្រសិនបើយើង ៖

- រក្សាសេចក្ដីជំនឿជឿលើអំណាចនៃដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។
- ដាក់ព្រះវរបិតាសួគ៌ជាមនុស្សទីមួយនៅក្នុងជីវិតរបស់យើង ។
- ឧទ្ទិសជីវិតរបស់យើង ហើយញែកពេលវេលារបស់យើងឲ្យបរិសុទ្ធចំពោះការស្គាល់នានគរព្រះ ។

Divine Redeemer ( ព្រះអង្គប្រោសលោះដ៏ទេវភាព ) ដោយ ស៊ីម៉ូន ឌូវ © Altius Fine Arts

ដើម្បីទប់ទល់នឹងវាដោយសេចក្ដីជំនឿ និងទំនុកចិត្តលើព្រះអម្ចាស់ ។

គោលបំណងនៃសារលិខិតរបស់ខ្ញុំគឺដើម្បីជួយអ្នកឲ្យមើលឃើញទុកជាមុនពីអនាគតរបស់អ្នក ។ សូមមានសេចក្ដីជំនឿ និងសេចក្ដីសង្ឃឹមចំពោះអនាគតដ៏ភ្លឺស្វាងដែលអ្នកជួប ។ យុវជនគឺជាឪពុកនាពេលអនាគត ។ យុវនារីគឺជាម្ដាយ និងអ្នកចិញ្ចឹមបីបាច់នាពេលអនាគត ។ អ្នកទាំងពីរគឺជា « ពូជជ្រើសរើស ជាពួកសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ ជារាស្ត្រដ៏ជាកេរអាករ » ( ពេត្រុសទី 1 2:9 ) ។

ពីព្រោះទាំងបុរស និងស្ត្រី អាទិភាពសំខាន់បំផុតមួយរបស់អ្នកគឺការស្វែងរកដៃគូអស់កល្បជានិច្ចរបស់អ្នក ប្រសិនបើអ្នកពុំទាន់ធ្វើវានៅឡើយ ។ អាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធនឹងផ្ដល់ឲ្យអ្នកនូវដៃគូម្នាក់ដើម្បីជួយអ្នកដើរលើផ្លូវត្រឹមត្រូវដែលដឹកនាំត្រលប់ទៅវត្តមាននៃព្រះវរបិតាសួគ៌របស់យើង និងព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ។ យើងត្រូវតែធ្វើផ្នែករបស់យើងដើម្បីបន្តការរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។ ■

*ដកស្រង់ចេញពីសុន្ទរកថាចាប់ផ្ដើមមួយដែលធ្វើឡើងនៅសកលវិទ្យាល័យ ព្រិកហាំ យ៉ង់–អៃដាហូ នៅថ្ងៃទី 6 ខែ មេសា ឆ្នាំ 2012 ។ សម្រាប់អត្ថបទទាំងស្រុងជាភាសាអង់គ្លេស សូមចូលទៅកាន់ web.byui.edu/devotionalsandspeeches/speeches.aspx ។*

**កំណត់ចំណាំ**

1. ហ្គរដុន ប៊ី ហ៊ិងគ្លី « Living in the Fulness of Times » *Ensign* ខែ វិច្ឆិកា ឆ្នាំ 2001 ទំព័រ 6, *លីអាហូណា* ខែ មករា ឆ្នាំ 2002 ទំព័រ 6 ។
2. *Teachings of Presidents of the Church: Joseph Smith* ( ឆ្នាំ 2007 ) ទំព័រ 142 ។
3. អ៊ែសរ៉ា ថាហ្វ បែនសឹន នៅក្នុងថូម៉ាស អេស ម៉នសុន « Dare to Stand Alone » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2011 ទំព័រ 62 ។
4. ថូម៉ាស អេស ម៉នសុន « May You Have Courage » *Liahona* ខែ ឧសភា ឆ្នាំ 2009 ទំព័រ 127 ។








# ប្រទេសម៉ិចស៊ិកបានអភិវឌ្ឍ

## ពីបញ្ហាទៅកាន់ភាពរឹងមាំ

*ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅប្រទេស ម៉ិចស៊ិកបានស្ថាបនានូវកេរមរតកនៃសេចក្ដីជំនឿរបស់ពួកគេ ដើម្បីនាំមកនូវអនាគតដ៏ស្រស់ស្អាតដល់ប្រទេសរបស់ពួកគេ ។*

**ដោយ សាលី ចនសុន អូឌេយឹក**
ទស្សនាវដ្ដីសាសនាចក្រ

នៅថ្ងៃទី 6 ខែ វិច្ឆិកា ឆ្នាំ 1945 ការអធិស្ឋានបានទទួលចម្លើយនៅពេលក្រុមទីមួយនៃពួកបរិសុទ្ធថ្ងៃចុងក្រោយម៉ិចស៊ិកបានមកដល់ព្រះវិហារបរិសុទ្ធ មេសា អារីហ្សូណា ដើម្បីទទួលពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធជាភាសាកំណើតរបស់ខ្លួន ។ ហ្វូសេ ក្រាសៀ នៅពេលនោះជាប្រធានសាខាមន់ធើររេ បានប្រាប់ឲ្យដឹងថា « យើងបានមកដើម្បីធ្វើកិច្ចការដ៏អស្ចារ្យសម្រាប់ខ្លួនឯង និងសម្រាប់ដូនតារបស់យើង ។. . . ប្រហែលជាយើងមួយចំនួនបានធ្វើការលះបង់ ប៉ុន្តែការលះបង់ទាំងនោះដែលយើងបានធ្វើគឺពុំឥតប្រយោជន៍ឡើយ ។ យើងមានអំណរណាស់ដោយបានធ្វើកិច្ចការទាំងនេះ » ។[1]

ប្រធាន ក្រាសៀ និងសមាជិកដែលបានធ្វើដំណើរទៅកាន់ព្រះវិហារបរិសុទ្ធបានដើរតាមដានជើងនៃពួកអ្នកត្រួសត្រាយផ្លូវពួកបរិសុទ្ធថ្ងៃចុងក្រោយម៉ិចស៊ិចពីជំនាន់ដើម ដែលបានលះបង់ដូចគ្នានេះចំពោះដំណឹងល្អដែលបានស្ដារឡើងវិញ ។



ប្រធាន ចច អ័លប៊ើត ស៊្មីធ បានធ្វើទស្សនកិច្ចនៅប្រទេសម៉ិចស៊ិក ហើយជួយបង្រួបបង្រួមសមាជិក នៅពេលលោកឈោងទៅជួយក្រុមអនុសញ្ញាទីបី ។

**ការស្ថាបនាគ្រឹះ**

ដែនដីភ្នំ វាលខ្សាច់ ព្រៃ និងឆ្នេរសមុទ្រដ៏ល្អស្រស់ស្អាត ប្រទេស ម៉ិចស៊ិក ពីបុរាណគឺជាផ្ទះសម្រាប់មនុស្សដែលបានសាងសង់ព្រះវិហារបរិសុទ្ធ និង ទីក្រុងដ៏ស្រស់ស្អាត ។ ជាច្រើនសតវត្សរ៍ ប្រជាជនម៉ិចស៊ិចបានស្ថាបនាគ្រឹះ នៃសេចក្តីជំនឿ និងការអធិស្ឋានដ៏រឹងមាំមួយដែលបានជួយពួកគេក្នុងគ្រាដ៏ លំបាក ។

ខណៈដែលពួកបរិសុទ្ធកំពុងស្ថាបនាសាសនាចក្រនៅក្នុងរដ្ឋ យូថាហ៍ នោះ ប្រជាជនម៉ិចស៊ិចបានកំពុងធ្វើកិច្ចការរៀបចំរចនាសម្ព័ន្ធសង្គមរបស់ពួកគេ ឡើងវិញ រួមទាំងការសរសេរច្បាប់រដ្ឋធម្មនុញ្ញថ្មីមួយដែលបែងចែក ព្រះវិហារ និងរដ្ឋដាច់ពីគ្នា ។ សារលិខិតនៃដំណឹងល្អបានមកដល់ប្រទេសម៉ិចស៊ិកនៅ ឆ្នាំ 1876 ជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនាដំបូង កាន់ព្រះគម្ពីរដែល បានជ្រើសរើសក្នុងព្រះគម្ពីរមរមន ដែលវាបានធ្វើទៅឲ្យមេដឹកនាំម៉ិចស៊ិក ។

**បន្ទាត់ពេលវេលា**

*ឆ្នាំ 1810 ៖ ប្រទេសម៉ិចស៊ិកបាន ប្រកាសឯករាជ្យ ហើយបានទទួល ឯករាជ្យនៅឆ្នាំ 1821 បន្ទាប់ពីស្ថិត នៅក្រោមការគ្រប់គ្រងរបស់ប្រទេស អេស្ប៉ាញរយៈពេល 300 ឆ្នាំ ។*

*ឆ្នាំ 1830 ៖ ព្រះគម្ពីរមរមនបាន បោះពុម្ព ហើយសាសនាចក្រ បានរៀបចំឡើងនៅក្នុង ភូមិប៉ាលម៉ៃរ៉ា រដ្ឋនូវយ៉ោក ស.រ.អា. ។*



*ឆ្នាំ 1846–1848 ៖ សង្គ្រាម ម៉ិកស៊ិក និងអាមេរិក ។ ពួក អ្នកត្រួសត្រាយផ្លូវបានតាំង លំនៅក្នុងភាគខាងលិច សហរដ្ឋ ។*



*ឆ្នាំ 1857–61 ៖ លោកប្រធាន បេនីតូ ជូអារ៉េស្ស បានរៀបចំ រដ្ឋាភិបាលម៉ិចស៊ិកឡើងវិញ ហើយបានស្ថាបនាសេរីភាព ខាងសាសនា ។*

មិនយូរប៉ុន្មាន បុណ្យជ្រមុជទឹកបានកើតមានឡើង ។

អំឡុងពេលសន្និសីទពិសេសមួយនៃសាសនាចក្រដែលធ្វើឡើងនៅថ្ងៃទី 6 ខែ មេសា ឆ្នាំ 1881 ប្រធានសាខា ស៊ិលវីយ៉ាណូ អាតេអាហ្គា ថ្នាក់ដឹកនាំ មូលដ្ឋានមួយចំនួន និងសាវក ម៉ូសេ ថាត់ឆើរ ( 1842–1909 ) បានឡើងទៅលើ ចំណោតភ្នំភ្លើង ។ ប៉ូប៉ូកាតេប៉េត ។ បន្ទាប់មក អែលឌើរ ថាត់ឆើរ បានឧទ្ទិស ដែនដីនេះសម្រាប់ការប្រកាសដំណឹងល្អ ។

នៅសន្និសីទនោះ ប្រធាន អាតេអាហ្គា បានអធិស្ឋាន ហើយអែលឌើរ ថាត់ឆើរ បានមានប្រសាសន៍ថា ៖ « ទឹកភ្នែករបស់គាត់បានហូរស្រក់មក ដើម្បី ធ្វើឲ្យពូជសាសន៍ និងប្រជាជនរបស់គាត់មានសេរីភាព ។. . . ខ្ញុំពុំធ្លាប់ឮបុរស ណាម្នាក់អធិស្ឋានដោយស្មោះត្រង់បែបនេះឡើយ ហើយទោះជាការអធិស្ឋានជា ភាសាមួយដែលខ្ញុំមិនយល់ ប៉ុន្តែខ្ញុំហាក់ដូចជាយល់តាមរយៈព្រះវិញ្ញាណ នូវអ្វី ដែលគាត់បានអង្វរសុំ » ។[2]

នៅពេលជាមួយគ្នានោះដែរ សាខាម៉ិចស៊ិកមួយចំនួនត្រូវបានស្ថាបនានៅ ក្នុងតំបន់ ។ ដេស៊ីដេរីយ៉ា យ៉ាណេស ជាស្ត្រីមេម៉ាយចំណាស់ម្នាក់រស់នៅរដ្ឋ ហ៊ីដាល់ហ្គូ បានមានសុបិនមួយពីកូនសៀវភៅរបស់ប៉ាលី ភី ប្រាត្ត *A Voice of Warning* ( *សំឡេងនៃការព្រមាន* ) ។ គាត់បានឲ្យកូនប្រុសរបស់គាត់ទៅ ទីក្រុងម៉ិចស៊ិក ដើម្បីយកកូនសៀវភៅនោះ ដែលទើបតែបានបកប្រែជាភាសា អេស្ប៉ាញ ។ គាត់បានចូលរួមនឹងសាសនាចក្រនៅឆ្នាំ 1880 ដោយក្លាយទៅជា ស្ត្រីទីមួយដែលចូលរួមក្នុងសាសនាចក្រនៅប្រទេសម៉ិចស៊ិក ។[3]

ចាប់តាំងពីពេលនោះមក សមាជិកសាសនាចក្រជាច្រើននៅប្រទេស ម៉ិចស៊ិកបានបន្តស្មោះត្រង់ដោយឆ្លងកាត់នូវទសវត្សនៃការបដិវត្តន៍ ការធ្វើ ទុក្ខទោស ភាពក្រីក្រ និងភាពឯកោ ។[4]

**គំរូនៃពួកអ្នកត្រួសត្រាយផ្លូវដ៏ស្មោះត្រង់**

គំរូមួយនៃសេចក្តីស្មោះត្រង់នេះគឺត្រូវបានគេឃើញនៅក្នុងសាខា សានប៉េដ្រូម៉ាទើរ ដែលបានរៀបចំឡើងនៅក្នុងឆ្នាំ 1907 ។ សមាជិកពីជំនាន់មុន បានជួបគ្នាតែនៅភាគខាងត្បូងនៃទីក្រុង ម៉ិចស៊ិកប៉ុណ្ណោះ គឺនៅក្នុងអគារមួយ ដែលបានសង់ឡើងដោយអ្នកទើបជ្រមុជទឹកថ្មីឈ្មោះ អាហ្គាស៊ីន ហារ៉ូ ដែល ត្រូវបានហៅឲ្យធ្វើជាអធិបតីនៅសាខានោះ ។ អំឡុងគ្រាដ៏លំបាកនៃការធ្វើ បដិវត្តន៍ក្នុងប្រទេសម៉ិចស៊ិក ជាពេលដែលយ៉ាងហោចណាស់ប្រជាជនម៉ិចស៊ិក មួយលាននាក់ត្រូវបានគេសម្លាប់ នោះពួកបរិសុទ្ធជាច្រើនបានស្វែងរកទីជំរកជ្រក កោននៅសាន ប៉េដ្រូ នៅពេលរដ្ឋរបស់ពួកគេបានក្លាយទៅជាទីលានចម្បាំង ។ បងប្អូនស្រីនៅក្នុងសមាគមសង្គ្រោះក្នុងសាន ប៉េដ្រូបានផ្តល់ដល់ជនភៀសខ្លួន ទាំងនេះនូវការបម្រើប្រកបដោយសេចក្តីមេត្តាយ៉ាងខ្លាំង ។[5]

ការថតរូបទាំងអស់ផ្តល់សិទ្ធិដោយការិយាល័យប្រវត្តិសាស្ត្រសាសនាចក្រ លើកលែងតែមានការកត់សម្គាល់ *Covered Wagons* ដោយ ...



សមាជិកក៏ត្រូវបានប្រទានពរឲ្យជាមួយនឹងថ្នាក់ដឹកនាំដែលមានការលះបង់ដូចជា រេ អិល ប្រាត្ត ។ ត្រូវបានហៅធ្វើជាប្រធានបេសកកម្មម៉ិចស៊ិកក្នុងឆ្នាំ 1907 គាត់បានបម្រើនៅក្នុងការហៅនោះរហូតដល់បានទទួលមរណភាពនៅឆ្នាំ 1931 ។ គាត់ស្រឡាញ់ប្រវត្តិសាស្ត្រ វប្បធម៌ និងប្រជាជនម៉ិចស៊ិក ហើយបានទទួលសេចក្ដីស្រឡាញ់ និងការទុកចិត្តរបស់ពួកគេ នៅពេលពួកគេធ្វើការរួមគ្នាដើម្បីពង្រឹងគ្រឹះរបស់សាសនាចក្រនៅទីនោះ ។ កិច្ចខិតខំរបស់ប្រធាន ប្រាត្ត ដើម្បីពង្រឹងថ្នាក់ដឹកនាំសាសនាចក្រជនជាតិម៉ិចស៊ិក បានបង្ហាញនូវសារៈសំខាន់យ៉ាងពិសេសក្នុងឆ្នាំ 1926 នៅពេលរដ្ឋាភិបាលម៉ិចស៊ិចបានចាប់ផ្ដើមពង្រឹងច្បាប់ដែលហាមឃាត់មិនឲ្យជនបរទេសគ្រប់គ្រងក្រុមជំនុំនៅក្នុងប្រទេសម៉ិចស៊ិកនោះ ។[6]

សាសនាចក្រក្នុងមូលដ្ឋានក្នុងរដ្ឋ អារីហ្សូណា ស.រ.អា. អែលឌើរ យ៉ូសែប ហ្វិលឌីង ស្មីធ ( 1876–1972 ) ដែលនៅពេលនោះជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា « ខ្ញុំមើលឃើញថា ភាសាអង់គ្លេសមិនគួរជាភាសាតែមួយនៅក្នុងការប្រជុំនៅព្រះវិហារបរិសុទ្ធឡើយ » ។[8] អែលឌើរ អាន់តូណេ អ័រ អាយវីនស៍ នៃពួកចិតសិបនាក់ និងអេឌូអាដូ បាលឌើរ៉ាស ក្នុងនាយកដ្ឋានបកប្រែរបស់សាសនាចក្រត្រូវបានស្នើសុំឲ្យបកប្រែពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធជាភាសាអេស្ប៉ាញ ។ ការបកប្រែនេះបានកំណត់ជំហានសម្រាប់ព្រះវិហារបរិសុទ្ធនឹងត្រូវបានសាងសង់ឡើងនៅលើទឹកដីផ្សេងទៀត ។[9]

ដោយមានពិធីនៅក្នុងព្រះវិហារបរិសុទ្ធជាភាសាអេស្ប៉ាញនៅព្រះវិហារបរិសុទ្ធ មេសា អារីហ្សូណា និងដោយមាន

*ឆ្នាំ 1875 ៖ ផ្នែកមួយចំនួននៃសៀវភៅមរមនត្រូវបានបកប្រែជាភាសាអេស្ប៉ាញ ហើយត្រូវបានបោះពុម្ព ។*

*ឆ្នាំ 1876 ៖ ពួកអ្នកផ្សព្វផ្សាយសាសនាដំបូងគេធ្វើដំណើរទៅប្រទេសម៉ិចស៊ិក ។*



*ឆ្នាំ 1881 ៖ សន្និសីទពិសេសត្រូវបានធ្វើឡើង, សាវក ម៉ូសេ ថាតឆើរ បានឧទ្ទិសដែនដីនោះសម្រាប់កិច្ចការផ្សព្វផ្សាយសាសនា ។*



*ឆ្នាំ 1885 ៖ ក្រុមមរមនត្រូវបានស្ថាបនាឡើងនៅប្រទេសម៉ិចស៊ិក ។*

*ឆ្នាំ 1886 ៖ ព្រះគម្ពីរមរមនពេញលេញត្រូវបានបោះពុម្ពជាភាសាអេស្ប៉ាញ ។*



**ប្រជាជនសំណព្វរបស់ព្រះអម្ចាស់**

« តើនរណាអាចដឹងទៅថាប្រទេសម៉ិចស៊ិកនឹងមានភាពល្អលាស់កាន់តែប្រសើរឡើង។ ដោយសារតែការជាប់គាំងនៅបច្ចុប្បន្ននេះនោះ ។ . . . ផ្លូវ [ នឹង ] ត្រូវបានរៀបចំសម្រាប់ការបង្រៀននៃដំណឹងល្អដ៏ពិតទៅកាន់ប្រជាជននៅលើទឹកដីនោះ ជាដំណឹងល្អដែលនាំឲ្យកើតមានការប្រោសលោះរបស់ពួកគេ ហើយធ្វើឲ្យពួកគេក្លាយជាប្រជាជនសំណព្វរបស់ព្រះអម្ចាស់ » ។[17]

**រេ អិល ប្រាត្ត ប្រធានបេសកកម្មម៉ិចស៊ិកនៅអំឡុងពេលការធ្វើបដិវត្តម៉ិចស៊ិក**

អំឡុងពេលនោះ មានសមាជិកមួយក្រុមបានបង្កើតក្រុមមួយដែលពួកគេហៅថា អនុសញ្ញាទីបី ហើយបានចាប់ផ្ដើមហៅថ្នាក់ដឹកនាំរបស់ពួកគេ ហើយសង់សាលាប្រជុំ ។

## ការស្ថាបនាគ្រឹះ

អាវ៉ើល អិល ភាស ត្រូវបានហៅជាប្រធានបេសកកម្មម៉ិចស៊ិកនៅឆ្នាំ 1942 ។ ដោយពឹងផ្អែកលើបទពិសោធន៍របស់គាត់ខណៈដែលធំដឹងក្ដីឡើងនៅ ឈីហួអាហួអាំ និងការបម្រើបេសកកម្មនៅប្រទេសម៉ិចស៊ិក ប្រធាន ភាស បានឈោងទៅជួយដោយសេចក្ដីស្រឡាញ់ និងការយល់ចិត្ត នៅពេលបានបង្រៀន ពង្រឹង ហើយធ្វើឲ្យសមាជិកមានភាពសាមគ្គីភាព ។ គាត់ក៏បានធ្វើការជាមួយនឹងសមាជិកនៃក្រុមអនុសញ្ញាទីបីដើម្បីដោះស្រាយកង្វល់របស់ពួកគេផងដែរ ។

គោលដៅមួយរបស់ប្រធាន ភាស គឺដើម្បីជួយសមាជិកឲ្យទៅកាន់ព្រះវិហារបរិសុទ្ធ ។[7] ក្នុង ឆ្នាំ 1943 កិច្ចខិតខំដើម្បីធ្វើឲ្យពរជ័យនៃព្រះវិហារបរិសុទ្ធកើតមានដល់សមាជិកជាច្រើនទៀតបានកើតឡើង ។ បន្ទាប់ពីការប្រជុំជាមួយនឹងថ្នាក់ដឹកនាំ

*ជារឿយៗ សមាជិកពីដើមបានលះបង់យ៉ាងធំធេងសម្រាប់ដំណឹងល្អ ។*





**អនាគតដ៏អស្ចារ្យមួយ**

« ខ្ញុំគិតពីអនាគតរបស់សាសនាចក្រនៅប្រទេសម៉ិចស៊ិចនឹងធ្វើឲ្យមនុស្សគ្រប់គ្នាភ្ញាក់ផ្អើល សូម្បីតែជនដែលបានប្រឡូកក្នុងកិច្ចការនេះក្ដី ។ ប្រជាជនម៉ិចស៊ិកគឺស្គាល់ពីសង្គមដែលពួកគេរស់នៅ ហើយមានរឿងមួយចំនួននៅក្នុងសង្គមនោះដែលពួកគេមិនចង់បាន ។ ពួកគេបានសម្លឹងមើលអ្វីដែលដំណឹងល្អបានផ្ដល់ឲ្យ ពួកគេចង់បានវា ហើយពួកគេនឹងយល់ព្រមដើម្បីបង់ថ្លៃគ្រប់យ៉ាងសម្រាប់វា » ។[18]

**អែលឌើរ ដានីយ៉ែល អិល ចនសុន ប្រធានតំបន់ម៉ិចស៊ិក**

ទស្សនកិច្ចមួយពីប្រធានសាសនាចក្រ ចច អ័លប៊ើត ស៊្មីធ ( 1870–1951 ) ទៅប្រទេសម៉ិចស៊ិក ក្នុងឆ្នាំ 1946 ដើម្បីជួយបង្រួបបង្រួមពួកបរិសុទ្ធម៉ិចស៊ិក[10] នោះសាសនាចក្របានចាប់ផ្ដើមរីកលូតលាស់តាមរបៀបមួយដែលជំនាន់ពីមុនបានត្រឹមតែស្រមើស្រមៃប៉ុណ្ណោះ ។ បេសកកម្ម និងស្តេកថ្មីជាច្រើនត្រូវបានបង្កើតឡើងពេញផ្ទៃប្រទេស ហើយសាលារៀនដែលឧបត្ថម្ភដោយសាសនាចក្របានលើកកម្ពស់ដល់ការអប់រំ ។

ក្នុងឆ្នាំ 1964 សាសនាចក្របានឧទ្ទិសឆ្លងសាលារៀន El Centro Escolar Benemérito de las Américas ជាសាលារៀនមួយដែលបានបម្រើសេចក្ដីត្រូវការរបស់សមាជិកខាងវិស័យអប់រំ សង្គម ខាងវិញ្ញាណ និងភាពជាអ្នកដឹកនាំរបស់សមាជិករហូតដល់បានក្លាយជាមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនានៅឆ្នាំ 2013 ។[11] បងស្រី ឡូរេណា ហ្គូមេស អាល់វ៉ារេស្ស ដែលបានបញ្ចប់ការសិក្សាពីសាលានោះបាននិយាយថា « Benemérito បានជួយខ្ញុំឲ្យរកឃើញ ហើយអភិវឌ្ឍនូវទេពកោសល្យរបស់ខ្ញុំ និងដើម្បីទទួលបានការអប់រំ និងចំណេះដឹងមួយនៃដំណឹងល្អដែលបានប្រទានពរដល់ជីវិតរបស់ខ្ញុំ ។ ឥឡូវនេះ វានឹងជួយដល់ពួកអ្នកផ្សព្វផ្សាយសាសនាផ្សាយដំណឹងល្អ ហើយនឹងបន្តប្រទានពរដល់ជីវិតរបស់ប្រជាជន គឺជារបៀបពិសេសមួយ » ។[12]

### យុគសម័យនៃការរីកចម្រើន

សន្និសីទនៅទីក្រុងម៉ិចស៊ិកនៅឆ្នាំ 1972 គឺជាចំណុចដ៏សំខាន់មួយទៀតក្នុងការរីកចម្រើនរបស់សាសនាចក្រ ។ សមាជិកបានធ្វើដំណើរយ៉ាងឆ្ងាយដើម្បីស្ដាប់ប្រធាន ហារ៉ូល ប៊ី លី ( 1899–1973 ) ទីប្រឹក្សារបស់លោក ពួកសាវកមួយចំនួន និងថ្នាក់ដឹកនាំដទៃទៀត ។ ក្រុមចម្រៀងពាងខុបោសថបានសម្ដែងនៅទីនោះ ដោយបន្ថែមនូវចំណីអារម្មណ៍ខាងវិញ្ញាណ ។ ពួកអ្នកចូលរួមនៅសន្និសីទបានស្រែកឡើងថា « វាលើសពីអ្វីដែលយើងស្រមើស្រមៃថានឹងកើតឡើងទៅទៀត—ជាសន្និសីទនៅក្នុងដែនដីផ្ទាល់របស់យើង » ។[13]

នៅទសវត្សរ៍ឆ្នាំ 1970 គឺជាពេលដ៏រីករាយនៃការរីកលូតលាស់ក្នុងប្រទេសម៉ិចស៊ិក ។ នៅឆ្នាំ 1970 មានសមាជិកជិត 70,000 នាក់នៅក្នុងប្រទេសនេះ លុះដល់ចុងទសវត្សរ៍មានជិតទៅដល់ 250,000 នាក់ ។ បីឆ្នាំក្រោយពីសន្និសីទនៅតំបន់នេះ អែលឌើរ ហាវីដ ដបុលយូ ហ៊ីនធើរ ( 1907–95 ) បានបំបែកស្តេកចំនួនបីដែលមានរួចហើយ ដើម្បីបង្កើតជា 15 ស្តេកនៅចុងសប្ដាហ៍មួយ ដោយហៅសមាជិកម៉ិចស៊ិកវ័យក្មេងជាច្រើនធ្វើជាអ្នកដឹកនាំ ។[14]

កិច្ចការផ្សព្វផ្សាយសាសនាក៏បានពង្រីកផងដែរនៅអំឡុងពេលនេះ ។ បេសកកម្មម៉ិចស៊ិក ដែលបានបើកជាផ្លូវការនៅឆ្នាំ 1879 ត្រូវបានបំបែកជាលើកដំបូងនៅឆ្នាំ 1956 ។ ឥឡូវនេះ ប្រទេសម៉ិចស៊ិកមានបេសកកម្ម 34 កន្លែង ។[15] បងប្រុស ចច ហ្សាម៉ូរ៉ា ដែលបានបម្រើជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ក្នុងបេសកកម្មម៉ិចស៊ិកស៊ីធីខាងជើងក្នុងទសវត្សរ៍ឆ្នាំ 1980 បានឃើញពីការរីកចម្រើននេះ ។ គាត់បាននឹកចាំពីតំបន់បេសកកម្មមួយរបស់គាត់ដែលសមាជិកត្រូវបានធ្វើដំណើររយៈពេលមួយម៉ោងទៅចូលរួមនៅព្រះវិហារ ។ ឥឡូវនេះមានស្តេកមួយនៅទីនោះ ។ គាត់និយាយថា « វាអស្ចារ្យណាស់ចំពោះខ្ញុំនូវរបៀបដែលព្រះអម្ចាស់ធ្វើការដើម្បីស្ថាបនាសាសនាចក្រ ដោយមិនគិតពីប្រទេស ឬវប្បធម៌ណានោះទេ » ។

### មានព្រះវិហារបរិសុទ្ធជាច្រើននៅលើដែនដីនេះ

ប្រជាជនម៉ិចស៊ិកស្រឡាញ់ពិធីការសង្គ្រោះរបស់ព្រះវិហារបរិសុទ្ធ ហើយយល់ព្រមដើម្បីធ្វើការលះបង់ពេលវេលា និងប្រាក់ដ៏អស្ចារ្យដើម្បីថ្វាយបង្គំនៅទីនោះ ។ គ្រាន់តែជាង 100 ឆ្នាំបន្ទាប់ពីអែលឌើរ ថាត់ឆើរ បានឧទ្ទិសឆ្លងដែនដីនេះសម្រាប់ការ

*ឆ្នាំ 1889 ៖ ពួកអ្នកផ្សព្វផ្សាយសាសនាត្រូវបានដកពីម៉ិចស៊ិកកណ្ដាល ។*

*ឆ្នាំ 1901 ៖ ការផ្សព្វផ្សាយត្រូវបន្តនៅតំបន់ទីក្រុងម៉ិចស៊ីកូ ។*

*ឆ្នាំ 1910 ៖ ការចាប់ផ្ដើមនៃបដិវត្តម៉ិចស៊ិក ។*



*ឆ្នាំ 1912 ៖ ការធ្វើដំណើរចេញពីក្រុមមរមន នៅក្នុងភាគខាងជើងប្រទេសម៉ិចស៊ិក ។*

*ឆ្នាំ 1913 ៖ ពួកអ្នកផ្សព្វផ្សាយសាសនាត្រូវបានដកចេញដោយសារការធ្វើបដិវត្ត ។ ប្រធានបេសកកម្ម រ៉េ អិល ប្រាត្ត បានដឹកនាំសាសនាចក្រនៅក្នុងប្រទេសម៉ិចស៊ិកតាមរយៈការឆ្លងឆ្លើយតាមសំបុត្រ ហើយបានធ្វើការជាមួយនឹងមនុស្សដែលនិយាយភាសាអេស្ប៉ាញនៅក្នុងសហរដ្ឋ ។*



iStockphoto/Thinkstock




*សមាជិកម៉ិចស៊ិកបានចូលរួមចំណែកនៅក្នុងគម្រោងសហគមន៍ ។ សមាជិកទាំងនេះបានជួយដាំកូនឈើនៅឆ្នាំ 2007 ។*



*ឆ្នាំ 1921 ៖ ពួកអ្នកផ្សព្វផ្សាយសាសនាត្រូវបានចាត់តាំងជាថ្មីនៅតំបន់ទីក្រុងម៉ិចស៊ីកូ ។*

*ឆ្នាំ 1926 ៖ ភាពជាតិនិយមរបស់ម៉ិចស៊ិកបានដឹកនាំទៅរកការដកចេញនូវរាល់បព្វជិតបរទេស ។*

*ទសវត្សរ៍ 1930 ៖ ពួកអ្នកដឹកនាំក្នុងមូលដ្ឋានរក្សាស្ថេរភាពនៃសាសនាចក្រនៅក្នុងប្រទេសម៉ិចស៊ិក ។*



*ឆ្នាំ 1945 ៖ ពិធីនៅក្នុងព្រះវិហារបរិសុទ្ធត្រូវបានបកប្រែជាភាសាអេស្ប៉ាញ ។ ការចាប់ផ្ដើមនៃការធ្វើដំណើរទៅព្រះវិហារបរិសុទ្ធ មេសា អារីហ្សូណា ។*



ផ្សព្វផ្សាយដំណឹងល្អ ព្រះវិហារបរិសុទ្ធមួយត្រូវបានសង់ឡើងនៅក្នុងទីក្រុងម៉ិចស៊ិក ។ ការបើកសម្ពោធនៅឆ្នាំ 1983 បានជួយនាំសាសនាចក្រចេញពីទីអាប់អួរនៅក្នុងប្រទេសម៉ិចស៊ិក នៅពេលមានមនុស្សរាប់ពាន់នាក់បានមកទស្សនាព្រះវិហារបរិសុទ្ធ ហើយបានសួរពីព័ត៌មានបន្ថែមទៀត ។ ក្នុងរយៈពេល 30 ឆ្នាំ ព្រះវិហារបរិសុទ្ធ 11 ថែមទៀតត្រូវបានឧទ្ទិសឆ្លងពេញផ្ទៃប្រទេស ហើយមានមួយទៀតកំពុងសាងសង់ ។

អ៊ីសាប៊ែល ឡេឌេស្ម៉ា បានធំឡើងនៅ តាំពីកូ ហើយចងចាំពីពេលដែលឪពុកម្ដាយនាងបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ មេសា អារីហ្សូណា ។ នាងនិយាយថា « វាចំណាយពេលពីរថ្ងៃដើម្បីធ្វើដំណើរទៅអារីហ្សូណា ហើយការធ្វើដំណើរនោះថ្លៃខ្លាំងណាស់ » ។ « នៅពេលព្រះវិហារបរិសុទ្ធម៉ិចស៊ិកស៊ីធីម៉ិចស៊ិក បានឧទ្ទិសឆ្លង ចម្ងាយផ្លូវត្រូវបានបន្ថយមកត្រឹមតែ 12 ម៉ោង ដោយធ្វើដំណើរតាមរថយន្ត » ។ ឥឡូវនេះដោយមានព្រះវិហារបរិសុទ្ធនៅ តាំពីកូ នោះយើងអាចចូលរួមបានញឹកញាប់ » ។

លីមហៃ អន់ទីវ៉េរ៉ូស ដែលបានបម្រើជាប្រធានព្រះវិហារបរិសុទ្ធអោស្សាកាម៉ិចស៊ិកពី ឆ្នាំ 2007 ដល់ 2010 បានមានប្រសាសន៍ថា « អស់អ្នកដែលមានទីបន្ទាល់ដ៏ស៊ីជម្រៅ ហើយខ្ជាប់ខ្ជួនពីដំណឹងល្អស្វែងរកវិធីដើម្បីមក សូម្បីតែមានការលំបាកលើចម្ងាយផ្លូវ និងហិរញ្ញវត្ថុក្ដី ហើយពួកគេមើលឃើញព្រះវិហារបរិសុទ្ធជានិមិត្តរូបនៃការការពារ » ។

បងស្រី ឡេឌេស្ម៉ា បានបន្ថែមថា « យើងត្រូវការព្រះវិញ្ញាណនៅក្នុងទីក្រុងរបស់យើង ហើយការមានព្រះវិហារបរិសុទ្ធនៅទីនេះជួយឲ្យការណ៍នោះកើតឡើង » ។ នៅពេលយើងមានបញ្ហា នៅពេលយើងសោកសៅ ព្រះវិហារបរិសុទ្ធគឺនៅជិត ហើយយើងស្វែងរកសេចក្ដីសុខសាន្តនៅទីនោះ » ។

### ការយកឈ្នះលើសេចក្ដីលំបាក

សមាជិកម៉ិចស៊ិកបានប្រឈមមុខនឹងឧបសគ្គ និងការល្បងទូទៅជាច្រើន ប៉ុន្តែពួកគេដឹងថា ពួកគេ និងពួកបរិសុទ្ធដទៃទៀតគឺជាកូនចៅនៃព្រះវរបិតាជាទីស្រឡាញ់ ។ ស្ថានភាពសេដ្ឋកិច្ច និងសង្គមពុំមែនជាបញ្ហានៅក្នុងរបៀបដែលពួកគេប្រព្រឹត្តចំពោះគ្នានោះឡើយ ។

### អាគ្រីគូល ឡូហ្សាណូ ហេរ៉េរ៉ា ៖ ប្រធានស្ដេកម៉ិចស៊ិកដំបូងគេ

អាគ្រីគូល ឡូហ្សាណូ ហេរ៉េរ៉ា ជាសមាជិកសាសនាចក្រវ័យក្មេងម្នាក់ នៅពេលគាត់បានឮប្រធាន ស្ពែនស៊ើរ ដបុលយូ ឃឹមបឹល ( ឆ្នាំ 1895–1985 ) នៅពេលនោះជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានលើកទឹកចិត្តសមាជិកក្នុងប្រទេសម៉ិចស៊ិកឲ្យខិតខំរៀនដើម្បីជួយពង្រឹងដល់ប្រទេសរបស់ខ្លួន ។ បងប្រុស ឡូហ្សាណូ បានសម្រេចចិត្តដើម្បីក្លាយជាមេធាវី និងជាអ្នកតស៊ូមតិម្នាក់សម្រាប់ប្រជាជនក្នុងប្រទេសរបស់គាត់ ។ គាត់ក៏ជាប្រធាននៃក្រុមប្រឹក្សាសម្រាប់សាសនាចក្រនៅក្នុងប្រទេសម៉ិចស៊ិកផងដែរ ហើយបានបម្រើជាប្រធានស្ដេកម៉ិចស៊ិកដំបូងគេ ជាប្រធានបេសកកម្ម ជាអ្នកតំណាងភូមិភាគរបស់ពួកសាវកដប់ពីរនាក់ និងជាប្រធាននៃព្រះវិហារបរិសុទ្ធ ម៉ិចស៊ីកូស៊ីធី ។[19]







គ្រួសារ មេនដេស្ស រស់នៅក្នុងទីក្រុងតូចមួយនៅលើភ្នំក្បែរទីក្រុង អោស្សាកា នៅភាគខាងត្បូងប្រទេសម៉ិចស៊ិក ។ ពួកគេនិយាយថា « មានពេលលំបាកៗខាង ហិរញ្ញវត្ថុ និងចម្ងាយផ្លូវ ប៉ុន្តែឆន្ទៈដើម្បីធ្វើអ្វីដែលព្រះអង្គសង្គ្រោះរបស់យើងចង់ឲ្យយើងធ្វើបានលើកទឹកចិត្តយើងឲ្យយកឈ្នះលើឧបសគ្គទាំងឡាយ » ។

ហ្គន់ស្សាឡូ មេនដេស្ស អាយុ 15 ឆ្នាំ បាននិយាយថា « នៅពេលអ្នករស់នៅទីកន្លែងមួយដែលមានគ្រោះថ្នាក់ការល្បួងទាំងឡាយអាចមានការលំបាក ប៉ុន្តែដោយមានជំនួយនៃការអធិស្ឋានយើងមិនទទួលយកភាពរីករាយនៃពិភពលោក ហើយយើងឈរជាសាក្សីចំពោះផ្លូវដ៏ប្រសើរមួយនៃជីវិត » ។

ដែលគាត់និយាយ ។ ចៃមី និងអាឡិច ពួកគេទាំងពីរនាក់បានដឹងថា ការកាន់បព្វជិតភាពគឺជាកិត្តិយស និងទំនួលខុសត្រូវមួយ ។ ចៃមី និយាយថា « ខ្ញុំដឹងថា បព្វជិតភាពត្រូវបានផ្ដល់ឲ្យដល់យុវជនដើម្បីសរសើរតម្កើងដល់ព្រះនាមរបស់ព្រះដោយការបម្រើដល់មនុស្សដទៃទៀត និងដោយការប្រកាសដំណឹងល្អ » ។

អំឡុងពេលទស្សនកិច្ចថ្មីៗនេះនៅប្រទេសម៉ិចស៊ិក អែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បាន ជួបយុវវ័យមកពីស្តេកចំនួនបី នៅក្នុងទីក្រុង ខានខាន់ ។ ពេលលោកនៅជាមួយនឹងយុវវ័យទាំងនេះ លោកបានមានប្រសាសន៍ថា « យើងបានឃើញពន្លឺនៅក្នុងកែវភ្នែករបស់ពួកគេ

ឆ្នាំ 1946 ៖ ប្រធាន ចច អ័លប៊ើត ស្ម៊ីធ បានទៅទស្សនកិច្ចប្រទេសម៉ិចស៊ិក ។



ទសវត្សរ៍ 1950 ៖ មណ្ឌល និងសាខាជាច្រើនបានបង្កើតនៅស្ទើរតែគ្រប់រដ្ឋទាំងអស់ក្នុងប្រទេសម៉ិចស៊ិក ។

ឆ្នាំ 1961 ៖ ស្តេកម៉ិចស៊ីកូស៊ីធីបានបង្កើតដោយមានប្រធានហារ៉ូល ប្រោនជាប្រធាន ។



ឆ្នាំ 1964 ៖ សាលា *Benemérito* បានបើកនៅក្នុងទីក្រុងម៉ិចស៊ីកូ ។

ឆ្នាំ 1967 ៖ ស្តេកទីពីរនៅក្នុងទីក្រុងម៉ិចស៊ីកូត្រូវបានរៀបចំឡើង ។ អាហ្គ្រីខូល ឡូហ្សាណូ ហេរ៉ា ត្រូវបានហៅជាប្រធានស្តេកដែលជាជនជាតិម៉ិចស៊ិកដំបូងគេ ។

ឆ្នាំ 1972 ៖ សន្និសីទប្រចាំតំបន់នៅក្នុងទីក្រុងម៉ិចស៊ីកូ ។







**ការសម្លឹងឆ្ពោះទៅកាន់អនាគត**

ដំណឹងល្អត្រូវបានស្ថាបនានៅប្រទេសម៉ិចស៊ិកជាយូរមកហើយ ប៉ុន្តែនៅមានតំបន់ខ្លះដែលសាសនាចក្រកំពុងតែអភិវឌ្ឍ ។ ចៃមី ក្រាស់ អាយុ 15 ឆ្នាំ និងគ្រួសាររបស់គាត់គឺជាសមាជិកនៃសាសនាចក្រតែមួយគត់នៅក្នុងក្រុងតូចមួយរបស់ពួកគេនៅលើភ្នំខាងលើទីក្រុង អោសាកា ។ គាត់ និងមិត្តរបស់គាត់ ហ្គន់ស្សាឡូ ធ្វើការសិក្សាថ្នាក់សិក្ខាសាលានៅផ្ទះរាល់សប្ដាហ៍ ។ រៀងរាល់ថ្ងៃសៅរ៍ ពួកគេបានធ្វើដំណើរពីរម៉ោងដោយជិះឡានក្រុងទៅរោងជំនុំដែលនៅជិតជាងគេបំផុតដើម្បីចូលរៀនថ្នាក់សិក្ខាសាលាជាមួយនឹងយុវវ័យផ្សេងទៀតក្នុងវួដរបស់ពួកគេ ។ ចៃមី បានចែកចាយនូវអ្វីដែលគាត់បានរៀនក្នុងថ្នាក់សិក្ខាសាលាជាមួយនឹងមិត្តរួមថ្នាក់របស់គាត់នៅឯសាលា ហើយបានឆ្លើយនឹងសំណួររបស់ពួកគេ ។ ប្អូនប្រុសរបស់ចៃមី ឈ្មោះ អាឡិច ជាឌីកុន គឺជាអ្នកដឹកនាំម្នាក់នៅក្នុងចំណោមមិត្តភក្តិរបស់គាត់ ។ អាឡិច និយាយថា នៅពេលគាត់សុំពួកគេដោយនិយាយពាក្យល្អកុំឲ្យប្រើពាក្យមិនល្អ ឬស្លៀកពាក់សំលៀកបំពាក់មិនសមរម្យ នោះពួកគេស្ដាប់តាមអ្វី

និងសេចក្ដីសង្ឃឹមនៅលើផ្ទៃមុខរបស់ពួកគេ ព្រមទាំងក្ដីស្រមៃដែលពួកគេមាន ។ ខ្ញុំនៅតែគិតពីអនាគតដ៏ភ្លឺថ្លាមួយដែលប្រទេសម៉ិចស៊ិកមាន » ។[16] ■

**កំណត់ចំណាំ**

1. ហិនរី អេ ស្ម៊ីធ « 200 Lamanites Gather in History-Making Conference, Temple Sessions » *Church News* ថ្ងៃទី 10 ខែ វិច្ឆិកា ឆ្នាំ 1945 ទំព័រ 8 ។
2. ម៉ូសេ ថាត់ឆើរ នៅក្នុង *Moses Thatcher Journal* ឆ្នាំ 1866–1868 ទំព័រ 54 ។
3. សូមមើល ប្រ៊ិតថានី អេ ឆាបមិន និង រីឆាដ អ៊ី ធើលេ ជុញ្ញ័រ *Women of Faith in the Latter Days* វ៉ុល1 ឆ្នាំ 1775–1820 ទំព័រ 461–470 ។
4. សូមមើល អូសិន ស្កត់ ខាដ « It's a Young Church in . . . Mexico » *Ensign* ខែ កុម្ភៈ ឆ្នាំ 1977 ទំព័រ 17–24 ។
5. សូមមើល ឃឹក ហេនរីចសិន « Mexican Mormon Pioneers » ពិពរណ៍ឆ្នាំ 2010 នៅមជ្ឈមណ្ឌលសម្រាប់អ្នកទស្សនានៃព្រះវិហារបរិសុទ្ធម៉ិចស៊ីស៊ីធី ម៉ិចស៊ិក ។
6. សូមមើល ហ្គែរី អ័រ ផ្លេក « Mormons in Mexico: The First 96 Years » *Ensign* ខែ កញ្ញា ឆ្នាំ 1972 ទំព័រ 20–21 ។
7. អេហ្វ ឡាម៉ុន ទូល្លីស « A Shepherd to Mexico's Saints: Arwell L. Pierce and the Third Convention » *BYU Studies* វ៉ុល37 លេខ 1 ( 1997 ) ៖ ទំព័រ 127–151 ។
8. សូមមើល អេឌូអាដូ បាល់ឌើរ៉ាស « Northward to Mesa » *Ensign* ខែ កញ្ញា ឆ្នាំ 1972 ទំព័រ 30 ។
9. សូមមើល អេឌូអាដូ បាល់ឌើរ៉ាស « Northward to Mesa » ទំព័រ 30–31 ។

## ការរីកលូតលាស់នៃសាសនាចក្រក្នុងប្រទេសម៉ិចស៊ិក




**ព្រះវិហារបរិសុទ្ធ** ៖ 12 ដោយ មាន 1 ទៀតបានប្រកាស នៅក្នុង ទីជួអាណា ។

**ស្តេក** ៖ 222

**មណ្ឌល** ៖ 36

**វួដ និងសាខា** ៖ 2,000

**បេសកកម្ម** ៖ 35

*គិតត្រឹមខែ មិថុនា ឆ្នាំ 2013

*ឆ្នាំ 1975 ៖ ស្តេកថ្មីចំនួន 12 កន្លែងត្រូវបានរៀបចំនៅក្នុងតំបន់មួយចំនួននៃប្រទេសម៉ិចស៊ិក ។*



*ឆ្នាំ 1983 ៖ ព្រះវិហារបរិសុទ្ធម៉ិចស៊ិកូស៊ីធី ត្រូវបានឧទ្ទិសឆ្លង ។*

*ឆ្នាំ 1993 ៖ សាសនាចក្រត្រូវបានរៀបចំឡើងវិញយ៉ាងស្របច្បាប់នៅប្រទេសម៉ិចស៊ិក ។*

*ឆ្នាំ 2000 ៖ ព្រះវិហារបរិសុទ្ធតូចៗចំនួនប្រាំបួនត្រូវបានឧទ្ទិសឆ្លង ។*



*ឆ្នាំ 2009 ៖ គណៈប្រធានតំបន់ជាជនជាតិម៉ិចស៊ិកដំបូងត្រូវបានហៅ ។*




*ឆ្នាំ 2013 ៖ មជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនាបានបើកនៅក្នុងទីក្រុងម៉ិចស៊ិកូ ។*

10. សូមមើល « The Church Moves On » *Improvement Era* ខែ កក្កដា ឆ្នាំ 1946 ទំព័រ 446, ចន ឌី ហ្គាលស៍ « Father Lehi's Children » *Improvement Era* ខែ កញ្ញា ឆ្នាំ 1946 ទំព័រ 556 ។
11. សូមមើល យ៉ូសែប វ៉ាកឃើរ « Missionary surge prompts LDS Church to open new MTC in Mexico » *Deseret News* ថ្ងៃទី 30 ខែ មករា ឆ្នាំ 2013, www.deseretnews.com ។
12. ពាក្យដកស្រង់នេះ និងពាក្យដកស្រង់លើកក្រោយពីសមាជិកសាសនចក្រសម័យទំនើបក្នុងប្រទេសម៉ិចស៊ិកបានមកពីបទសម្ភាសន៍ជាមួយអ្នកនិពន្ធនៅថ្ងៃទី 7 ខែ កុម្ភៈ ឆ្នាំ 2013 ។
13. នៅក្នុង ជេ អិម ថត « The Remarkable Mexico City Area Conference » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1972 ទំព័រ 88 ។
14. សូមមើលអេលិនន័រ ណូល *Howard W. Hunter* ( ឆ្នាំ 1994 ) ទំព័រ 202 ។
15. សូមមើល ដន អិល សៀល « One Million in Mexico » *Ensign* ខែ កក្កដា ឆ្នាំ 2004 ទំព័រ 34, គ្រីស្ទីន មិនើរ « The Church in Oaxaca, Mexico » *Ensign* ខែ មេសា ឆ្នាំ 2001 ទំព័រ 78 ។
16. ដកស្រង់ពីបទសម្ភាសន៍មួយជាមួយនាយកដ្ឋានសោតទស្សន៍ ខែ មេសា ឆ្នាំ 2012 ។
17. រេ អិល ប្រាត្ត នៅក្នុង *The Young Woman's Journal* វ៉ុល25 លេខ 9 ( ឆ្នាំ 1914 ) ទំព័រ 539 ។
18. ដកស្រង់ពីបទសម្ភាសន៍មួយជាមួយនឹងអ្នកនិពន្ធនៅថ្ងៃទី 5 ខែ មេសា ឆ្នុ 2013 ។
19. សូមមើល « Agricol Lozano Herrera: Mexican Mormon Church Leader » http://mittromneymormon.net/meet-some-mormons-2/meet-some-mormons-2/agricol-lozano-herrera-mexican-mormon-church-leader ។




*សិស្សថ្នាក់សិក្ខាសាលានៅ អេាស្សាកា រីករាយក្នុងការជួបជុំគ្នា ។*


Joseph Fielding Smith

# ភក្ដីភាព និង ភាពស្មោះត្រង់

## ការបំផុសគំនិតដកស្រង់ចេញពីខ្សែជីវិត និង ការបង្រៀនរបស់ យ៉ូសែប ហ្វីលឌីង ស្ម៊ីធ

ដោយ ហាត់ ដបុលយូ ប្រ៊ូស្ទី ជុញ្ញ័រ

នៅពេល យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ដែលមានវ័យ 33 ឆ្នាំ ដើរចូលទៅក្នុងរោងឧបោសថ សលត៍ លេក នៅថ្ងៃទី 6 ខែ មេសា ឆ្នាំ 1910 ដើម្បីចូលរួមក្នុងសន្និសីទទូទៅ នោះ មានអ្នកនាំផ្លូវម្នាក់បាននិយាយមកកាន់លោកថា « មែនហើយ យ៉ូសែប តើនរណាទៅនឹងក្លាយជាសាវកថ្មី ? »

យ៉ូសែប បានតបថា « ខ្ញុំមិនដឹងនោះទេ » ។ « ប៉ុន្តែវានឹងពុំមែនជាអ្នក ហើយក៏ពុំមែនជាខ្ញុំដែរ ! »[1]

នៅពេលឈ្មោះរបស់ពួកសាវកដប់ពីរនាក់ត្រូវបានអានសម្រាប់ការបោះឆ្នោតគាំទ្រ រំពេចនោះ យ៉ូសែប បានទទួលអារម្មណ៍ថា ឈ្មោះរបស់លោកអាចនឹងត្រូវបានគេលើកឡើងនៅពេលបន្ទាប់ទៀត ។ វាជាការពិតមែន ហើយបន្ទាប់មកលោកត្រូវបានគាំទ្រជាបុរសទី 12 នៅក្នុងកូរ៉ុមដ៏អស្ចារ្យនេះ ។

ការបន្ទាបខ្លួន និងភាពកំប្លុកកំប្លែងរបស់ យ៉ូសែប បានបង្ហាញនៅពេលលោកចេញពីសន្និសីទ ហើយត្រលប់ទៅផ្ទះវិញ ដើម្បីប្រាប់ដល់គ្រួសាររបស់គាត់ពីការហៅថ្មីរបស់គាត់ ។ លោកបានប្រាប់ដល់ភរិយារបស់លោកនូវពាក្យដែលធ្វើឲ្យងឿងឆ្ងល់ ដោយមានប្រសាសន៍ថា ៖ « បងគិតថា យើងត្រូវលក់គោ » ។ ប្រាកដណាស់ គាត់មានការភ្ញាក់ផ្អើលនៅពេលគាត់រង់ចាំការពន្យល់បន្ថែមទៀត ។ ចម្លើយដ៏សាមញ្ញរបស់លោកគឺ « បងគ្មានពេលដើម្បីមើលថែវាទៀតទេ ! » ។[2] នេះជាការចាប់ផ្ដើមនៃការបម្រើជាសាវកម្នាក់ ដែលអស់រយៈពេលច្រើនជាងប្រាំមួយឆ្នាំ ។

ចៅប្រុសរបស់ ហៃរ៉ុម ស្ម៊ីធ ឈ្មោះ យ៉ូសែប ហ្វីលឌីង ស្ម៊ីធ គឺជាប្រធានទី 10 នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ លោកបានបម្រើយ៉ាងយូរជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ពីមុនការហៅរបស់លោកឲ្យបម្រើជាប្រធាននៃសាសនាចក្រលើសពីប្រធានផ្សេងទៀតនៃសាសនាចក្រនេះ ។ នៅក្នុងរយៈពេល 60 ឆ្នាំរបស់លោកក្នុងនាមជាសមាជិកក្នុងកូរ៉ុមនៃពួកសាក្សីពិសេសនោះ ដំបូងលោកបានធ្វើដំណើរដោយជិះនៅលើខ្នងសេះ និងដោយរទេះ ហើយក្រោយមកដោយរថយន្ត និងតាមយន្តហោះប្រតិកម្មដើម្បីបង្រៀនដល់ពួកបរិសុទ្ធ ។ ការបង្រៀន និងការនិពន្ធជាច្រើនរបស់លោកបានប្រទានពរដល់សាសនាចក្រ និងអស់អ្នកណាដែលបានស្ដាប់តាមសារលិខិតដ៏បំផុសគំនិតរបស់លោក ។




*« ចូរយើងមានភក្ដីភាព ហើយស្មោះត្រង់ជានិច្ច ដោយមានបំណងប្រាថ្នាមួយដើម្បីគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ហើយគោរពទ្រង់ ហើយចងចាំសេចក្ដីសញ្ញាដែលយើងបានធ្វើជាមួយនឹងទ្រង់ » ។*



ខ្ញុំត្រូវបានអញ្ជើញឲ្យសរសេរអត្ថបទនេះ ដោយសារទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ជាអ្នកដែលខ្ញុំពេញចិត្តនឹងហៅគាត់ថាជាជីតា ។ ខ្ញុំមានចិត្តរំភើបចំពោះឆាកជីវិតរបស់លោកតាំងពីកំណើតរបស់ខ្ញុំ នៅពេលលោកបានធ្វើពិធីដាក់ឈ្មោះឲ្យខ្ញុំ និងការប្រសិទ្ធពររហូតដល់លោកបានទទួលមរណៈភាព នៅពេលខ្ញុំស្ថិតនៅក្នុងចំណោមចៅប្រុសជាច្រើនដែលបានបម្រើជាអ្នកសែងក្តារមឈូសនៅក្នុងបុណ្យសពរបស់លោក ។

## ព្យាការីដែលបានតែងតាំងទុកជាមុន

ដូចគ្នានឹងពួកព្យាការីទាំងអស់របស់ព្រះដែរ យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ត្រូវបានតែងតាំងទុកជាមុនដើម្បីមកកាន់ផែនដីស្របតាមកាលវេលាដ៏ទេវភាពរបស់ព្រះអម្ចាស់ ( សូមមើលកិច្ចការ 17:26 ) ។ យ៉ូសែប ជាកូនទីបួន ប៉ុន្តែជាកូនប្រុសដំបូងរបស់ ជូលីណា ឡែមសុន ស្ម៊ីធ ។ នៅក្នុងវិញ្ញាណដ៏រាបសានៃម្តាយដ៏ស្មោះត្រង់ឈ្មោះ ហាន់ណា នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ( សូមមើល សាំយ៉ូអែលទី 1 1:11 ) នោះជូលីណាបានសច្ចាថា ប្រសិនបើព្រះអម្ចាស់នឹងប្រទានកូនប្រុសម្នាក់ដល់គាត់ « គាត់នឹងធ្វើអ្វីគ្រប់យ៉ាងនៅក្នុងអំណាចរបស់គាត់ដើម្បីជួយកូនប្រុសនោះឲ្យបានជាប្រយោជន៍ដល់ព្រះអម្ចាស់ និងឪពុករបស់ខ្លួន » ។[3] ព្រះអម្ចាស់មិនគ្រាន់តែឆ្លើយតបចំពោះការទូលសុំរបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែក៏បានសម្តែងឲ្យគាត់ឃើញពីមុនកំណើតកូនប្រុសរបស់គាត់ថា កូននេះនឹងត្រូវបានហៅឲ្យបម្រើជាសាក្សីពិសេសម្នាក់របស់ទ្រង់នៅថ្ងៃណាមួយនៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។[4]

យ៉ូសែប បានកើតនៅថ្ងៃទី 19 ខែ កក្កដា ឆ្នាំ 1876 ជាកូនរបស់ យ៉ូសែប អេហ្វ ស្ម៊ីធ និង ជូលីណា ឡែមសុន ស្ម៊ីធ ។ នៅកំណើតរបស់ យ៉ូសែប ឪពុករបស់លោកគឺជាសាវក និងជាទីប្រឹក្សារបស់ប្រធាន ព្រិកហាំ យ៉ង់ ។ នៅពេល យ៉ូសែប មានអាយុប្រាំបួនខែ ឪពុកម្តាយរបស់លោកបានយកលោកទៅការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ សេន ចច យូថាហ៍ ។ ក្រោយមក លោកបានមានប្រសាសន៍ចំអកលេងថា « ការចាត់តាំងដំបូងរបស់ខ្ញុំក្នុងសាសនាចក្រគឺដើម្បីអមដំណើរ ព្រិកហាំ យ៉ង់ ទៅការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ សេន ចច យូថាហ៍ » ។[5]

នៅពេល យ៉ូសែប បានទទួលពរអយ្យកោរបស់លោកនៅវ័យ 19 ឆ្នាំ លោកអយ្យកោដ៏បំផុសគំនិតម្នាក់បានដាក់ដៃលើក្បាលរបស់ យ៉ូសែប ហើយបានប្រកាសថា ៖ « វាជាអភ័យឯកសិទ្ធិរបស់ឯងដើម្បីរស់នៅរហូតដល់វ័យចំណាស់សមល្មមមួយ និងតាមព្រះទ័យរបស់ព្រះអម្ចាស់ដើម្បីអាចក្លាយជាបុរសម្នាក់ដ៏ខ្លាំងក្លានៅក្នុងអ៊ីស្រាអែល ។. . . ពិតណាស់ ឯងនឹងឈរនៅក្នុងចំណោមមនុស្សទូទៅជាព្យាការី និងជាអ្នកទទួលវិវរណៈម្នាក់សម្រាប់ពួកគេ ត្បិតព្រះអម្ចាស់បានប្រទានពរដល់អ្នក ហើយបានតែងតាំងអ្នកសម្រាប់ការហៅនេះ » ។[6]

## ជីវិតគ្រួសារ ៖ ការផ្សំបញ្ចូលគ្នារវាងសេចក្តីស្រឡាញ់ និងការសាកល្បង

ចំពោះ យ៉ូសែប ហ្វីលឌីង ស្ម៊ីធ « គ្រួសារគឺជាក្រុមដ៏សំខាន់បំផុតនៅក្នុងគ្រានេះ ឬនៅភាពអស់កល្បជានិច្ច » ។[7] លោកបានចិញ្ចឹមបីបាច់នៅក្នុងគ្រួសារមួយដែលមានសេចក្តីស្រឡាញ់ សេចក្តីជំនឿ បទដ្ឋានសីលធម៌ខ្ពស់ និងក្រមសីលធម៌ធ្វើការងារ

*ខាងលើ ៖ រូបថតរបស់យ៉ូសែប ហ្វីលឌីង ស្ម៊ីធ វ័យក្មេង នេះត្រូវបានដាក់នៅក្នុងព្រះគម្ពីរប៊ីបរបស់ឪពុកម្តាយលោក ។ ខាងស្តាំ ៖ យ៉ូសែប លេងកីឡា handball ដោយរីករាយជាមួយនឹងបងប្រុសរបស់លោក ដេវីឌ ។ ខាងក្រោម ៖ អែលឌើរ ស្ម៊ីធ ( ទីពីររាប់ពីខាងឆ្វេងមក ) ជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនាផ្សេងទៀតនៅក្នុងប្រទេសអង់គ្លេស ឆ្នាំ 1901 ។ រូបថតនៅទំព័របន្ទាប់ក៏ជារូបថតនៅពេលលោកជាអ្នកផ្សព្វផ្សាយសាសនាផងដែរ ។ ខាងក្រោម ខាងស្តាំ ៖ អែលឌើរ ស្ម៊ីធ ( ខាងឆ្វេង ) ជាមួយនឹងសាវក ចច អ័លប៊ើត ស្ម៊ីធ និងអ៊ីស្រាអែល ស្ម៊ីធ នៅឆ្នាំ 1936 ។*









ដោយឧស្សាហ៍ ហើយលោកបានខិតខំជាបន្តបន្ទាប់ដើម្បីនាំយកគោលការណ៍ដូចគ្នានោះចូលទៅក្នុងគ្រួសាររបស់លោកផ្ទាល់ ។ ( សូមមើល ជំពូកទី 4, 15 និង 16 នៃ *Teachings of Presidents of the Church: Joseph Fielding Smith* ) ។

លោកបានរៀបការនឹង លូអី អេមីលី ស៊្មីតលីហ្វ ក្នុងព្រះវិហារបរិសុទ្ធ សលត៍ លេក ក្នុងឆ្នាំ 1898 ។ មួយឆ្នាំក្រោយមក លោកត្រូវបានហៅទៅបេសកកម្មនៅចក្រភពអង់គ្លេសរយៈពេលពីរឆ្នាំ ហើយត្រូវបានគាំទ្រដោយស្មោះពីភរិយារបស់លោក ។ ក្រោយពេលត្រលប់មកវិញ អ្នកទាំងពីរបានចាប់ផ្ដើមជីវិតរួមគ្នាវិញ ហើយត្រូវបានប្រទានពរឲ្យនូវកូនស្រីពីរនាក់ ។ ជាអកុសល អំឡុងពេលដ៏លំបាកនៃការមានទម្ងន់ជាលើកទីបី លូអី បានទទួលមរណៈភាព ។

នៅក្នុងភាពសោកសៅរបស់លោក យ៉ូសែប បានអធិស្ឋានថា « សូមជួយដល់ទូលបង្គំផង ឱ ព្រះអម្ចាស់អើយ ដើម្បីទូលបង្គំអាចរស់នៅដោយមានភាពសក្ដិសមដើម្បីបានជួបនឹងនាងនៅក្នុងសិរីល្អដ៏នៅអស់កល្បជានិច្ច ដើម្បីបានរួមរស់នឹងនាងជាថ្មីម្ដងទៀត ជារៀងរហូតទៅមិនបែកគ្នាឡើយ ។. . . សូមជួយទូលបង្គំឲ្យចិញ្ចឹមបីបាច់កូនតូចៗដ៏ស្រស់ស្អាតរបស់ទូលបង្គំ ដើម្បីពួកគេនឹងបន្តនៅបរិសុទ្ធ ហើយគ្មានស្នាមប្រឡាក់ពេញមួយជីវិតរបស់ពួកគេ » ។[8]

ដោយមានការជម្រុញពីឪពុករបស់លោក បុរសពោះម៉ាយដែលមានកូនពីរនាក់រូបនេះបានស្វែងរកភរិយា និងម្ដាយសម្រាប់កូនតូចៗរបស់ខ្លួនប្រកបដោយការអធិស្ឋាន ។ បំណងប្រាថ្នាដ៏សុចរិតរបស់លោកត្រូវបានប្រទានពរឲ្យដោយមាន អេធេល ចចជីណា រេណុល ត្រូវបាននាំមកក្នុងជីវិតរបស់លោក ។ ពួកគាត់បានរៀបការនៅខែ វិច្ឆិកា ឆ្នាំ 1908 ក្នុងព្រះវិហារបរិសុទ្ធ សលត៍ លេក ។ ស្ត្រីដ៏អស្ចារ្យរូបនេះបានក្លាយជាម្ដាយកូនស្រីពីរនាក់ដំបូងរបស់យ៉ូសែប ហើយក្រោយមកបានផ្ដល់កំណើតដល់កូនប្រាំបួននាក់បន្ថែមទៀត ។

មានគ្រាមួយ បន្ទុកដ៏ធ្ងន់ធ្ងររបស់ភរិយាលោកបានជិតជាប់នឹងគំនិតរបស់សាវករូបនេះ នៅពេលលោកធ្វើដំណើរទៅសន្និសីទស្ដេកមួយ ។ លោកបានសរសេរសំបុត្រមួយឲ្យភរិយារបស់លោក ដោយមានប្រសាសន៍ថា ៖ « បងកំពុងគិតពីអូន ហើយប្រាថ្នាថាបងអាចនៅជិតអូនជានិច្ចសម្រាប់ពីរបីសប្ដាហ៍ខាងមុខ ដើម្បីជួយមើលថែដល់អូន ។ បងនឹងជួយអូននូវរាល់កិច្ចការដែលបងអាចធ្វើបាន ហើយសង្ឃឹមថាអូននឹងអាច *ទទួលអារម្មណ៍នេះ* ចេញពីដួងចិត្តរបស់បង ។ សូមប្រាប់កូនៗផងឲ្យចេះធ្វើល្អនឹងអូន និងចំពោះគ្នាទៅវិញទៅមក » ។[9]

បន្ទាប់មកលោកបានចែកចាយជាមួយនឹងភរិយារបស់លោកជាមួយនឹងអារម្មណ៍ដ៏ជ្រាលជ្រៅក្នុងដួងចិត្តរបស់លោកនូវកំណាព្យមួយ ដែលក្រោយមកបានក្លាយទៅជាទំនុកតម្កើងព្រះមួយរបស់យើង « Does the Journey Seem Long? ( តើដំណើរមើលទៅហាក់ដូចជាវែងឆ្ងាយឬ ? ) » ( ល.រ. 127 ) ។

ជាអកុសល អេធេល បានទទួលមរណៈភាព នៅឆ្នាំ 1937 ។ នៅពេលភរិយារបស់លោកបានទទួលមរណៈភាព មានកូននៅក្នុងបន្ទុកប្រាំនាក់ដែលមិនទាន់រៀបការ ។ អែលឌើរ ស្ម៊ីធ បានទទួលការបំផុសគំនិតឲ្យស្វែងរកភរិយា និងដៃគូម្នាក់ទៀត ។ នៅឆ្នាំ 1938 លោកបានរៀបការនឹង ជេស៊ី អេវ៉ាន់ស៍ ស្ម៊ីធ នៅក្នុងព្រះវិហារបរិសុទ្ធ សលត៍ លេក ។

មនុស្សម្នាក់ដែលបានស្គាល់ពួកគាត់យ៉ាងច្បាស់បានសរសេរថា ៖ « ថ្វីបើមានអាយុខុសគ្នាម្ភៃប្រាំមួយឆ្នាំ និងមានបុគ្គលិកលក្ខណៈ ជំនាញ និងការបំពាក់បំប៉នខុសគ្នាក្ដី ក៏យ៉ូសែប ហ្វីលឌីង ស្ម៊ីធ និងជេស៊ី អេវ៉ាន់ស៍ ស្ម៊ីធ មានភាពសក្ដិសមនឹងគ្នាខ្លាំងណាស់ ។. . . រឿងមួយដែលចងភ្ជាប់ភាពខុសគ្នាយ៉ាងខ្លាំងរវាងបុគ្គលិកលក្ខណៈរបស់អ្នកទាំងពីរនេះគឺសេចក្ដីស្រឡាញ់ និងការគោរពដ៏ស្មោះត្រង់ដែលពួកគាត់មានចំពោះគ្នា » ។[10] ( សូមមើល ទំព័រ 6–23 ក្នុងសៀវភៅសិក្សានេះ ) ។

## អ្នកស្វែងរកការរៀនសូត្រដោយការសិក្សា និងដោយសេចក្ដីជំនឿផងដែរ

យ៉ូសែប ហ្វីលឌីង ស្ម៊ីធ មានកេរ្ដិ៍ឈ្មោះល្បីល្បាញក្នុងសាសនាចក្រថាជាអ្នកប្រាជ្ញខាងព្រះគម្ពីរ និងដំណឹងល្អ ។ នៅការចាប់ផ្ដើមនៃយុវវ័យរបស់លោក លោកមានបំណងប្រាថ្នាដ៏ធំមួយដើម្បី « ស្វែងរកការរៀនសូត្រគឺដោយការសិក្សា និងដោយសារសេចក្ដីជំនឿផង » ( គ. និង ស. 88:118 ) ។ លោកបានអានព្រះគម្ពីរមរមនចប់ពីរលើកពីមុនលោកមានអាយុ 10 ឆ្នាំ ។ នៅពេលមិត្តរបស់លោកបាត់រូបលោក នោះជារឿយៗពួកគេឃើញលោកក្នុងជង្រុកដាក់ចំបើងកំពុងអានព្រះគម្ពីរ ។[11]

លោកបានប្រាប់ដល់ក្រុមជំនុំមួយនៅប៉ុន្មានឆ្នាំក្រោយមកថា « ចាប់តាំងពីពេលដែលខ្ញុំចេះអានជាលើកដំបូង ខ្ញុំមានចិត្តរីករាយ និង ពេញចិត្តយ៉ាងខ្លាំងនៅក្នុងការសិក្សាព្រះគម្ពីរ. . .លើសពីអ្វីៗទាំងអស់នៅក្នុងពិភពលោកនេះ » ។[12] ( សូមមើលជំពូកទី 10 និង 18 ) ។

មានគ្រាមួយប្រធាន ហ៊ីប៊ើរ ចេ ក្រាន្ត ( ឆ្នាំ 1856–1945 ) បានសរសើរ





*ខាងលើ ៖ ប្រធានស្ម៊ីធ និងកូនប្រុសរបស់លោក ។ ខាងលើស្ដាំដៃ ៖ អែលឌើរ ស្ម៊ីធ ត្រូវបានរាក់ទាក់ដោយ ប្រធាន ដេវីឌ អូ មិកឃេ នៅឆ្នាំ 1961 ។ ខាងស្ដាំ ៖ ប្រធានស្ម៊ីធ បានអង្គុយនៅលើវេទិកាក្នុងរោងឧបោសថ សលត៍ លេក ។ ខាងក្រោម ៖ ប្រធានស្ម៊ីធ ឈរឲ្យគេថតរូបនៅការលេងកីឡាវាយកូនបាល់មួយ ជាកីឡាដែលលោកចូលចិត្តលេងកាលពីក្មេង ។*





ដល់ការរៀនសូត្ររបស់ប្រធានស្ម៊ីធ ដោយបានមានប្រសាសន៍ថា « ខ្ញុំបានគិតថា លោកគឺជាបុរសដ៏អស្ចារ្យខាងបទគម្ពីរនៅក្នុងចំណោមពួកអ្នកមានសិទ្ធិអំណាចទូទៅដែលយើងមាន » ។[13]

ការស្រេកឃ្លានរបស់លោកចំពោះការរៀនសូត្រមិនបានធ្វើឲ្យលោកខកខានក្នុងការចូលរួមក្នុងកីឡា និងល្បែងកម្សាន្តកាលពីនៅក្មេង ឬនៅពេលពេញវ័យនោះឡើយ ។ លោកចូលចិត្តលេងកីឡាវាយកូនបាល់ ហើយល្បែងកម្សាន្តជាច្រើនដែលយុវវ័យដែលរស់នៅក្នុងសង្គមកសិកម្មមួយលេង ។ ក្នុងនាមជាមនុស្សពេញវ័យម្នាក់ លោកបានក្លាយជាកីឡាករដ៏ឆ្នើមផ្នែកកីឡា handball ហើយបានចូលរួមជាទៀងទាត់ក្នុងព្រឹត្តិការណ៍កីឡារបស់លោក ។ លោកក៏ចូលរួមក្នុងកីឡាជាការជួបគ្នាជាគ្រួសារផងដែរ ។ ខ្ញុំនៅចាំយ៉ាងច្បាស់ពីការលេងកីឡាមួយ នៅពេលលោកតារបស់ខ្ញុំបានចោលបាល់ទៅចំនឹងម៉ាស៊ីនថតរបស់អ៊ុំប្រុសម្នាក់ដែលកំពុងថតនៅផ្នែកខាងឆ្វេងនៃទីលានប្រកួត ។

## អ្នកការពារសេចក្ដីជំនឿដែលមានចិត្តសប្បុរស

សូម្បីតែពីមុន ការហៅរបស់លោកជាសាវកក្ដី យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ត្រូវបានគេស្គាល់ថា ជាអ្នកការពារសេចក្ដីជំនឿម្នាក់ដែលម្ដងម្កាលធ្វើឲ្យមនុស្សមួយចំនួនគិតខុសពីលោកថាជាមនុស្សតឹងរឹង ។ ទោះបីជាលោកមិនបញ្ឈប់នូវបំណងប្រាថ្នារបស់លោកដើម្បីមានភក្ដីភាពចំពោះសេចក្ដីសញ្ញា និងដើម្បីលើកទឹកចិត្តមនុស្សទាំងអស់ឲ្យឱបក្រសោបជាប់នឹងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញក្ដី លោកក៏មាននូវផ្នែកទន់ភ្លន់ដែលត្រូវបានទទួលស្គាល់ដោយស្មោះពីសំណាក់គ្រួសារ និងពួកអ្នកស្គាល់លោកដែរ ។ ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃីមបឹល ( ឆ្នាំ 1895–1985 ) បានមានប្រសាសន៍ថា ៖ « យើងធ្លាប់បាននិយាយជាច្រើនដងថា ដោយសារពួកដប់ពីរនាក់នឹងក្លាយជាចៅក្រមនៃអ៊ីស្រាអែល នោះយើងគ្រប់គ្នានឹងរីករាយដោយមានការមើលថែពីលោក ពីព្រោះការកាត់សេចក្ដីរបស់លោកនឹងមានចិត្តសប្បុរស មានក្ដីមេត្តា យុត្តិធម៌ និងបរិសុទ្ធ » ។[14]

ប្រធាន ស្ម៊ីធ បានបង្ហាញគំរូមួយនៃចិត្តសប្បុរសបែបនេះនៅក្នុងការប្រជុំមួយដែលគាត់បាននិយាយពីគ្រោះថ្នាក់មួយទាក់ទងនឹងរថយន្តរបស់សាសនាចក្រ ។ មានបុរសវ័យចំណាស់ម្នាក់បើកឡានដឹកបន្លែដែលគ្មានការធានារ៉ាប់រងបានមកប៉ះនឹងរថយន្តរបស់សាសនាចក្រ ។ បន្ទាប់ពីការពិភាក្សាគ្នាខ្លះៗមក គេបានលើកទឹកចិត្តឲ្យសាសនាចក្រប្ដឹងពីបញ្ហានេះនៅក្នុងតុលាការ ។ ប៉ុន្តែ ប្រធានស្ម៊ីធ បានមានប្រសាសន៍ថា ៖ « មែនហើយ យើងអាចធ្វើបាន ។ ហើយប្រសិនបើយើងខិតខំឲ្យអស់ពីលទ្ធភាព នោះយើងអាចថែមទាំងដកហូតឡានពីបុរសក្រីក្រម្នាក់នោះផងដែរ ដូច្នេះតើគាត់នឹងប្រកបរបរចិញ្ចឹមជីវិតបានដោយរបៀបណា ? » គណៈកម្មការនោះបានផ្លាស់ប្ដូរអនុសាសន៍របស់ខ្លួន ហើយបានទុកឲ្យបញ្ហានោះបញ្ចប់ទៅ ។[15]

ខ្ញុំបានឃើញពីសេចក្ដីស្រឡាញ់ដែលមនុស្សដទៃទៀតមានចំពោះលោក នៅពេលដើរសំដៅទៅរកប្រធាន ហារ៉ូល ប៊ី លី ( ឆ្នាំ 1899–1973 ) នៅកន្លែងបញ្ចុះសពក្នុងទីក្រុង សលត៍ លេក បន្ទាប់ពីការឧទ្ទិសផ្នូររបស់ប្រធានស្ម៊ីធ ។ ខ្ញុំបាននិយាយទៅកាន់លោកថា « ប្រធានលី តាំងនាមជាសមាជិកម្នាក់ក្នុងគ្រួសារខ្ញុំចង់ឲ្យលោកដឹងពីអំណរគុណដ៏ធំធេងដែលខ្ញុំមានសម្រាប់ចិត្តសប្បុរសដែលលោកមានចំពោះលោកតារបស់

ខ្ញុំ » ។ លោកបានមើលមុខខ្ញុំ ហើយបានមានប្រសាសន៍ដោយទន់ភ្លន់ថា « ខ្ញុំស្រឡាញ់បុរសម្នាក់នោះ ! »

**អ្នកបម្រើដ៏ពិត ហើយស្មោះត្រង់**

ការបម្រើរបស់ប្រធានស្ម៊ីធត្រូវបានកត់សម្គាល់ដោយការគោរពប្រតិបត្តិតាមការបង្រៀនរបស់ព្រះគម្ពីរក្នុងការប្រកាសពីការប្រែចិត្ត ( សូមមើល ឧទាហរណ៍ គ. និង ស. 6:9, 11:9 ) ។ លោកបានមានប្រសាសន៍ថា ៖ « វាជាបេសកកម្មរបស់ខ្ញុំ ខ្ញុំគិតថា វាត្រូវបានបំផុសគំនិតដោយព្រះវិញ្ញាណរបស់ព្រះអម្ចាស់នៅក្នុងការធ្វើដំណើររបស់ខ្ញុំក្នុងស្តេកនៃស៊ីយ៉ូន ដើម្បីនិយាយទៅកាន់មនុស្សទូទៅថា *ឥឡូវនេះ* គឺជាថ្ងៃនៃការប្រែចិត្ត ហើយអំពាវនាវដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយឲ្យចងចាំពីសេចក្តីសញ្ញារបស់ខ្លួន. . .ដោយជម្រុញពួកគេឲ្យមាន*ភក្ដីភាព ហើយស្មោះត្រង់* នៅគ្រប់កិច្ចការទាំងអស់ » ។[16] ( សូមមើល ជំពូកទី 5 ) ។

ក្នុងមួយជីវិតរស់នៅរបស់លោកអស់រយៈពេលជិត 96 ឆ្នាំ ប្រធានស្ម៊ីធ បានអធិស្ឋានថា លោកនឹងបន្តមានភក្តីភាព ហើយស្មោះត្រង់ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត ។ ពិតណាស់ ប្រធាន ប៊យដ៍ ឃេ ផាកកឺ ជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់នៅបច្ចុប្បន្ននេះ បានសង្កេតឃើញថា ៖ « សូម្បីតែពេលលោកមានអាយុលើសកៅសិបឆ្នាំក៏ដោយ លោកបានអធិស្ឋានថាលោកនឹងអាចរក្សាសេចក្តីសញ្ញា និងកាតព្វកិច្ចរបស់លោក ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុតដែរ » ។[17]

ចំពោះប្រធានស្ម៊ីធ « ភក្តីភាព ហើយភាពស្មោះត្រង់ » គឺលើសពីឃ្លាដែលគ្រាន់តែថាឡើងវិញជារឿយៗទៅទៀត ។ វាជាអារម្មណ៍ដ៏អស្ចារ្យនៃសេចក្តីសង្ឃឹមរបស់លោកចំពោះមនុស្សគ្រប់គ្នា—ចំពោះសមាជិកសាសនាចក្រដែលបានធ្វើសេចក្តីសញ្ញា ហើយជាការពិតណាស់ចំពោះកូនចៅទាំងអស់របស់ព្រះវរបិតាសួគ៌របស់យើង ។ ប្រធានស្ម៊ីធបានទទូចអង្វរថា « យើងគួរតែជាមនុស្សដ៏ដំបូងគេបង្អស់ . . .ចំពោះនគរព្រះ និងសេចក្តីសុចរិតរបស់ទ្រង់ » ។ ចូរយើងមានភក្តីភាព ហើយស្មោះត្រង់ជានិច្ច ដោយមានបំណងប្រាថ្នាមួយដើម្បីគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ហើយគោរពទ្រង់ ហើយចងចាំសេចក្តីសញ្ញាដែលយើងបានធ្វើជាមួយនឹងទ្រង់ ។ នេះជាការអធិស្ឋានរបស់ខ្ញុំដើម្បីជាប្រយោជន៍ដល់អ៊ីស្រាអែលទាំងមូល » ។[18] ( សូមមើល ជំពូក 19–22 ) ។

នៅពេលអ្នកសញ្ជឹងគិតនូវការបង្រៀនដ៏បំផុសគំនិតរបស់លោក នោះទីបន្ទាល់របស់អ្នកនឹងត្រូវបានពង្រឹង ហើយអ្នកនឹងត្រូវបានប្រទានពរឲ្យជាមួយនឹងការកើនឡើងនូវការយល់ដឹងពីសេចក្តីពិតដ៏បរិសុទ្ធ ហើយសាមញ្ញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ វគ្គសិក្សានេះនឹងបង្កើនបំណងប្រាថ្នារបស់អ្នកដើម្បីរស់នៅជាមនុស្សមាន « ភក្តីភាព ហើយស្មោះត្រង់ » ។ ■

*កំណត់ចំណាំ ៖ ម្តាយរបស់អ្នកនិពន្ធឈ្មោះ ណាអូមី ស្ម៊ីធ ប្រ៊ូស្ទី បានកើតនៅឆ្នាំដែលយ៉ូសែប ហ្វីលឌីង ស្ម៊ីធ ត្រូវបានហៅបំរើចូលទៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ហើយជាកូនទីពីររបស់ អេធែល ចចជីណា ស្ម៊ីធ ជាស្រ្តីដែលប្រធានស្ម៊ីធ បានរៀបការជាមួយបន្ទាប់ពីភរិយាដំបូងរបស់លោកបានទទួលមរណៈភាពទៅ ។*

**កំណត់ចំណាំ**

1. *Teachings of Presidents of the Church: Joseph Fielding Smith* ( ឆ្នាំ 2013 ) ទំព័រ 16 ។
2. យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ជុញ្ញ័រនិង ចន ជេ ស្ទួរ៉េត *The Life of Joseph Fielding Smith* ( ឆ្នាំ 1972 ) ទំព័រ 176 ។
3. *Teachings: Joseph Fielding Smith* ទំព័រ 1, សូមមើលផងដែរ ប្រ៊ូស អ័រ ម៉ាក់ខនឃី « Joseph Fielding Smith: Apostle, Prophet, Father in Israel » *Ensign* ខែ សីហា ឆ្នាំ 1972 ទំព័រ 29 ។
4. សូមមើល ប្រ៊ូស អ័រ ម៉ាក់ខន់ឃី « Joseph Fielding Smith » ទំព័រ 29 ។
5. យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានដកស្រង់នៅក្នុងស្ម៊ីធ និង ស្ទួរ៉េត *The Life of Joseph Fielding Smith*ទំព័រ 49 ។
6. បានដកស្រង់នៅក្នុងស្ម៊ីធ និង ស្ទួរ៉េត*The Life of Joseph Fielding Smith* ទំព័រ vii ។
7. *Teachings: Joseph Fielding Smith* ទំព័រ 76 ។
8. *Teachings: Joseph Fielding Smith* ទំព័រ 275 ។
9. យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានដកស្រង់នៅក្នុងស្ម៊ីធ និង ស្ទួរ៉េត*The Life of Joseph Fielding Smith* ទំព័រ 188–89 ។
10. *Teachings: Joseph Fielding Smith* ទំព័រ 22, 23 ។
11. សូមមើល *Teachings: Joseph Fielding Smith* ទំព័រ 4 ។
12. *Teachings: Joseph Fielding Smith* ទំព័រ 4 ។
13. ហ៊ីប៊ើរ ចេ ក្រាន្ត នៅក្នុង ហ្វ្រេនស៊ីស អិម ហ្គីបបុន *Joseph Fielding Smith: Gospel Scholar, Prophet of God* ( ឆ្នាំ 1992 ) ទំព័រ 290 ។
14. ស្ពែនស៊ើរ ដបុលយូ ឃឹមបឹល នៅក្នុង ប្រ៊ូស អ័រ ម៉ាក់ខន់ឃី « Joseph Fielding Smith » *Ensign* ខែ សីហា ឆ្នាំ 1972 ទំព័រ 28 ។
15. សូមមើល លូស៊ីល ស៊ី ធេត *Boyd K. Packer: A Watchman on the Tower* ( ឆ្នាំ 1995 ) ទំព័រ 176 ។
16. យ៉ូសែប ហ្វីលឌីង ស្ម៊ីធ នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1919 ទំព័រ 88 ការគូសបញ្ជាក់បានបន្ថែម ។
17. ប៊យដ៍ ឃេ ផាកកឺ « Covenants » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1990 ទំព័រ 84 ។
18. យ៉ូសែប ហ្វីលឌីង ស្ម៊ីធ នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1912 ទំព័រ 124–25 ។

**វគ្គសិក្សាឆ្នាំ 2014**

នៅឆ្នាំនេះ បងប្អូនស្រ្តីនៃសមាគមសង្រ្គោះ និងពួកអ្នកកាន់បព្វជិតភាពមិលគីស្សាដែកនឹងសិក្សាអំពី *Teachings of Presidents of the Church: Joseph Fielding Smith* *( ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ហ្វីលឌីង ស្ម៊ីធ )* ។ សៀវភៅណែនាំការសិក្សានេះនឹងជួយធ្វើឲ្យប្រាកដថា ការបង្រៀនដ៏បំផុសគំនិតរបស់ប្រធានស្ម៊ីធ នឹងត្រូវបានដាក់ឲ្យប្រើប្រាស់សម្រាប់ជំនាន់បច្ចុប្បន្ន និងអនាគត ចាប់តាំងពីលោកបានទទួលមរណៈភាពនៅក្នុងឆ្នាំ 1972 ជាពេលដែលសមាជិកភាពសាសនាចក្រមានត្រឹមតែជាង 3 លាននាក់ប៉ុណ្ណោះ ។ ឥឡូវនេះ មនុស្សមួយចំនួនដែលកំពុងរស់នៅនឹងមានការចងចាំផ្ទាល់ខ្លួនមួយពីជីវិតគំរូរបស់ប្រធានស្ម៊ីធ ប៉ុន្តែមនុស្សទាំងអស់អាចត្រូវបានផ្តល់កម្លាំងចិត្ត ហើយបំផុសគំនិតតាមរយៈអំណាចនៃការបង្រៀនរបស់លោក ។

នៅពេលអ្នកសិក្សា ហើយសញ្ជឹងគិតប្រកបដោយការអធិស្ឋានពីការបង្រៀនរបស់ប្រធានស្ម៊ីធ នោះអ្នកនឹងដឹងពីរបៀបដែលព្រះអម្ចាស់បានប្រើលោកឲ្យធ្វើជាអ្នកនាំពាក្យដើម្បីបង្រៀនយ៉ាងច្បាស់ពីគោលការណ៍ទាំងឡាយដែលនាំមកនូវពរជ័យដ៏ធំធេងនៅពេលពួកគេអនុវត្តតាម ។ អ្នកនឹងសិក្សាប្រធានបទដូចជា ៖

- ទំនាក់ទំនងរបស់យើងចំពោះព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌ និងព្រះអង្គសង្គ្រោះរបស់យើង
- ព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់យើង
- បេសកកម្មរបស់ព្យាការីយ៉ូសែប ស្ម៊ីធ
- សារៈសំខាន់នៃសេចក្តីសញ្ញាក្នុងព្រះវិហារបរិសុទ្ធ
- របៀបដើម្បីនៅក្នុងលោកិយនេះ ប៉ុន្តែពុំមែនជារបស់ផងលោកិយ
- របៀបរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទដោយការមានភក្តីភាព ហើយស្មោះត្រង់

សៀវភៅណែនាំការសិក្សានេះមាននៅតាមអ៊ិនធើរណែត ក្នុងគេហទំព័រ LDS.org និងសម្រាប់ទូរស័ព្ទដៃនៅក្នុង mobile.lds.org ។

# តើខ្ញុំសុំអានសៀវភៅនោះបានទេ ?

ប្រហែលជា 50 ឆ្នាំមុន ដៃគូផ្សព្វផ្សាយសាសនារបស់ខ្ញុំ និងខ្ញុំបានដើរគោះទ្វារនៅក្បែរសកលវិទ្យាល័យ គ័រដូបា នៅប្រទេស អាហ្សង់ទីន មានយុវជនម្នាក់បានអញ្ជើញយើងឲ្យចូលទៅក្នុងផ្ទះរបស់គាត់ ។ វំពេចនោះ វាបង្ហាញយ៉ាងច្បាស់ថាគាត់ និងមិត្តរបស់គាត់បានអញ្ជើញយើងឲ្យចូលមកដើម្បីជជែកតវ៉ាពីវត្តមានរបស់ព្រះប៉ុណ្ណោះ ។

យើងមិនចង់ជជែកតវ៉ាទេ ប៉ុន្តែផ្ទុយទៅវិញយើងបានយល់ព្រមជួបនៅពេលក្រោយដើម្បីពិភាក្សាពីសារលិខិតរបស់យើងនៅក្នុងបរិយាកាសល្អមួយសម្រាប់ការរៀនសូត្រ ។ នៅពេលយើងបានត្រលប់មកវិញ យុវជននោះបានពន្យល់ពីហេតុផលដែលគាត់បានជឿថាគ្មានព្រះ ។ គាត់បាននិយាយថា មនុស្សបានបង្កើតព្រះឡើង ដោយសារសេចក្តីត្រូវការរបស់ខ្លួនដើម្បីជឿលើអ្វីមួយប្រសើរជាងជាអ្វីមួយដែលអរូបី ។

នៅពេលដល់វេនរបស់យើង ខ្ញុំបានសួរថា « តើអ្នកដឹងថាមានសហរដ្ឋដោយរបៀបណា ? » ខ្ញុំបានថ្លែងទីបន្ទាល់ពីភាពពិតរបស់វា ហើយបានសួរប្រសិនបើមានភស្តុតាងផ្សេងទៀតដែលបង្ហាញពីវត្តមានរបស់វា ។ គាត់បាននិយាយថា គាត់បានអានវានៅក្នុងសៀវភៅ និងសារព័ត៌មាន ។ បន្ទាប់មក ខ្ញុំបានសួរប្រសិនបើគាត់ជឿលើទីបន្ទាល់របស់ខ្ញុំ និងអ្វីដែលគាត់បានអាន ។ គាត់បាននិយាយទាំងបង្ខំចិត្តថា គាត់ជឿ ។

ខ្ញុំបាននិយាយថា « ដូច្នេះយើងមិនអាចបដិសេធទីបន្ទាល់របស់ជនមកពីសហរដ្ឋដូចជាខ្ញុំបានឡើយ » ។ « ឬយើងក៏មិនអាចបដិសេធពីទីបន្ទាល់របស់ជនដែលសរសេរពីវាបានដែរ » ។ យុវជននោះបានយល់ស្រប ។

បន្ទាប់មកខ្ញុំបានសួរថា « ដោយផ្អែកលើភស្តុតាងនេះ តើយើងអាចបដិសេធនូវទីបន្ទាល់របស់ជនដែលបានឃើញព្រះ ហើយបានសរសេរពីបទពិសោធន៍របស់ពួកគេបានទេ ? » ខ្ញុំបានបង្ហាញព្រះគម្ពីរប៊ីបដល់គាត់ ដោយប្រាប់គាត់ថា វាមាននូវទីបន្ទាល់របស់បុរសស្ត្រីដែលបានឃើញ ហើយបាននិយាយជាមួយនឹងព្រះ និងព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំបានសួរថាតើយើងអាចបដិសេធនូវទីបន្ទាល់ដែលមាននៅក្នុងព្រះគម្ពីរប៊ីបបានទេ ហើយគាត់បានឆ្លើយទាំងស្ទាក់ស្ទើរថា ទេ ។

ក្រោយមកខ្ញុំបានសួរថា « តើអ្នកគិតយ៉ាងណាដែរពីសៀវភៅមួយសរសេរឡើងដោយមនុស្សមួយក្រុមផ្សេងទៀតក្រៅពីជននៅក្នុងព្រះគម្ពីរប៊ីបដែលបានឃើញព្រះដែលជាអ្នកនិពន្ធនៃព្រះគម្ពីរប៊ីបនោះ ? » គាត់បានឆ្លើយថា គឺគ្មានសៀវភៅបែបនោះទេ ។

**យើងបានឲ្យព្រះគម្ពីរមរមនទៅយុវជននោះ ហើយបានថ្លែងទីបន្ទាល់ពីសេចក្តីស្រឡាញ់ដែលព្រះមានចំពោះកូនចៅរបស់ទ្រង់ ។**




យើងបានបង្ហាញព្រះគម្ពីរមរមនដល់គាត់ ហើយបានបង្រៀនគាត់ពីគោលបំណងរបស់វា ។ យើងបានថ្លែងទីបន្ទាល់ថា ព្រះគម្ពីរនោះពិត ហើយថាព្រះនៅតែធ្វើការទាក់ទងតាមរយៈព្យាការីដែលនៅរស់របស់ទ្រង់នៅសព្វថ្ងៃនេះ ។

គួរឲ្យភ្ញាក់ផ្អើល យុវជននោះបាននិយាយថា « ខ្ញុំធ្លាប់ធ្វើឲ្យពួកគ្រូគង្វាលមកពីព្រះវិហារផ្សេងមានការច្របូកច្របល់ ។ អ្នកមាននូវអ្វីមួយដែលខ្ញុំពុំធ្លាប់ឮពីមុនមក ។ តើខ្ញុំសុំអានសៀវភៅនោះបានទេ ? យើងបានឲ្យព្រះគម្ពីរនោះទៅគាត់ ហើយបានថ្លែងទីបន្ទាល់ពីសេចក្តីស្រឡាញ់ដែលព្រះមានចំពោះកូនចៅរបស់ទ្រង់ ។

ដោយសារការសិក្សាត្រូវបានបញ្ចប់ យើងមិនអាចទៅជួបនឹងយុវជនម្នាក់នេះម្តងទៀតឡើយ ពីមុនគាត់ត្រលប់ទៅផ្ទះរបស់គាត់វិញនៅប្រទេស បូលីវៀ ។ ប៉ុន្តែ ខ្ញុំបានអធិស្ឋានថា គាត់នឹងអានព្រះគម្ពីរមរមន ហើយទទួលបានទីបន្ទាល់មួយ ។

នៅឆ្នាំ 2002 ខ្ញុំត្រូវបានហៅឲ្យបម្រើជាប្រធានសាខាក្នុងសាខាអេស្ប៉ាញមួយនៅមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា ប្រូវ៉ូ ។ នៅថ្ងៃអាទិត្យមួយ ខ្ញុំបានលើកឡើងពីដំណើររឿងដូចគ្នានេះប្រាប់ទៅពួកអ្នកផ្សព្វផ្សាយសាសនា ។ ក្រោយមក មានអ្នកផ្សព្វផ្សាយសាសនាម្នាក់មកពីប្រទេស បូលីវៀ បានប្រាប់ខ្ញុំថា គាត់ធ្លាប់ឮបុរសចំណាស់ម្នាក់នៅក្នុងស្តេករបស់គាត់ប្រាប់ពីដំណើររឿងពីការផ្លាស់ប្រែចិត្តជឿរបស់ខ្លួន—ជាដំណើររឿងដូចគ្នាដែលខ្ញុំបានលើកឡើងនៅទីនេះ ។

ទឹកភ្នែករបស់ខ្ញុំបានស្រក់ហូរចុះមក ។ បន្ទាប់ពី 40 ឆ្នាំ ខ្ញុំបានទទួលចម្លើយនឹងការអធិស្ឋានរបស់ខ្ញុំពីយុវជនម្នាក់នោះមកពីប្រទេស បូលីវៀ ។ គាត់បានដឹងពីវត្តមានរបស់ព្រះ និងផែនការសុភមង្គលដ៏អស្ចារ្យរបស់ទ្រង់ ។ ខ្ញុំដឹងថា នៅថ្ងៃណាមួយយើងនឹងជួបគ្នាម្តងទៀត ហើយខ្ញុំនឹងរីករាយជាមួយនឹងគាត់នៅក្នុងដំណឹងល្អ ។ ■

នៀល អ័រ ខាដុន រដ្ឋ យូថាហ៍ ស.រ.អា.

រចនាដោយ ប្រាយស៍ ខ្លាក

# ការធ្វើដំណើរទៅកាន់ព្រះវិហារបរិសុទ្ធរបស់ម៉ាម៉ា សេហ្វី

នាថ្ងៃមួយ ខណៈដែលខ្ញុំនៅក្នុងការិយាល័យបេសកកម្ម មិកស៊ិក កាលពីឆ្នាំ 1940 មានស៊ីស្ទើរម្នាក់បានមកពីទីក្រុងតូចមួយនៃ អូហ្សូមបា ដែលមានទីតាំងនៅជើងភ្នំ ប៉ូប៉ូកាតេប៉េត ជាកន្លែងមានភ្នំភ្លើងសកម្មមួយ ប្រហែលជា 43 ម៉ែល ( 70 គីឡូម៉ែត្រ ) ប៉ែកអាគ្នេយ៍នៃទីក្រុងមិកស៊ិក ។ យើងទាំងអស់គ្នាស្គាល់គាត់ ។ ឈ្មោះគាត់ គឺ ម៉ាម៉ា សេហ្វី ។

ពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង បានរស់នៅក្នុងផ្ទះដីឥដ្ឋតូចរបស់គាត់ ជាកន្លែងដែលគាត់តែងតែទុកបន្ទប់មួយសម្រាប់តែពួកគេ ។ ម៉ាម៉ា សេហ្វី មានកម្ពស់មិនដល់ប្រាំហ្វីតផង ( 1.5 ម. ) គាត់រកចំណូលសម្រាប់ចិញ្ចឹមជីវិតដោយការលក់ផ្លែឈើនៅផ្សារក្នុងក្រុងជុំវិញ អូហ្សូមបា ។ ក្រុងនីមួយៗ បើកផ្សារលក់តាមថ្ងៃផ្សេងៗគ្នា ហើយគាត់បានទៅផ្សារនីមួយៗដើម្បីលក់ផ្លែឈើ ។

គាត់បានមកការិយាល័យបេសកកម្មនាថ្ងៃនោះ ដោយមាននូវស្បោងម្សៅដ៏ធំមួយ ។ ក្នុងស្បោងនោះមានសុទ្ធតែ *tostones* ពេញ ដែលជាកាក់ប្រាក់កន្លះប៉េសូ ដែលគាត់បានសន្សំអស់ជាច្រើនឆ្នាំមកនោះ ។ ប្រាក់មួយចំណែកខ្លះ បានមកពីជំនាន់នៃ ព័រហ្វីរីយ៉ូ ឌីយ៉ាហ្ស ដែលបានគ្រប់គ្រងប្រទេសមិកស៊ិក ចាប់ពីឆ្នាំ 1884 ដល់ឆ្នាំ 1911 ។ ម៉ាម៉ា សេហ្វី បានធ្វើដំណើរមកពី អូហ្សូមបា ទៅផ្ទះបេសកកម្មតាមរថយន្តក្រុង ជាមួយនឹងស្បោងប្រាក់របស់គាត់ ។  គាត់បានប្រាប់ប្រធាន អារ៉វែល អិល. ភីស ថាគាត់បានសន្សំប្រាក់ជាច្រើនឆ្នាំមកហើយ ដើម្បីគាត់អាចធ្វើដំណើរទៅព្រះវិហារបរិសុទ្ធទីក្រុងសលត៍ លេក ដើម្បីទទួលពិធីអំណោយទានពិសិដ្ឋរបស់គាត់ ។

គាត់បានទទួលការអនុញ្ញាតឲ្យចាកចេញពីប្រទេស អ្នកផ្សព្វផ្សាយសាសនាម្នាក់បានឲ្យវ៉ាលីដល់គាត់ខ្ចី ហើយយើងបាននាំគាត់ទៅជិះរថភ្លើង ។ ប្រធាន ភីស បានទូរស័ព្ទទៅមនុស្សម្នាក់នៅ អ៊ែល ផាសូ រដ្ឋតិចសាស ដើម្បីទៅជួបគាត់ពេលរថភ្លើងឆ្លងកាត់ព្រំដែន ស.ហ.រ ហើយនាំ ម៉ាម៉ា សេហ្វី ឡើងជិះរថយន្តក្រុងទៅទីក្រុងសលត៍ លេក ។ សមាជិកនៃសាខាអេស្ប៉ាញជាច្រើន នៅទីក្រុងសលត៍ លេក បានទៅជួបគាត់នៅកន្លែងឡានក្រុង ហើយបានមើលថែពីតម្រូវការស្នាក់នៅរបស់គាត់ ហើយជួយគាត់នៅក្នុងព្រះវិហារបរិសុទ្ធ ។

ប៉ុន្មានសប្ដាហ៍ក្រោយមក ម៉ាម៉ា សេហ្វី បានត្រឡប់ទៅកាន់ទីក្រុង មិកស៊ិកវិញ រួចហើយត្រឡប់ទៅផ្ទះ នៅ អូហ្សូមបា ។ គាត់បានធ្វើដំណើរផ្លូវឆ្ងាយដោយសុវត្ថិភាព ។ បន្ទាប់មកគាត់បានទៅលក់ផ្លែឈើនៅផ្សារវិញ ។

ម៉ាម៉ា សេហ្វី ពុំចេះនិយាយភាសាអង់គ្លេសទេ ដូច្នេះយើងបានសួរគាត់ពីរបៀបដែលគាត់គ្រប់គ្រងក្នុងការបញ្ជាទិញអាហារ នៅពេលធ្វើដំណើរតាមឡានក្រុងពី អ៊ែល ផាសូ ទៅទីក្រុងសលត៍ លេក ដោយរបៀបណា—ជាការធ្វើដំណើរអស់ជាច្រើនថ្ងៃ ។ គាត់បាននិយាយថា មានមនុស្សម្នាក់បានបង្រៀនគាត់ឲ្យចេះនិយាយ « នំផ្លែប៉ោម » ជាភាសាអង់គ្លេស ដូច្នេះរាល់ពេលដែលឡានក្រុងឈប់សម្រាប់បរិភោគអាហារ គាត់នឹងទិញនំផ្លែប៉ោម ។

ដោយសារនោះជាភាសាអង់គ្លេសតែមួយម៉ាត់គត់ ដែលគាត់ចេះ នោះគាត់បានរស់នៅដោយបរិភោគនំផ្លែប៉ោម អំឡុងពេលធ្វើដំណើរតាមឡានក្រុងទាំងទៅ *និង*ទាំងមកវិញ ។ ប៉ុន្តែ ម៉ាម៉ា សេហ្វី ពុំខ្វល់នោះទេ ។ ប៉ុន្តែ គាត់បានត្រឡប់មកវិញដោយការដឹងគុណ ហើយពេញចិត្តនឹងបទពិសោធន៍របស់គាត់នៅក្នុងព្រះវិហារបរិសុទ្ធ ។ ■

ខេទី វ៉ែនធូរ៉ា រដ្ឋយូថាហ៍ ស.រ.អា



ម៉ាម៉ា សេហ្វី បានធ្វើដំណើរប្រហែលជា 43 ម៉ែល ( 70 គ.ម ) ទៅផ្ទះបេសកកម្ម ដោយជិះឡានក្រុង ជាមួយនឹងស្បោងប្រាក់របស់គាត់ ។

# ទៅជួសជុលម៉ាញ៉េរបស់គាត់

អ្នកជិតខាងរបស់យើង គឺជាអ្នកគ្រប់គ្រងយុវវ័យនៅព្រះវិហារក្នុងមូលដ្ឋានមួយ ហើយយុវវ័យនៃព្រះវិហាររបស់គាត់ បានមកសួរសុខទុក្ខគាត់ជាញឹកញាប់ ។ វាមិនមានអ្វីភ្ញាក់ផ្អើលទេ ដែលឃើញមានឡានជាច្រើនចតនៅខាងមុខផ្ទះរបស់គាត់ទាំងយប់ទាំងថ្ងៃនោះ ។

យុវវ័យមួយចំនួនទាំងនេះ ចាក់ម៉ាញ៉េឮខ្លាំងៗនៅក្នុងឡានរបស់ពួកគេគ្រប់ពេល ។ យើងអាចឮពួកគេមកពីចម្ងាយ ហើយនៅពេលពួកគេមកកាន់តែជិត នោះបង្អួចផ្ទះរបស់យើងរង្គើរហើយ ។ ជាញឹកញាប់ ភ្លេងខ្លាំងៗនឹងធ្វើឲ្យយើងភ្ញាក់ឡើងទាំងយប់ ។ ភាពធុញទ្រាន់របស់ខ្ញុំបានផ្ដុំច្រើនឡើងៗ ហើយខ្ញុំបានចាប់ផ្ដើមមើលទៅក្មេងៗទាំងនេះ ដូចជាសត្រូវរបស់ខ្ញុំ ។

មានថ្ងៃមួយ ខណៈដែលខ្ញុំកំពុងតែបោសស្លឹកឈើ ខ្ញុំបានឮសម្លេងម៉ាញ៉េឡានចាក់ខ្លាំងៗមកពីចម្ងាយ ។ មិនយូរប៉ុន្មានសម្លេងនោះបានមកកាន់តែជិត ហើយកាន់តែឮខ្លាំងឡើង ។ ពេលដែលអ្នកបើកឡានបត់ឡានត្រង់កាច់ជ្រុង ចូលមកផ្ទះអ្នកជិតខាងខ្ញុំ នោះខ្ញុំខឹង ហើយខ្ញុំបានអធិស្ឋានសុំឲ្យព្រះវរបិតាសួគ៌ បំផ្លាញម៉ាញ៉េនោះ ។

ការអធិស្ឋានយ៉ាងខ្លាំងរបស់ខ្ញុំ បានក្លាយទៅជាការអធិស្ឋានសរសើរ និងដឹងគុណវិញ នៅពេលដែលម៉ាញ៉េនោះឈប់ឮនៅរំពេចដែលគាត់នោះបើកឡានចូលមក ។ ខ្ញុំធ្លាប់ជួសជុលម៉ាញ៉េឡាន ហើយដឹងថា តាមរយៈសម្លេងនោះ ដែលវាពុំត្រូវបានគេបិទ— នោះវានឹងឈប់ដើរ ។

យុវជននោះ ខកចិត្តដែលម៉ាញ៉េឡានគាត់ បានឈប់ដើរ ហើយមិត្តគាត់ជាច្រើនបានមកលួងលោមចិត្តគាត់ ។ ផ្ទុយទៅវិញ ខ្ញុំមានអារម្មណ៍ពេញចិត្តណាស់ ពេលឃើញនូវអ្វីដែលខ្ញុំបានគិតថា គឺជាព្រះហស្តរបស់ព្រះដែលធ្វើឲ្យម៉ាញ៉េនោះឈប់ដើរ ។

**ខ្ញុំមានអារម្មណ៍ពេញចិត្តណាស់ ពេលឃើញនូវអ្វីដែលខ្ញុំបានគិតថា គឺជាព្រះហស្តរបស់ព្រះដែលធ្វើឲ្យម៉ាញ៉េរបស់យុវជននោះឈប់ដើរ ។**



ប៉ុន្តែនៅពេលខ្ញុំបន្តមើលហេតុការណ៍នោះ ខ្ញុំបានដឹងថា ខ្ញុំកំពុងមើលខ្លួនខ្ញុំ ពេលខ្ញុំមានចារិកដូច្នោះកាលពីច្រើនឆ្នាំកន្លងទៅ ។ ដួងចិត្តខ្ញុំបានទន់ភ្លន់វិញ ហើយខ្ញុំបានចាប់ផ្ដើមគិតថា ក្មេងប្រុសនេះពុំមែនជាសត្រូវរបស់ខ្ញុំទេ ។ បន្ទាប់មកព្រះវិញ្ញាណបានខ្សឹបប្រាប់ថា « ចូរទៅជួសជុលម៉ាញ៉េរបស់គាត់ទៅ » ។

ខ្ញុំបានភ្ញាក់ផ្អើលដោយការបំផុសគំនិតនេះ ហើយព្យាយាមមិនគិតពីវា ។ ហេតុអ្វីក៏ខ្ញុំគួរទៅជួសជុលអ្វីដែលកំពុងតែធ្វើឲ្យជីវិតរបស់ខ្ញុំពុំសុខស្រួលនោះ ? ប៉ុន្តែការបំផុសគំនិតបានកើតមានឡើងម្ដងទៀត ហើយខ្ញុំបានធ្វើតាម ។

បន្ទាប់ពីខ្ញុំបានសុំជួយហើយ រំពេចនោះខ្ញុំបានមើលឃើញប្រភពនៃបញ្ហា ។ ជួសជុលតែមួយភ្លែត ។ មិនយូរប៉ុន្មាន ម៉ាញ៉េបានចាក់ឮម្ដងទៀតឮខ្លាំងដូចពីដើម ។

យុវជននោះ បានថ្លែងអំណរគុណ ហើយបានសួរ បើសិនជាមានអ្វីដែលគាត់អាចធ្វើសម្រាប់ខ្ញុំវិញ ។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំត្រូវក្រោកពីព្រលឹមទៅធ្វើការ ហើយបើគាត់អាចបិទសម្លេងភ្លេងរបស់គាត់បន្តិចនៅពេលល្ងាច នោះខ្ញុំពិតជាមានអំណរគុណណាស់ ។ គាត់ញញឹម ហើយអះអាងនឹងខ្ញុំថាគាត់នឹងធ្វើដូច្នោះបាន ។

គាត់មិនត្រឹមតែបន្ថយសម្លេងម៉ាញ៉េរបស់គាត់នៅពេលយប់ប៉ុណ្ណោះទេ គឺគាត់ថែមទាំងបានក្លាយជាប៉ូលីសការពារសម្លេងម៉ាញ៉េរបស់ខ្ញុំ ដែលគាត់ត្រូវមើលឲ្យប្រាដកថា សម្លេងម៉ាញ៉េរបស់មិត្តភិក្តគាត់ត្រូវបន្ថយសម្លេងផងដែរ ។ ចាប់ពីពេលនោះមក យើងពុំដែលមានបញ្ហានឹងតន្ត្រីឮខ្លាំងៗពេលយប់ទៀតទេ ។

ព្រះវរបិតាសួគ៌ ពិតជាបានស្ដាប់ឮ ហើយឆ្លើយការអធិស្ឋានរបស់ខ្ញុំមែន ។ ដំណោះស្រាយរបស់ទ្រង់ ផ្ដល់នូវភាពសុខសាន្ត និង ភាពស្ងប់ស្ងាត់ ជាមេរៀនដ៏មានតម្លៃមួយ អំពីការធ្វើតាមព្រះវិញ្ញាណ ហើយជាការយល់ដឹងដ៏ល្អប្រសើរមួយអំពីអ្វីដែលមានន័យថា « ឲ្យស្រឡាញ់ខ្មាំងសត្រូវរបស់អ្នក » ( លូកា 6:27 ) ។ ■

ខេន អេ. រ៉ាសិល, រដ្ឋហ្វ្លរីដា, ស.រ.អា

# សួស្ដី កូនចៀមតូច

ស្វាមីរបស់ខ្ញុំ និងខ្ញុំ បានជួយកូនស្រីរបស់យើង និងកូនប្រុសពីរនាក់របស់នាងទៅព្រលានយន្តហោះ ជាកន្លែងដែលពួកគេរៀបចំធ្វើដំណើរត្រឡប់ទៅផ្ទះវិញ ។ យើងបានជួយកូនស្រីរបស់យើង នៅពេលនាងរាប់មើលវ៉ាលី ដាក់លិខិតឆ្លងដែន និងមើលកូនរពឹសអាយុបីឆ្នាំម្នាក់ ។ ថមមី ចៅប្រុសអាយុមួយខួបរបស់យើង គេងលក់នៅក្នុងរទេះរុញរបស់គាត់ ទាល់តែយើងដាស់គាត់ឲ្យភ្ញាក់ឡើង ។ គាត់ភ័យស្លន់ នៅពេលគាត់សម្របខ្លួនទៅនឹងសម្លេង ពន្លឺភ្លើងភ្លឺៗ និង ភាពអ៊ូអរនោះ ។

ខ្ញុំបានឃើញនូវទឹកមុខរបស់គាត់ ហើយបានដឹងនូវអ្វីដែលហៀបនឹងកើតឡើង ដូច្នេះខ្ញុំបានស្រែកប្រាប់កូនស្រីរបស់ខ្ញុំ ។ នាងបានមកជាប្រញាប់ដាក់បាតដៃនាងផ្ទប់មុខថមមី ហើយមើលសម្លឹងទៅចំគាត់ រួចនិយាយដោយក្ដីស្រឡាញ់ថា « សួស្ដី កូនចៀមតូច » ។

ភ្លាមនោះ គាត់ឈប់ជ្រួញចិញ្ចើម ឈប់ស្រែក ហើយឈប់ចំកោងខ្លួន ដែលរាងកាយទាំងមូលឲ្យសញ្ញាថា ធុញទ្រាន់ហើយ ។ គាត់បានញញឹមមុនពេលបិទភ្នែកគេងទៅវិញ ។ ភាពភ័យខ្លាចរបស់គាត់បានជំនួសដោយការអះអាងដ៏ស្ងប់ស្ងាត់ ហើយសេចក្ដីសុខសាន្តបានគ្រប់ដណ្ដប់លើគាត់ ។ វាជារឿងតូចមួយ ប៉ុន្តែជាការសម្ដែងឲ្យឃើញប្រកបដោយអានុភាពអំពីការទុកចិត្តរបស់ ថមមី ទៅលើម្ដាយរបស់គាត់ ។ ការប៉ះ សម្លេង និង វត្តមានរបស់នាង បានជួយលួងលោមគាត់ ។

ដូចជា ថមមី យើងទាំងអស់គ្នាមានអារម្មណ៍ភ័យខ្លាច មិនពិតប្រាកដ ហើយច្របូកច្របល់ ។ វាជាការលួងលោមចិត្ត ពេលដឹងថា ព្រះយេស៊ូវគ្រីស្ទ ជាអ្នកគង្វាលល្អ ស្រែកហៅរកយើង ។ ទ្រង់ស្គាល់ហ្វូងរបស់ទ្រង់ ហើយយើងអាចទុកចិត្តលើទ្រង់ទាំងស្រុងបាន ។ ទ្រង់មានបន្ទូលដោយក្ដីស្រឡាញ់ថា « ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្ដីសុខសាន្តរបស់ខ្ញុំដល់អ្នក ។. . . កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភ ឬភ័យឡើយ » ( យ៉ូហាន 14:27 ) ។

ខ្ញុំដឹងថា អំឡុងពេលនៃភាពមិនពិតប្រាកដ នោះយើងអាចទទួលបានការលួងលោមចិត្ត និង ការអះអាង នៅពេលយើងងាកបែរទៅរកអ្នកគង្វាលល្អ ដោយក្ដីជំនឿ និង ការទុកចិត្ត ។ នៅពេលខ្ញុំទទួលបាននូវពរដោយការលួងលោមនៅក្នុងកណ្ដាលនៃភាពអ៊ូអែ នោះខ្ញុំចូលចិត្តគិតអំពីគ្រាដែលនៅព្រលានយន្តហោះជាមួយនឹងកូនស្រី និង ចៅប្រុសរបស់ខ្ញុំ ។ ដូចជា ថមមី ខ្ញុំអាចដកដង្ហើមរសាយ នៅពេលបន្ទុករបស់ខ្ញុំត្រូវបានលើកចេញ ។ អំឡុងពេលនោះ ខ្ញុំមានអារម្មណ៍ផ្ទាល់មួយថា « សួស្ដី កូនចៀមតូច » មកពីអ្នកគង្វាលរបស់ខ្ញុំ ។ ■

ខូលីន សូឡូម៉ូន ទីក្រុងអុនតារីយ៉ូ ប្រទេសកាណាដា

ចៅប្រុសអាយុមួយខួបរបស់យើង ភ័យស្លន់ នៅពេលគាត់សម្របខ្លួនទៅនឹងសម្លេង ពន្លឺភ្លើងភ្លឺៗ និង ភាពអ៊ូអរនោះ នៅព្រលានយន្តហោះ ។



# ការស៊ូទ្រាំ **បានល្អ**

**ដោយអែលឌើរ ជេ. គ្រីស្តូហ្វើរ ឡានសឹង**
ពួកចិតសិបនាក់ប្រចាំតំបន់ តំបន់ប៉ែក
ឥសាន្តនៃអាមេរិកខាងជើង

ផែនការនៃសេចក្តីសង្គ្រោះ គឺជាផែនការដ៏អស្ចារ្យមួយ ហើយចំណែកនៃផែនការនោះ រួមមានការយកឈ្នះលើឧបសគ្គទាំងឡាយ ដែលពេលខ្លះមករារាំង និង ឃាត់ឃាំងយើងមិនឲ្យសម្រេចបាននូវក្តីសង្ឃឹម និង សុបិនរបស់យើង ។ យើងទាំងអស់គ្នាជួបនូវវិបត្តិជាច្រើនអំឡុងពេលជីវិតយើងនៅលើផែនដី ។ វិបត្តិខ្លះតូច ហើយវិបត្តិខ្លះធំ ។

វិបត្តិតូចមួយ អាចជាការអស់សាំងនៅលើដងផ្លូវមួយ ដែលមានចរាចរណ៍ដ៏ចង្អៀត ។ វិបត្តិដ៏ធំនោះ អាចជាការបាត់បង់មនុស្សជាទីស្រឡាញ់ ឧប្បទ្ទវហេតុធ្វើឲ្យពិការ ឬ សោកនាដកម្មក្នុងគ្រួសារ ។ វិបត្តិខ្លះទៀត យើងធ្វើឲ្យមានដោយខ្លួនឯង តាមរយៈការមិនគោរពប្រតិបត្តិចំពោះក្រិត្យវិន័យរបស់ព្រះ ឬ ច្បាប់មនុស្សជាតិ ។ វិបត្តិមួយចំនួនទៀតកើតមានមកលើយើង ដោយយើងគ្មានកំហុសអ្វីសោះ ។ ខ្ញុំគិតថា យើងភាគច្រើនជួបបទពិសោធន៍នូវអ្វីដែលអាចនឹងនិយាយថាជា « រឿងអកុសល » នៃជីវិត ។ នរណាដែលធ្លាប់លេងល្បែងមួយ ដែលមានបាល់មួយ ដែលបោកលោតយ៉ាងខ្លាំង ។ វាជាផ្នែកនៃល្បែង ។ ពួកគេពុំរំពឹងអំពីទំហំ ឬ ភាពញឹកញាប់ទេ ។

អ្នកលេងល្អ បានដឹងថា រឿងអកុសល គឺជាចំណែកមួយនៃជីវិត ហើយព្យាយាមដើម្បីបន្តរស់នៅដោយក្តីជំនឿ និងភាពក្លាហាន ។ ដើម្បីស្មោះត្រង់ចំពោះបំណងប្រាថ្នារបស់យើង ដើម្បីរស់នៅជាមួយព្រះវរបិតាសួគ៌ម្តងទៀត នោះយើងត្រូវតែរកវិធីមួយដើម្បីឆ្លងកាត់ឧបសគ្គទាំងឡាយ ហើយរកឲ្យឃើញនូវអ្វីដែលសំខាន់ពិតនៅក្នុងជីវិត ។

**យើងពុំគួររំពឹងឲ្យព្រះអម្ចាស់ដកឧបសគ្គនានារបស់យើងចេញ ដោយគ្រាន់តែយើងសន្យានឹងទ្រង់ថា យើងនឹងនៅស្មោះត្រង់ជានិច្ច បើទ្រង់ធ្វើនោះទេ ។ ប៉ុន្តែ យើងត្រូវស៊ូទ្រាំឲ្យបានល្អ រួចហើយយើងនឹងបានទទួលពរ ។**

**គ្រាន់តែបន្តហែលទឹក**

នៅពេលកូនស្រីតែម្នាក់គត់របស់យើង លីនសី នៅក្មេង នោះនាង និង ខ្ញុំចូលចិត្តមើលខ្សែភាពយន្តជាមួយគ្នា ។ រឿងមួយ ដែលយើងចូលចិត្តមើលជាមួយគ្នាជាច្រើនដង គឺរឿងតុក្កតាដែលមានចំណងជើងថា *Finding Nemo* ( *ការស្វែងរកនីម៉ូ* ) ។ នៅក្នុងខ្សែភាពយន្ត នីម៉ូ ត្រូវបានចាប់ដោយអ្នកមុជទឹកម្នាក់ ហើយទីបំផុតទៅរស់នៅក្នុងអាងត្រីមួយ ក្នុងការិយាល័យរបស់ពេទ្យធ្មេញម្នាក់ ។ ឪពុករបស់វា ម៉ើរលីន បានតាំងចិត្តទៅរក នីម៉ូ ។ ម៉ើរលីន បានជួបនឹងត្រីមួយក្បាលឈ្មោះ ដូរី អំឡុងពេលវាធ្វើដំណើរ ។ ពួកវាបានជួបនឹងឧបសគ្គមួយហើយមួយទៀត នៅពេលពួកវាព្យាយាមស្វែងរក នីម៉ូ ។ មិនថាឧបសគ្គនោះធំ ឬ តូចទេ សាររបស់ដូរី ទៅដល់ ម៉ើរលីន គឺដដែលថា ៖ « គ្រាន់តែបន្តហែលទឹកទៅ » ។

ជាច្រើនឆ្នាំក្រោយមក លីនសី បានបម្រើបេសកកម្មមួយនៅសានទីអាហ្គូ ប្រទេសឈីលី ។ បេសកកម្មនោះពិបាក ។ មានការខកចិត្តជាច្រើន ។ រាល់សប្តាហ៍នៅចុងបញ្ចប់នៃអ៊ីម៉ែលរបស់ខ្ញុំ ខ្ញុំបានសរសេរថា « គ្រាន់តែបន្តហែលទឹកទៅ » ។ ដោយក្តីស្រឡាញ់ពី ឪពុក » ។

រូបភាពយកពី Photodisc/Thinkstock



នៅពេល លីនសី មានផ្ទៃពោះកូនទីពីររបស់នាង នាងបានដឹងថា ទារកក្នុងផ្ទៃរបស់នាង មានប្រហោងក្នុងបេះដូង ហើយថា ទារកនោះមានជំងឺមិនគ្រប់លក្ខណៈ ។ នៅពេលខ្ញុំសរសេរអ៊ីម៉ែលទៅនាង ក្នុងពេលដ៏ពិបាកនេះ ខ្ញុំបានបញ្ចប់ក្នុងអ៊ីម៉ែលខ្ញុំនូវពាក្យ « គ្រាន់តែបន្តហែលទឹកទៅ » ។

ឧបសគ្គជាច្រើនចូលមកក្នុងជីវិតរបស់យើងម្នាក់ៗ ប៉ុន្តែដើម្បីឆ្លងកាត់វាបាន ហើយទៅដល់កន្លែងដែលយើងចង់ទៅ នោះយើងត្រូវតែបន្តហែលទឹក ។

វគ្គបទគម្ពីរដែលខ្ញុំចូលចិត្តមួយ គឺនៅកណ្ឌ 121 នៃគោលលទ្ធិ និង សេចក្ដីសញ្ញា ។ វាមាននូវសារដ៏អស្ចារ្យមួយ ដែលព្យាការីយ៉ូសែប ស្ម៊ីធ ចាប់ផ្ដើមនៅក្នុងជម្រៅនៃភាពអស់សង្ឃឹម ហើយក្រោកឡើងទៅដល់ស្ថានសេលេស្ទាលដ៏ខ្ពស់ ។ កណ្ឌនេះ និងកណ្ឌ 122 និង 123 ចេញមកពីសំបុត្រមួយ ដែលយ៉ូសែប បានសរសេរទៅកាន់សាសនាចក្រ ។ ដើម្បីយល់ឲ្យបានកាន់តែប្រសើរនូវវិវរណៈដ៏អស្ចារ្យទាំងនេះ យើងគួរតែដាក់វាតាមបរិបទត្រឹមត្រូវ ។

យ៉ូសែប និងអ្នកដើរតាមលោកមួយចំនួន ត្រូវបានជាប់ឃុំនៅក្នុងគុកនៅលីបឺធី រដ្ឋមីសសួរី ចាប់ពីខែធ្នូ ឆ្នាំ 1838 រហូតដល់ខែមេសា ឆ្នាំ 1839 ។ គុកគ្មានកំដៅទេ ហើយអាហារ គឺស្ទើរតែបរិភោគពុំបាន ។ ពួកលោក ជាប់នៅក្នុងគុកក្រោមដី ដែលមានកម្រាលខាងក្រោមជាដី ហើយពិដានទាបយ៉ាងខ្លាំង ដែលពួកលោកពុំអាចឈរមួយជំហរបានទេ ។ នៅគ្រានោះ ពួកបរិសុទ្ធ ត្រូវគេបណ្ដេញចេញពីផ្ទះ ។ នៅក្នុងចំណោមភាពចលាចលនេះ អភិបាលលីលប៊ើន ដបុលយូ ប័ហ្គ បានចេញបញ្ជាដ៏ព្រៃផ្សៃរបស់គាត់ ។

យ៉ូសែប បានសួរថា « ឱ ព្រះអង្គអើយ តើព្រះអង្គគង់នៅទីណា ? ហើយតើព្រះពន្លា ដែលគ្របបាំងទីបំពួនទ្រង់នៅទីណា ? ( គ. និង ស. 121:1 ) ។ យ៉ូសែប ស្ម៊ីធដដែលនេះ ត្រូវបានព្រះជាព្រះវរបិតា ព្រះយេស៊ូវគ្រីស្ទ ម៉ូរ៉ូណៃ យ៉ូហានបាទីស្ទ ពេត្រុស យ៉ាកុប និង យ៉ូហាន និង អ្នកដទៃទៀតពីស្ថានសួគ៌ យាងមកជួប ។ មិនយូរប៉ុន្មាន បន្ទាប់ពីសំណួររបស់លោកនៅក្នុងខដំបូង នោះយ៉ូសែបបានបង្ហាញនូវភាពមួរម៉ៅរបស់លោកថា ៖

« សូមឲ្យសេចក្ដីខ្ញាល់របស់ទ្រង់ឆួលឡើងទាស់នឹងពួកខ្មាំងសត្រូវរបស់ពួកទូលបង្គំ ហើយនៅក្នុងសេចក្ដីឃោរឃៅនៃព្រះហឫទ័យរបស់ទ្រង់ សូមព្រះអង្គសងសឹកដោយដាវរបស់ទ្រង់ពីការអយុត្តិធម៌ទាំងឡាយឲ្យពួកទូលបង្គំផងចុះ ។

សូមនឹកចាំដល់ពួកបរិសុទ្ធរបស់ទ្រង់ដែលមានទុក្ខលំបាក ឱព្រះរបស់ទូលបង្គំអើយ ហើយពួកអ្នកបម្រើរបស់ទ្រង់នឹងត្រេកអរចំពោះព្រះនាមរបស់ទ្រង់ជារៀងដរាបតទៅ » ( ខ 5–6 ) ។

ព្រះអម្ចាស់បានឆ្លើយតបចំពោះការទូលរបស់យ៉ូសែប ដោយនិយាយថា « បុត្រយើងអើយ ចូរមានសេចក្ដីសុខសាន្តដល់ព្រលឹងបុត្រចុះ សេចក្ដីជំនាស់ និងសេចក្ដីទុក្ខលំបាករបស់អ្នក នោះគ្រាន់តែមួយភ្លែតប៉ុណ្ណោះទេ » ( ខ 7 ) ។

បន្ទាប់មកទ្រង់បានបង្រៀនដល់យ៉ូសែប នូវគោលការណ៍ដ៏អស្ចារ្យមួយថា ៖ « ហើយខណៈនោះ បើសិនជាអ្នកស៊ូទ្រាំការណ៍នោះដោយហ្មត់ចត់ នោះព្រះទ្រង់នឹងដំកើងអ្នកឡើងនៅស្ថានខ្ពស់ អ្នកនឹងបានជ័យជំនះលើពួកខ្មាំងសត្រូវរបស់អ្នកទាំងអស់ » (  ខ 8 ) ។

សារលិខិតគឺថ្លែងចំៗ ហើយច្បាស់ៗ ។ យើងពុំគួររំពឹងឲ្យព្រះអម្ចាស់ដកឧបសគ្គរបស់យើងចេញ ដោយគ្រាន់តែសន្យានឹងទ្រង់ថា យើងនឹងនៅស្មោះត្រង់ជានិច្ច បើទ្រង់ធ្វើនោះឡើយ ។ ផ្ទុយទៅវិញ បើយើងស៊ូទ្រាំបានល្អ នោះយើងនឹងបានទទួលពរជ័យ។ នោះគឺជាមេរៀនជីវិតដ៏អស្ចារ្យមួយ សម្រាប់យើងម្នាក់ៗ ។

ការណែនាំបន្ថែមទៀត បានមកនៅក្នុងខ. 10 ត្រង់កន្លែងដែលព្រះអម្ចាស់ប្រាប់យ៉ូសែបថា « អ្នកពុំទាន់បានដូចយ៉ូបទេ មិត្តភក្ដិទាំងឡាយរបស់អ្នក ពុំបានទាស់នឹងអ្នក ឬចោទប្រកាន់ថា អ្នកប្រព្រឹត្តអំពើរំលង ដូចជាពួកគេបានធ្វើដល់យ៉ូបនោះទេ » ។ ទោះជាយ៉ូប បានរងទុក្ខប៉ុណ្ណាក៏ដោយ ក៏យើងបានរៀនដឹងថា « កូនមនុស្សបានចុះទាបជាងការណ៍ទាំងនោះទៅទៀត ។ តើអ្នកធំជាងទ្រង់ឬអី ? ( គ. និង ស. 122:8 ) ។

កណ្ឌ 122 បន្ថែមពីលើកណ្ឌ 121 ។ ខ្ញុំហៅវាថាកណ្ឌ *បើសិន* ។ ពាក្យ *បើសិន* លេចឡើងចំនួន 15 ដង ។ ឧទាហរណ៍ ខប្រាំបាននិយាយថា « *បើសិនជា*អ្នកត្រូវបានហៅឲ្យឆ្លងកាត់សេចក្ដីវេទនា*បើសិនជា*អ្នកមានគ្រោះនៅក្នុងចំណោមពួកបងប្អូនក្លែងក្លាយអ្នកក្នុងសាសនាចក្រ*បើសិនជា*អ្នកមានគ្រោះនៅក្នុងចំណោមពួកចោរប្លន់*បើសិនជា*អ្នកមានគ្រោះដោយដី ឬដោយទឹក » ( គ និងស 122:5 ការគូសបញ្ជាក់បន្ថែម ) ។

បើយើងជំនួសឧបសគ្គទាំងនោះ មកឧបសគ្គដែលយើងជួបនៅ ក្នុងពិភពលោកបច្ចុប្បន្ន ប្រហែលជាយើងអាចរៀនអ្វីមួយ ដូចជា *បើសិនជា* ខ្ញុំមានសេចក្ដីស្លាប់ក្នុងគ្រួសារខ្ញុំ ឬ *បើសិនជា* មិត្តប្រុស ឬ មិត្តស្រីរបស់ខ្ញុំទាត់ខ្ញុំចោល ឬ *បើសិនជា* ខ្ញុំមានបន្ទុកខាងហិរញ្ញវត្ថុ ឬ *បើសិនជា* ខ្ញុំធ្លាតជាងនេះ ។

បន្ទាប់ពីពាក្យ *បើសិនជា* ទាំងនេះ ព្រះអម្ចាស់បានមានបន្ទូលថា « បុត្រា [ ឬបុត្រី ]យើងអើយ ចូរអ្នកដឹងថា គ្រប់ការណ៍ទាំងនេះ នឹងផ្ដល់ការពិសោធន៍ដល់អ្នក ហើយនឹងទៅជាការល្អដល់អ្នកទៅវិញ » ( ខ 7 ) ។ ម្យ៉ាងទៀត ឧបសគ្គទាំងឡាយដែលយើងមានក្នុងជីវិត គឺជាប្រយោជន៍ និងសំខាន់ណាស់នៅទីបំផុត ។

ព្យាការីសរសេរថា « ហេតុដូច្នេះហើយ បងប្អូនដ៏ស្ងួនភ្ងាអើយ ចូរយើងប្រព្រឹត្តការណ៍ទាំងនេះ ដែលនៅក្នុង អំណាចយើងដោយមានចិត្តរីករាយចុះ ហើយលំដាប់នោះ យើងអាចឈរនៅស្ងៀមដោយជឿ ជាក់ថានឹងបានឃើញសេចក្ដីសង្គ្រោះពីព្រះ និងបានព្រះពាហុទ្រង់បើកសម្ដែងមកឲ្យឃើញ » ( គ.និងស. 123:17 )។

ជីវិតគឺពោរពេញដោយឧបសគ្គ ហើយឧបសគ្គមួយចំនួនហាក់ដូចជាពុំអាចជំនះបាននោះទេ ។ យើងត្រូវស៊ូទ្រាំវាដោយរីករាយ និងស្មោះត្រង់ ។ តាមរយៈការធ្វើដូច្នោះ នោះយើងនឹងត្រឡប់ទៅរស់នៅជាមួយព្រះជារៀងរហូតយ៉ាងពិតប្រាកដ ។

**គំរូរបស់ព្រះអង្គសង្គ្រោះ**

គំរូដ៏មហិមាបំផុត ដែលយើងមានអំពីការស៊ូទ្រាំ គឺជីវិតរបស់ព្រះអង្គសង្គ្រោះ ។ ដង្វាយធួនតម្រូវថា ទ្រង់ បានចុះទាបជាងការណ៍ទាំងនោះ

ទៅទៀត ហើយផ្តល់នូវជីវិតដ៏ឥតខ្ចោះរបស់ទ្រង់ជំនួសយើង ។ ដោយចុះទាបជាងការណ៍ទាំងនោះ ទ្រង់បានរងទុក្ខសម្រាប់ភាពសោកសៅ និង អំពើបាបនៃជីវិតទាំងអស់ « ដែលបណ្ដាលឲ្យយើងគឺជាព្រះដែលមហិមាលើសអ្វីៗទាំងអស់ ត្រូវញ័រដោយសារតែការឈឺចាប់ ហើយត្រូវច្រួចលោហិតចេញពីគ្រប់រន្ធញើស ហើយត្រូវរងទុក្ខព្រមទាំងរូបកាយ និង វិញ្ញាណផង » ( គ. និង ស. 19:18 ) ។

ព្រះយេស៊ូវជ្រាបនូវអ្វីដែលតម្រូវពីទ្រង់ ហើយទ្រង់មានបន្ទូលតាមរបៀបមនុស្សថា « ឱព្រះវរបិតានៃទូលបង្គំអើយ បើសិនជាបាន នោះសូមឲ្យពែងនេះកន្លងហួសពីទូលបង្គំទៅ » ( ម៉ាថាយ 26:39 ) ។ ទោះជាដូច្នោះក្ដី ទ្រង់ស្ម័គ្រព្រះទ័យដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាទ្រង់ ហើយស៊ូទ្រាំនូវរឿងទាំងអស់ ។

**អ្វីដែលយើងប្រែក្លាយ ធ្វើឲ្យមានភាពខុសប្លែកគ្នាទាំងស្រុង**

អាជីវកម្មដែលខ្ញុំមានសព្វថ្ងៃនេះ គឺបានបង្កើតឡើងដោយឪពុករបស់ខ្ញុំកាលពីជិត 60 ឆ្នាំកន្លងទៅ ។ គាត់ទទួលមរណភាពនៅឆ្នាំ 1980 បានបន្សល់ឲ្យខ្ញុំដឹកនាំក្រុមហ៊ុនពីវ័យក្មេងនៃអាយុ 30 ឆ្នាំ ។

នៅកាលវ័យនោះ ស្ថានភាពជាច្រើនបានកើតឡើង ដែលតម្រូវឲ្យខ្ញុំធ្វើការសម្រេចចិត្តជាច្រើនដែលជះឥទ្ធិពលដល់អនាគតនៃអាជីវកម្មទន់ខ្សោយរបស់យើង ។ ខ្ញុំបានធ្វើការយ៉ាងខ្លាំងដើម្បីធ្វើឲ្យដូចជាឪពុករបស់ខ្ញុំ ដែលគាត់បានធ្វើ ហើយខ្ញុំបានចំណាយពេលយ៉ាងច្រើន លុតជង្គង់ចុះ ព្យាយាមដើម្បីដឹងនូវអ្វីដែលត្រូវធ្វើ ។ នៅក្នុងការសម្រេចចិត្តទាំងនោះ ខ្ញុំពុំដែលមានអារម្មណ៍អានុភាពដ៏ស្ងប់ស្ងាត់ ឬការដឹកនាំអ្វីនោះទេ ។ ទីបំផុត ខ្ញុំបានធ្វើនូវអ្វីដែលខ្ញុំគិតថាល្អបំផុត ហើយដើរឆ្ពោះទៅមុខ ។ ប៉ុន្តែខ្ញុំខកចិត្ត ខ្ញុំពុំអាចទទួលបាននូវការបញ្ជាក់ណាមួយចំពោះសកម្មភាពរបស់ខ្ញុំទេ ។

មានយប់មួយ ឪពុករបស់ខ្ញុំបានមករកខ្ញុំនៅក្នុងសុបិនមួយ ។ ខ្ញុំបានចាប់ផ្ដើមបន្ទោសគាត់ ដែលពុំជួយឲ្យខ្ញុំដឹងនូវអ្វីដែលត្រូវធ្វើ ។ គាត់បានមានប្រសាសន៍ថា គាត់បានដឹងជាមុនអំពីស្ថានភាពរបស់ខ្ញុំ ប៉ុន្តែគាត់រវល់នៅកន្លែងដែលគាត់នៅនោះ ហើយអាជីវកម្មមុនរបស់គាត់គឺពុំសំខាន់ប៉ុន្មាននោះទេ ។ គាត់មានប្រសាសន៍ថា « គ្រីស្ទ យើងពុំខ្វល់អំពីអាជីវកម្មនៅទីនេះទេ » ។ « អ្វីដែលយើងខ្វល់យ៉ាងខ្លាំងនោះគឺអ្វីដែលកូនត្រូវប្រែក្លាយ ដោយសារតែអាជីវកម្មរបស់កូននោះ » ។



ដើម្បីនៅស្មោះត្រង់ចំពោះបំណងប្រាថ្នារបស់យើងដើម្បីរស់នៅជាមួយព្រះវរបិតាសួគ៌ម្ដងទៀត នោះយើងត្រូវតែស្វែងរកផ្លូវមួយដើម្បីធ្វើការឆ្លងកាត់ឧបសគ្គទាំងឡាយ ហើយរកឲ្យឃើញនូវអ្វីដែលសំខាន់ពិតប្រាកដនៅក្នុងជីវិត ។

នោះជាមេរៀនដ៏អស្ចារ្យមួយ ដែលខ្ញុំមិនអាចបំភ្លេចបាន ។ អ្វីដែលយើងទទួលបាន អំឡុងពេលជីវិតរបស់យើង គឺមិនសំខាន់ទេ ប៉ុន្តែអ្វីដែលយើងប្រែក្លាយនៅក្នុងជីវិតនេះ ធ្វើឲ្យមានភាពខុសប្លែកទាំងស្រុង ។

ពេលខ្លះ យើងភ្លេចថា នៅក្នុងជីវិតមុនជីវិតនេះ យើងបានច្បាំងការពារផែនការរបស់ព្រះវរបិតាអំពីសិទ្ធិជ្រើសរើសខាងសីលធម៌នៅក្បែរព្រះអង្គសង្គ្រោះ ។ ហើយយើងបានឈ្នះ ! លូស៊ីហ្វើរ និង អ្នកដើរតាមរបស់វា ត្រូវបានបណ្ដេញចេញ ហើយយើងបានទទួលឱកាសដើម្បីមានពិសោធន៍នូវជីវិតដែលយើងបានច្បាំងការពារនោះ ។ ផែនការរបស់ព្រះវរបិតា មានបញ្ចូលនូវដង្វាយធួន ។ កិច្ចការរបស់យើង គឺត្រូវប្រឈមមុខនឹងឧបសគ្គរបស់យើង ហើយស៊ូទ្រាំវាឲ្យបានល្អ ។ នៅពេលយើងធ្វើដូច្នេះ នោះដង្វាយធួន មានអត្ថន័យក្នុងជីវិតរបស់យើង ហើយយើងបំពេញកិច្ចការនិងសិរីល្អរបស់ព្រះអម្ចាស់ថា ៖ « ដើម្បីនាំឲ្យមានអមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ( ម៉ូសេ 1:39 ) ។

ខ្ញុំថ្លែងជាសាក្សីថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។ ទ្រង់គឺជាព្រះអង្គសង្គ្រោះនៃពិភពលោក ។ ទ្រង់គឺជាម្ចាស់នៃមេត្រីភាព និងជាអង្គគាំទ្ររបស់យើងជាមួយព្រះវរបិតា ។ ខ្ញុំថ្លែងជាសាក្សីថា ព្រះវរបិតាស្គាល់យើងតាមឈ្មោះ ស្រឡាញ់យើងដោយមិនគិតអំពីភាពពុំឥតខ្ចោះរបស់យើង ហើយនឹងរៀបចំកន្លែងមួយសម្រាប់យើង បើសិនជាយើងស្មោះត្រង់ ហើយស៊ូទ្រាំដល់ទីបំផុត ។ ■

*ចេញមកពីប្រសាសន៍មួយក្នុងការប្រជុំធម្មនិដ្ឋាន « That’s Life » ដែលបានផ្ដល់ឲ្យនៅ BYU–Hawaii នៅថ្ងៃទី 30 ខែតុលា ឆ្នាំ 30, 2012 ។ សម្រាប់អត្ថបទទាំងស្រុងជាភាសាអង់គ្លេស សូមចូលទៅកាន់ devotional.byuh.edu/archive ។*



ដោយ ប្រធាន
ហិនរី ប៊ី. អាវរិង
ទីប្រឹក្សាទីមួយក្នុង
គណៈប្រធានទីមួយ

# ការរៀបចំ អំណោយ សម្រាប់ គ្រួសារនាពេលអនាគត របស់អ្នក

*ឆ្នាំនេះ សូមចាប់ផ្ដើមបង្កើតអំណោយមួយចំនួន—អំណោយដ៏អស្ចារ្យ—សម្រាប់គ្រួសារនាពេលអនាគតរបស់អ្នក ។*





ខ្ញុំតែងតែប្រមែធ្វើជាអ្នកផ្ដល់អំណោយដ៏អស្ចារ្យម្នាក់ ។ ខ្ញុំនឹកស្រមៃអំពីមនុស្សដែលបើកអំណោយខ្ញុំ ហើយបង្ហាញក្ដីអំណរទាំងស្រក់ទឹកភ្នែក ហើយមានស្នាមញញឹមដែលបង្ហាញថា ការផ្ដល់ឲ្យ ពុំមែនគ្រាន់តែអំណោយតែម៉្យាង វាបានប៉ះដល់ដួងចិត្តរបស់ពួកគេ ។ អ្នកប្រហែលជាមានក្ដីស្រមៃដូច្នោះដែរហើយ ។ អ្នករាល់គ្នាជាច្រើនប្រហែលអ្នក ជាអ្នកជំនាញខាងការផ្ដល់អំណោយរួចទៅហើយ ។

មានអ្វីមួយដែលអ្នកអាចធ្វើនៅក្នុងឆ្នាំនេះ ដើម្បីចាប់ផ្ដើមក្លាយទៅជាអ្នកផ្ដល់អំណោយដល់ខ្លួនអ្នកកាន់តែល្អ ។ តាមពិតទៅ ក្នុងនាមជាសិស្ស អ្នកមានឱកាសពិសេសមួយចំនួន ។ អ្នកអាចចាប់ផ្ដើមដាក់អំណោយមួយចំនួន—អំណោយដ៏អស្ចារ្យ—បង់ថ្លៃទុកមុនសម្រាប់គ្រួសារនាពេលអនាគតរបស់អ្នក ។ ខ្ញុំនឹងប្រាប់អ្នកអំពីវា ។

**ការសរសេរអត្ថបទសម្រាប់សាលា**

អ្នកអាចចាប់ផ្ដើមនៅក្នុងបន្ទប់របស់អ្នកនាថ្ងៃនេះ ។ តើមានអត្ថបទសាលាណាដែលមិនទាន់បានសរសេរ គរទុកនៅកន្លែងណាទេ ? ( ខ្ញុំស្មានថា មានគរនៅទីនោះ ខ្ញុំគិតថា ខ្ញុំស្គាល់បន្ទប់របស់អ្នក ) ។ ប្រហែលជាវាបានវាយជាអត្ថបទរួចហើយ ហើយរួចរាល់ដើម្បីនឹងប្រគល់ដល់គ្រូហើយ ។ ហេតុអ្វីក៏ត្រូវខ្វល់ច្រើនជាមួយនឹងវា ? ខ្ញុំបានរៀនពីមូលហេតុ អំឡុងថ្នាក់រៀនខាងសាសនា ដែលខ្ញុំបានបង្រៀនពេលនៅសាកលវិទ្យាល័យ រិក ( ឥឡូវជាសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់–អៃដាហូ ) ។ វាគឺជាការបង្រៀនមកពីកណ្ឌ 25 នៃគោលលទ្ធិ និងសេចក្ដីសញ្ញា ។ នៅក្នុងកណ្ឌនោះ អិមម៉ា ស្ម៊ីធ ត្រូវបានប្រាប់ថា នាងគួរតែចំណាយពេលរបស់នាងដើម្បី « ការសរសេរ និងដើម្បីការរៀនសូត្រដ៏ច្រើន » ( ខ 8 ) ។ ប្រហែលជានៅបីជួរខាងក្រោយ មានយុវនារីសក់សម្បុរទង់ដែងម្នាក់ ជ្រួញចិញ្ចើម នៅពេលខ្ញុំជម្រុញឲ្យសិស្សក្នុងថ្នាក់ឧស្សាហ៍នៅក្នុងការបង្កើតជំនាញសរសេរ ។ នាងបានលើកដៃរបស់នាង ហើយនិយាយថា « នោះវាមិនសមហេតុផលចំពោះខ្ញុំសោះ ។ អ្វីដែលខ្ញុំនឹងសរសេរ គឺជាការសរសេរសំបុត្រទៅកូនៗរបស់ខ្ញុំប៉ុណ្ណឹង » ។ នោះធ្វើឲ្យមានសំណើចពេញថ្នាក់រៀន ។ ពេលមើលទៅគាត់ ខ្ញុំអាចស្រមៃឃើញថាមានកូនជាច្រើននៅជុំវិញគាត់ ហើយខ្ញុំអាចមើលឃើញថា មានសំបុត្រជាច្រើនដែលគាត់នឹងសរសេរ ។ ប្រហែលជា ការសរសេរប្រកបដោយអានុភាព នឹងពុំសំខាន់ចំពោះគាត់ទេ ។

បន្ទាប់មក មានយុវជនម្នាក់នៅខាងក្រោយ បានក្រោកឈរឡើង ។ គាត់និយាយតិចតួចណាស់ក្នុងត្រីមាសនោះ ខ្ញុំមិនប្រាកដថា គាត់ធ្លាប់បាននិយាយពីមុនទេ ។ គាត់មានអាយុច្រើនជាងសិស្សដទៃ ហើយគាត់ជាមនុស្សខ្មាស់អៀន ។ គាត់សួរថា តើគាត់អាចនិយាយបានឬទេ ។ គាត់បានប្រាប់ដោយសម្លេងតិចៗអំពីការធ្លាប់ធ្វើជាទាហានម្នាក់នៅប្រទេសវៀតណាម ។ ថ្ងៃមួយ ដោយគាត់គិតថាវាស្ងប់ស្ងាត់ នោះគាត់បានដើរចេញពីកាំភ្លើងរបស់គាត់ ហើយដើរឆ្លងពីបន្ទាយរបស់គាត់ទៅកាន់កន្លែងដាក់សំបុត្រ ។ ពេលគាត់កាន់សំបុត្រនៅក្នុងដៃរបស់គាត់ គាត់បានឮសញ្ញា និងសម្រែក ហើយស្នូរកាំភ្លើងត្បាល់ និង កាំភ្លើងបានផ្ទុះឡើង នៅខាងមុខពីសត្រូវ ។ គាត់បានច្បាំងនៅតាមផ្លូវត្រឡប់មកយកកាំភ្លើងរបស់គាត់វិញ ដោយប្រើដៃរបស់គាត់ជាអាវុធ ។ គាត់បានបណ្ដេញសត្រូវចេញ ជាមួយនឹងពលទ័ពដែលនៅរស់រានមានជីវិត ។ បន្ទាប់មកគាត់អង្គុយចុះនៅក្នុងចំណោមអ្នកនៅរស់ និងអ្នកស្លាប់មួយចំនួន ហើយគាត់បានបើកសំបុត្ររបស់គាត់ ។ វាគឺជាសំបុត្រមកពីម្ដាយរបស់គាត់ ។ ម្ដាយគាត់បានសរសេរថា គាត់មានបទពិសោធន៍ខាងវិញ្ញាណមួយ ដែលអះអាងដល់គាត់ថា កូននឹងនៅរស់រានមានជីវិត ដើម្បីត្រឡប់មកផ្ទះវិញ បើកូនជាមនុស្សសុចរិត ។ នៅក្នុងថ្នាក់រៀនខ្ញុំ ក្មេងប្រុសនោះ បាននិយាយតិចៗថា « សំបុត្រនោះគឺជាខគម្ពីរចំពោះខ្ញុំ ។ ខ្ញុំបានរក្សាវាទុក » ។ រួចគាត់បានអង្គុយចុះ ។

អ្នកអាចនឹងមានកូនម្នាក់នៅថ្ងៃណាមួយ ប្រហែលជា កូនប្រុសម្នាក់ ។ តើអ្នកអាចមើលឃើញមុខរបស់គាត់ឬទេ ? តើអ្នកអាចមើលឃើញថា គាត់នៅកន្លែងណាមួយ ជួនកាល នៅក្នុងគ្រោះថ្នាក់នៃជីវិតរមែងស្លាប់ឬទេ ? តើអ្នកអាចដឹងពីភាពភ័យខ្លាចនៅក្នុងដួងចិត្តគាត់ឬទេ ? តើវាប៉ះដល់ដួងចិត្តអ្នកឬទេ ? តើអ្នកនឹងចង់ផ្ដល់ឲ្យដោយសេរីឬទេ ? តើមានការលះបង់អ្វីខ្លះ ដែលនឹងចំណាយដើម្បីសរសេរសំបុត្រដែលបេះដូងរបស់អ្នកនឹងចង់ផ្ញើរទៅនោះ ? សូមចាប់ផ្ដើមអនុវត្តនាល្ងាចនេះ ។ ត្រឡប់ទៅបន្ទប់របស់អ្នក ហើយសរសេរ និង អានហើយសរសេរឡើងវិញ នូវអត្ថបទនោះម្ដងហើយម្ដងទៀត ។ អ្នកនឹងឃើញថា វាពុំដូចជាការលះបង់នោះទេ បើអ្នកនឹកគិតពីកូនប្រុសនោះ ដឹងពីដួងចិត្តកូន ហើយគិតអំពីសំបុត្រដែលកូននឹងត្រូវការនៅថ្ងៃមួយនោះ ។

**ការដោះស្រាយលំហាត់គណិតវិទ្យា**

ឥឡូវ អ្នករាល់គ្នាមួយចំនួនពុំមានអត្ថបទមួយរង់ចាំអ្នកទេ ។ វាអាចជាសៀវភៅមួយ ដែលមាន

រចនារូបភាពដោយ ឌូនី រ៉ែល



លំហាត់គណិត លាក់នៅក្នុងនោះ ។ ខ្ញុំនឹងប្រាប់អ្នកអំពីថ្ងៃមួយនៅក្នុងអនាគតរបស់អ្នក ។ អ្នកនឹងមានកូនប្រុស ឬកូនស្រីដែលពេញវ័យ នឹងនិយាយថា « ខ្ញុំស្អប់សាលារៀន » ។ បន្ទាប់ពីការស្ដាប់ដោយយកចិត្តទុកដាក់មួយចំនួន អ្នកនឹងរកឃើញថា វាពុំមែនជាសាលារៀន ឬក៏មិនមែនជាគណិតវិទ្យាដែរគាត់ ឬនាងស្អប់នោះ —តែវាគឺជាអារម្មណ៍នៃការបរាជ័យទៅវិញទេ ។

អ្នកនឹងដឹងយ៉ាងត្រឹមត្រូវអំពីអារម្មណ៍ទាំងនោះ ហើយអ្នកនឹងត្រូវបំផុសគំនិត ហើយអ្នកនឹងចង់ផ្ដល់ឲ្យដោយឥតគិតថ្លៃ ។ ដូច្នេះ អ្នកនឹងបើកសៀវភៅ រួចនិយាយថា « តោះ ចូរយើងមើលបញ្ហាមួយជាមួយគ្នា » ។ ចូរគិតអំពី ការតក់ស្លុតដែលអ្នកនឹងទទួលនៅពេលអ្នកមើលឃើញថា ទូកកំពុងចែវដែលរយៈពេលពីរម៉ោងទៅ ហើយត្រឡប់មកវិញក្នុងរយៈពេលប្រាំម៉ោង ហើយសំណួរនៅតែសួរថា តើចរន្តទឹកហូរលឿនប៉ុណ្ណា ឬតើទូកបានធ្វើដំណើរឆ្ងាយប៉ុណ្ណា ។ អ្នកអាចនឹងគិតថា « មែនហើយ ខ្ញុំនឹងធ្វើឲ្យកូនរបស់ខ្ញុំមានអារម្មណ៍ល្អប្រសើរ ដោយការបង្ហាញដល់ពួកគេថា ខ្ញុំក៏ពុំចេះធ្វើគណិតដែរ » ។ ខ្ញុំសូមផ្ដល់ឱវាទដល់អ្នកខ្លះៗ ៖ ពួកគេនឹងមើលឃើញវាថាជាអំណោយដ៏សោះកក្រោះមួយ ។

មានអំណោយដែលល្អប្រសើរជាង ប៉ុន្តែវានឹងចំណាយការខិតខំពីពេលឥឡូវនេះ ។ ឪពុកខ្ញុំ កាលគាត់នៅក្មេង គាត់ត្រូវតែដោះស្រាយលំហាត់ចែវទូក និងលំហាត់ជាច្រើនដទៃទៀត ។ នោះគឺជាផ្នែកនៃឧបករណ៍ដែលគាត់ត្រូវការ ដើម្បីក្លាយទៅជាអ្នកវិទ្យាសាស្ត្រ ដែលនឹងធ្វើឲ្យមានភាពខុសប្លែកគ្នាចំពោះគីមីវិទ្យា ។ ប៉ុន្តែគាត់ក៏បានធ្វើឲ្យមានភាពខុសប្លែកចំពោះខ្ញុំផងដែរ ។ បន្ទប់គ្រួសាររបស់យើង មើលទៅពុំប្រណិត ដូចជាបន្ទប់គ្រួសាររបស់គេមួយចំនួនទេ ។ បន្ទប់នោះ គឺមានគ្រឿងសង្ហារឹមមួយប្រភេទគឺមាន —កៅអីមួយចំនួន —ហើយជញ្ជាំងមួយចំហៀងមានការតុបតែង— ជាក្ដារខៀនពណ៌បៃតង ។ ខ្ញុំបានឈានចូលដល់វ័យដែលកូនប្រុស ឬកូនស្រីរបស់អ្នក នឹងឈានដល់ ។ ខ្ញុំពុំជឿងឆ្ងល់ទេ បើខ្ញុំអាចដោះស្រាយលំហាត់គណិតវិទ្យានេះបាន តែខ្ញុំបានសារភាពដោយអស់ពីចិត្តថា ខ្ញុំពុំអាចដោះស្រាយបានទេ ។ ហើយគ្រូបង្រៀនខ្ញុំមួយចំនួនទទួលស្គាល់ថា នោះគឺជាការពិតផងដែរ ។

ប៉ុន្តែឪពុកខ្ញុំពុំព្រមទេ ។ គាត់បានគិតថា ខ្ញុំអាចដោះស្រាយលំហាត់នោះបាន ។ ដូច្នេះយើងបានរៀនជាមួយនឹងគ្នានៅលើក្ដារខៀននោះ ។ ខ្ញុំពុំចាំអំពីអំណោយជាច្រើនដែលឪពុកខ្ញុំបានខ្ចប់ឲ្យខ្ញុំនោះទេ ។ ប៉ុន្តែខ្ញុំចាំអំពីក្ដារខៀន និងសំឡេងតិចៗរបស់គាត់ ។ ការបង្រៀនរបស់គាត់ចំណាយច្រើនជាងអ្វីដែលខ្ញុំត្រូវការ និង យកចិត្តទុកដាក់ ។ វាចំណាយច្រើនជាងការស្ម័គ្រចិត្ត ក្នុងការចំណាយពេលរបស់គាត់នាគ្រានោះ ដែលវាមានតម្លៃដូចគ្នា ។ វាចំណាយពេលដែលគាត់បានចំណាយពីមុននៅពេលគាត់មានឱកាសដូចជាអ្នកមាននៅពេលនេះ ។ ពីព្រោះតែគាត់បានចំណាយពេលនាគ្រានោះ នោះគាត់ និងខ្ញុំអាចមានពេលនៅលើក្ដារខៀន ហើយគាត់អាចជួយខ្ញុំ ។

ហើយដោយសារគាត់ផ្ដល់ដល់ខ្ញុំនូវបទពិសោធន៍ដូច្នោះ នោះខ្ញុំមានកូនប្រុសម្នាក់ ដែលឲ្យខ្ញុំអង្គុយជាមួយគាត់មួយឆ្នាំ ។ យើងបានអុំទូកដូចគ្នាចុះឡើង ។ ហើយគ្រូបង្រៀនរបស់គាត់ បានសរសេរថា « មានការរីកចម្រើនច្រើន » នៅលើកាតរបាយការណ៍របស់គាត់ ។ ប៉ុន្តែខ្ញុំនឹងប្រាប់អ្នកនូវអ្វីដែលរីកចម្រើនបំផុតនោះគឺ ៖ អារម្មណ៍នៃកូនល្អមានអំពីខ្លួនគាត់ ។ គ្មានអ្វីដែលខ្ញុំនឹងដាក់នៅក្រោមដើមគ្រីស្ទម៉ាស សម្រាប់ ស្ពោតមានតែពាក់កណ្ដាលនៃឱកាសនៃការប្រែក្លាយជាអ្នកទទួលមរតកគ្រួសារ ដែលជាមោទនភាពនៃការជោគជ័យរបស់គាត់ទេ ។

## ការរៀនសិល្បៈ និង តន្ត្រី

ប្រហែលជាមានអ្នកចេះសិល្បៈខ្លះៗ ( ឬក៏ជាតន្ត្រីឬទេ ? ) សិស្សញញឹម ។ ពួកគេកំពុងគិតថា « គាត់នឹងមិនអាចបញ្ចុះបញ្ចូលខ្ញុំថា ខ្ញុំមានអំណោយទានដែលលាក់ទុក នៅក្នុងកិច្ចការដែលពុំទាន់ធ្វើរួច*របស់ខ្ញុំ*បានទេ » ។ ខ្ញុំល្បងលមើលសិន ។ កាលពីសប្ដាហ៍មុន ខ្ញុំបានទៅព្រឹត្តការណ៍មួយ ជាកិត្តិយសដល់យុវជនម្នាក់ ។ មានការចាក់បញ្ចាំងស្លាយមួយ ។ ពន្លឺបានបាញ់ចុះ ហើយខ្ញុំបានស្គាល់សំឡេងពីរ ។ មួយគឺជាសំឡេងអ្នកចម្រៀងដ៏ល្បីនៅពីខាងក្រោយ ហើយសំឡេងមួយទៀត ជាអ្នកពោល នោះគឺជាសំឡេងឪពុករបស់យុវជននោះ ។

ឪពុកគាត់ច្បាស់ជាចំណាយពេលយ៉ាងច្រើនម៉ោងរៀបចំស្លាយនោះ សរសេរពាក្យដែលហោះឡើង រួចហើយដាក់តន្ត្រី និង ពាក្យបញ្ចូល និងសំឡេងឲ្យត្រូវគ្នា ។ អ្នកនឹងមានកូនប្រុសនាថ្ងៃណាមួយ ដែលនឹងត្រូវបានផ្ដល់កិត្តិយសនៅព្រឹត្តការណ៍មួយដូច្នោះដែរ មានបងប្អូនជីដូនមួយ

រូបថតដោយ iStockphoto/Thinkstock និង



និងពូមីងរបស់គាត់ទាំងអស់គ្នាមកទស្សនា ។ អ្នកនឹងចង់ប្រាប់កូនថាគាត់ជានរណា ហើយគាត់អាចប្រែក្លាយទៅជាអ្វី ដោយអស់ពីដួងចិត្តអ្នក ។ ទោះជាអ្នកអាចផ្ដល់អំណោយនោះនាគ្រានោះ ដែលអាស្រ័យទៅលើអារម្មណ៍ដែលអ្នកដឹងពីដួងចិត្តគាត់នាពេលនេះ ហើយបានប៉ះដល់ដួងចិត្ត ហើយចាប់ផ្ដើមស្ដាបនាជំនាញដ៏ឆ្នៃប្រឌិត ដែលអ្នកនឹងត្រូវការនោះក្ដី ។ នោះវានឹងមានអត្ថន័យច្រើនជាងអ្នកអាចសុបិននាពេលនេះ ខ្ញុំសន្យានឹងអ្នក ។

**ការប្រែចិត្តឥឡូវនេះ**

នៅមានអំណោយផ្សេងទៀត ដែលអ្នករាល់គ្នាមួយចំនួនចង់ផ្ដល់ឲ្យ ដែលវាតម្រូវឲ្យចាប់ផ្ដើមឲ្យបានឆាប់ ។ ខ្ញុំបានឃើញវាបានចាប់ផ្ដើមនៅគ្រាមួយ ពេលខ្ញុំធ្វើជាប៊ីស្សព ។ មានយុវជនម្នាក់អង្គុយទល់មុខខ្ញុំ ។ គាត់បាននិយាយអំពី កំហុសទាំងឡាយដែលគាត់បានធ្វើ ។ ហើយគាត់បាននិយាយថា គាត់ចង់ឲ្យកូនៗដែលគាត់នឹងមាននៅថ្ងៃមួយ មានឪពុកដែលអាចប្រើបព្វជិតភាពខ្លួន ហើយដែលពួកគេអាចផ្សាភ្ជាប់ជាមួយគ្នាដ៏នៅអស់កល្បជានិច្ចខ្លាំងណាស់ ។ គាត់បាននិយាយថា គាត់ដឹងថា តម្លៃ និងការឈឺចាប់នៃការប្រែចិត្តនឹងមានទំហំធំណាស់ ។ បន្ទាប់មក គាត់បាននិយាយអ្វីមួយ ដែលខ្ញុំនឹងពុំអាចបំភ្លេចបានថា ៖ « ប៊ីស្សព ខ្ញុំត្រឡប់មកវិញហើយ ។ ខ្ញុំនឹងធ្វើអ្វីគ្រប់យ៉ាង ។ ខ្ញុំត្រឡប់មកវិញហើយ » ។ គាត់មានអារម្មណ៍សោកស្ដាយ ។ ហើយគាត់មានសេចក្ដីជំនឿទៅលើព្រះគ្រីស្ទ ។ ហើយវានៅតែត្រូវចំណាយពេលរាប់ខែក្នុងការខិតខំដោយឈឺចាប់ ។

ដូច្នោះហើយ នៅកន្លែងណាដែលមានគ្រួសារមួយ ដែលមានអ្នកកាន់បព្វជិតភាពសុចរិតនៅជាមេគ្រួសារ ។ នោះពួកគេមានសេចក្ដីសង្ឃឹមដ៏អស់កល្ប និងសេចក្ដីសុខសាន្តនៅលើផែនដី ។ គាត់ប្រហែលជានឹងផ្ដល់ដល់គ្រួសាររបស់គាត់នូវអំណោយគ្រប់ប្រភេទដែលបានខ្ចប់ទុកយ៉ាងភ្លឺថ្លា ប៉ុន្ដែគ្មានអ្វីដែលសំខាន់ស្មើនឹងអំណោយមួយដែលគាត់បានចាប់ផ្ដើមកាលពីជាយូរមក នៅក្នុងការិយាល័យរបស់ខ្ញុំទេ ហើយនឹងពុំឈប់ផ្ដល់ឲ្យនោះឡើយ ។ ពេលនោះគាត់ដឹងពីតម្រូវការរបស់កូនៗដែលគាត់មានតែនៅក្នុងសុបិន ហើយគាត់បានផ្ដល់ឲ្យតាំងពីមុន ហើយឲ្យដោយសេរី ។ គាត់បានលះបង់អំនួត និងភាពខ្ជិលច្រអូស និងអារម្មណ៍ស្ពឹកស្រពន់របស់គាត់ ។ ខ្ញុំដឹងប្រាកដថា វាហាក់ដូចជាមិនមែនជាការលះបង់ទេនាពេលនេះ ។

គាត់អាចផ្ដល់អំណោយនោះ ដោយសារមាននរណាម្នាក់ទៀតបានផ្ដល់អំណោយនោះជាយូរមកហើយ ។ ព្រះដែលជាព្រះវរបិតាបានប្រទានដល់យើងនូវព្រះរាជបុត្រារបស់ទ្រង់ ហើយព្រះយេស៊ូវគ្រីស្ទ ប្រទានដល់យើងនូវដង្វាយធួន ដែលជាអំណោយទានដ៏មហិមាបំផុត លើអំណោយទាន ទាំងអស់ ព្រមទាំងការប្រទានឲ្យទាំងអស់ ។ ព្រះអង្គសង្គ្រោះបានដឹងនូវការឈឺចាប់ និងការទុក្ខសោកនៃអំពើបាបទាំងអស់ ដែលនឹងធ្លាក់មកលើយើងទាំងអស់គ្នា និងអ្នកដែលនឹងកើតមក ( សូមមើល ហេព្រើរ 4:14–16 ) ។

ខ្ញុំថ្លែងទីបន្ទាល់របស់ខ្ញុំចំពោះអ្នកថា ព្រះយេស៊ូវបានប្រទានអំណោយដោយសេរី ដោយស្ម័គ្រព្រះទ័យ ចំពោះយើងទាំងអស់គ្នា ។ ហើយខ្ញុំថ្លែងទីបន្ទាល់ទៅអ្នកថា នៅពេលអ្នកទទួលអំណោយនោះ ដែលបានឲ្យមកអ្នក តាមរយៈការពលិកម្មគ្មានព្រំដែន នោះវានឹងនាំមកនូវសេចក្ដីអំណរចំពោះអ្នកដែលផ្ដល់ឲ្យ ( សូមមើល លូកា 15:7 ) ។

« អ្នករាល់គ្នាទទួលបានដោយទទេ ត្រូវឲ្យទទេដែរ » ( ម៉ាថាយ 10:8 ) ។ ខ្ញុំអធិស្ឋានសុំឲ្យយើងឲ្យទទេដែល ។ ខ្ញុំអធិស្ឋានសុំឲ្យយើងនឹងត្រូវបានទទួលការបំផុសអារម្មណ៍ពីអ្នកដទៃ ដែលយើងនឹងផ្ដល់ឲ្យដោយគ្មានអារម្មណ៍នៃការបង្ខិតបង្ខំ ឬការរំពឹងចង់បានចំណេញមកវិញឡើយ ហើយសុំឲ្យយើងនឹងដឹងថា ពលិកម្មមានភាពផ្អែមល្ហែមចំពោះយើង នៅពេលយើងរក្សាទុកនូវក្ដីអំណរ ដែលវានាំមកក្នុងដួងចិត្តអ្នកដទៃទៀត ។ ■

*ចេញមកពីប្រសាសន៍ក្នុងការប្រជុំធម្មនិដ្ឋាន « Gifts of Love » ដែលផ្ដល់ឲ្យនៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់ នៅថ្ងៃទី 16 ខែ ធ្នូ ឆ្នាំ 1980 ។ សម្រាប់អត្ថបទទាំងស្រុងជាភាសាអង់គ្លេស សូមចូលទៅកាន់ speeches.byu.edu។*





# បាវចនាម៉្ងូតឆល ឆ្នាំ 2014



*« ចូរមកកាន់ព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ ហើយចូរលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធចុះ » ( មរ៉ូណៃ 10:32 ) ។*



*គណៈប្រធានយុវជនទូទៅ*

## « មករកព្រះគ្រីស្ទ »

**ដោយគណៈប្រធានយុវជនទូទៅ**

យុវជននៃបព្វជិតភាពអើរ៉ុន ឆ្នាំនេះបាវចនាម៉្ងូតឆលរបស់យើង បំផុសគំនិតអ្នកឲ្យគិតអំពីទំនាក់ទំនងរបស់អ្នកជាមួយព្រះយេស៊ូវគ្រីស្ទ ព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះរបស់យើង ហើយនឹងរបៀបដែលអ្នកអាចប្រែក្លាយដូចជាទ្រង់ ។ បាវចនារបស់យើងគឺ « ចូរមករកព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ ហើយចូរលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធចុះ » ( មរ៉ូណៃ 10:32 ) ។

នេះគឺជាការអញ្ជើញដ៏ពិសិដ្ឋមួយ ដើម្បីខិតទៅជិតនឹងព្រះរាជបុត្រានៃព្រះ ។ តាមរយៈដង្វាយធួនរបស់ទ្រង់ នោះយើងអាចទទួលបានអំណាចនៃការបម្រើ ដើម្បីលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធក្នុងជីវិតរបស់យើង ហើយដើម្បីដឹងអំពីក្ដីស្រឡាញ់ដ៏គ្មានទីបំផុតរបស់ទ្រង់ ។នៅពេលយើងធ្វើដូច្នោះ នោះយើងនឹងរកឃើញសេចក្ដីសុខសាន្ត និងសុភមង្គលពិត ។

នៅពេលអ្នកធ្វើតាមការអញ្ជើញឲ្យមករកព្រះគ្រីស្ទ នោះអ្នកនឹងមកដើម្បីយល់ដឹងអំពីកាតព្វកិច្ចពិសិដ្ឋរបស់អ្នក ដើម្បី « អញ្ជើញមនុស្សទាំងអស់មករកព្រះគ្រីស្ទ » ( គ&ស 20:59 ) ផងដែរ ។ ដួងចិត្តរបស់អ្នកនឹងពេញដោយបំណងប្រាថ្នាមួយ ដើម្បីដឹកនាំអ្នកដទៃមករកទ្រង់ ដើម្បីពួកគេអាចទទួលបានពរជ័យដូចគ្នាដែលអ្នកបានទទួល ហើយបន្តទទួល ។

មានយុវជនម្នាក់ ឈ្មោះ ម៉ៃឃល បានបំពេញកាតព្វកិច្ចរបស់គាត់ តាមរយៈការជួយដល់ ចូស ជាមិត្តម្នាក់មកពីសាលារៀន ។

ថ្ងៃមួយ ចូស បានសួរគាត់ថា « ម៉ៃឃល តើហេតុអ្វីបានជាអ្នកសប្បាយជានិច្ចដូច្នេះ ? »

ម៉ៃឃល បាននិយាយថា « វាដោយសារតែខ្ញុំធ្វើការបម្រើ » ។

« ហេតុអ្វីបានជាអ្នកធ្វើការបម្រើ ? »

ខាងឆ្វេង ៖ ក្រាហ្វិកដោយ ឌីសាញ ហ្វាម, ស្រង់លម្អិតចេញមកពី *ព្រះគ្រីស្ទជាមួយនឹងក្មេងប្រុស* ដោយ ខាល ហែនរិច ប៊្លុច

ចម្លើយគឺថា « ដោយសារខ្ញុំកាន់បព្វជិតភាព ហើយវាជាកាតព្វកិច្ចរបស់ខ្ញុំ » ។

ចូស បាននិយាយថា « ខ្ញុំចង់ដឹងបន្ថែមទៀតអំពីបព្វជិតភាព » ។

ម៉ែយល បានអញ្ជើញ ចូស ឲ្យមកចូលរួមសកម្មភាពក្នុងសាសនាចក្រ ហើយក្រោយមកមកក្នុងការប្រជុំរបស់សាសនាចក្រ ។ ទីបំផុត ចូស និង គ្រួសាររបស់គាត់ ត្រូវបានបង្រៀនដោយអ្នកផ្សព្វផ្សាយសាសនា ហើយបានទទួលបុណ្យជ្រមុជទឹក ។ ចូស បាននិយាយថា « កិច្ចការផ្សព្វផ្សាយសាសនា គឺជាមូលដ្ឋាននៃសាសនាចក្ររបស់យើង ។ បើសិនជាយើងនឹងទៀងត្រង់ ហើយសុចរិតក្នុងការទំនាក់ទំនងប្រចាំថ្ងៃរបស់យើង នោះអ្នកទាំងឡាយដែលនៅជុំវិញយើង នឹងកត់សម្គាល់ ហើយសួរយើងដូចជាខ្ញុំត្រូវបានគេសួរដែរ ។ ម៉ែយល គឺជាឧបករណ៍មួយនៅក្នុងផែនការដ៏មហិមារបស់ព្រះ » ។

« ពាក្យថា ‹ មករកព្រះគ្រីស្ទ › គឺជាការអញ្ជើញមួយ ។ វាគឺជាការអញ្ជើញដ៏សំខាន់បំផុត ដែលអ្នកមិនធ្លាប់ធ្វើចំពោះនរណាម្នាក់ពីមុនមក ។ វាគឺជាការអញ្ជើញដ៏សំខាន់បំផុត ដែលមនុស្សគ្រប់គ្នាអាចទទួលយកបាន » ។[1]

—ប្រធាន ហិនរី ប៊ី អាវរិង ជាទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ

នៅពេលអ្នកខិតទៅជិតនឹងព្រះអម្ចាស់ នោះអ្នកនឹងមានបំណងប្រាថ្នាមួយ ដើម្បីបម្រើអ្នកដទៃដូចជាម៉ែយលបានធ្វើ ។ ហើយនៅពេលអ្នកធ្វើនោះអ្នកនឹងរកឃើញនូវការសន្យានេះ មកពីប្រធាន ហ៊ែនរី ប៊ី អាវរិង ជាទីប្រឹក្សាទីមួយ នៅក្នុងគណៈប្រធានទីមួយ ជាការពិតថា ៖ « នៅពេលអ្នកដាក់ដួងចិត្តរបស់អ្នកអញ្ជើញដល់មនុស្សដទៃឲ្យមករកព្រះគ្រីស្ទ នោះដួងចិត្តអ្នកនឹងបានផ្លាស់ប្ដូរ ។ អ្នកនឹងធ្វើកិច្ចការរបស់ទ្រង់សម្រាប់ទ្រង់ ។ អ្នកនឹងឃើញថា ទ្រង់រក្សាការសន្យារបស់ទ្រង់ ដើម្បីរួមតែមួយនឹងអ្នក នៅក្នុងការបម្រើរបស់អ្នក ។ អ្នកនឹងបានស្គាល់ទ្រង់ ។ ពេលនោះ អ្នកនឹងមកដើម្បីប្រែក្លាយដូចជាទ្រង់ ហើយ ‹ បានល្អឥតខ្ចោះនៅក្នុងទ្រង់ › ។[2]

នេះគឺជាបេះដូងនៃបាវចនារបស់ឆ្នាំនេះ ។ ■

**កំណត់ចំណាំ**

1. ហ៊ែនរី ប៊ី. អាវរិង « Come unto Christ » *Liahona*, ខែមិនា ឆ្នាំ 2008,ទំព័រ 49 ។
2. ហ៊ែនរី ប៊ី. អាវរិង « Come unto Christ » *Liahona,* ខែមិនា ឆ្នាំ 2008, ទំព័រ 52 ។

# អ្នកត្រូវបានអញ្ជើញ

**ដោយគណៈប្រធានយុវនារីទូទៅ**

តើនរណាដែលមិនចូលចិត្តការអញ្ជើញ ? នៅពេលយើងទទួលការអញ្ជើញមួយ ដើម្បីចូលរួមនៅក្នុងពិធីខួបកំណើត ឬពិធីភោជនីយអាហារអាពាហ៍ពិពាហ៍ យើងមានអារម្មណ៍រីករាយដើម្បីអាចសប្បាយរីករាយជាមួយនឹងអ្នកដទៃក្នុងព្រឹត្តការសំខាន់ៗក្នុងជីវិតរបស់ពួកគេ ។ បាវចនាម៉្វូឆលសម្រាប់ឆ្នាំ 2014 ក៏មាននូវការអញ្ជើញដ៏រីករាយមួយដែលសំខាន់ដ៏អស់កល្បផងដែរថា ៖ « ចូរមករកព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ ហើយចូរលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធចុះ » ( មរ៉ូណៃ 10:32 ) ។

ការអញ្ជើញជាច្រើនតម្រូវឲ្យមានការឆ្លើយតបមួយ —ចម្លើយមួយ— ដើម្បីបង្ហាញថាយើងទទួលយកការអញ្ជើញ ឬអត់ ។ តើអ្នកបានឆ្លើយតបការអញ្ជើញនេះនៅក្នុងជីវិតរបស់អ្នកឬទេ ? ការមករកព្រះគ្រីស្ទ មានន័យថា យើងកំពុងរក្សាសេចក្ដីសញ្ញាដ៏ពិសិដ្ឋ ដែលយើងបានធ្វើនៅពិធីបុណ្យជ្រមុជទឹក ។ វាមានន័យថា យើងបានទទួលយកព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះដោយផ្ទាល់របស់យើង ។ វាមានន័យថា យើងទទួលស្គាល់ ហើយជឿនូវអ្វីដែលអាលម៉ា បានបង្រៀនដល់កូនប្រុសរបស់គាត់ ស៊ីបឡុន ៖ « គ្មានផ្លូវ ឬ មធ្យោបាយឯណាផ្សេងទៀតទេ ដែលនាំឲ្យមនុស្សបានសង្គ្រោះ មានតែដោយ និងតាមរយៈព្រះគ្រីស្ទមួយប៉ុណ្ណោះ » ( អាលម៉ា 38:9 ) ។ ការទទួលយកការអញ្ជើញនេះ មានន័យថា យើងមានការតាំងចិត្តដើម្បីដើរតាមគំរូដ៏ឥតខ្ចោះរបស់ព្រះគ្រីស្ទ ដោយការរស់នៅប្រកបដោយគុណធម៌ និងមានជីវិតដែលបានឧទ្ទិស ហើយដោយក្ដីស្រឡាញ់ និងការបម្រើដល់អ្នកដទៃ ។

ការអញ្ជើញនេះ គឺពុំមែនសម្រាប់ព្រឹត្តការតែមួយដងនោះទេ វាគឺជាដំណើរការមួយ ។ យើងត្រូវបានអញ្ជើញឲ្យដើរតាមផ្លូវមួយ ដែលនឹងដឹកនាំយើងទៅព្រះវិហារបរិសុទ្ធ ដែលយើងធ្វើសេចក្ដីសញ្ញាបន្ថែមទៀត ជាមួយព្រះវរបិតាយើងនៅស្ថានសួគ៌ ហើយចូលរួមក្នុងពិធីបរិសុទ្ធសំខាន់ចំពោះការលើកតម្កើងរបស់យើង ។ ផ្លូវនេះ អាចរួមមានការបម្រើបេសកកម្ម ។ វានឹងបញ្ចូលទាំងអាពាហ៍ពិពាហ៍ក្នុង



គណៈប្រធានយុវនារីទូទៅ

ព្រះវិហារបរិសុទ្ធ និងការក្លាយទៅជាបុរស និង ស្ត្រីសុចរិតនៅក្នុងនគរនៃព្រះ ។ វាក៏មានន័យផងដែរថាជាការកាន់ខ្ជាប់ដរាបដល់ចុងបំផុត ។ ដូចជាការអញ្ជើញបានថ្លែង នៅពេលយើងមករកព្រះគ្រីស្ទ នោះយើងអាចបានល្អឥតខ្ចោះក្នុងទ្រង់ ។ ព្រះគ្រីស្ទបានធ្វើឲ្យវាកើតឡើងបាន ដើម្បីស្ថិតនៅលើផ្លូវសេចក្ដីសញ្ញានេះ តាមរយៈសេចក្ដីជំនឿទៅលើទ្រង់ និងតាមរយៈការប្រែចិត្ត ។ ដំណើរការនៃការប្រែក្លាយទៅជាល្អឥតខ្ចោះនេះ អាចចាប់ផ្ដើមនៅថ្ងៃនេះ ដង្វាយធួននៃព្រះគ្រីស្ទធ្វើឲ្យវាកើតឡើងបាន ។

ការអញ្ជើញនេះ សុំឲ្យយើងលះបង់ចោលខ្លួនយើងនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធចុះ— ដើម្បីខុសប្លែកពីម៉ូត បទដ្ឋាន និងការអនុវត្តរបស់លោកិយ ។ យើងត្រូវបានអញ្ជើញឲ្យ « ទុកចោលរបស់ទាំងឡាយនៃលោកិយនេះ ហើយចូរស្វែងរករបស់ទាំងឡាយណា ដែលគ្រាន់បើជាងនេះវិញ ( គ និង ស. 25:10 ) ។ យើងសូមថ្លែងទីបន្ទាល់ថា ការទទួលយកការអញ្ជើញដើម្បី « មករកព្រះគ្រីស្ទ ហើយបានល្អឥតខ្ចោះនៅក្នុងទ្រង់ចុះ » នឹងដឹកនាំទៅរកសុភមង្គលក្នុងជីវិតនេះ និងជីវិតដ៏អស់កល្បជានិច្ច នៅក្នុងពិភពខាងមុខ ។ អ្នកត្រូវបានអញ្ជើញឲ្យឆ្លើយតបនៅថ្ងៃនេះ ! ■

# មរ៉ូណៃ 10:32

*បាវចនាម៉ូចលឆ្នាំនេះ គឺជាការអញ្ជើញមួយមកពីមរ៉ូណៃដើម្បីដើរតាមព្រះអង្គសង្គ្រោះ ។*



**ចូរបានល្អឥតខ្ចោះនៅក្នុងទ្រង់**

« យើងពុំចាំបាច់ត្រូវស្រងាកចិត្តឡើយ បើកិច្ចខិតខំយ៉ាងខ្លាំងបំផុតរបស់យើង ឆ្ពោះទៅរកការល្អឥតខ្ចោះក្នុងពេលឥឡូវនេះ មើលទៅហាក់ដូចជាលំបាកយ៉ាងខ្លាំង ហើយគ្មានទីបញ្ចប់ក្ដី ។ ការល្អឥតខ្ចោះ គឺមិនទាន់សម្រេចទេ ។ វាអាចកើតមានពេញលេញតែក្រោយពេលរស់ឡើងវិញ និងតាមរយៈព្រះអម្ចាស់តែប៉ុណ្ណោះ ។ វារង់ចាំមនុស្សទាំងអស់ដែលស្រឡាញ់ទ្រង់ ហើយរក្សាបទបញ្ញត្តិរបស់ទ្រង់ » ។

**អែលឌើរ រ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Perfection Pending » *Ensign,* ខែវិច្ឆិកា ឆ្នាំ 1995, ទំព័រ 88 ។**

**ស្រឡាញ់ព្រះ**

តើអ្នកអាចបង្ហាញព្រះវរបិតាសួគ៌ថា អ្នកស្រឡាញ់ទ្រង់ដោយរបៀបណា ? ចូរពិចារណាអំពីយោបល់ទាំងនេះ ហើយសូមបន្ថែមនូវយោបល់ផ្ទាល់ខ្លួនអ្នក ។ នៅក្នុងកំណត់ហេតុរបស់អ្នក ចូរសរសេរអំពី អ្វីដែលអ្នកនឹងធ្វើ ។

- កាន់តាមព្រះបញ្ញត្តិ ។
- ស្រឡាញ់ និងបម្រើដល់អ្នកដទៃ ។
- បំពេញនូវការទទួលខុសត្រូវក្នុងសាសនាចក្រ ។
- អធិស្ឋានដោយស្មោះ ។

**« មករកព្រះគ្រីស្ទ » ។**

ព្រះគម្ពីរមាននូវការអញ្ជើញជាច្រើន ឲ្យមករកព្រះគ្រីស្ទ ។ សូមរកមើលឧទាហរណ៍មួយចំនួនដែលរៀបរាប់នៅខាងក្រោយ ។ តើខគម្ពីរទាំងនេះបង្រៀនអ្នកអំពីពរជ័យនៃការយាងមករកព្រះអង្គសង្គ្រោះយ៉ាងណាខ្លះ ? តើអ្នកអាចរកខគម្ពីរបន្ថែមទៀត ដែលមានការអញ្ជើញនេះឬទេ ?

- អោមណៃ 1:26
- អាលម៉ា 5:34–35
- នីហ្វៃទី 3 12:19–20
- ម៉ាថាយ 11:28–30
- យ៉ូហាន 6:35

32 មែនហើយ ចូរមករកព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ ហើយចូរលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធចុះ; ហើយបើសិនជាអ្នករាល់គ្នានឹងលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធ ហើយស្រឡាញ់ព្រះឲ្យអស់ពីសមត្ថភាព អស់ពីគំនិត និងអស់ពីកម្លាំងរបស់អ្នក នោះព្រះគុណរបស់ទ្រង់ល្មមដល់អ្នកហើយ ដោយសារព្រះគុណនៃព្រះ នោះអ្នករាល់គ្នាអាចបានល្អឥតខ្ចោះ នៅក្នុងព្រះគ្រីស្ទ; ហើយបើសិនជាដោយសារព្រះគុណនៃព្រះ ដែលអ្នករាល់គ្នាបានល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ នោះអ្នករាល់គ្នានឹងពុំអាចបដិសេធព្រះចេស្ដានៃព្រះបានឡើយ ។

**ព្រះគុណ**

« ពាក្យ *ព្រះគុណ* ពេលប្រើនៅក្នុងព្រះគម្ពីរ គឺសំដៅសំខាន់ទៅលើជំនួយពីព្រះ និងកម្លាំងដែលយើងទទួល តាមរយៈដង្វាយធួននៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ » ។

***ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងដំណឹងល្អ*** **( ឆ្នាំ 2004 ) ទំព័រ 127 ។**



**ព្រះគុណទ្រង់ គឺល្មមគ្រប់គ្រាន់សម្រាប់អ្នក**

« ពួកគ្រីស្ទានមួយចំនួនបានចោទប្រកាន់ដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយ . . . អំពីការបដិសេធព្រះគុណនៃព្រះ តាមរយៈការប្រកាសថា ពួកគេអាចទទួលបានសេចក្ដីសង្គ្រោះផ្ទាល់ខ្លួនពួកគេ ។ យើងឆ្លើយចំពោះការចោទប្រកាន់នេះថា. . . ‹ ត្បិតយើងព្យាយាមខំ. . . បញ្ចុះបញ្ចូលកូនចៅយើង. . . ដើម្បីឲ្យជឿដល់ព្រះគ្រីស្ទ ហើយឲ្យស្រុះស្រួលនឹងព្រះ ត្បិតយើងដឹងថា មានតែដោយព្រះគុណទេ ទើបយើងបានសង្គ្រោះ បន្ទាប់ពីអ្វីៗទាំងអស់ ដែលយើងអាចធ្វើបាន › ( នីហ្វៃទី 2 25:23 ) ។ ហើយតើ ‹ អ្វីៗទាំងអស់ ដែលយើងអាចធ្វើបានមានអ្វីខ្លះ › ? ប្រាកដណាស់ វារួមបញ្ចូលទាំងការប្រែចិត្ត ( សូមមើល អាលម៉ា 24:11 ) និងពិធីបុណ្យជ្រមុជទឹក ការរក្សាបទបញ្ញត្តិ និងការកាន់ខ្ជាប់ដរាបដល់ចុងបំផុត » ។

**អែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Have You Been Saved ? » *Liahona,* ខែកក្កដា ឆ្នាំ 1998,ទំព័រ 68; *Ensign,* ខែឧសភា ឆ្នាំ 1998, ទំព័រ 56 ។**

**ល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ**

*ល្អឥតខ្ចោះ*ដូចដែលបានប្រើនៅក្នុងបទគម្ពីរ មានន័យថា « បានអភិវឌ្ឍទាំងស្រុង ទាំងមូល និងពេញលេញ សុចរិតទាំងស្រុង ។ ល្អឥតខ្ចោះ ក៏អាចមានន័យផងដែរថា គ្មានអំពើបាប ឬគ្មានអំពើអាក្រក់មានតែព្រះគ្រីស្ទមួយប៉ុណ្ណោះ ល្អឥតខ្ចោះទាំងស្រុង ។ អ្នកដើរតាមពិតរបស់ព្រះគ្រីស្ទ អាចប្រែជាល្អឥតខ្ចោះ តាមរយៈព្រះគុណ និងដង្វាយធួនរបស់ទ្រង់ » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ល្អឥតខ្ចោះ » scriptures.lds.org ) ។

ក្រាហ្វិកដោយ ទីណា ហ្គម



*កំណត់ចំណាំរបស់អ្នកបោះពុម្ពផ្សាយ ៖ នៅទំព័រនេះពុំមែនមានន័យថាវាពន្យល់ដ៏ទូលំទូលាយពី ខគម្ពីរដែលបានជ្រើសរើសនោះទេ វាគ្រាន់តែជាចំណុចចាប់ផ្ដើមមួយសម្រាប់ការសិក្សាផ្ទាល់ខ្លួនរបស់ អ្នកប៉ុណ្ណោះ ។*



# ចូរមករក
# ព្រះគ្រីស្ទ

« ចូរមករកព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់
ហើយចូរលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធចុះ »
( មរ៉ូណៃ 10:32 ) ។

ស្រង់លម្អិតចេញមកពី *ព្រះគ្រីស្ទជាមួយនឹងក្មេងប្រុស* ដោយ ខាល ហេនរិច ប្លុក



# តើការ **ដឹងអំពីក្រុមព្រះ** អាចផ្លាស់ប្ដូរខ្ញុំដោយរបៀបណា ?

*គោលការណ៍ចំនួនប្រាំអំពីក្រុមព្រះ អាចធ្វើឲ្យមានភាពខុសប្លែកមួយនៅក្នុងរបៀបដែលអ្នករស់នៅ ។*

**ដោយ ឡូរី ហ៊ុល្លី**
ទស្សនាវដ្ដីសាសនាចក្រ

យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា « វាគឺជាគោលការណ៍ទីមួយនៃដំណឹងល្អ ដើម្បីដឹងឲ្យច្បាស់អំពីចរិកលក្ខណៈរបស់ព្រះ » ។[1] អ្វីដែលយើងដឹងអំពីក្រុមព្រះ អាចផ្លាស់ប្ដូររបៀបដែលយើងរស់នៅ ពុំមែននៅក្នុងរឿងធំៗទេ ប៉ុន្តែនៅក្នុងរឿងតូចៗជារៀងរាល់ថ្ងៃ ។ ចូរពិចារណាអំពីរបៀបដែលចំណេះដឹងរបស់អ្នកអំពីក្រុមព្រះ មានឥទ្ធិពលមកលើជីវិតរបស់អ្នក នៅពេលអ្នកអានអំពីគោលការណ៍ទាំងប្រាំនេះ ។

**ក្រុមព្រះ ស្រឡាញ់យើង ហើយចង់ឲ្យអ្វីដែលល្អបំផុតដល់យើង ។**

សមាជិកនៃក្រុមព្រះ គឺអស់កល្ប ហើយគ្មានទីបំផុត ប៉ុន្តែក្រុមទ្រង់ នៅតែយកព្រះទ័យទុកដាក់ ដើម្បីឲ្យយើងសប្បាយ ហើយធ្វើល្អ ។ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ 1910– 2008 ) បានថ្លែងទីបន្ទាល់ថា ៖ « ក្រុមទ្រង់ ចាប់ព្រះទ័យចំពោះយើង ហើយយើងជាខ្លឹមនៃកង្វល់ដ៏ខ្លាំងរបស់ទ្រង់ ។ ទ្រង់មានពេលសម្រាប់យើងម្នាក់ៗ ។ យើងទៅរកព្រះបិតា តាមរយៈព្រះរាជបុត្រា ។ ទ្រង់គឺជាអង្គអង្វរជំនួសរបស់យើង នៅឯបល្ល័ង្កនៃព្រះ ។ តើជាការអស្ចារ្យយ៉ាងណាទៅ ដែលយើងក៏អាចទូលទៅកាន់ព្រះបិតានៅក្នុងព្រះនាមនៃព្រះរាជបុត្រា » ។[2]

ដោយសារសមាជិកនៃក្រុមព្រះ ស្រឡាញ់យើង ហើយចង់ឲ្យអ្វីដែលល្អបំផុតសម្រាប់យើង នោះការជ្រើសរើសរបស់យើងសំខាន់ ជាពិសេសនូវរឿងតូចៗ ដែលយើងធ្វើរាល់ថ្ងៃ ដែលនាំយើងឲ្យខិតទៅកាន់តែជិតពួកទ្រង់ ។ យើងមានសក្ដានុពលគ្មានដែនកំណត់ ហើយព្រះខ្វល់ព្រះទ័យអំពីជោគជ័យរបស់យើង ទោះជានៅក្នុងរឿងតូចៗ ។

**ព្រះវរបិតាសួគ៌ ប្រទានឲ្យយើងនូវអ្វីៗទាំងអស់ ។**

យើងដឹងថា ព្រះវរបិតាសួគ៌ បានប្រទានដល់យើងអ្វីៗគ្រប់យ៉ាង ដូច្នេះយើងគួរតែព្យាយាមដើម្បីស្គាល់ព្រះហស្តរបស់ទ្រង់ ហើយមានអំណរគុណ ។ នៅពេលយើងមានអំណរគុណ នោះយើងមានទង្វើផ្សេង ។ ប្រធាន ថូម៉ាស អេស ម៉នសុន បានសន្យាថា « យើងអាចលើកខ្លួនយើងឡើង និង អ្នកដទៃផងដែរ នៅពេលយើង

មេរៀនទាំងឡាយនៅថ្ងៃអាទិត្យ

ប្រធានបទខែនេះ ៖ ក្រុមព្រះ



បដិសេធដើម្បីបន្តនៅក្នុងអណាចក្រនៃគំនិតអវិជ្ជមាន ហើយបណ្ដុះនៅក្នុងដួងចិត្តយើងនូវគំនិតនៃការដឹងគុណមួយនោះ » ។[3]

ដោយសារអ្វីៗដែលយើងមានគឺបានមកពីព្រះ ( សូមមើល ម៉ូសាយ 2:20–21 គ. និងស. 59:21 ) ការដឹងគុណរបស់យើង អាចធ្វើឲ្យយើងមានឆន្ទៈចែករំលែកកាន់តែច្រើនជាមួយអ្នកដទៃ ។ ការណ៍នេះ រួមមានទាំងពេលវេលា និងទេពកោសល្យរបស់យើង ក៏ដូចជាពរជ័យខាងសម្ភាររបស់យើងដែរ ។

**ព្រះវរបិតាសួគ៌ គឺប្រកបដោយក្ដីមេត្តាករុណា ។**

កិច្ចការរបស់ព្រះ និង សិរីល្អរបស់ព្រះ គឺ « ដើម្បីនាំឲ្យមានអមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ( ម៉ូសេ 1:39 ) ។ ទ្រង់ចង់ឲ្យយើងមានជោគជ័យ ដូច្នេះទ្រង់បានប្រទាននូវការអភ័យទោសដល់យើង ចំពោះកំហុសដែលយើងបានធ្វើ ។ ក្ដីមេត្តាករុណារបស់ទ្រង់ ក៏បានប្រទាននូវការអភ័យទោស នៅពេលយើងធ្វើកំហុសដដែលៗផងដែរ ។ ព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធ នឹងជួយយើងផ្លាស់ប្ដូរ ។

ក្ដីមេត្តាករុណារបស់ព្រះ បង្រៀនយើងអំពីការអភ័យទោស ។ ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ជាទីប្រឹក្សាទីពីរ នៅក្នុងគណៈប្រធានទីមួយ បានមានប្រសាសន៍ថា « ដោយសារតែព្រះស្រឡាញ់យើងយ៉ាងខ្លាំង ដូច្នេះយើងក៏ត្រូវស្រឡាញ់ និងអភ័យទោសចំពោះគ្នាទៅវិញទៅមកផងដែរ » ។[4] នេះរួមទាំងការអភ័យទោសដល់ខ្លួនយើងផងដែរ ។

**ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខសម្រាប់យើង ។**

តាមរយៈដង្វាយធួន ព្រះអង្គសង្គ្រោះបានទទួលបទពិសោធន៍នូវការឈឺចាប់ និងការសោកសៅទាំងអស់របស់យើង ( សូមមើលអាលម៉ា 7:11–13 ) ។ បើសិនជាយើងមានថ្ងៃមួយដែលលំបាក ហើយមានអារម្មណ៍ដូចជាគ្មាននរណាម្នាក់យល់ពីយើង នោះយើងអាចដឹងថា ព្រះអង្គសង្គ្រោះគឺយល់ពីយើង ។ ហើយនៅពេលយើងមានថ្ងៃល្អ ហើយចង់ចែកចាយវាឲ្យនរណាម្នាក់ ព្រះអង្គសង្គ្រោះ គឺគង់នៅទីនោះសម្រាប់យើង ។ ទ្រង់ចង់ចែកចាយក្ដីអំណររបស់យើង ដូចជាទ្រង់ចែកការឈឺចាប់របស់យើង ។

**ព្រះវិញ្ញាណបរិសុទ្ធដឹកនាំយើង ។**

ព្រះយេស៊ូវគ្រីស្ទ បានសន្យានឹងសាវករបស់ទ្រង់ថា អង្គលួងលោមចិត្ត ឬព្រះវិញ្ញាណបរិសុទ្ធ អាចគង់នៅជាមួយពួកគេជានិច្ច ដើម្បីបង្រៀន និងលួងលោមចិត្តពួកគេ ( សូមមើល យ៉ូហាន 14:16–17, 26–27 ) ។ យើងក៏អាចមានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីដឹកនាំយើងផងដែរ ។ ហើយយើងអាចទុកចិត្តថា ចម្លើយទាំងឡាយដែលព្រះវិញ្ញាណបរិសុទ្ធប្រទានឲ្យ នឹងជួយដល់យើង ។ ព្រមជាមួយនឹងការដឹកនាំរបស់ទ្រង់ នោះយើងអាចមានទំនាក់ទំនងយ៉ាងខ្ជាប់ខ្ជួនជាមួយនឹងក្រុមព្រះ ។ ហើយនៅពេលយើងធ្វើតាមការបំផុសគំនិតដែលយើងទទួល នោះយើងនឹងចាប់ផ្ដើមស្គាល់ពួកទ្រង់កាន់តែល្អប្រសើរ ។ ■

**កំណត់ចំណាំ**

1. យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church* 6: 305 ។
2. ហ្គរដុន ប៊ី ហ៊ិងគ្លី « In These Three I Believe » *Liahona*, ខែកក្កដា ឆ្នាំ 2006, ទំព័រ 8 ។
3. ថូម៉ាស អេស. ម៉នសុន « The Divine Gift of Gratitude » *Liahona*, ខែវិច្ឆិកា ឆ្នាំ 2010, ទំព័រ 88 ។
4. ឌៀថើរ អេស្វ អុជដូហ្វ « The Merciful Obtain Mercy » *Liahona*, ខែឧសភា ឆ្នាំ 2012, ទំព័រ 76 ។



រូបថតដោយ វែលឌិន ស៊ី. អាន់ឌើសិន និង ម៉ាថាយ រៀ, *ការនិមិត្តដំបូង*, ដោយ ដែល ពាសុន; *ព្រះគ្រីស្ទនៅក្នុងសួនច្បារគែតសេម៉ានី*, ដោយហេរី អាន់ឌើសិន

## ចូលរួមក្នុងការសន្ទនា





**រឿងទាំងឡាយដើម្បីពិចារណាសម្រាប់ថ្ងៃអាទិត្យ**

- តើអ្នកត្រូវបានប្រទានពរដោយព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ ឬព្រះវិញ្ញាណបរិសុទ្ធនៅពេលណា ?
- តើអ្នកមានអារម្មណ៍នៅជិតបំផុតនឹងពួកទ្រង់នៅពេលណា ?
- តើអ្នកអាចរៀនអ្វីខ្លះ អំពីខ្លួនអ្នក តាមរយៈការរៀនអំពីពួកទ្រង់ ?

**រឿងទាំងឡាយ ដែលអ្នកអាចធ្វើ**

- ចូរសរសេរនៅក្នុងកំណត់ហេតុរបស់អ្នក អំពីរបៀបដែលអ្នកត្រូវបានផ្លាស់ប្ដូរ ដោយសារការស្គាល់ក្រុមព្រះ ។
- សូមចែកចាយអារម្មណ៍របស់អ្នកនៅព្រះវិហារ ឬនៅតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ។



**ដោយ ល៉ែរី អិម ហ្គីបសុន**
ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានយុវជនទូទៅ

# ខ្ញុំ ចងចាំទ្រង់ *ជានិច្ច*

*របៀបដែលយើងរក្សាថ្ងៃបរិសុទ្ធឲ្យបរិសុទ្ធ គឺជាការបង្ហាញតាមរយៈអាកប្បកិរិយាអំពីសេចក្ដីសញ្ញារបស់យើង ដើម្បីចងចាំព្រះយេស៊ូវគ្រីស្ទជានិច្ច ។*

ខ្ញុំនឹកចាំថា ក្នុងនាមជាក្មេងអាយុ 11 ឆ្នាំ ដែលត្រូវបានប៊ីស្សពដើរនាំខ្ញុំដោយគារវភាពទៅក្នុងរោងជំនុំនៃអគារវួដថ្មីរបស់យើង ជាកន្លែងដែលគាត់អង្គុយជាមួយខ្ញុំនៅតុសាក្រាម៉ង់ ។ គាត់មានប្រសាសន៍ថា « ល៉ែរី តើប្អូនដឹងឬទេ ថាប្អូននឹងត្រូវបានតែងតាំងក្នុងតំណែងឌីកុនក្នុងបព្វជិតភាពអើរ៉ុននាពេលឆាប់ៗនេះហើយ ។ តើអ្នកបានដឹងអំពី ពរជ័យ និងកាតព្វកិច្ចដ៏ពិសេស ដែលនឹងកើតមានឬទេ ? គាត់បានប្រាប់ខ្ញុំថា ខ្ញុំនឹងមានការទទួលខុសត្រូវពិសិដ្ឋ ដើម្បីធ្វើកិច្ចការដូចដែលព្រះអង្គសង្គ្រោះបានធ្វើ នៅក្នុងការផ្ដល់នូវនិមិត្តរូបនៃពិធីសាក្រាម៉ង់ដ៏បរិសុទ្ធ ទៅដល់អ្នកទាំងឡាយដែលនៅក្នុងសាលាប្រជុំរបស់យើង ។ ខ្ញុំរំភើបចិត្តយ៉ាងខ្លាំងជាមួយនឹងទំហំនៃការហៅបព្វជិតភាព ដែលខ្ញុំបានទទួល ។

ប៊ីស្សពរបស់ខ្ញុំបានសុំឲ្យខ្ញុំទន្ទេញការអធិស្ឋានសាក្រាម៉ង់ពីរ ហើយគិតអំពីរបៀបដែលការអធិស្ឋាននោះ ត្រូវនឹងជីវិតរបស់ខ្ញុំ ។ គាត់បានមានប្រសាសន៍ថា ខ្ញុំត្រូវតែព្យាយាមធ្វើនូវរឿងទាំងឡាយដែលការអធិស្ឋានសាក្រាម៉ង់ សុំដល់យើងម្នាក់ៗធ្វើ បើសិនជាខ្ញុំត្រូវធ្វើជំនួសព្រះអង្គសង្គ្រោះ នៅក្នុងការផ្ដល់សាក្រាម៉ង់ដល់អ្នកដទៃ ។ បន្ទាប់ពីខ្ញុំបានត្រឡប់មកផ្ទះវិញ ឪពុករបស់ខ្ញុំ បានជួយខ្ញុំមើលការអធិស្ឋានសាក្រាម៉ង់ ទាំងនៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ( 20:76–79 ) និងព្រះគម្ពីរមរមន ( មរ៉ូណៃ 4; 5 ) ។ ខ្ញុំអានវាដោយយកចិត្តទុកដាក់ជាលើកដំបូងនៅក្នុងជីវិតខ្ញុំ ។ ខ្ញុំបានស្ដាប់ដោយយកចិត្តទុកដាក់ នៅពេលការអធិស្ឋានទាំងនេះធ្វើឡើងនៅក្នុងព្រះវិហារ ។ ខ្ញុំពិចារណាពាក្យទាំងឡាយ នៅពេលនំប៉័ងត្រូវបានចែក ប៉ុន្តែឥទ្ធិពលនៃសេចក្ដីសញ្ញាសាក្រាម៉ង់ទាំងស្រុងបានស្ដែងចេញមក នៅពេលខ្ញុំស្ដាប់ពាក្យទាំងនេះនៅក្នុងការប្រសិទ្ធពរទឹក ៖ « ដើម្បីឲ្យពួកគេចងចាំដល់ទ្រង់ជានិច្ច » ។ ខ្ញុំបានសួរខ្លួនឯងថា « តើខ្ញុំចងចាំទ្រង់ *ជានិច្ច* ឬទេ ? តើពាក្យ *ជានិច្ច* មានន័យយ៉ាងណា ? តើខ្ញុំអាចចងចាំទ្រង់ជានិច្ចដោយរបៀបណា ? រាល់ពេលដែលខ្ញុំស្ដាប់ឮការអធិស្ឋានសាក្រាម៉ង់ដ៏ពិសិដ្ឋទាំងនោះ ខ្ញុំបាននឹកគិតដល់សំណួរដដែលទាំងនោះ ។

របៀបដែលយើងរក្សាថ្ងៃបរិសុទ្ធឲ្យបរិសុទ្ធ គឺជាការបង្ហាញផ្នែកខាងក្រៅនៃសេចក្ដីសញ្ញារបស់យើងជាមួយព្រះវរបិតាសួគ៌ ដើម្បីចងចាំព្រះយេស៊ូវគ្រីស្ទជានិច្ច ។ *ថ្ងៃបរិសុទ្ធ គួរតែក្លាយជាគ្រឹះសម្រាប់ការចងចាំរបស់យើងអំពីទ្រង់ សម្រាប់ថ្ងៃប្រាំមួយថ្ងៃដទៃទៀតក្នុងសប្ដាហ៍ ។*

ថ្ងៃអាទិត្យគឺជាថ្ងៃមួយ ដើម្បីបន្ថយល្បឿនឈប់សម្រាក និង ចងចាំទ្រង់ ។ យើងចូលរួមការប្រជុំសាសនាចក្ររបស់យើង នឹកគិតអំពីកម្លាំង ពរជ័យ និងការធ្លាក់របស់យើង ស្វែងរកការអភ័យទោស ទទួលទានសាក្រាម៉ង់ និងពិចារណាអំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះជំនួសយើង ។ យើងព្យាយាមដើម្បីកុំឲ្យមានការរំខានពីអ្វីៗផ្សេង ដែលនឹងរារាំងយើងមិនឲ្យថ្វាយបង្គំទ្រង់ ត្បិត « នៅថ្ងៃនេះ » ដូចព្រះអម្ចាស់បានមានបន្ទូល « អ្នកមិនត្រូវធ្វើអ្វីឡើយ » (  គ. និង ស. 59:13 ) ។ រាល់សកម្មភាពដែលយើងចូលរួមអំឡុងថ្ងៃបរិសុទ្ធ គួរតែស្ថិតនៅក្នុងការរក្សាឲ្យមានវិញ្ញាណនៃការចងចាំអំពីព្រះគ្រីស្ទ ។ បើមានអ្វីដែលយើងកំពុងធ្វើនៅក្នុងថ្ងៃបរិសុទ្ធដែលនាំយើងមិនឲ្យចងចាំអំពី ព្រះអង្គសង្គ្រោះ និងការបម្រើនៅថ្ងៃបរិសុទ្ធ ដូចដែលទ្រង់នឹងបម្រើនោះប្រហែលជាយើងគួរតែពិចារណាឡើងវិញនូវអ្វីដែលយើងកំពុងធ្វើនោះ ។ ការចងចាំ ថ្ងៃបរិសុទ្ធគឺជាថ្ងៃមួយដែលបានតាំងឡើង ពុំគ្រាន់តែ « សម្រាកពីការងាររបស់អ្នក » ប៉ុន្តែក៏ « ដើម្បីថ្វាយភក្ដីភាពរបស់អ្នកដល់ព្រះដ៏ខ្ពស់បំផុត » ( គ. និង ស. 59:10 ) ។

យើងត្រូវតែរៀបចំផែនការជីវិតរបស់យើងតាមរបៀបមួយ ដែលគ្មានការដោះសារ ដើម្បីងាកចេញពីការញែកឲ្យបរិសុទ្ធនៃថ្ងៃរបស់ព្រះអម្ចាស់ក្នុងផ្នែកណាមួយឡើយ ។ វាគឺជាថ្ងៃមួយដើម្បីធ្វើកិច្ចការរបស់ទ្រង់ ជាថ្ងៃមួយដែលជីវិតរបស់យើងទាំងមូល អាចត្រូវបានពរ និងរំពឹកដោយការមានបទពិសោធន៍ពិសិដ្ឋៗ ។ វាគឺជាថ្ងៃមួយសម្រាប់ការរីកចម្រើនខាងវិញ្ញាណផ្ទាល់ខ្លួន និងជាមួយក្រុមគ្រួសារយើង ។



សូមចំណាយពេលខ្លះនៅថ្ងៃនេះ បង្កើតផែនការដែលប្រកបដោយការគិតគូចំពោះអ្វីៗ ដែលអ្នកនឹងធ្វើដើម្បី ធ្វើឲ្យថ្ងៃបរិសុទ្ធ ជាថ្ងៃពិសិដ្ឋដ៏ពិតមួយ និងជាថ្ងៃបរិសុទ្ធនៅក្នុងជីវិតរបស់អ្នក ។ បន្ទាប់មកចូរធ្វើតាមផែនការរបស់អ្នក ។

សូមចងចាំនូវការសន្យាដ៏អស្ចារ្យរបស់ព្រះអម្ចាស់ ចំពោះអ្នកទាំងឡាយដែលគោរពដល់ថ្ងៃឈប់សម្រាកដោយត្រឹមត្រូវថា ៖ « ហើយដរាបណាអ្នករាល់គ្នាប្រព្រឹត្តការទាំងនេះដោយអំណរគុណ ដោយទឹកចិត្ត និងទឹកមុខរីករាយ . . . នោះផលបរិបូរនៃផែនដីជារបស់ផងអ្នករាល់គ្នាហើយ » ( គ និង ស 59:15–16 ) ។ តើយើងអាចបោះបង់ចោលនូវពរជ័យទាំងនេះនៅក្នុងជីវិតរបស់យើង និងជីវិតសមាជិកគ្រួសាររបស់យើងឬទេ ?

ខ្ញុំជឿលើការគោរពថ្ងៃបរិសុទ្ធ ។ ខ្ញុំថ្លែងជាសាក្សីម៉ឺងម៉ាត់ និងដោយរាបសារថា ការរក្សាថ្ងៃបរិសុទ្ធ គឺជាបទបញ្ញត្តិមួយរបស់ព្រះយើង ដែលមានព្រះជន្មរស់ ហើយដែលស្រឡាញ់យើងម្នាក់ៗ ។ ខ្ញុំថ្លែងទីបន្ទាល់ថា បើយើងនឹងធ្វើតាម ហើយរស់នៅតាមបញ្ញាព្រះ ដើម្បីរក្សាថ្ងៃបរិសុទ្ធឲ្យបរិសុទ្ធ នោះព្រះអម្ចាស់ នឹងប្រទានពរដល់យើង ដឹកនាំយើង ហើយបំផុសគំនិតយើងនៅក្នុងការដោះស្រាយបញ្ហា ដែលប្រឈមមុខនឹងយើងវិញ ។ ■

រូបគំនូរដោយ ឃើន ស្ពីរ៍



# បន្ថែមពីលើ
# ភាពជោគជ័យ

**ដោយ ដានីយ៉ែល កាវ៉េ**

នៅពេលខ្ញុំមានអាយុ 14 ឆ្នាំ គ្រូបង្រៀនរូបវិទ្យា បានឃើញពីទេពកោសល្យរបស់ខ្ញុំខាងគណិតវិទ្យា ហើយបានឲ្យខ្ញុំចូលទៅក្នុងការប្រគួតប្រជែងប្រឡងគណិតវិទ្យានៅប្រទេសប្រេស៊ីល ។ មានដំណាក់កាលបី ។ ដំណាក់កាលទីមួយ និង ទីពីរ នឹងធ្វើឡើងនៅថ្ងៃសៅរ៍ ។ ខ្ញុំត្រូវបានជាប់ទៅដំណាក់កាលទីបី ហើយបានឃើញថា វានឹងធ្វើឡើងពីរថ្ងៃ គឺ ថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យ ។

បន្ទាប់មក ខ្ញុំបានប្រាប់គ្រូ និងនាយកនៃការប្រឡងរបស់ខ្ញុំថា ខ្ញុំនឹងមិនធ្វើការប្រឡងនៅថ្ងៃអាទិត្យទេ ដោយសារវាជាថ្ងៃរបស់ព្រះអម្ចាស់ ។ នាយកសាលាបានសុំខ្ញុំឲ្យនិយាយជាមួយនឹងអ្នកដឹកនាំសាសនាចក្ររបស់ខ្ញុំ ដើម្បីឲ្យខ្ញុំអាចទៅប្រឡងនៅថ្ងៃអាទិត្យ ព្រោះបើខ្ញុំពុំប្រឡងទេ នោះខ្ញុំនឹងត្រូវធ្លាក់ ។ ខ្ញុំបាននិយាយថា ខ្ញុំអាចលះបង់អ្វីៗទាំងអស់បាន ប៉ុន្តែខ្ញុំមិនអាចលះបង់ព្រះបានទេ ។

ខ្ញុំពុំសោកស្ដាយទេ ពីព្រោះខ្ញុំមានសង្ឃឹមថា ព្រះឲ្យកិត្តិយសដល់អ្នកទាំងឡាយណាដែលគោរពទ្រង់ ។ ខ្ញុំបានចាំ ម៉ាថាយ 6:33ថា ៖ « ចូរស្វែងរកនគរ នឹងសេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង » ។

ប៉ុន្មានសប្ដាហ៍ក្រោយមក យើងបានទាក់ទងទៅលេខាខាងការប្រឡងនោះ ជាអ្នកដែលបានប្រាប់ថា ខ្ញុំពុំអាចធ្វើការប្រឡងនៅថ្ងៃណាផ្សេងបានទេ ហើយថាខ្ញុំនឹងត្រូវគេបញ្ឈប់ ។ បន្ទាប់ពីការសន្ទនាជាច្រើន គាត់បានឲ្យយោបល់ដល់ខ្ញុំថា ខ្ញុំត្រូវសរសេរអ៊ីម៉ែលមួយទៅគាត់ពន្យល់អំពីស្ថានភាព ។ បន្ទាប់ពីការផ្ញើអ៊ីម៉ែលនោះ ខ្ញុំបានអធិស្ឋានដល់ព្រះវរបិតាសួគ៌ ហើយនិយាយថា ខ្ញុំនឹងធ្វើតាមព្រះទ័យទ្រង់ ។

នៅយប់ក្រោយមក ខ្ញុំបានទទួលអ៊ីម៉ែលមួយមកពីអ្នកសម្របសម្រួល ដែលប្រាប់ថា ជំនួសឲ្យការប្រលងនៅថ្ងៃអាទិត្យ ខ្ញុំអាចធ្វើការប្រឡងនៅថ្ងៃចន្ទបាន តាមពេលដែលល្អបំផុតសម្រាប់ខ្ញុំ ហើយគាត់ថែមទាំងផ្ដល់ឲ្យការប្រឡងនោះនៅក្នុងទីក្រុងខ្ញុំផ្ទាល់ ដើម្បីខ្ញុំនឹងមិនខានរៀន ពេលព្រឹកនៅសាលារៀន ។

បន្ទាប់ពីបានទទួលដំណឹងល្អនេះ ខ្ញុំបានអធិស្ឋានអរគុណដល់ព្រះអម្ចាស់ ដោយសារទ្រង់បានជួយខ្ញុំ ។ ឪពុកម្ដាយរបស់ខ្ញុំ បានទៅព្រះវិហារបរិសុទ្ធដើម្បីថ្លែងអំណរគុណ ។

**យោបល់គន្លឹះគឺអំពីការរក្សាថ្ងៃបរិសុទ្ធ**

« ព្រះអម្ចាស់ បានប្រទានថ្ងៃបរិសុទ្ធសម្រាប់ជាប្រយោជន៍របស់អ្នក និងបានបញ្ជាឲ្យអ្នករក្សាវាឲ្យបាន បរិសុទ្ធ ។

« ការគោរពដល់ថ្ងៃបរិសុទ្ធ រួមមានទាំងការចូលរួមរាល់ការប្រជុំក្នុងសាសនាចក្រទាំងអស់របស់អ្នក ។ . . .

« ចូររៀបចំក្នុងអំឡុងសប្ដាហ៍ ដើម្បីឲ្យអ្នកអាចរក្សាថ្ងៃអាទិត្យ សម្រាប់សកម្មភាពនានា ដែលលើកតម្កើងដែលសមរម្យសម្រាប់ថ្ងៃបរិសុទ្ធ ។ . . .

« ការគោរពថ្ងៃបរិសុទ្ធនឹងនាំឲ្យអ្នកខិតកាន់តែជិតព្រះអម្ចាស់ និងក្រុមគ្រួសាររបស់អ្នក ។វានឹងផ្ដល់ដល់អ្នកនូវទស្សនវិស័យដ៏អស់កល្បជានិច្ច និងកម្លាំងខាងវិញ្ញាណ » ។

***ដើម្បីកម្លាំងនៃយុវជន*** **( កូនសៀវភៅ ឆ្នាំ 2011 ) ទំព័រ 27 ។**

នៅពេលលទ្ធផលប្រឡងចេញមក ខ្ញុំបានទទួលមេដាយមាស ។ ព្រះអម្ចាស់ឲ្យកិត្តិយសដល់អ្នកទាំងឡាយដែលគោរពទ្រង់ ។ ■



*អ្នកនិពន្ធរស់នៅ សៅ ផាឡូ ប្រទេស ប្រេស៊ីល ។*

# ទៅកាន់គោលដៅ

## តើយុវជនត្រូវតែ **បម្រើបេសកកម្ម** ពេលគេឈានចូលដល់អាយុ 18 ឆ្នាំភ្លាមឬ ? ហើយតើយុវនារីត្រូវបានលើកទឹកចិត្តកាន់តែខ្លាំងបន្ថែមទៀត ដើម្បីបម្រើបេសកកម្មនាពេលឥឡូវនេះ ដើម្បីពួកគេអាចទៅនៅអាយុ 19 ឆ្នាំឬ ?

**នៅ**ពេលប្រធាន ថូម៉ាស អេស ម៉នសុន បានប្រកាសអំពីការផ្លាស់ប្ដូរអាយុដែលអាចទៅបម្រើជាអ្នកផ្សព្វផ្សាយសាសនា នោះលោកមានប្រសាសន៍ថា « ខ្ញុំពុំឲ្យយោបល់ថា គ្រប់យុវជនទាំងអស់ នឹង— ឬ គួរតែ— បម្រើនៅពេលដល់អាយុនេះនោះទេ ។ ប៉ុន្តែដោយផ្អែកលើកាលៈទេសៈរបស់បុគ្គល ក៏ដូចជាផ្អែកទៅលើការសម្រេចចិត្តដោយអ្នកដឹកនាំបព្វជិតភាពនានា នោះជម្រើសនេះ បានអនុវត្តក្នុងពេលឥឡូវនេះ ។[1] ចូរពិចារណាអំពីសុខភាពខាងរាងកាយ និងខាងសតិអារម្មណ៍របស់អ្នក ការរៀបចំខាងថវិកា និងការរៀបចំខាងវិញ្ញាណ ។ អ្នកអាចប្រឹក្សាជាមួយឪពុកម្ដាយ និងអ្នកដឹកនាំបព្វជិតភាព អំពីពរជ័យទាំងនេះ នៅពេលសម្រេចចិត្តអំពីពេលត្រឹមត្រូវដើម្បីបម្រើ ។

ស្ដីអំពីយុវនារី ប្រធាន ម៉នសុន បានមានប្រសាសន៍ថា « យុវនារី. . . ពុំស្ថិតនៅក្រោមការបង្គាប់ដូចគ្នានេះ ដើម្បីបម្រើដូចជាយុវជននោះទេ ។ ទោះយ៉ាងណា យើងសូមអះអាងនឹងយុវនារីទាំងឡាយក្នុងសាសនាចក្រថា ពួកគេនឹងចូលរួមចំណែក យ៉ាងមានតម្លៃក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ហើយយើងសូមស្វាគមន៍ចំពោះការបម្រើរបស់ពួកគេ » ។[2] ■

**កំណត់សំគាល់**

1. ថូម៉ាស អេស. ម៉នសុន « Welcome to Conference » *Liahona*, ខែវិច្ឆិកា ឆ្នាំ 2012, ទំព័រ 4–5 ។
2. ថូម៉ាស អេស. ម៉នសុន « Welcome to Conference » 5 ។

## តើខ្ញុំអាចធ្វើអ្វីខ្លះ បើខ្ញុំទទួល **សម្ពាធឲ្យល្មើសបទដ្ឋានសាសនាចក្រ** ដោយយុវវ័យដទៃទៀត ដែលជាសមាជិកសាសនាចក្រសកម្មផងដែរនោះ ? ខ្ញុំពុំចង់បង្ហាញថាជាអ្នកសុចរិតតែខ្លួនឯង ឬអ្នកវិនិច្ឆ័យនោះទេ ។

**ចូ**រមានភាពក្លាហាន ដើម្បីឈរសម្រាប់បទដ្ឋានទាំងឡាយនៃសាសនាចក្រ ទោះជាមានសម្ពាធកំពុងតែមកពីយុវជនពួកបរិសុទ្ធថ្ងៃចុងក្រោយដទៃទៀត ដែលស្គាល់បទដ្ឋាន ហើយដែលអាចគេគិតថា អ្នកកំពុងតែធ្វើជាមនុស្សសុចរិតតែខ្លួនឯងក្ដី ។ តើមួយណាមានភាពប្រថុយប្រថានខ្លាំងជាង ៖ ការមិនគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់ ឬការធ្វើឲ្យដូចជាមិត្តរបស់អ្នកមួយចំនួន ? ( ឥឡូវ បើគេកំពុងដាក់សម្ពាធមកដល់អ្នកឲ្យធ្វើអ្វីមួយ ដែលធ្វើឲ្យអ្នកមានអារម្មណ៍មិនស្រណុក *ក្នុងខ្លួន*ឬដែលល្មើសនឹងបទដ្ឋានមួយ ដែលបានដាក់ដោយ*គ្រួសារ*របស់អ្នក ជាជាងសាសនាចក្រ នោះអ្នកនៅតែអាចឈរសម្រាប់ខ្លួនអ្នក ដោយនិយាយសាមញ្ញថា អ្នកសុំមិនធ្វើវា ហើយសុំឲ្យពួកគេគោរពដល់អារម្មណ៍របស់អ្នក ) ។



ប្រាកដណាស់ អ្នកគួរតែព្យាយាម ដើម្បីគ្រប់គ្រងស្ថានភាពជាក់ស្ដែង ។ ដូចដែលព្យាការី អាលម៉ា បានប្រាប់ដល់កូនប្រុសជាអ្នកផ្សព្វផ្សាយសាសនារបស់គាត់ ស៊ីបឡុនថា « ចូរប្រើសេចក្ដីក្លាហាន ប៉ុន្តែកុំកោងកាច » អាលម៉ា 38:12 ។ ពុំចាំបាច់មានការស្ដីបន្ទោសខ្លាំងៗ ឬឥរិយាបថវាយឫកនោះទេ ។ អ្នកអាចគ្រាន់តែប្រាប់ឲ្យគេដឹងតាមធម្មតានូវបទដ្ឋានអ្វីខ្លះ ដែលអ្នកបានជ្រើសរើសរស់នៅតាមបានហើយ ។ ហើយបើសិនជាសមាជិកសកម្មក្នុងសាសនាចក្រ សុំឲ្យអ្នកល្មើសនឹងបទដ្ឋានសាសនាចក្រដែលដឹងច្បាស់ហើយនោះ ចូរចងចាំនូវអ្វីដែលប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ជាទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ បានមានប្រសាសន៍ថា ៖ « ចូរធ្វើជាមិត្តចំពោះមនុស្សទូទៅទាំងអស់ ប៉ុន្តែកុំបន្ទាបបទដ្ឋានរបស់អ្នកឲ្យសោះ » ។[1] ■

**កំណត់ចំណាំ**

1. ឌៀថើរ អេស្វ អុជដូហ្វ « Your Wonderful Journey Home » *Liahona*, ខែឧសភា ឆ្នាំ 2013, ទំព័រ 128 ។

រចនារូបថតដោយ ម៉ាថាយ រៀ

# ពរជ័យ ទាំងសងខាង




*ការចូលរួមក្នុងព្រះវិហារបរិសុទ្ធ និងពង្សប្រវត្តិ គឺសំខាន់ទាំងពីរ នៅពេលបានរួមបញ្ចូលគ្នា នោះវានាំមកនូវពរជ័យបន្ថែមទៀត ។*

**ដោយប្រ៊ីតានី ប៊ីធី**
ទស្សនាវដ្ដីសាសនាចក្រ

នៅពេលអ្នកបើកទំព័រទស្សនាវដ្ដី *លីអាហូណា*ខែនេះ សូមរកមើលបណ្ដុំពណ៌ផ្សេងៗជាច្រើន ដែលធ្វើឲ្យរូបភាពគំនូ ឬការរចនានីមួយៗមានភាពទាក់ទាញ និងស្រស់ស្អាតយ៉ាងខ្លាំងនោះ ។ ពណ៌ជាច្រើន អាចកើតមានឡើងបានដោយសារពណ៌សំខាន់ពីរគឺ —ក្រហម លឿង ឬខៀវ —ដាក់បញ្ចូលគ្នាដើម្បីបង្កើតពណ៌ថ្មី ពណ៌មួយដែលពុំអាចកើតមានឡើងបាន បើពណ៌សំខាន់ទាំងនេះ នៅដាច់ដោយឡែកពីគ្នា ។

ពង្សប្រវត្តិ និង កិច្ចការព្រះវិហារបរិសុទ្ធមានភាពស្រដៀងគ្នាក៏ដូចជាពណ៌ទាំងនោះដែរ ៖ អ្នកអាចទទួលបានពរជ័យបន្ថែមទៀតដោយការបញ្ចូលនូវការងារសំខាន់ៗពីរនេះរួមគ្នា ។ នោះគឺដោយសារពង្សប្រវត្តិ និងកិច្ចការព្រះវិហារបរិសុទ្ធ តាមធម្មតា ជាផ្នែកពីរនៃកិច្ចការតែមួយ —ជាកិច្ចការនៃសេចក្ដីសង្គ្រោះ ។ ប្រាកដណាស់ អ្នកនឹងនៅតែទទួលបានពរជ័យដ៏មហិមា តាមរយៈការជួយដល់អ្នកដទៃធ្វើពង្សប្រវត្តិរបស់ពួកគេ និងការចូលរួមក្នុងព្រះវិហារបរិសុទ្ធដើម្បីធ្វើកិច្ចការសម្រាប់អ្នក

ទាំងឡាយដែលឈ្មោះ មានផ្ដល់ឲ្យនៅទីនោះ ។ ប៉ុន្តែអ្នកទទួលបានពរជ័យកាន់តែមហិមា— រីករាយនឹងពណ៌ជាច្រើនដេរដាស —នៅពេលអ្នករួមបញ្ចូលផ្នែកទាំងពីរជាមួយគ្នា ហើយរកឈ្មោះគ្រួសារ*របស់យើងផ្ទាល់* ហើយធ្វើកិច្ចការសម្រាប់*ជីដូនជីតា*របស់អ្នកនៅក្នុងព្រះវិហារបរិសុទ្ធ ។

ដូចដែលអែលឌើរ រីឆាដ ជី ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀន ៖

« កិច្ចការព្រះវិហារបរិសុទ្ធ និង ពង្សប្រវត្តិ គឺជាកិច្ចការមួយដែលចែកជាពីរផ្នែក ។ . . .

« ព្រះវរបិតានៅស្ថានសួគ៌សព្វព្រះទ័យឲ្យយើងម្នាក់ៗទទួលបានពរជ័យទាំងសងខាងនៃកិច្ចការជំនួសដ៏សំខាន់នេះ ។ ទ្រង់បានដឹកនាំអ្នកផ្សេងឲ្យបង្ហាញយើងពីរបៀបដើម្បីធ្វើបាន ។ វាស្ថិតលើអ្នក និងខ្ញុំទេ ដែលត្រូវទទួលយកពរជ័យទាំងនោះ ។

« កិច្ចការអ្វីដែលអ្នកធ្វើនៅក្នុងព្រះវិហារបរិសុទ្ធ គឺជាពេលដែលបានចំណាយយ៉ាងល្អ ប៉ុន្តែការទទួល ពិធីបរិសុទ្ធ ជំនួសឲ្យជីដូនជីតាផ្ទាល់របស់អ្នកម្នាក់ នឹងធ្វើឲ្យពេលវេលាក្នុងព្រះវិហារបរិសុទ្ធកាន់តែ ពិសិដ្ឋ ហើយថែមទាំងទទួលបានពរជ័យកាន់តែអស្ចារ្យទៀតផង » ។[1]

ដូច្នេះ តើ « ពរជ័យកាន់តែមហិមា » មួយចំនួន ដែលកើតមាន នៅពេលយើងទទួល « ពរជ័យទាំងសងខាង » មានអ្វីខ្លះ ? នៅផ្នែកខាងស្ដាំមានការសន្យាមួយចំនួនចេញមកពីសាវកសម័យទំនើប ។



### *ការបន្សុទ្ធ ឥទ្ធិពលខាងវិញ្ញាណ*

« កិច្ចការពង្សប្រវត្តិរបស់សមាជិកសាសនាចក្រ មានឥទ្ធិពលបន្សុទ្ធ ឥទ្ធិពលខាងវិញ្ញាណ ឥទ្ធិពលស្រទន់មកលើអ្នកទាំងឡាយណាដែលទាក់ទងនឹងកិច្ចការនោះ ។ពួកគេយល់ថា ពួកគេកំពុងតែចងចំណងគ្រួសាររបស់គេជាមួយគ្នា ។. . . នៅពេលយើងស្រាវជ្រាវរកខ្សែស្រឡាយរបស់យើងផ្ទាល់ នោះយើងចាប់អារម្មណ៍កាន់តែខ្លាំងជាងគ្រាន់តែរកឈ្មោះ . . .ចំណាប់អារម្មណ៍របស់យើង បង្វែរដួងចិត្តរបស់យើងទៅរកជីដូនជីតាយើង យើងព្យាយាមដើម្បីស្វែងរកពួកគាត់ ហើយដើម្បីស្គាល់ និង បម្រើដល់ពួកគាត់ » ។[2]



### *ចំណែកនៃកិច្ចការកាន់តែអស្ចារ្យមួយ*

« ទំនាក់ទំនងខាងវិញ្ញាណ . . . ត្រូវបានបង្កើតឡើង ។. . . នៅពេលដួងចិត្តរបស់យើង បង្វែរទៅរកជីដូនជីតារបស់យើង នោះមានអ្វីមួយផ្លាស់ប្ដូរនៅក្នុងខ្លួនយើងហើយ ។យើងមានអារម្មណ៍ថាមានចំណែកអ្វីមួយដែលខ្លាំងជាងខ្លួនយើង » ។[3]



### *ការចាំយាមទប់ទល់នឹងការល្បួង*

« យើងម្នាក់ៗទទួលបានប្រយោជន៍មកពីមរណៈជនទាំងអស់។ការរៀននូវរឿងទាំងឡាយនោះ ជួយយើងឲ្យកាន់តែយល់ពិតថា យើងជានរណា ហើយយើងមកពីកន្លែងណា ។. . . តើអ្នកកំពុងតែធ្វើការស្រាវជ្រាវរកគ្រួសារផ្ទាល់ខ្លួនរបស់អ្នក ហើយកំពុងតែជួយដល់អ្នកដទៃធ្វើការស្រាវជ្រាវរកគ្រួសាររបស់គេដែរឬទេ ? សម្រាប់មនុស្សវ័យក្មេងម្នាក់នៅក្នុងពិភពលោកទុច្ចរិត ដែលយើងរស់នៅសព្វថ្ងៃ នោះគឺជាការចាំយាមដ៏មហិមាបំផុតមួយទប់ទល់នឹងការល្បួងនៃមារសត្រូវ » ។[4]



### *ជំនួយមកពីពិភពដែលមើលមិនឃើញ*

« ប្រសិនបើយើងនឹងធ្វើកិច្ចការរបស់យើង ជំនួសឲ្យអ្នកទាំងឡាយនៅក្នុងពិភពដែលមើលមិនឃើញ ដែលពួកគាត់ទន្ទឹង និងអធិស្ឋានសុំឲ្យយើងអាចធ្វើកិច្ចការសម្រាប់ពួកគាត់ នោះពិភពដែលមើលមិនឃើញ នឹងផ្ដល់ជំនួយមកយើងវិញនៅថ្ងៃនេះក្នុងតម្រូវការបន្ទាន់របស់យើង ។មានបុគ្គលយ៉ាងច្រើននៅពិភពដទៃជាងនៅទីនេះ ។មានអំណាច និង កម្លាំងខ្លាំងជាងនៅទីនោះ ជាងយើងមាននៅលើផែនដីនេះ » ។[5]

**កំណត់ចំណាំ**

1. រីឆាដ ជី ស្កត « The Joy of Redeeming the Dead » *Liahona*, ខែវិច្ឆិកា ឆ្នាំ 2012, ទំព័រ 93–94 ។
2. ប៊ីយដ៍ ឃេ ផាកកឺ « Your Family History: Getting Started » *Liahona*, ខែសីហា ឆ្នាំ 2003, ទំព័រ 17 ។
3. រ័សុល អិម ណែលសិន « Generations Linked in Love » *Liahona*, ខែឧសភា ឆ្នាំ 2010, ទំព័រ 92 ។
4. ដេវីឌ អេ បែដណា « The Time Is Now » lds.org/youth/family-history/leaders ។
5. ចន អេ វីឌសូ នៅក្នុង Conference Report ខែមេសា ឆ្នាំ 1943, ទំព័រ 39 ។

រូបថតដោយ វែលឌិន ស៊ី អាន់ឌើសិន និង ស៊ូ ប្រូមីហ្វិល គ្រីស្ទេនសិន ចន អេ វីឌសូ ដោយ អា អឺ ហ្វ៊ីក



## ខ្ញុំរកបានឈ្មោះមួយ

« ដើម្បីត្រៀមខ្លួនសម្រាប់ការធ្វើដំណើរទៅកាន់ព្រះវិហារបរិសុទ្ធជាក្រុមយុវវ័យវួដ យើងបានរៀបចំ សកម្មភាពម៉ូឆលមួយ ដើម្បីស្រាវជ្រាវរកឈ្មោះគ្រួសារដែលយើងអាចនាំទៅព្រះវិហារបរិសុទ្ធ ។ ខ្ញុំអង្គុយនៅជិតមិត្តរបស់ខ្ញុំ ហើយក៏រអ៊ូរទាំខ្លះៗថា ខ្ញុំរកមិនបានឈ្មោះដែលចាំបាច់ត្រូវធ្វើពិធីបរិសុទ្ធបានសោះ ។ បន្ទាប់ពីធ្វើការស្រាវជ្រាវយ៉ាងច្រើន familysearch.org ខ្ញុំរកឃើញឈ្មោះមួយ ។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ !

« ខ្ញុំក៏ប្រញាប់រត់ទៅជួបអ្នកប្រឹក្សាខាងពង្សប្រវត្តិរបស់យើង ហើយសួរគាត់ថាត្រូវធ្វើនូវជំហានបន្ទាប់ទៀតអ្វីខ្លះ ។ គាត់បានបង្ហាញខ្ញុំនូវរបៀបដើម្បីរក្សាឈ្មោះទុក ហើយបោះពុម្ពចេញ ដើម្បីខ្ញុំអាចធ្វើកិច្ចការ ព្រះវិហារបរិសុទ្ធ ។ គាត់ក៏បាននិយាយផងដែរថា ស្ត្រីនេះ គឺជាបុគ្គលពិតម្នាក់ មិនមែនគ្រាន់តែជាឈ្មោះនៅលើអេក្រង់នោះទេ ។ ខ្ញុំទទួលអារម្មណ៍ពីព្រះវិញ្ញាណ ហើយដឹងថា បុគ្គលនេះកំពុងរង់ចាំកិច្ចការរបស់គាត់ ត្រូវបានធ្វើឲ្យសម្រេច ហើយកំពុងរង់ចាំខ្ញុំឲ្យរកឈ្មោះរបស់គាត់ ។ ខ្ញុំអាចនាំឈ្មោះគាត់ទៅព្រះវិហារបរិសុទ្ធ ។ ខ្ញុំមានអំណរគុណណាស់ដើម្បីមានឱកាសបម្រើដល់ជីដូនជីតារបស់ខ្ញុំ ហើយជួយនាំក្ដីអំណរនៃដំណឹងល្អដល់គាត់ » ។

លៀ ជី នូវយ៉ោក ស.ហ.អា



### *ចុះបើខ្ញុំគ្មានអ៊ិនធើណិតផង ?*

ទោះជាឈ្មោះពង្សប្រវត្តិរបស់អ្នក ចាំបាច់ត្រូវផ្ញើរទៅតាមអ៊ិនធើណិតដើម្បីធ្វើកិច្ចការព្រះវិហារបរិសុទ្ធសម្រាប់ពួកគេក្ដី ក៏អ្នកពុំចាំបាច់មានអ៊ិនធើណិតនៅផ្ទះដែរ ។ ចូរប្រមូលឈ្មោះ ព័ត៌មាន និងរឿងគ្រួសារ មកពីសាច់ញាតិនៅរស់របស់អ្នកមក ហើយរកមើល បើសិនជាមានមជ្ឈមណ្ឌលពង្សប្រវត្តិនៅក្នុងមូលដ្ឋាន ដែលអ្នកអាចផ្ញើឈ្មោះទាំងនោះបាន familysearch.org ។ នៅក្នុងតំបន់ទាំងឡាយ ដែលអ៊ិនធើណិតមានដែនកំណត់ ចូរនិយាយទៅកាន់អ្នកប្រឹក្សាខាងពង្សប្រវត្តិក្នុងវួដ ឬ ស្ដេក អំពីធនធានទាំងឡាយដែលពួកគេមានដើម្បីវាយបញ្ចូលទិន្នន័យជាអេឡិចត្រូនិចសម្រាប់អ្នក ។



### *តើនោះមានន័យថា ខ្ញុំពុំគួរទៅព្រះវិហារបរិសុទ្ធ បើខ្ញុំពុំមានឈ្មោះគ្រួសារទៅទេនោះ ?*

ពុំមែនទេ !ការចូលរួមក្នុងព្រះវិហារបរិសុទ្ធនាំមកនូវពរជ័យដ៏បរិបូរ ទាំងសម្រាប់អ្នក និងអ្នកទាំងឡាយដែលអ្នកបានជ្រមុជទឹកជំនួស ធ្វើពិធីបញ្ជាក់ជំនួស មិនថាពួកគេជាជីដូនជីតារបស់អ្នក ឬអត់នោះទេ ។អ្នកគួរតែទៅចូលរួមព្រះវិហារបរិសុទ្ធ ទោះជាអ្នកគ្មានឈ្មោះគ្រួសារម្នាក់ក្ដី ។គណៈប្រធានទីមួយបានបង្រៀនថា ៖ « សមាជិកដែលលទ្ធភាពមានកម្រិត ក្នុងការធ្វើការស្រាវជ្រាវពង្សប្រវត្តិសម្រាប់គ្រួសារគេផ្ទាល់ ត្រូវបានលើកទឹកចិត្តឲ្យធ្វើពិធីបរិសុទ្ធជំនួសឲ្យឈ្មោះដែលបានផ្ដល់ឲ្យ ដោយសមាជិកដទៃទៀត ឬដោយព្រះវិហារបរិសុទ្ធ » ( លិខិតគណៈប្រធានទីមួយ ថ្ងៃទី 8 ខែតុលា ឆ្នាំ 2012 ) ។



### ការអញ្ជើញមួយមកពីគណៈប្រធានទីមួយ

« នៅពេលសមាជិកទាំងឡាយនៃសាសនាចក្ររកឃើញឈ្មោះជីដូនជីតារបស់ខ្លួន ហើយយកឈ្មោះទាំងនោះទៅកាន់ព្រះវិហារបរិសុទ្ធ ដើម្បីធ្វើពិធីបរិសុទ្ធនោះនឹងទទួលបាននូវបទពិសោធន៍នៃព្រះវិហារបរិសុទ្ធយ៉ាងលើសលប់ ។. . . យើងសូមលើកទឹកចិត្តជាពិសេសដល់យុវវ័យ . . . ឲ្យធ្វើកិច្ចការព្រះវិហារបរិសុទ្ធសម្រាប់ឈ្មោះជីដូនជីតារបស់ខ្លួន ឬសម្រាប់ជីដូនជីតានៃសមាជិកដែលនៅក្នុងវួដ និងស្ដេករបស់ពួកគេ » ។

**សារលិខិតគណៈប្រធានទីមួយចុះថ្ងៃទី 8 ខែ តុលា ឆ្នាំ 2012 ។**



# សំឡេងយុវវ័យ ៖ ពរជ័យទាំងឡាយនៃពង្សប្រវត្តិ

ថ្មីៗនេះ យុវវ័យមកពីទីក្រុង នូវយ៉ោក ស.រ.អា. ត្រូវបានអញ្ជើញដោយគណៈប្រធានស្តេកទៅស្វែងរកឈ្មោះមួយ ដើម្បីនាំយកទៅព្រះវិហារបរិសុទ្ធ ជាផ្នែកមួយនៃសន្និសីទយុវវ័យពិសេសមួយ ។ ពួកគេបានរកឃើញពរជ័យដ៏មហិមា នៅពេលពួកគេមានអារម្មណ៍ថា ដួងចិត្តរបស់ពួកគេបានបង្វែរទៅកាន់ឪពុករបស់ពួកគេ ( សូមមើល ម៉ាឡាគី 4:5–6 ) ។

## នាំឈ្មោះគ្រួសារទៅកាន់ព្រះវិហារបរិសុទ្ធ

- « ខ្ញុំធ្លាប់គិតថា ពង្សប្រវត្តិ គឺគ្រាន់តែជារឿងមួយទៀតដើម្បីធ្វើ ប៉ុន្តែឥឡូវខ្ញុំដឹងថា ឈ្មោះទាំងនេះ គឺជាបុគ្គល*ពិត* ដែលកំពុងរង់ចាំអស់រយៈពេលជាច្រើនឆ្នាំហើយ ។ បទពិសោធន៍ព្រះវិហារបរិសុទ្ធរបស់ខ្ញុំ គឺមានភាពខុសប្លែកពេលដែលខ្ញុំនាំឈ្មោះគ្រួសារទៅ ។ ខ្ញុំគិតថា វាគឺដោយសារតែកិច្ចខិតខំ ពេលវេលា និងការអធិស្ឋានដែលបានធ្វើ ដើម្បីទៅស្វែងរកឈ្មោះ*មួយ*នោះ ។ ប៉ុន្តែឈ្មោះ *មួយ* គឺមានតម្លៃហើយ ដោយសារនោះជា *មនុស្សម្នាក់* ដែលត្រូវការនៅជាមួយព្រះវរបិតាឯស្ថានសួគ៌ » ។ —ហានណា អេ., អាយុ 13 ឆ្នាំ
- « បន្ទាប់ពីការស្វែងរកឈ្មោះបុគ្គលម្នាក់ នោះអ្នកចាប់ផ្តើមមានទំនាក់ទំនងនឹងបុគ្គលនោះនៅពិភពវិញ្ញាណ ។ ការនាំឈ្មោះផ្ទាល់របស់អ្នក គឺជាវិធីមួយដើម្បីពង្រឹងចំណងនេះ ។ វាជួយអ្នកឲ្យយល់ពីគ្រួសារអស់កល្បជានិច្ចរបស់អ្នក » ។ —ស្ពែនសើរ អេស., អាយុ 15 ឆ្នាំ
- « ការនាំឈ្មោះគ្រួសារទៅព្រះវិហារបរិសុទ្ធ ជួយអ្នកដឹងពីភាពពិតថា អ្នកទាំងនោះជានរណា ។ ពួកគាត់មិនមែនគ្រាន់តែជាឈ្មោះនៅលើសន្លឹកក្រដាសមួយនោះទេ ពួកគាត់គឺជាបងប្អូនប្រុសស្រីពិត ដែលចែកចាយប្រវត្តិអ្នក —ហើយជាផ្នែកមួយនៃប្រវត្តិអ្នកនោះ » ។ —លីលី អ៊ិន., អាយុ 16 ឆ្នាំ

## ការទទួលពរជ័យ

- « ខ្ញុំបានកត់សម្គាល់ឃើញភាពខុសគ្នាមួយនៅក្នុងជីវិតខ្ញុំ ។ វាគឺជាអារម្មណ៍ដ៏កក់ក្តៅ និងជាអារម្មណ៍នៃការការពារមួយ » ។ —ណូអេ អ., អាយុ 13 ឆ្នាំ
- « អ្នកអាចមានអារម្មណ៍ក្នុងបេះដូងរបស់អ្នកថាអ្នកមានចំណែកនៅ ក្នុងកិច្ចការមួយដែលកាន់តែប្រសើរ ។ ការផ្តល់ឲ្យគ្រួសាររបស់អ្នកនូវឱកាសដើម្បីទទួលពរជ័យព្រះវិហារបរិសុទ្ធ គឺជាអារម្មណ៍មួយដែលខុសប្លែកពីគេទាំងអស់ » ។ —ខូរីន ស៊ី., អាយុ 17 ឆ្នាំ
- « ខ្ញុំបានមានអារម្មណ៍កាន់តែសុខស្រួល និងស្ងប់ស្ងាត់ចាប់តាំងពីខ្ញុំបានចាប់ផ្តើមធ្វើពង្សប្រវត្តិ ។ នៅពេលខ្ញុំនាំឈ្មោះគ្រួសារទៅព្រះវិហារបរិសុទ្ធ នោះវាផ្តល់នូវអារម្មណ៍នៃក្តីអំណរដ៏លើសលប់មួយ » ។ —ថៃលើរ អិម., អាយុ 16 ឆ្នាំ
- « វាបានបង្កើនសេចក្តីស្រឡាញ់របស់ខ្ញុំចំពោះព្រះអង្គសង្គ្រោះ ព្រះវរបិតាសួគ៌ និងជីដូនជីតារបស់ខ្ញុំ ។ វាបានជួយខ្ញុំឲ្យកាន់តែខិតទៅជិតគ្រួសារផ្ទាល់របស់ខ្ញុំ ហើយបានបង្កើនទីបន្ទាល់របស់ខ្ញុំអំពីដំណឹងល្អ » ។ —អាឡិចសាន់ដ្រា អេច., អាយុ 14 ឆ្នាំ
- « ខ្ញុំសប្បាយរីករាយច្រើនជាងមុន » ។ —រ៉ូស អេស., អាយុ 12 ឆ្នាំ
- « ជាមួយនឹងឈ្មោះនីមួយៗ ខ្ញុំមានអារម្មណ៍នៃក្តីសុខសាន្ត និងរំភើបចិត្តដ៏លើសលប់ ដូចជាមានមនុស្សដែលកំពុងរង់ចាំខ្ញុំ » ។ —រីនុន ប៊ី., អាយុ 15 ឆ្នាំ
- « ខ្ញុំដឹងថាខ្ញុំមកពីកន្លែងណា ហើយទំនុកចិត្តរបស់ខ្ញុំកំពុងតែស្ថាបនាឡើង » ។ —អេលីស្សា អិល., អាយុ 13 ឆ្នាំ
- « ខ្ញុំមិនសូវមានការឈ្លោះទាស់ទែងគ្នានៅក្នុងផ្ទះរបស់ខ្ញុំទេ » ។ —ហ្គេរីហ្គ អិល., អាយុ 12 ឆ្នាំ
- « ខ្ញុំយល់អំពីសារៈសំខាន់នៃក្រុមគ្រួសារកាន់តែច្រើនឡើងៗ ។ ខ្ញុំចង់មានភាពកាន់តែជិតស្និតនឹងគ្រួសាររបស់ខ្ញុំនៅលើផែនដី » ។ —អិមម៉ា អិល., អាយុ 15 ឆ្នាំ
- « វាបានជួយខ្ញុំឲ្យយល់កាន់តែច្រើនអំពីផែនការរបស់ព្រះចំពោះខ្ញុំ ។ ខ្ញុំមានអារម្មណ៍កាន់តែជិតនឹងព្រះវរបិតា និងដំណឹងល្អ ដោយសារតែខ្ញុំបានយល់កាន់តែច្បាស់ អំពីពិធីបរិសុទ្ធដែលកំពុងកើតមានឡើង » ។ —ណូអេ ស៊ី., អាយុ 14 ឆ្នាំ ■

**តើអ្នកនឹងធ្វើអ្វីខ្លះ ?**

តើអ្នកនឹងធ្វើអ្វីខ្លះ ដើម្បី « ប្រកាសពរជ័យទាំងនោះ » នៃការស្វែងរកឈ្មោះគ្រួសារ បន្ទាប់មកនាំឈ្មោះទាំងនោះទៅព្រះវិហាបរិសុទ្ធ ? សូមដាក់ផែនការមួយថ្ងៃនេះ ដើម្បីនាំការសន្យាទាំងឡាយនៃការទទួលពរជ័យទាំងសងខាងមកក្នុងជីវិតរបស់អ្នក ។

# ទីកន្លែងរបស់យើង

## ខគម្ពីរបំផុសគំនិតមួយ

« [ ព្រះយេស៊ូវគ្រីស្ទ ] នឹងអង្វរជំនួសកូនចៅមនុស្សទាំងអស់ ហើយអ្នកណាដែលជឿដល់ទ្រង់នោះនឹងបានសង្គ្រោះ » ( នីហ្វៃទី 2 2:9 ) ។

នៅក្នុងគម្ពីរនេះ ពាក្យ *អង្វរជំនួស* មានអត្ថន័យធំធេងណាស់ ។ វាមានន័យថា « ការធ្វើជាអន្តរាគណ្ដាលដើម្បីជួយដល់ភាគីពីរដោះស្រាយបញ្ហាមួយ » ។ នៅក្នុងករណីនេះ ព្រះអង្គសង្គ្រោះ គឺជាអន្តរាគណ្ដាល ដែលជួយមនុស្សទាំងអស់ដែលបានបែកចេញពីព្រះវរបិតាសួគ៌ ដោយសារតែអំពើបាប ។

បទគម្ពីរនេះ បានជួយខ្ញុំដឹងអំពីសារៈសំខាន់នៃព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំមានអំណរគុណចំពោះដង្វាយធួនរបស់ទ្រង់ ។ មានតែតាមរយៈទ្រង់ប៉ុណ្ណោះ ដែលយើងអាចរស់ម្ដងទៀតនៅជាមួយព្រះបិតារបស់យើងនៅឯស្ថានសួគ៌ ។

ហានីស្សា អេ ប្រទេសឥណ្ឌា





## តើនរណាចង់អធិស្ឋានខ្លះ ?

នៅក្នុងបេសកកម្មរបស់ខ្ញុំ ដៃគូខ្ញុំ និងខ្ញុំ បានបង្រៀនគ្រួសារមួយដែលមានកូនជាច្រើន ។ អំឡុងពេលមួយក្នុងម៉ោងដាក់ផែនការយើងបានអធិស្ឋាន ហើយពិភាក្សាអំពីមេរៀនអ្វី ដែលយើងគួរបង្រៀនដល់កុមារតូចៗបន្ទាប់ទៀត ហើយយើងទាំងពីរនាក់បានយល់ស្របដើម្បីបង្រៀនអំពីការអធិស្ឋាន ។

នៅពេលយើងទៅដល់ផ្ទះរបស់គេ ជីដូន និងចៅៗមានចិត្តរំភើបណាស់ ។ យើងបានចាប់ផ្ដើមមេរៀនដោយការអធិស្ឋាន ។ កុមារនៅស្ងាត់ស្ងៀម ហើយត្រៀមខ្លួនជាស្រេចដើម្បីស្ដាប់ ។ យើងបានពន្យល់ដល់ពួកគេអំពីរបៀប និងមូលហេតុដែលត្រូវអធិស្ឋាន ។ ដើម្បីបញ្ចប់មេរៀនរបស់យើង យើងបានសួរពួកគេថា « តើនរណាចង់អធិស្ឋានបិទ ? » ពួកគេទាំងអស់គ្នាចង់អធិស្ឋាន ! ដូច្នេះយើងបានដាក់កាលវិភាគមួយសម្រាប់ពួកគេ ដើម្បីអធិស្ឋានរាល់ពេលដែលយើងទៅបង្រៀនមេរៀនមួយ ។ យើងក៏បានអញ្ជើញពួកគេឲ្យអធិស្ឋានផងដែរ នៅពេលយើងពុំបាននៅជាមួយនឹងពួកគេ ។

បន្ទាប់ពីមេរៀននោះ ខ្ញុំបានគិតថា « តើហេតុអ្វីបានជាកុមារតូចៗទាំងនេះ ចង់អធិស្ឋាន ខណៈដែលអ្នករៀនវ័យចំណាស់របស់យើង ពិបាកនឹងធ្វើការអធិស្ឋានវិញដូច្នេះ ? ខ្ញុំរកបានចម្លើយមួយនៅក្នុង Bible Dictionary ( វចនានុក្រមព្រះគម្ពីរបរិសុទ្ធ ) ៖ « ដរាបណាយើងរៀនអំពីទំនាក់ទំនងពិតដែលយើងឈរឆ្ពោះទៅរកព្រះ ( ដូចជា ព្រះគឺជាព្រះវរបិតារបស់យើង ហើយយើងគឺជាកូនចៅរបស់ទ្រង់ ) នោះការអធិស្ឋាន នឹងមានលក្ខណៈចេញពីធម្មជាតិហើយ ដោយមិនចាំបាច់បង្ខំនៅក្នុងផ្នែករបស់យើង ( ម៉ាថាយ 7:7 11 ) ។ ការលំបាកជាច្រើនអំពីការអធិស្ឋានបានកើតឡើងមកពីការភ្លេចនូវទំនាក់ទំនងនេះ » ( « ការអធិស្ឋាន » សូមមើលផងដែរ សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ការអធិស្ឋាន » scriptures.lds.org ) ។

ចាប់ពីពេលនោះមក ខ្ញុំបានព្យាយាមជួយមនុស្សឲ្យយល់អំពីទំនាក់ទំនងពិតរបស់ពួកគេជាមួយនឹងព្រះវរបិតាសួគ៌របស់យើង ។ ព្រះវរបិតាសួគ៌របស់យើង ចង់មានបន្ទូលមកកាន់កូនចៅរបស់ទ្រង់ ដូចជាឪពុកម្ដាយនៅលើផែនដីរបស់យើងចង់និយាយនឹងយើងផងដែរ ។ ទ្រង់ស្រឡាញ់យើង ទ្រង់ចង់មានបន្ទូលមកកាន់យើង ហើយទ្រង់ចង់ឲ្យយើងទូលទៅកាន់ទ្រង់ ។

ចាប៉ីល អិម ប្រទេសភីលីពីន

## កិច្ចការពង្សប្រវត្តិរបស់គ្រួសារ

ខ្ញុំបានរកឃើញគោលដៅក្នុងសៀវភៅការអភិវឌ្ឍខ្លួន ដែលបានជម្រុញឲ្យខ្ញុំចាប់ផ្ដើមដើមឈើគ្រួសាររបស់ខ្ញុំ ។ នៅពេលណាដែលខ្ញុំទៅបរិភោគអាហារថ្ងៃត្រង់នៅផ្ទះលោកតាលោកយាយរបស់ខ្ញុំ ពួកគាត់បានប្រាប់ខ្ញុំនូវរឿងជាច្រើនមកពីជីវិតរបស់ពួកគាត់ និងសាច់ញាតិផ្សេងទៀតរបស់ខ្ញុំ ។ ខ្ញុំបានចាប់ផ្ដើមទៅមជ្ឈមណ្ឌលពង្សប្រវត្តិ ហើយប្រមូលព័ត៌មានអំពីគ្រួសារខ្ញុំ ។

ខ្ញុំនៅចាំ ពេលខ្ញុំរកបានព័ត៌មានអំពីលោកយាយលួតរបស់ខ្ញុំ ។ គាត់បានមកប្រទេសអាស្សង់ទីនតាមកប៉ាល់មួយ ពេលគាត់មានផ្ទៃពោះ ។ អំឡុងពេលធ្វើដំណើរតាមកប៉ាល់ គាត់បានកប់សពកូនប្រុសរបស់គាត់នៅក្នុងសមុទ្រ ។ ចំពោះខ្ញុំគាត់គ្រាន់តែជារឿងមួយប៉ុណ្ណោះ រហូតដល់ខ្ញុំបានរកឃើញឈ្មោះរបស់គាត់នៅក្នុងកំណត់ត្រាមួយ ។ ខ្ញុំកាន់តែជិតស្និតនឹងលោកតាលោកយាយរបស់ខ្ញុំ ហើយខ្ញុំបានស្គាល់ជីដូនជីតាខ្ញុំ ដូចខ្ញុំធ្លាប់រស់នៅជាមួយពួកគាត់ដូច្នោះដែរ ។ ខ្ញុំបានរកឃើញព័ត៌មានអំពីជីដូនជីតារបស់ខ្ញុំ បានចែកដំណឹងល្អអំពីការផ្សាភ្ជាប់ដ៏អស់កល្បជានិច្ច ហើយបានជួយប្រទានពរដល់មនុស្សរាប់ជំនាន់ ។

ខ្ញុំបន្តរកឃើញសម្បត្តិដែលកប់លាក់ទុក អរគុណចំពោះកម្មវិធី FamilySearch ។ ខ្ញុំស្រឡាញ់នូវអ្វីដែលប្រធាន ថូម៉ាស អេស ម៉នសុន មានប្រសាសន៍ ៖ « ខ្ញុំថ្លែងទីបន្ទាល់ថា នៅពេលយើងធ្វើដោយអស់ពីសមត្ថភាពយើង ដើម្បីសម្រេចនូវកិច្ចការដែលនៅពីមុខយើង នោះ ព្រះអម្ចាស់នឹងឲ្យយើងនូវកូនសោពិសិដ្ឋដែលចាំបាច់ដើម្បីចាក់បើករតនសម្បត្តិ ដែលយើងស្វែងរកយ៉ាងខ្លាំងនោះ » ។[1] តាមរយៈកិច្ចខិតខំរបស់យើង នោះយើងនឹងរកឃើញកូនសោទាំងឡាយទៅកាន់រតនសម្បត្តិដ៏អស់កល្បជានិច្ចរបស់យើង ហើយថ្ងៃមួយយើងនឹងអាចជួបនឹងជីដូនជីតារបស់យើងដោយផ្ទាល់ ។

យ៉ាអែល ប៊ី., ប្រទេសអាស្សង់ទីន





**កំណត់ចំណាំ**

1. ថូម៉ាស អេស. ម៉នសុន « The Key of Faith » *Ensign*, ខែកុម្ភៈ ឆ្នាំ 1994, ទំព័រ 5; *Tambuli*, ខែឧសភា ឆ្នាំ 1994,ទំព័រ 5 ។

## ការទទួលទីបន្ទាល់មួយ មកពីព្រះវិញ្ញាណបរិសុទ្ធ

នៅពេលខ្ញុំបានចូលរួមសាសនាចក្រនៅអាយុ ប្រាំបួនឆ្នាំ ខ្ញុំបានជឿថា សាសនាចក្រពិតរួចទៅហើយ ដូច្នេះខ្ញុំគិតថា វាពុំចាំបាច់ដើម្បីសួរព្រះ ថាតើសាសនាចក្រពិត ឬអត់នោះទេ ។ បន្ទាប់ពីក្លាយជាសមាជិកអស់រយៈពេលជាច្រើនឆ្នាំមក ខ្ញុំបានចាប់ផ្ដើមសង្ស័យ ។ ពេលនោះក្នុងការប្រជុំសាក្រាម៉ង់ នៅពេលខ្ញុំស្ដាប់ទំនុកតម្កើង « ការអធិស្ឋានដំបូងរបស់យ៉ូសែប ស្ម៊ីធ » ( *ទំនុកកំកើងទំព័រ* 14 ) ខ្ញុំបានអធិស្ឋានសួរព្រះវរបិតាសួគ៌ បើសាសនាចក្រនេះពិត ហើយបើយ៉ូសែប ស្ម៊ីធពិតជាបានឃើញទ្រង់ និងព្រះយេស៊ូវមែនឬ ។ គំនិតមួយបានចូលមកក្នុងសតិខ្ញុំថា ពិត សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ គឺពិត ហើយយ៉ូសែប ពិតជាបានឃើញព្រះជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទមែន ។ ភ្នែកខ្ញុំបានពេញទៅដោយទឹកភ្នែក ហើយខ្ញុំមានអារម្មណ៍ព្រះវិញ្ញាណបរិសុទ្ធដុតកំដៅក្នុងបេះដូងខ្ញុំ ។

ថ្ងៃនេះ ខ្ញុំអាចបញ្ជាក់ថា ព្រះវិញ្ញាណបរិសុទ្ធ បានថ្លែងទីបន្ទាល់ដល់ខ្ញុំអំពីសេចក្ដីពិតពេញលេញនៃសាសនាចក្រនេះ ។ ខ្ញុំដឹងថា យ៉ូសែប ស្ម៊ីធ បានឃើញព្រះជាព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ខ្ញុំពុំអាចបដិសេធបានទេ ។ ទីបន្ទាល់នេះ បានផ្ដល់នូវភាពក្លាហានដល់ខ្ញុំ ដើម្បីចែកចាយទីបន្ទាល់ខ្ញុំជាមួយអ្នកដទៃ ។

ចាម៉ារ៉ា អូ., ប្រទេស ប្រេស៊ីល

ពីឆ្វេង ៖ ព្រះគ្រីស្ទ ដែលរស់ឡើងវិញ ដោយ វ៉លធើរ រ៉ាន អ៊ុង, រចនាដោយអនុគ្រោះពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ រូបថតដោយ ឡេស្លី និលសុន រូបថតដោយអនុគ្រោះ យ៉ាអែល ប៊ី., រូបថត និងស្តុកតិ៍ iStockphoto/Thinkstock

# Hola Amigos !*

# យើងឈ្មោះ ម៉ាហូនរី និង ហេលេមិន មកពីប្រទេស ម៉ិចស៉ិក

រៀបចំកាបូបអ្នកទៅ ! មកជួបនឹងមិត្តនៅជុំវិញពិភពលោក !




រូបថតដោយ ចូនខាឡូស សាន់តូយ៉ូ លំអរូបភាពដោយ ជូម៉ាស ធាល

ចេញមកពីការសម្ភាសមួយជាមួយអាមី ចេន លីវិត

ម៉ាហូនរី និងហេលេមិន គឺជាបងប្អូនប្រុសនឹងគ្នា ដែលរស់នៅលើឆ្នេរសមុទ្រនៃប្រទេសម៉ិកស៉ិក ។ ឪពុកម្ដាយរបស់ពួកគេដាក់ឈ្មោះពួកគេ តាមបុរសដ៏អស្ចារ្យពីរនាក់ក្នុងគម្ពីរមរមន ។ ម៉ាហូនរី ម៉ូរីអានគុមើរ គឺជាបងរបស់យ៉ារេឌ ។ គាត់បានមើលឃើញព្រះអង្គុលីរបស់ព្រះអម្ចាស់ ។ មេបញ្ជាការហេលេមិន គឺជាអ្នកដឹកនាំសុចរិតម្នាក់ ។ គាត់បានដឹកនាំកងទ័ពកម្លោះពីរពាន់នាក់ ។ ■

* « សួស្ដី ! ពួកម៉ាក » ជាភាសាអេស្ប៉ាញ ។



*បងប្អូនប្រុសទាំងនេះ សង្ឃឹមថានឹងរស់នៅតាមឈ្មោះ ដែលឪពុកម្ដាយពួកគេបានដាក់ឲ្យគេ ។ ពួកគេចង់ធ្វើដូចជា ម៉ាហូនរី និងហេលេមិន មកពីព្រះគម្ពីរមរមន ។*



ឪពុកម្ដាយយើង បានផ្សាភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ហ្គូដាឡាចារ៉ា ក្នុងឆ្នាំ 2003 ។ នេះគឺជាព្រះវិហារបរិសុទ្ធដែលជិតជាងគេបំផុត ទៅកន្លែងដែលយើងរស់នៅ ។ វាចំណាយពេលប្រហែលជាប្រាំមួយម៉ោង ដើម្បីធ្វើដំណើរទៅទីនោះ ។ យើងចូលចិត្តទៅទស្សនាព្រះវិហារបរិសុទ្ធ ហើយដឹងថា ថ្ងៃមួយយើងនឹងចូលទៅខាងក្នុង ដូចជាឪពុកម្ដាយរបស់យើងធ្វើនាពេលនេះដែរ ។

## ខ្ញុំចូលចិត្តមើលព្រះវិហារបរិសុទ្ធ



ព្រះវិហារបរិសុទ្ធហ្គូដាឡាយ៉ារ៉ា មិកស៊ីក គឺជាព្រះវិហារបរិសុទ្ធទី 11 នៃព្រះវិហារបរិសុទ្ធទាំងដប់បីក្នុងប្រទេសមិកស៊ិក ។







យើងចូលចិត្តចំណាយពេលជាគ្រួសារ ។ ជារៀងរាល់ថ្ងៃសៅរ៍ យើងទៅមាត់សមុទ្រជិតផ្ទះរបស់យើង ។ យើងបរិភោគបង្គារ—ជាអាហារដែលយើងចូលចិត្ត —និង ជាកូស និងតូទៀរ ( ជាស៊ាំងវិចមួយប្រភេទ ) ។ យើងដើរនៅតាមបណ្ដោយផ្លូវម៉ាឡេគូន ឬផ្លូវនៅជាប់មាត់សមុទ្រ ។ យើងធ្វើប្រាសាទពីដីខ្សាច់ ហើយលេងនៅក្នុងសមុទ្រ ។

## ត្រៀមខ្លួននឹងទៅជាស្រេច !

កាបូបរបស់ម៉ាហូនរី និងហេលេមិន បានដាក់ពេញនូវរបស់សំណប់ចិត្តពួកគេមួយចំនួន ។ តើរបស់ទាំងអស់នេះណាមួយ ដែលអ្នកនឹងវេចនៅក្នុងកាបូបរបស់អ្នក ?



សាក្សីពិសេស



# តើការធ្វើជា**ពួកគ្រីស្ទាន** មានន័យដូចម្ដេច ?

**ដោយអែលឌើរ**
**រ៉ូប៊ើត ឌី ហែល**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*សមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ គឺជាសាក្សីពិសេសរបស់ព្រះយេស៊ូវគ្រីស្ទ ។*




រចនាដោយ អេរុន ប៊ូស៊ី

ចេញមកពី « *Being a More Christian Christian* » Liahona, *ខែវិច្ឆិកា ឆ្នាំ 2012*, 90–92 ។

# លិខិតឆ្លងដែន

## មិត្តភាពនៅជុំវិញពិភពលោក



សូមរកមើលតែមប្រទេសថ្មីមួយ ដើម្បីដាក់នៅក្នុងលិខិតឆ្លងដែនអ្នក នៅក្នុងច្បាប់ទស្សនាវដ្តី*លីអាហូណា*ក្រោយៗ ។



ប្រេស៊ីល



7

តុងហ្គា



8

កូរ៉េខាងត្បូង



9

ប្រទេសឈីលី



10

អង់គ្លេស



11

ស៊ុយអែត



12

Passport
passeport
pasaporte

មិត្តភាពនៅជុំវិញពិភពលោក



រូបថត

លិខិតឆ្លងដែន #

ឈ្មោះ

សញ្ជាតិ

ថ្ងៃខែឆ្នាំកំណើត

កាលបរិច្ឆេទបច្ចុប្បន្ន



ម៉ិកស៊ិក



1

រ៉ុស្ស៊ី



2

ហ្ស៊ីមបាវេ



3

ហ្វីលីពីន



4

នូវែលសេឡង់



5

អ៊ីតាលី



6

# មិត្តភាពនៅជុំវិញពិភពលោក



# ទំព័ររបស់យើង



តាំងពីខ្ញុំនៅតូច ម្ដាយ នឹងឪពុករបស់ខ្ញុំ បានបង្រៀនខ្ញុំអំពីព្រះវិហារបរិសុទ្ធ ។ វានៅឆ្ងាយណាស់ ប៉ុន្តែខ្ញុំចូលចិត្តទៅទីនោះជាមួយគ្រួសារខ្ញុំ ។ នៅពេលខ្ញុំផ្សាភ្ជាប់នឹងឪពុកម្ដាយខ្ញុំ ទីបំផុតខ្ញុំអាចចូលទៅខាងក្នុង —វាស្រស់ស្អាតណាស់ ។ តទ្បូវនៅពេលខ្ញុំទៅ ខ្ញុំរង់ចាំនៅខាងក្រៅ ។ នៅពេលខ្ញុំធំឡើង ខ្ញុំនឹងធ្វើសេចក្ដីសញ្ញាផ្ទាល់ខ្លួនរបស់ខ្ញុំក្នុងព្រះវិហារបរិសុទ្ធ ។

**ដាវីឌ វី អាយុ 6 ឆ្នាំ នីការ៉ាហ្គា**



ខ្ញុំដឹងថា ព្រះយេស៊ូវ គ្រីស្ទមានព្រះជន្មរស់ ហើយថា ទ្រង់យកព្រះទ័យទុកដាក់នឹងយើងទាំងអស់គ្នា ហើយខ្ញុំដឹងថា សាសនាចក្រពិត ។

**អូស៊ីរីស អិម អាយុ 6 ឆ្នាំ ប្រទេស ប្រេស៊ីល**



**ទ្រីស អិម អាយុ 8 ឆ្នាំ ប្រទេសប្រេស៊ីល**



ខ្ញុំពិតជាចូលចិត្តច្រៀងទំនុកតម្កើងនៃសាសនាចក្រ ហើយចូលរួមក្នុងរាត្រីជួបជុំក្រុមគ្រួសារជាមួយគ្រួសារខ្ញុំ ។ ខ្ញុំមានប្អូនពីរនាក់ ឈ្មោះ យ៉ាបេឌ និង សារ៉ា ហើយខ្ញុំស្រឡាញ់ពួកគេណាស់ ។ ខ្ញុំចូលចិត្តជួយដល់ម្ដាយខ្ញុំ នៅពេលគាត់ចម្អិនអាហារ ពីព្រោះនៅពេលខ្ញុំធំឡើង ខ្ញុំចង់ចម្អិនអាហារឲ្យបានឆ្ងាញ់ដូចជាគាត់អញ្ចឹង ។

**អាំបា អេ អាយុ 9 ឆ្នាំ អេក្វាឌ័រ**

ខ្ញុំចូលចិត្តជួយម្ដាយខ្ញុំធ្វើរាត្រីជួបជុំក្រុមគ្រួសារ ។ គ្រួសាររបស់យើង ចង់ទៅព្រះវិហារបរិសុទ្ធ ដូច្នេះយើងអាចរស់នៅជាមួយគ្នាជានិរន្តន៍ ។ នៅពេលខ្ញុំធំឡើង ខ្ញុំចង់បម្រើបេសកកម្មដូចជាបងប្អូនជីដូនមួយរបស់ខ្ញុំ ។ ខ្ញុំស្រឡាញ់ព្រះវរបិតាសួគ៌ និងព្យាការី ប្រធាន ថូម៉ាស អេស ម៉នសុន ។ ខ្ញុំចូលចិត្តចម្រៀងថ្នាក់កុមារ « សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ » ។

**ខេឌី ភី., អាយុ 12 ឆ្នាំ ហុងឌូរ៉ាស**



**ឌី វ៉ាន ហ៊ីប អាយុ 11 ឆ្នាំ ប្រទេសកម្ពុជា**



ខ្ញុំទទួលការបង្រៀននៅក្នុងដំណឹងល្អ ចាប់តាំងពីខ្ញុំនៅតូច ។ នៅពេលខ្ញុំមានអាយុប្រាំបីឆ្នាំ ខ្ញុំបានសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក ។ ខ្ញុំបានទន្ទេញចាំមាត្រានៃសេចក្ដីជំនឿទាំង 13 សម្រាប់ថ្ងៃពិសេសនោះ ។ នៅពេលខ្ញុំចេញមកពីទឹកវិញ ខ្ញុំទទួលអារម្មណ៍អ្វីមួយដ៏ខ្លាំង ។ ម្ដាយរបស់ខ្ញុំ បានប្រាប់ខ្ញុំថា អារម្មណ៍ទាំងនោះមកពីព្រះវិញ្ញាណបរិសុទ្ធ ។ ខ្ញុំដឹងថា យ៉ូសែប ស្ម៊ីធ បានស្ដារសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ថាព្រះគម្ពីរមរមនពិត ហើយថា ប្រធាន ថូម៉ាស អេស ម៉នសុន ជាព្យាការីនៅរស់ ។

**អាប៊ីហ្គេល អេ អាយុ 8 ឆ្នាំ ប្រទេសអេស្ប៉ាញ**



# ដូចជាព្រះគម្ពីរ !

*យើងបានគិតថា ការដើរឡើងភ្នំនឹងអស្ចារ្យណាស់ រហូតដល់យើងបានមើលឃើញសញ្ញានៅតាមផ្លូវលំ ។*

**ដោយ រ៉េណេ ប៉េត ម៉ាគ្គី**
ផ្អែកទៅលើដំណើររឿងពិតមួយ

« *យើងនឹងសម្រាលបន្ទុកទាំងឡាយ ដែលដាក់នៅលើស្មាអ្នកផង* » ( *ម៉ូសាយ 24:14* ) ។

អាយុដប់ឆ្នាំ ឈ្លាសវៃណាស់ ។ យើងចូលចិត្តស្វែងយល់ដោយខ្លួនឯង ។

ឪពុករបស់ខ្ញុំតែងតែប្រាប់ខ្ញុំឲ្យប្រៀបប្រដូចខគម្ពីរមកនឹងខ្លួនខ្ញុំ ។ *ប្រៀបប្រដូច* មានន័យថា អ្នកព្យាយាមប្រើអ្វីដែលអ្នករៀនមកពីខគម្ពីរមកក្នុងជីវិតរបស់អ្នក ។ ដូច្នេះ នៅពេលយើងអានជាមួយគ្នាជាគ្រួសារ ពេលខ្លះខ្ញុំនិយាយភ្លាមមុនពេលឪពុកខ្ញុំពន្យល់វាដល់យើង ។ ដូចជា « ប៉ា ខ្ញុំដឹង យើងត្រូវតមអាហារ និងអធិស្ឋានដូចជាបាននិយាយនៅក្នុងខគម្ពីរ » ។

គាត់ញញឹម ពីព្រោះខ្ញុំតែងតែយល់សារលិខិតត្រឹមត្រូវ ។

ប៉ុន្តែមានគ្រាមួយ ខ្ញុំបានរកឃើញថា ខគម្ពីរពិតជាដូចជាជីវិតខ្ញុំខ្លាំងណាស់ ! វាបានកើតឡើងនៅពេលយើងដើរឡើងភ្នំទៅបោះជំរុំជាគ្រួសារ ។





« ចូរយើងតាំងចិត្តអានគម្ពីរ . . . ឲ្យកាន់តែមានគោលបំណង និងកាន់តែផ្ដោតយកចិត្តទុកដាក់ » ។

**ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ជាទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ « Your Potential, Your Privilege »** ***Liahona,*** **ខែឧសភា ឆ្នាំ 2011,ទំព័រ 59 ។**

ខ្ញុំបានស្ពាយកាបូបធំរបស់ខ្ញុំ និងតង់សម្រាប់ដេក ហើយខ្ញុំមិនរអ៊ូរទាំទេ ។ បន្ទាប់មក វាមានចម្ងាយត្រឹមតែ បួនម៉ែល ( 6.5 គ.ម ) ទៀតប៉ុណ្ណោះទៅដល់ស្ទឹងហើយ ។ ខ្ញុំអាចធ្វើបាន គ្មានបញ្ហាទេ ។

ការដើរឡើងភ្នំពុំពិបាកខ្លាំងទេ ប៉ុន្តែខ្ញុំរីករាយដើម្បីឈប់សម្រាកម្ដង បន្ទាប់ពីដើរបានពីរម៉ែល ( 3 គ.ម ) ។ បន្ទាប់មកយើងមើលឃើញសញ្ញាតាមផ្លូវលំដំបូងគេ ។ សញ្ញាប្រាប់ថា ស្ទឹងគឺនៅមានចម្ងាយប្រាំមួយម៉ែល ( 9.5 គ.ម ) ទៀត ។ ឪពុកខ្ញុំពុំចាំបាច់ប្រាប់ខ្ញុំថា ផ្លូវលំនោះនឹងមានចម្ងាយពីរដងទៀត ឆ្ងាយជាងអ្វីដែលយើងបានគិតពីដំបូង ។ ខ្ញុំបានយល់ដឹងរួចទៅហើយ ។ គាត់ *ចាំបាច់*ត្រូវរំឭកយើងអំពីការរក្សាទុកទឹករបស់យើងសម្រាប់ចម្ងាយផ្លូវឆ្ងាយនោះ ។

ដំបូន្មានរបស់ឪពុកខ្ញុំសំខាន់ ប៉ុន្តែពិបាកធ្វើតាម ។ ព្រះអាទិត្យពេលរសៀលមានកំដៅក្ដៅ ហើយយើងស្ទើរតែគ្មានម្លប់ជ្រកនៅតាមផ្លូវលំនោះទេ ។ វាហាក់ដូចជាយើងនឹងទៅពុំដល់បឹងនោះទេ ។

មនុស្សចាស់ឈប់តាមផ្លូវជាមួយនឹងក្មេងតូច ហើយបងប្អូនជីដូនមួយដែលធំជាង បានដើរទៅមុខ ។ ខ្ញុំនៅជាមួយនឹងបងប្អូនជីដូនមួយខ្ញុំដែលមានអាយុស្របាលគ្នា ហើយយើងបានទៅដល់កន្លែងមួយនៅចន្លោះផ្លូវរវាងពួកគាត់ ។

នៅពេលយើងមើលពុំឃើញនរណាម្នាក់នៅខាងមុខ ឬនៅខាងក្រោយយើង យើងចាប់ផ្ដើមមានអារម្មណ៍ភ័យព្រួយ ។ កាបូបស្ពាយរបស់យើងហាក់ដូចជាធ្ងន់ ហើយដបទឹករបស់យើងអស់ទឹកទៀត ។ ប៉ា តើយើងត្រូវទៅឆ្ងាយប៉ុណ្ណាទៀតទៅ ?

ទីបំផុត យើងបានភ័យបារម្ភយ៉ាងខ្លាំង ហើយបាននឿយហត់ ដល់យើងបានសម្រេចចិត្តថាឈប់សិន រួចអធិស្ឋាន ។

បន្ទាប់ពីការអធិស្ឋាន យើងបានលើកកាបូបស្ពាយ ហើយបានដើរទៅមុខទៀតដោយយឺតៗ ។

បន្តិចក្រោយមក យើងបានឮសម្លេងជើងសេះជិះមកតាមផ្លូវយើង ។ យើងបានរង់ចាំមើលឃើញបុរសម្នាក់ជិះសេះសំដៅមកកាន់យើង ។

គាត់បានឈប់ ហើយឲ្យទឹកដល់យើងខ្លះ ។ គាត់បានពន្យល់ប្រាប់ថា បងប្អូនជីដូនមួយធំៗរបស់យើង បានប្រញាប់ទៅដល់ស្ទឹង ដោយមានដបដាក់ទឹកដើម្បីយកមកឲ្យពួកយើង ។ បុរសបានឮថាយើងត្រូវការទឹក នោះគាត់បានយល់ព្រមជួយ ។ « តើមាននរណាចង់ឲ្យខ្ញុំជួយស្ពាយកាបូបទេ ? » គាត់បានសួរ ។

ខ្ញុំបានមើលទៅបងប្អូនជីដូនមួយខ្ញុំ ហើយគេបានញញឹមដាក់ខ្ញុំ ។ យើងពិតជាមិនអីទេ !

យើងបាននិយាយទៅបុរសនោះថា « អ្នកអាចទៅជួយដល់អ្នកដទៃទៀតចុះ » ។ « យើងមិនអីទេ » ។

ហើយវាជាការពិត ! នៅតាមផ្លូវធ្វើដំណើរទៅបឹងបន្តទៀតនោះ យើងមានអារម្មណ៍ហាក់ដូចជាពួកទេវតាលើកកាបូបស្ពាយរបស់យើង ហើយរុញយើងឲ្យទៅមុខដូច្នោះដែរ ។ ក្រោយមកនៅពេលខ្ញុំបានប្រាប់ឪពុកខ្ញុំអំពីរឿងនេះ ឪពុកបានញញឹមហើយម្ដាយបានស្រក់ទឹកភ្នែក ។

មួយសប្ដាហ៍ក្រោយមក គ្រួសារខ្ញុំបានអានម៉ូសាយ 24 ។ ភ្នែករបស់ខ្ញុំបានបើកធំៗ នៅពេលយើងអានពាក្យទាំងនេះថា ៖ « យើងនឹងសម្រាលបន្ទុកទាំងឡាយ ដែលដាក់នៅលើស្មាអ្នកផង ហើយសូម្បីតែរូបអ្នកក៏នឹងមិនអាចចាប់អារម្មណ៍ថា មានបន្ទុកទាំងនោះនៅលើខ្នងអ្នកឡើយ » ( ខ 14 ) ។

ខ្ញុំបានភ្លាត់មាត់ថា « នោះជាអ្វីដែលបានកើតឡើងនៅតាមផ្លូវលំ » ។ ខ្ញុំពុំចាំបាច់គិតអំពីរបៀបដើម្បីប្រើគម្ពីរនេះនៅក្នុងជីវិតរបស់ខ្ញុំទេ— គម្ពីរនេះបានពិពណ៌នាជីវិតរបស់ខ្ញុំរួចទៅហើយ ! វាអស្ចារ្យណាស់ ! ខ្ញុំស្ទើរតែមិនអាចចាំរកខគម្ពីរផ្សេង ដែលប្រដូចនឹងជីវិតខ្ញុំណាស់ ។

ហើយនោះជាអ្វីដែលខ្ញុំបានរៀនថា ខ្ញុំបានប្រដូចខគម្ពីរមកខ្លួនខ្ញុំ ហើយខ្ញុំក៏អាចប្រដូចខ្លួនខ្ញុំទៅនឹងខគម្ពីរដែរ ! ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*

# ណូអេ

ជាព្យាការីម្នាក់នៃគម្ពីរសញ្ញាចាស់ ។ គាត់រក្សាបទបញ្ញត្តិ ហើយបានជួយគ្រួសារគាត់ឲ្យមានសុវត្ថិភាពពីទឹកជំនន់ ដោយការស្ដាប់តាមព្រះបន្ទូលរបស់ព្រះ ។ អ្នកអាចរក្សាបទបញ្ញត្តិ ហើយជួយគ្រួសារអ្នកផងដែរ ដោយការអានចេញពីគម្ពីរសញ្ញាចាស់ជារៀងរាល់សប្ដាហ៍ក្នុងឆ្នាំនេះ ។

ចូរឲ្យមនុស្សពេញវ័យម្នាក់ ជួយអ្នកកាត់ទំព័រផាត់រូបនេះចេញ ឬបោះពុម្ពវាចេញមក liahona.lds.org ។ រាល់សប្ដាហ៍ បន្ទាប់ពីអ្នកអាន ចូរផាត់ពណ៌នៅក្នុងចម្លោះទាំងអស់ដែលមានលេខក្នុងសប្ដាហ៍នោះ ដោយប្រើពណ៌ដែលអ្នកគិតថាល្អ ។ សូមមើលទំព័រ 76 សម្រាប់ឃោបល់ការអានប្រចាំសប្ដាហ៍ ។ អ្នកអាចអានដោយខ្លួនឯង ឬ ជាមួយក្រុមគ្រួសារអ្នក ។ នៅពេលអ្នកអានចប់ អ្នកនឹងអានខ្លះៗអំពីរឿងសំខាន់បំផុតនៅក្នុងគម្ពីរសញ្ញាចាស់ ! ■







28
5
29
41
25
24
26
18
52
9
1
15
14
10
12
23
51
21
19
48
13
22
44
32
43
42
49
18
30
31
50
36
47
7
20
6
19
21
33
17
20
46
45
22
51
16
23
14
24
34
2


แผ่น

យោបល់ការអានប្រចាំសប្ដាហ៍សម្រាប់ « សំណូមពរអំពីព្រះគម្ពីរសញ្ញាចាស់ » ( សូមមើលទំព័រ 74–75 ) ។

| សប្ដាហ៍ | ការអាន |
|---|---|
| 1 | **ផែនការនៃសេចក្ដីសង្គ្រោះ ៖** ម៉ូសេ 1:39; អ័ប្រាហាំ 3:12, 22–28; 4:1 |
| 2 | **ការបង្កបង្កើត ៖** លោកុប្បត្តិ 1; 2:1–3 |
| 3 | **អ័ដាម និង នាងអេវ៉ា ៖** លោកុប្បត្តិ 2:7–9, 15–25 |
| 4 | **ការធ្លាក់ ៖** លោកុប្បត្តិ 3 |
| 5 | **កាអ៊ីន និង អេបិល ៖** លោកុប្បត្តិ 4:1–16 |
| 6 | **ទីក្រុងអេណុក ៖** ម៉ូសេ 6:21, 26–28; 7:13–21 |
| 7 | **ទូកធំរបស់ណូអេ ៖** លោកុប្បត្តិ 6:5, 7–9, 13–22; 7:1–19, 23–24 |
| 8 | **គ្រួសាររបស់ណូអេ ត្រូវបានសង្គ្រោះ ៖** លោកុប្បត្តិ 8:6–13, 15–17 |
| 9 | **ប៉ មបាបិល ៖** លោកុប្បត្តិ 11:1–9; អេធើរ 1:1–3, 33–43 |
| 10 | **សេចក្ដីសញ្ញារបស់អ័ប្រាហាំ ៖** អ័ប្រាហាំ 1:1–4; 2:6–13; លោកុប្បត្តិ 17:1–7 |
| 11 | **អ័ប្រាហាំ និងឡុត ៖** លោកុប្បត្តិ 13:1–13; 19:1, 15–17, 24–29 |
| 12 | **អ័ប្រាហាំ និងអ៊ីសាក ៖** លោកុប្បត្តិ 22:1–18 |
| 13 | **អ៊ីសាក និង រ៉េបិកា ៖** លោកុប្បត្តិ 24:1–4, 7–20, 61–67 |
| 14 | **យ៉ាកុប និង អេសាវ ៖** លោកុប្បត្តិ 25:21–34; 27:1–23 |
| 15 | **យ៉ាកុប និង រ៉ាជែល ៖** លោកុប្បត្តិ 29:1–2, 10–30 |
| 16 | **យ៉ាកុប ក្លាយទៅជាអ៊ីស្រាអែល យ៉ូសែបត្រូវបានលក់ទៅកាន់អេស៊ីព្ទ ៖** លោកុប្បត្តិ 35:9–12; 37:3–14, 18–34 |
| 17 | **យ៉ូសែបនៅក្នុងអេស៊ីព្ទ ៖** លោកុប្បត្តិ 39:1–4, 7–20; 40:1–3, 5–8; 41:1, 8–12, 14, 29–36, 39–40 |
| 18 | **ការអភ័យទោសរបស់យ៉ូសែប ៖** លោកុប្បត្តិ 42:3–16; 43:15; 44:1–12, 18, 33–34; 45:3–8 |
| 19 | **កំណើត និងការហៅរបស់ម៉ូសេ ៖** និក្ខមនំ 1:8–14, 22; 2:1–6, 10–21; 3:1–14, 19–20; 4:10–12 |
| 20 | **សេចក្ដីវេទនា ៖** និក្ខមនំ 7:10–14, 20–21; 8:6, 17, 24; 9:6, 10, 23; 10:14–15, 22; 11:5; 12:30–32, 41–42 |
| 21 | **និក្ខមនំ ៖** និក្ខមនំ 14:5–16, 19–31 |
| 22 | **ពួកសាសន៍អ៊ីស្រាអែល បានទទួលនំម៉ានាមកពីស្ថានសួគ៌ ៖** និក្ខមនំ 16:1–8, 21–31, 35 |
| 23 | **ក្រិត្យវិន័យទាំងដប់ប្រការ; ពស់លង្ហិន ៖** និក្ខមនំ 19:1–5, 20; 20:1–17; 31:18; ជនគណនា 21: 4–9 |
| 24 | **កូនស្រីរបស់សល្ផិហាត ៖** ជនគណនា 27:1–7 |
| 25 | **យ៉ូស្វេ និងចម្បាំងនៃយេរីខូរ ៖** យ៉ូស្វេ 1:1–11, 16–17; 2:1–6, 14; 3:5–9, 13–17; 6:1–5, 13–16, 20, 23; 24:14–18 |
| 26 | **គេឌាន ៖** ចៅហ្វាយ 6:6–16; 7:1–7, 16–22; 8: 22–23 |
| 27 | **សាំសុន និង ដេលីឡា ៖** ចៅហ្វាយ 13:1–5, 24; 16:2–23, 28–30 |
| 28 | **នាងរស់ និង ន៉ាអូមី ៖** នាងរស់ 1:1–9, 14–16; 2:1–8, 15–18; 3:1, 3–11; 4:13, 17; យ៉ូហាន 7:42 |
| 29 | **សាំយូអែល, ព្យាការីក្មេង ៖** សាំយូអែលទី 1 1:9–11, 17–20, 24–28; 2:26; 3:1–11, 16–20 |
| 30 | **ដេវីឌ និងកូលីយ៉ាត ៖** សាំយូអែលទី 1 16:7; 17:1, 4–24, 32–33, 37–51 |
| 31 | **ដាវីឌ និង យ៉ូណាថាន ៖** សាំយូអែលទី 1 18:1–9; 19:1–10; 23:14–18; 24:9–10, 16–19; សាំយូអែលទី 2 1:4, 11–12 |
| 32 | **ដាវីឌ និងបាតសេបា ៖** សាំយូអែលទី 2 11:1–4, 14–17, 26–27; 12:1–7, 9, 13 |
| 33 | **ស្ដេចសាឡូម៉ូន ៖** ពង្សាវតារក្សត្រទី 1 2:1–4, 12; 3:3–28; 6:1 |
| 34 | **រេហូបោម ៖** ពង្សាវតារក្សត្រទី 1 11:43; 12:1–21 |
| 35 | **អេលីយ៉ា ជាព្យាការី ៖** ពង្សាវតារក្សត្រទី 1 17; 19:11–12 |
| 36 | **អេលីយ៉ា និងព្យាការីក្លែងក្លាយព្រះបាល ៖** ពង្សាវតារក្សត្រទី 1 18:16–18, 21–39 |
| 37 | **ណាម៉ាន់ ត្រូវបានជាសះស្បើយ ៖** ពង្សាវតារក្សត្រទី 2 5 |
| 38 | **អេលីសេ និងស្ត្រីមេម៉ាយ ៖** ពង្សាវតារក្សត្រទី 2 4:1–6 |
| 39 | **អេសាយ និង ហេសេគា ៖** ពង្សាវតារក្សត្រទី 2 18:1–7; អេសាយ 36:1–2, 4, 13–15; 37:1–7, 15–21, 33–38; 38:1–7 |
| 40 | **ការព្យាករណ៍ទាំងឡាយរបស់អេសាយ ៖** អេសាយ 1:17–19; 2:2–4; 11:6–10; 53:3–5; 55:8–9; 58:6–14 |
| 41 | **យ៉ូសៀស និង អែសរ៉ា អានបទគម្ពីរ ៖** ពង្សាវតារក្សត្រទី 2 22:1–4, 8–13; 23:1–4, 24–25; នេហេមា 8:1–8 |
| 42 | **ទំនុកដំកើង និង សុភាសិត ៖** ទំនុកដំកើង 1:1–3; 19:1–3; 24:1–4; សុភាសិត 3:5–6 |
| 43 | **នាងអេសធើរ ៖** នាងអេសធើរ 2:5–9, 17; 3:2–13; 4; 5:1–8; 7; 8:3–11, 17 |
| 44 | **យ៉ូប ៖** យ៉ូប 1; 19:13–26; 27:2–6; 42:10 |
| 45 | **យេរេមា ៖** យេរេមា 1:1, 4–9; 18:1–6; អេសាយ 64:8 |
| 46 | **ព្រះវិហារបរិសុទ្ធរបស់សាឡូម៉ូន ៖** របាក្សត្រទី 1 28:20; 29:6–9; របាក្សត្រទី 2 5:1; 6:1–3 |
| 47 | **ដានីយ៉ែល និងអាហាររបស់ស្ដេច ៖** ដានីយ៉ែល 1:1, 3–20 |
| 48 | **សាដ្រាក់ មែសាក់ និង អ័បេឌនេកោ ៖** ដានីយ៉ែល 3:1, 4–30 |
| 49 | **ដានីយ៉ែល និងសត្វតោ ៖** ដានីយ៉ែល 6 |
| 50 | **យ៉ូណាស និងត្រីបាឡែន ៖** យ៉ូណាស 1; 2; 3:1–5 |
| 51 | **បទគម្ពីរបន្ថែម ៖** អេម៉ុស 3:7; នេហុម 1:7; ហាបាគុក 3:19; សេផានា 3:16–20 |
| 52 | **ម៉ាឡាគី ៖** ម៉ាឡាគី 3:8–12; ម៉ាឡាគី 4:5–6 |



**ដោយ រ៉ូសម៉ារី អិម វិកសុម**
ប្រធានអង្គការបឋមសិក្សាទូទៅ

# ផ្លូវជោគជ័យ

*« ឱ ផែនការនៃព្រះរបស់យើងធំណាស់ហ្ន៎ » ( នីហ្វៃទី 2 9:13 ) ។*

អំឡុងនិទារឃរដូវ ស្វាមីខ្ញុំ និងខ្ញុំបានចូលរួមក្នុងការលេងកីឡាបាល់ឱបចៅប្រុសយើង ដែលមានអាយុ 4 ឆ្នាំ ។ យើងមានក្តីរំភើបខ្លាំងណាស់ នៅពេលចៅរត់គ្រប់ទិសដេញតាមបាល់នោះ ។ នៅពេលចុងបញ្ចប់ កញ្ចែបានផ្លុំឡើង អ្នកលេងទាំងនោះពុំដឹងថានរណាឈ្នះ ឬនរណាចាញ់នោះឡើយ ។ ពួកគេគ្រាន់តែលេងកំសាន្តប៉ុណ្ណោះ ។

គ្រូបង្វឹកសុំឲ្យអ្នកលេង ចាប់ដៃជាមួយនឹងក្រុមដទៃ ។ បន្ទាប់មក យើងបានមើលឃើញអ្វីមួយដ៏អស្ចារ្យណាស់ ។ គ្រូបង្វឹករបស់ពួកគេបានប្រកាសពីផ្លូវជោគជ័យ ។

ឪពុកម្តាយ យាយតា និងនរណាដែលបានមកមើលកីឡា បានក្រោកឈរឡើង ហើយបានឈរជាពីរជួរទល់មុខគ្នា ។ បន្ទាប់មកគេបានលើកដៃឡើងបង្កើតជាទ្វារកោងមួយ ។ កុមារទាំងឡាយបានសើចនៅពេលពួកគេរត់នៅក្រោមដៃរបស់មនុស្សពេញវ័យដែលអបអរ ហើយចូលតាមផ្លូវនោះ ។

មិនយូរប៉ុន្មាន កុមារមកពីក្រុមផ្សេងបានសម្រេចចិត្តចូលរួមសប្បាយដែរ ។ អ្នកលេងទាំងអស់បានទទួលការអបអរដោយមនុស្សពេញវ័យនៅពេលពួកគេរត់តាមផ្លូវជោគជ័យ ។



នៅក្នុងគំនិតរបស់ខ្ញុំ ខ្ញុំអាចមើលឃើញរូបភាពផ្សេងទៀត ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំកំពុងមើលកុមារទាំងនេះ រស់នៅតាមផែនការរបស់ព្រះវរបិតាសួគ៌ ដែលបានបង្កើតសម្រាប់កុមារគ្រប់រូប ។ ពួកគេរត់នៅលើផ្លូវតូច និងចង្អៀតក្រោមដៃរបស់មនុស្សដែលស្រឡាញ់ពួកគេ ។ កុមារម្នាក់ៗមានអារម្មណ៍រីករាយក្នុងការនៅលើផ្លូវនោះ ។

ព្រះយេស៊ូវគ្រីស្ទ បាន « គូសផ្លូវ ហើយដឹកនាំផ្លូវ » សម្រាប់យើងម្នាក់ៗ ។[1] បើសិនជាយើងធ្វើតាមការដឹកនាំរបស់ទ្រង់ នោះយើងទាំងអស់គ្នា ត្រឡប់ទៅកាន់គេហដ្ឋានសួគ៌របស់យើង ហើយមានសុវត្ថិភាពនៅក្នុងព្រះហស្តរបស់ព្រះវរបិតាសួគ៌ ។ ■

**កំណត់ចំណាំ**

1. « ឱ ប្រាជ្ញា និងក្តីស្រឡាញ់ដ៏ធំអស្ចារ្យ » *ទំនុកតំកើង* ទំព័រ 19 ។

រូបថតដោយ គារបិតស៊ូប ប៊ូសាត រេខាដោយ ខាទី ម៉ាក់ឌី

រៀនបន្ថែមទៀតអំពីបាវចនាថ្នាក់អង្គការបឋមសិក្សារបស់ខែនេះ !

# ព្រះវរបិតាសួគ៌ បានរៀបចំផ្លូវមួយសម្រាប់ឲ្យខ្ញុំត្រឡប់ទៅរកទ្រង់វិញ

## មុនពេលយើងមកកាន់ផែនដី យើងទាំងអស់គ្នាបានរស់នៅស្ថានសួគ៌ជាមួយព្រះវរបិតាសួគ៌ និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ។

ព្រះវរបិតាសួគ៌ បានបង្ហាញផែនការរបស់ទ្រង់ដល់យើង ។យើងបានជ្រើសរើសធ្វើតាមផែនការរបស់ព្រះវរបិតាសួគ៌ ហើយមកកាន់ផែនដី ។

ព្រះវរបិតាសួគ៌ ស្រឡាញ់យើង ហើយចង់ឲ្យយើងត្រឡប់ទៅរកទ្រង់វិញ ។ទ្រង់បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ដើម្បីបង្ហាញផ្លូវយើង ហើយជួយយើងត្រឡប់ទៅរកទ្រង់វិញ ។





យើងដើរតាមផ្លូវត្រឡប់ទៅកាន់ព្រះវរបិតាសួគ៌វិញដោយ ៖



ការទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់



ការទទួលទានសាក្រាម៉ង់



ការចុះសេចក្ដីសញ្ញាក្នុងព្រះវិហារបរិសុទ្ធ



និងការរស់នៅដោយសេចក្ដីជំនឿ ។

នៅពេលយើងត្រឡប់ទៅព្រះវរបិតាសួគ៌វិញ នោះទ្រង់នឹងស្វាគមន៍យើងឲ្យត្រឡប់ទៅវិញដោយលាតព្រះហស្ដ !

រូបភាពពិភពលោក © ខូប៊ីស; លម្អិតចេញមកពី *ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ*, ដោយ ឌែល ផាសុន; រចនារូបថតដោយ វែលឌិន ស៊ី. អាន់ឌើរសិន, ខូឌី ប៊ែល, ហ្វ្រេត ដាយមិន, ម៉ាថាយ រៀរ, គ្រីស្ទីណា ស្មីធ; រចនាដោយ ស្ទីវ ក្រូប






## ផ្លូវមួយសម្រាប់ខ្ញុំ

ចូរធ្វើបណ្ណប្រកាសមួយ តំណាងឲ្យផ្លូវរបស់អ្នកត្រឡប់ទៅកាន់ព្រះវរបិតាសួគ៌វិញ ។ចូរគូសផ្លូវមួយនៅលើក្រដាស ឬក្ដារបណ្ណប្រកាស ។ចូរឲ្យមនុស្សពេញវ័យម្នាក់ជួយអ្នក កាត់រូបភាពតូចៗ ហើយបិទស្កុត ឬបិទការរូបភាពនៅតាមផ្លូវ ។បន្ថែមរូបថត ឬគូររបស់អ្នកនៅគ្រាសំខាន់ៗដូចជាពិធីបុណ្យជ្រមុជទឹក ។

**អ្នកនឹងត្រូវការ ៖**

- ក្រដាសមួយសន្លឹក ឬក្ដារបណ្ណប្រកាស
- កន្ត្រៃ
- កាវ ឬស្កុត
- កូល័រទៀន ប៊ិចហ្វឺត ឬខ្មៅដៃ

## ចម្រៀង និង ព្រះគម្ពីរ

- « He Sent His Son » ( *Children's Songbook*, ទំព័រ 34–35 )
- យ៉ូហាន 3:16

## គំនិតយោបល់សម្រាប់ការនិយាយក្នុងគ្រួសារ

សារលិខិតនេះពន្យល់អំពី ផែនការរបស់ព្រះវរបិតាសួគ៌តាមរបៀបដ៏សាមញ្ញបំផុតមួយ ។ អ្នកអាចឲ្យសមាជិកគ្រួសារ ឆ្លាស់វេណគ្នាប្រើរូបភាពដើម្បីពន្យល់អំពីផ្នែកផ្សេងៗនៃផែនការ ។បន្ទាប់មកអ្នកអាចនិយាយជាមួយគ្នាអំពីរបៀបដែលអ្នកអាចជួយគ្នាទៅវិញទៅមក ឲ្យស្ថិតនៅលើផ្លូវដែលនាំត្រឡប់ទៅរកព្រះវរបិតាសួគ៌វិញ ។

# តើទ្រង់អាចឃើញខ្ញុំឬទេ ?

ដោយ ធេរេសា ស្ដារ

នៅព្រឹកមុនពេលកូនប្រុសរបស់ខ្ញុំ ដានីយ៉ែល ចូលរៀនសាលាមត្តេយ្យថ្ងៃទីមួយរបស់គាត់ គាត់មានកង្វល់មួយចំនួនអំពីការចាកចេញពីផ្ទះទៅចូលសាលារៀន ។ ខ្ញុំចង់ធ្វើឲ្យប្រាកដថា គាត់មានអារម្មណ៍ថា បានត្រៀមខ្លួនជាស្រេចដើម្បីប្រឈមមុខនឹងបញ្ហាទាំងឡាយក្នុង « ពិភពលោកពិត » ។ ខ្ញុំបានប្រាប់ដានីយ៉ែលថា ខ្ញុំនឹងនឹកគាត់ខ្លាំងណាស់ ពេលគាត់ទៅឆ្ងាយ ។ ខ្ញុំបានប្រាប់គាត់ថា ទោះជាខ្ញុំពុំអាចនៅជាមួយគាត់នៅសាលារៀនក្ដី ក៏គាត់ពុំចាំបាច់ខ្លាច ឬមានអារម្មណ៍ឯកោឡើយ ព្រោះព្រះវរបិតាសួគ៌នឹងទតមើលមកលើគាត់ ។ ខ្ញុំបានរំឭកគាត់ថា គាត់អាចអធិស្ឋានគ្រប់ពេល គ្រប់ទីកន្លែង នោះព្រះនឹងស្ដាប់ឮគាត់ជានិច្ច ។

នៅពេលខ្ញុំនិយាយ ដានីយ៉ែល ដែលមានអាយុជិតប្រាំឆ្នាំ បានស្ដាប់ដោយយកចិត្តទុកដាក់ ។ បន្ទាប់ពីបានគិតខ្លះៗ គាត់បានតបថា « តើទ្រង់អាចមើលឃើញកូន ពេលកូននៅក្នុងផ្ទះឬទេ ? »

ខ្ញុំអះអាងនឹងគាត់ថា « ឃើញ » ។

« តើទ្រង់មើលឃើញកូន ពេលកូននៅក្រៅផ្ទះឬទេ ? » គាត់បានសួរ ។

ខ្ញុំតបថា « ឃើញ ទ្រង់អាចមើលឃើញកូនជានិច្ច » ។

ដោយទឹកមុខរំភើប ដានីយ៉ែល បានរត់ភ្លាមទៅរានហាលខាងក្រោយផ្ទះ ។ ខ្ញុំបានដើរយ៉ាងគៀកពីក្រោយគាត់ ។ ដានីយ៉ែល បានមើលទៅលើមេឃដ៏ស្រឡះ ពណ៌ផ្ទៃមេឃ រួចសួរថា « បើកូនមើលទៅលើមេឃ ហើយញញឹម តើទ្រង់នឹងទតមើលឃើញកូន ហើយនឹងញញឹមតបមកកូនវិញឬទេ ? »



*ដានីយ៉ែល បានរត់ទៅរានហាលផ្ទះ ហើយបានសួរខ្ញុំថា « បើកូនមើលទៅលើមេឃហើយញញឹម តើព្រះនឹងញញឹមត្រឡប់មកកូនវិញទេ ? »*

ខ្ញុំអួលដើមករនិយាយពុំរួច ខ្ញុំក៏បានងក់ក្បាលថា « ឃើញ ! » ។

ពេលកំពុងមើលទៅលើមេឃ ភ្នែកគាត់រំពៃរកមើល ដោយក្ដីជំនឿដូចជាក្មេងដ៏ឥតខ្ចោះ ដានីយ៉ែល បានសួរដោយរិះគិតថា « តើកូនអាចមើលឃើញទ្រង់ឬទេ ? »

ខ្ញុំបានឆ្លើយថា « កូនពុំអាចមើលឃើញទ្រង់ទេ ប៉ុន្ដែកូននឹងដឹងថាទ្រង់គង់នៅទីនោះ ពីព្រោះកូននឹងដឹងថាទ្រង់ញញឹមនៅក្នុងបេះដូងរបស់កូន » ។

ដានីយ៉ែល ឈរញញឹមនៅពេលគាត់សំឡឹងមើលទៅលើមេឃ ។ ខ្ញុំបានដឹងថា គាត់ធ្លាប់ឃើញនូវស្នាមញញឹមដ៏ទេវភាពនោះ ចាក់ជ្រៅទៅក្នុងព្រលឹងរបស់គាត់ តាមរយៈទឹកមុខដូចទេវតារបស់គាត់ ដែលប្រកបដោយភាពសុខសាន្តនោះ ។

ចេញមកពីបបូរមាត់នៃកុមារតូចៗ យើងរៀនច្រើនអំពីសេចក្ដីជំនឿដ៏បរិសុទ្ធ —សេចក្ដីជំនឿដែលយើងសង្ឃឹមថាពួកគេនឹងតោងជាប់នៅជារៀងរហូត ។ ពួកគេបានរកឃើញដោយឥតសង្ស័យអំពីរឿងនោះ ទោះជាជីវិតល្អ ឬពេលខ្លះវាពិបាកក្ដី ។ យើងអធិស្ឋានសុំឲ្យសេចក្ដីជំនឿរបស់ពួកគេនឹងគាំទ្រដល់ពួកគេ ។

នៅពេលមានរឿងលំបាកនៅក្នុងជីវិតផ្ទាល់ខ្លួនខ្ញុំ ខ្ញុំចាំនូវគំរូរបស់ដានីយ៉ែល ហើយដោយសេចក្ដីជំនឿដូចជាកូនក្មេងទាំងស្រុង តាមដែលមនុស្សធំអាចធ្វើបាន នោះខ្ញុំបានមើលទៅស្ថានសួគ៌ ហើយសួរផងដែរថា « តើទ្រង់ អាចឃើញខ្ញុំឬទេ ? » រួចខ្ញុំបានពិចារណាដោយស្ងាត់ស្ងៀមដូចជាដានីយ៉ែលថា « តើខ្ញុំអាចមើលឃើញទ្រង់ឬទេ ? » នៅពេលខ្ញុំពិចារណាអំពីក្ដីមេត្តាករុណាដ៏ទន់ភ្លន់របស់ទ្រង់យ៉ាងបរិបូរនៅក្នុងជីវិតខ្ញុំ នោះព្រះវិញ្ញាណបរិសុទ្ធ បញ្ជាក់ប្រាប់ថា ខ្ញុំពិតជាបានដឹងពីក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌មែន ។ ព្រះវិញ្ញាណអះអាងខ្ញុំថា ខ្ញុំតែងតែអាចបានរំឭកក្ដីស្រឡាញ់របស់ទ្រង់នៅក្នុងសេចក្ដីជំនឿ និងបានបំផុសដោយក្ដីសង្ឃឹមជានិច្ច ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*




គំនូរគូរដោយ រ៉ូប៊ើត ធី. បារ៉េត

# ហារ៉ូល ប៊ី លី

**ហារ៉ូល ប៊ី លី** បានរៀនដើម្បីស្គាល់ព្រះវិញ្ញាណចាប់តាំងពីនៅក្មេង ។ ថ្ងៃមួយ គាត់បានដើរទៅកាន់ **រោង**បាក់បែកមួយ ប៉ុន្តែមានសំឡេងមួយបានហៅឈ្មោះគាត់ ហើយបានប្រាប់គាត់ថាកុំឲ្យទៅទីនោះ ។ ហារ៉ូលបានគោរពតាម ។ គាត់បានបន្តធ្វើតាមព្រះវិញ្ញាណនៅពេញមួយជីវិតរបស់គាត់ ដូចជា នៅពេលគាត់ដឹកនាំ **កម្មវិធីសុខុមាលភាពសាសនាចក្រ** ។ គាត់ក៏បានដឹកនាំការិយាល័យសាសនាចក្រ ដែលបានបង្កើត **សម្ភាររៀនសូត្រ** ដើម្បីជួយដល់សមាជិកឲ្យស្គាល់ព្រះវិញ្ញាណនៅក្នុងជីវិតរស់នៅរបស់ពួកគេផងដែរ ។

# ក៏មាននៅក្នុងទស្សនាវដ្ដីច្បាប់នេះផងដែរ

## សម្រាប់មជ្ឈិមវ័យវ័យក្មេង



ទំព័រ 42

### ការស៊ូទ្រាំ បានល្អ

យើងពុំគួររំពឹងចង់រត់គេចចេញពីការសាកល្បងរបស់យើង ដោយសន្យានឹងព្រះអម្ចាស់ថា យើងនឹងនៅតែស្មោះត្រង់ជានិច្ចនោះទេ ។ យើងគួរតែរៀបផែនការដើម្បីស៊ូទ្រាំឲ្យបានល្អជំនួសវិញ រួចហើយយើងនឹងត្រូវបានប្រទានពរ ។

## សម្រាប់យុវវ័យ

### ពរជ័យ ទាំងសងខាង



តើមានពរជ័យអ្វីខ្លះ ដែលកើតចេញមកពីការធ្វើពង្សប្រវត្តិ និងការយកឈ្មោះរបស់ជីដូនជីតាទៅព្រះវិហារបរិសុទ្ធ ? យុវវ័យមកពីទីក្រុងនូវយ៉ោក ស.រ.អា ទាំងនេះ ចែកចាយបទពិសោធន៍របស់ពួកគេ ។

ទំព័រ 60

## សម្រាប់កុមារ

ទំព័រ 69







សូមរកមើលតែមរបស់ប្រទេសនៅក្នុង *លីអាហូណា* ដើម្បីបន្ថែមទៅលើលិខិតឆ្លងដែនរបស់អ្នកឆ្នាំនេះ !

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN
4 02109 81258 2
10981 Jan 14